

# ការរក្សាកុមារឱ្យ រួចផុត ពីការរំលោភបំពាន

## កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់ការអប់រំកុមារ និងមនុស្សវ័យក្មេង

Australian Aid

World Vision

**ការរក្សាកុមារឱ្យរួចផុតពីការរំលោភបំពាន៖**
កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់ការអប់រំកុមារ និងមនុស្សវ័យក្មេង

ISBN: 978-0-9925214-8-6
រក្សាសិទ្ធិ © ឆ្នាំ ២០១៤ ដោយអង្គការទស្សនៈពិភពលោកកម្ពុជា

សម្ភារនៅក្នុងឯកសារបោះពុម្ពផ្សាយនេះអាចយកទៅប្រើ និងកែសម្រួលបាន ឱ្យតែមានការបញ្ជាក់ប្រភពឯកសារត្រឹមត្រូវថាបាន ដកស្រង់ពីប្រភពឯកសារនេះ។ អ្នកអាចទាញយកឯកសារអេឡិចត្រូនិចពីគេហទំព័រ http://www.childsafetourism.org ឬ http://wvi.org/asiapacific/childsafetourism. ។ សូមផ្ញើសំណួរ ឬ យោបល់ត្រឡប់ទៅកាន់អ៊ីម៉ែល childsafetourism@wvi.org.

**រូបថត:** រូបថតទាំងអស់គឺរក្សាសិទ្ធិដោយអង្គការទស្សនៈពិភពលោក។ រូបថតទំព័រមុខដោយ លីឈាង សីហា។ រូបកុមារដែលប្រើក្នុងសម្ភារអប់រំនេះ គ្រាន់តែជាការលម្អប៉ុណ្ណោះ គម្រោងកុមារភាពមិនយករូបពិតរបស់កុមាររងគ្រោះដោយការរំលោភបំពានមកប្រើទេ។
អង្គការទស្សនៈពិភពលោក ធ្វើការដោយយោងតាមបទដ្ឋានការពារកុមារក្នុងការថតរូបរបស់កុមារ។
រចនាដោយ: Inís Communication. កាតយកតាមខ្លួនដោយ: Cam Vien Ha. មានការលំនាំតាមជាសាខ្មែរ កែសម្រួល និងរចនាដោយ រចនាឌីហ្សាញ រូបភាពដោយ: Jose Encinas.

គម្រោងកុមារភាពគឺជាការផ្តួចផ្តើមគំនិតមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីការពារកុមារឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍ ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (ឆ្នាំ ២០១១-២០១៤)។




# ការរក្សាកុមារឱ្យ រួចផុត ពីការរំលោភបំពាន

កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់ការអប់រំកុមារ និងមនុស្សវ័យក្មេង

# សេចក្ដីថ្លែងអំណរគុណ

ការបង្កើតសៀវភៅណែនាំអ្នកសម្របសម្រួលដែលដឹកនាំដោយ Aarti Kapoor ប្រធានកម្មវិធី និង Afrooz Kaviani នាយកបច្ចេកទេសនៅក្នុងផ្នែកបង្ការរបស់គម្រោងកុមារភាពនេះ មានការចូលរួមពីមនុស្ស និងអង្គការជាច្រើន។ ឧបករណ៍អ្នកសម្របសម្រួល រួមបញ្ចូលនូវព័ត៌មាននិងគំនិតនានា ដែលបានមកពីឯកសារ ដែលមានចំណងជើងថា ការអប់រំការការពារកុមារ៖ សម្ភារមេរៀនដើម្បីគាំទ្រដល់ការបង្រៀន និងការរៀនក្នុងការ អភិវឌ្ឍផ្ទាល់ខ្លួន ការអប់រំផ្លូវកាយ និងផ្លូវចិត្ត របស់សាលាអប់រំ New South Wales និស្សិត Welfare Directorate (ឆ្នាំ ១៩៩៧)។ សូមថ្លែងអំណរគុណ Pauline Hyde អ្នកពិគ្រោះយោបល់ ដែលបានជួយ ពិនិត្យឡើងវិញ និងផ្ដល់ដំបូន្មានផ្នែកជំនាញការ លើសេចក្ដីព្រាងច្បាប់ទីមួយនៃកញ្ចប់ឧបករណ៍អ្នក សម្របសម្រួលក្នុងឆ្នាំ២០១២។

សូមថ្លែងអំណរគុណផងដែរចំពោះលោកផង់ ចិន្តា, Chalermrat Chaiprasert, Chansamone Bouakhamvongsa និងNguyen Khanh Hoi អ្នកសម្របសម្រួលថ្នាក់ជាតិ របស់គម្រោងកុមារភាព ផ្នែកបង្ការក្នុងប្រទេសកម្ពុជា ថៃ ឡាវ និងប្រទេសវៀតណាម ដែលបានចូលរួមគំនិត ការអនុវត្តសាកល្បង និងការសម្របសម្រួលថ្នាក់ជាតិ ទៅលើកញ្ចប់ឧបករណ៍អ្នកសម្របសម្រួលចាប់តាំងពីឆ្នាំ ២០១២-២០១៤។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះយោបល់និងយោបល់ត្រឡប់ ដ៏មានតម្លៃពីសំណាក់សហការីនានា ដូចជា Kristine Mikhailidi អ្នកជំនាញផ្នែកកម្មវិធីការពារកុមារ និង Leen Decadt ទីប្រឹក្សាផ្នែកការពារកុមារ របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ និងដៃគូនានា នៅកម្រិតមូលដ្ឋាន ដែលបានប្រើប្រាស់ឯកសារអប់រំ ទាំងអស់នេះ។ សូមថ្លែងអំណរគុណចំពោះ Verity Kowal មន្ត្រីផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនងនៅក្នុង គម្រោងកុមារភាពផ្នែកបង្ការ ដែលបានជួយសរសេរបញ្ចប់ទៅលើកញ្ចប់ ឧបករណ៍វេទិកាពិភាក្សា សម្រាប់ការ បោះពុម្ពផ្សាយក្នុងឆ្នាំ២០១៤នេះ។ សូមថ្លែងអំណរគុណផងដែរចំពោះ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សា ជាតិកម្ពុជាដើម្បីកុមារ សមាជិកក្រុមការងារ គម្រោងកុមារភាពផ្នែកបង្ការ លោក ហ៊ឹម ជា លោកស្រី សាយ សុម៉ាលី និងលោកស្រី ស៊ឹម សុជាតា ជាទីប្រឹក្សា ដែលបានចូលរួមក្នុងការបង្កើត សម្ភារនេះឡើង ជាភាសាខ្មែរ ។

# មាតិកា


បុព្វកថា ii

សារតា iv

គោលបំណងនៃកញ្ចប់ឧបករណ៍ v

របៀបប្រើប្រាស់កញ្ចប់ឧបករណ៍ vi

ផ្នែកទី១៖ សេចក្តីផ្តើម 1

តើនរណាអាចសម្របសម្រួលវគ្គនេះបាន? 3
តើនរណាគួរចូលរួមក្នុងវគ្គនេះ? 4
តើលទ្ធផលរំពឹងទុកពីវគ្គសិក្សានេះមានអ្វីខ្លះ? 5
តើធ្វើយ៉ាងណាដើម្បីទទួលបានការយល់ព្រមចូលរួមរបស់កុមារ និងមនុស្សវ័យក្មេង? 6
តើឪពុកម្តាយ គ្រួសារ និងសហគមន៍មានតួនាទីអ្វីខ្លះ? 6
គន្លឹះសម្រាប់ធ្វើការជាមួយកុមារ និងមនុស្សវ័យក្មេង 7
ការពិចារណាលើចំនុចសំខាន់ៗ សម្រាប់វគ្គបណ្តុះបណ្តាលស្តីពីកិច្ចការពារកុមារ 8
តើខ្ញុំត្រូវការអ្វីខ្លះ ដើម្បីបង្រៀនវគ្គនេះ? 13
តើគេអាចវាយតម្លៃដំណើរការវគ្គដោយបណ្តុះបណ្តាលដោយរបៀបណា? 15

ផ្នែកទី ២៖ ផែនការវគ្គសិក្សា 17

គម្រោងមេរៀនសម្រាប់វគ្គរយៈពេលកន្លះថ្ងៃ 19
សម្រាប់កុមារអាយុ ៥-៧ ឆ្នាំ 21
សម្រាប់កុមារអាយុ ៨-១០ ឆ្នាំ 39
សម្រាប់កុមារអាយុ ១១-១៧ ឆ្នាំ 69

ផ្នែកទី៣៖ ឧបសម្ព័ន្ធ 99

ឧបសម្ព័ន្ធទី១៖ គំរូលិខិតសម្រាប់ការចូលរួមដោយស្ម័គ្រចិត្ត 101
ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន 104
ឧបសម្ព័ន្ធទី៣៖ ល្បែងស្ទាងគំនិត និងសាងទំនុកចិត្ត 113
ឧបសម្ព័ន្ធទី៤៖ ល្បែងថាមពល 115
ឧបសម្ព័ន្ធទី៥៖ គំនូសអំពីរាងកាយរបស់កុមារី និងកុមារា 117
ឧបសម្ព័ន្ធទី៦៖ សេណារីយ៉ូស្តីពី "អារម្មណ៍អាចផ្លាស់ប្តូរ" 118
ឧបសម្ព័ន្ធទី៧៖ កាតសេណារីយ៉ូស្តីពី "ការប៉ះពាល់ដែលមិនបង្កជាបញ្ហា ឬជាការរំលោភបំពានផ្លូវភេទ" 121
ឧបសម្ព័ន្ធទី៨៖ សន្លឹកវាយតម្លៃខ្លួនឯង 123
ឧបសម្ព័ន្ធទី៩៖ កាតរឿងសម្ងាត់ 124
ឧបសម្ព័ន្ធទី១០៖ ទម្រង់វាយតម្លៃ 126
ឧបសម្ព័ន្ធទី១១៖ សន្លឹកកិច្ចការស្តីពីការកំណត់អាកប្បកិរិយាមិនសមស្រប 127
ឧបសម្ព័ន្ធទី១២៖ សន្លឹកកិច្ចការស្តីពីសញ្ញាតឿនអាសន្ន 129
ឧបសម្ព័ន្ធទី១៣៖ កាតវាយតម្លៃស្ថានភាព 132
ឧបសម្ព័ន្ធទី១៤៖ របាយការណ៍អ្នកសម្របសម្រួល 134

# បុព្វកថា

វិស័យទេសចរណ៍នៅប្រទេសកម្ពុជា  មានការរីកចម្រើនជាបន្តបន្ទាប់យ៉ាងឆាប់ រហ័ស។ នៅឆ្នាំ ២០១៣ ប្រទេសកម្ពុជា បានទទួលស្វាគមន៍ដំណើរកំសាន្តរបស់ ភ្ញៀវទេសចរអន្តរជាតិចំនួន ៤.២ លាននាក់ ដែលចំនួននេះបានកើនឡើង១៧% ធៀបនឹងឆ្នាំ២០១២។ ការអភិវឌ្ឍវិស័យទេសចរណ៍ កំពុងនាំមកនូវ ឱកាសជាច្រើនសម្រាប់ប្រទេសកម្ពុជានិងសហគមន៍នានា។
ក្នុងពេលជាមួយគ្នានេះ យើងក៏បានសង្កេតឃើញនូវ ចំណុចអវិជ្ជមាននៃទំនាក់ទំនង រវាងវិស័យទេសចរណ៍ និងការកេងប្រវ័ញ្ចលើកុមារ។ នៅក្នុងប្រទេសកម្ពុជា យើងបានឃើញកុមារងាយរងគ្រោះ និង ក្រុមគ្រួសាររបស់កុមារទាំងនោះ ត្រូវបានទាក់ទាញឱ្យចូលទៅកាន់គោលដៅទេសចរណ៍ ដើម្បីរកប្រាក់ចំណូល។ កុមារា និង កុមារី អាចធ្វើការនៅក្នុង ឧស្សាហកម្មទេសចរណ៍ នៅក្នុងលក្ខខណ្ឌ ដែលមិនអំណោយ ផលដល់សុវត្ថិភាព និង សុខុមាលភាពរបស់ពួកគេ។ កុមារដែលរកប្រាក់ចំណូលបានពីភ្ញៀវទេសចរ តាមរយៈការ លក់វត្ថុអនុស្សាវរីយ៍ ឬការខាត់ស្បែកជើង ទំនងជា មិនសូវបានទៅសាលារៀនឡើយ។ កុមារទាំងនេះត្រូវប្រឈម មុខនឹងភាពងាយរងគ្រោះក្នុងកម្រិតខ្ពស់ ពីការរំលោភបំពានលើរាងកាយ អារម្មណ៍ និងផ្លូវភេទ។

នៅក្នុងអនុតំបន់ទន្លេមេគង្គ ទាំងកុមារា និងកុមារី គឺជាជនរងគ្រោះដោយការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ រួមទាំងក្នុងវិស័យទេសចរណ៍ និងធ្វើដំណើរ។ កុមារដែលធ្វើការនៅតាមចិញ្ចើមថ្នល់ ឬក្នុងវិស័យក្រៅប្រព័ន្ធជាគោលដៅរបស់អ្នករំលោភបំពានផ្លូវភេទកុមារ។ ក្រៅពីនេះអ្នករំលោភ បំពានអាចនឹងតម្រង់ទៅរកកុមារងាយរងគ្រោះ តាមរយៈការបម្រើការងារនៅក្នុងសាលារៀន ឬសេវាថែទាំកុមារតាមមណ្ឌលនានា ។
តាមរយៈគម្រោងកុមារភាព រដ្ឋាភិបាលអូស្ត្រាលីបានវិនិយោគក្នុងការប្រយុទ្ធប្រឆាំង នឹងទម្រង់នៃការកេងប្រវ័ញ្ចដ៏ជាក់លាក់នេះនៅក្នុងអនុតំបន់ទន្លេមេគង្គ។

គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដែលបានចំណាយថវិកា ៧,៥ លានដុល្លា ដើម្បីប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ក្នុងអនុតំបន់ទន្លេមេគង្គ (ឆ្នាំ២០១១-២០១៤)។ គម្រោងកុមារភាពនេះពឹងផ្អែកលើការជួយឧបត្ថម្ភ ក្នុងរយៈពេលវែងរបស់ប្រទេសអូស្ត្រាលី សម្រាប់កម្មវិធីនានា ដើម្បីការពារនិងទប់ស្កាត់ការរំលោភ បំពានមកលើកុមារឱ្យបានកាន់តែប្រសើរឡើង។
គម្រោងកុមារភាព បាននាំមកនូវកិច្ចសហប្រតិបត្តិការរវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម ដើម្បីឆ្លើយតបទៅនឹងបញ្ហាដ៏ធ្ងន់ធ្ងរនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍។ គម្រោងនេះ ដំណើរការនៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម។ គម្រោងនេះ មានទាំងកម្មវិធីបង្ការ និងការពារ ។

នៅក្នុងប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោកកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍នានា និងរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា ដើម្បីការពារកុមារា និងកុមារី ឱ្យរួចផុតពីការក្លាយខ្លួនជាជនរងគ្រោះ នៅក្នុងការរំលោភបំពានផ្លូវភេទ ទាំងនៅក្នុងវិស័យទេសចរណ៍ និងក្នុងការធ្វើដំណើរ។
តាមការស្រាវជ្រាវរបស់អង្គការទស្សនៈពិភពលោកបានបង្ហាញថា មានកង្វះខាតយ៉ាងខ្លាំងផ្នែក ចំណេះដឹង និងការយល់ដឹងនៅក្នុងកម្រិតសហគមន៍ ពាក់ព័ន្ធទៅនឹងប្រធានបទ **“អ្វីជាការរំលោភបំពានផ្លូវភេទ ហើយតើវាកើតឡើងដូចម្តេច?”**។ យើងដឹងថា អ្នករំលោភបំពានឆក់ឱកាសទាញយកប្រយោជន៍ពីចំណេះដឹងតិចតួច និងការយល់ខុសទាំងនេះ ដើម្បីធ្វើការរំលោភបំពានកុមារានិងកុមារី។ វាចាំបាច់ណាស់សម្រាប់ការចែករំលែកព័ត៌មានច្បាស់លាស់ ដល់សមាជិកសហគមន៍ ពីការរំលោភបំពានផ្លូវភេទ និងវិធីការពារខ្លួនពីការរំលោភបំពាន

ទាំងនេះ។ សូម្បីតែកុមារតូច ក៏អាចរៀនពីវិធីការពារខ្លួនមិនឱ្យរងការរំលោភបំពានផ្លូវភេទបានដែរ។ អ្វីដែលសំខាន់នោះគឺយើងត្រូវឱ្យកុមារបានដឹងព័ត៌មានពិតប្រាកដ និងទាន់សភាពការណ៍អំពីការរំលោភបំពានផ្លូវភេទកុមារ។ តាមបទពិសោធន៍នានានៅក្នុងពិភពលោកក៏បានបង្ហាញឱ្យយើងដឹងដែរថា ព័ត៌មាននេះមិនត្រឹមតែផ្តល់ជំនាញដើម្បីជួយកុមារឱ្យស្គាល់ពីស្ថានភាពគ្រោះថ្នាក់ និងការពារខ្លួនឱ្យរួចផុតពីការរំលោភបំពានប៉ុណ្ណោះទេ ព្រមទាំងចេះពីរបៀបស្វែងរកជំនួយ វាផ្តល់អំណាចដល់កុមារ ដើម្បីការពារនិងរាយការណ៍ពីការរំលោភ បំពានដែលកំពុងកើតឡើងទៀតផង។ លទ្ធផលដ៏សំខាន់មួយទៀត គឺព័ត៌មាននេះបានក្លាយជាមធ្យោបាយមួយ ដែលជួយផ្តល់ការអប់រំ ដល់កុមារដែលរងគ្រោះដោយសាររំលោភបំពាន ឱ្យមានការយល់ដឹងកាន់ច្បាស់ថា មិនគួរមានអារម្មណ៍ថា ខ្លួនបានធ្វើរឿងខុសឆ្គងឬមានកំហុសឡើយ។ ការទទួលខុសត្រូវក្នុងកិច្ចការ ពារកុមារត្រូវតែជាបន្ទុកដ៏ធ្ងន់របស់មនុស្សពេញវ័យទាំងអស់។ កុមារមិនត្រូវទទួលការ ស្តីបន្ទោស ចំពោះការរំលោភបំពាន មកលើខ្លួនឡើយ ។

ហេតុនេះហើយ *រក្សាសុវត្ថិភាពឱ្យរួចផុតពីការរំលោភបំពាន៖ សៀវភៅណែនាំអ្នកសម្របសម្រួល សម្រាប់ការអប់រំកុមារ និងមនុស្សវ័យក្មេង* មានតម្លៃគួរត្រូវបោះពុម្ព។ សៀវភៅនេះ បានរៀបចំកិច្ចតែងការបង្រៀន និងសម្ភារឧបទេសផ្សេងៗ ដែលអាចឱ្យអ្នកសម្របសម្រួលប្រើប្រាស់ដើម្បីជួយឱ្យកុមារ និងមនុស្សវ័យក្មេង ឱ្យទទួលបានចំណេះដឹងនិងជំនាញសមស្របតាមសភាពការណ៍ ដើម្បីដឹងពីកិច្ចការពារ និងបញ្ឈប់ទង្វើរំលោភបំពានផ្លូវភេទ។ សៀវភៅនេះ ជួយឱ្យអ្នកសម្របសម្រួលរៀបចំពេលវេលាបង្រៀន ដោយមានការ ប្រាស្រ័យទាក់ទងគ្នាជាមួយកុមារ និងមនុស្សវ័យក្មេង ទាំងក្នុងបរិបទផ្លូវការនិងក្រៅផ្លូវការ ដោយប្រើប្រាស់សម្ភារតូចតាច ឬដោយប្រើបច្ចេកវិជ្ជា។ គំនិតនានានៅក្នុងសៀវភៅណែនាំនេះ ត្រូវបានអង្គការសហគមន៍នានា សាលារៀន និងស្ថាប័នរដ្ឋាភិបាលយកមកប្រើប្រាស់រួចហើយនៅក្នុងប្រទេសកម្ពុជា។

យើងសង្ឃឹមថា ការបោះពុម្ពផ្សាយជាផ្លូវការនេះ នឹងផ្តល់ព័ត៌មានត្រឹមត្រូវ ដល់កុមារា និងកុមារីកាន់តែច្រើននៅទូទាំងប្រទេស និងចូលរួមចំណែកក្នុងកិច្ចការពារកុមារ ឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទ។

សូមលើកទឹកចិត្តឱ្យមានការប្រើប្រាស់ដ៏ទូលំទូលាយនូវអត្ថបទបោះពុម្ពនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរដ្ឋាភិបាលអូស្ត្រាលី សម្រាប់ការវិនិយោគលើកិច្ចការដ៏មានសារសំខាន់ទាំងនេះ។

# សារតា

គម្រោងកុមារភាព ផ្នែកបង្ការ គឺជាការផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីការពារកុមារពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (ឆ្នាំ២០១១-២០១៤)។ គម្រោងកុមារភាព បាននាំមកនូវកិច្ចសហប្រតិបត្តិការគ្នារវាងអង្គការទស្សនៈពិភពលោក និងការិយាល័យ អង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀននិងឧក្រិដ្ឋកម្ម។ គម្រោងនេះប្រើប្រាស់ទាំងវិធីបង្ការ និងវិធីការពារ។

អង្គការទស្សនៈពិភពលោក ធ្វើការជាដៃគូជាមួយរាជរដ្ឋាភិបាល និងសហគមន៍ដើម្បីទប់ស្កាត់កុមារពីការរងគ្រោះដោយការរំលោភបំពានផ្លូវភេទ ក្នុងវិស័យទេសចរណ៍និងការធ្វើដំណើរ។ តាមរយៈព័ត៌មាន ការអប់រំ និងការទំនាក់ទំនង អង្គការទស្សនៈពិភពលោក មានគោលបំណងបំពាក់នូវចំណេះដឹង និងជំនាញដល់សមាជិកសហគមន៍  អាជីវកម្មទេសចរណ៍ និងមន្ត្រីរដ្ឋាភិបាល ដើម្បីធ្វើឱ្យវិស័យទេសចរណ៍មានសុវត្ថិភាពសម្រាប់កុមារ។

ដោយផ្អែកតាមការស្រាវជ្រាវ ទៅលើការយល់ដឹងរបស់សហគមន៍ ពីការរំលោភបំពានផ្លូវភេទកុមារ ទាំងផ្នែកអប់រំនិងទំនាក់ទំនងរបស់គម្រោងកុមារភាព ផ្នែកបង្ការ បានខិតខំផ្តល់នូវព័ត៌មានថ្មីៗ និងសមស្របនឹងវប្បធម៌ ដើម្បីបំពេញចំណេះដឹងដែលនៅមានការខ្វះខាត ជំនឿ និងការយល់ខុស ពីការរំលោភបំពានផ្លូវភេទដែលធ្វើឱ្យកុមារងាយរងគ្រោះដោយការរំលោភបំពាន។ ទោះបីជាកុមារ ត្រូវបានបង្រៀនពីវិធីដែលអាចការពារខ្លួនពីការរំលោភ បំពានហើយក៏ដោយ វាសំខាន់ណាស់ដែលពួកគេទទួលបានព័ត៌មានត្រឹមត្រូវ និងសមស្របនឹងការអភិវឌ្ឍន៍របស់គេ អំពីការរំលោភបំពានផ្លូវភេទ។

# គោលបំណងនៃកញ្ចប់ឧបករណ៍

រក្សាសុវត្ថិភាពពីការរំលោភបំពាន៖  កញ្ចប់ឧបករណ៍សម្រាប់អប់រំដល់កុមារ និងមនុស្សវ័យ ក្មេងមានផ្ទុក នូវឯកសារដែលផ្តល់ជូនដល់កុមារ និងមនុស្សវ័យក្មេងក្រោមអាយុ១៨ឆ្នាំ នូវចំណេះដឹង និង បំណិនសមស្រប តាមកម្រិតអភិវឌ្ឍរបស់កុមារ ដើម្បីអាចកំណត់បាននូវការរំលោភបំពានផ្លូវភេទ ក៏ដូចជាបង្ការ និងបញ្ឈប់ទង្វើទាំងនោះ។[1]  កញ្ចប់ឧបករណ៍នេះ ផ្តល់ដល់អ្នកសម្របសម្រួលនូវគោលការណ៍ណែនាំដែល ងាយអនុវត្ត ដើម្បីរៀបចំវគ្គសិក្សាខ្លីហើយច្បាស់ **រយៈពេលមួយម៉ោង** ជាមួយកុមារនិង មនុស្សវ័យក្មេង ក៏ ដូចជាធ្វើផែនការស៊ីជម្រៅដែលអាចបែងចែកជាប្រធានបទសំខាន់ៗ។ ឯកសារទាំងនេះអាចយកទៅប្រើ ដើម្បីសម្របសម្រួលវគ្គសិក្សា **រយៈពេលកន្លះថ្ងៃជាប់គ្នា** ឬចែកជាវគ្គខ្លីៗ (ពោលគឺបែងចែកជាវគ្គៗ) សម្រាប់វគ្គសិក្សារយៈខ្លី ដែលអាចអនុវត្តបានច្រើនថ្ងៃ ឬលើសពីមួយសប្តាហ៍។

ប្រសិនបើពេលវេលាគ្រប់គ្រាន់ គេក៏អាចបញ្ចូលសកម្មភាពបន្ថែមផងដែរ។ មេរៀននេះ នឹងរួមបញ្ចូលជាមួយកម្មវិធីជាច្រើន ដោយផ្តោតលើការពង្រឹងអំណាចដល់កុមារ និងមនុស្សវ័យក្មេង និងរៀបចំពួកគេសម្រាប់ជីវិតប្រចាំថ្ងៃ។ ខណៈដែលមានចន្លោះ ប្រហោង ក្នុងការបញ្ចូលសម្ភារនិងសម្លេងជំនួយ ទៅក្នុងកញ្ចប់ឧបករណ៍នេះ ឯកសារនេះត្រូវបានបង្កើតឡើង សម្រាប់ទាំងការប្រើប្រាស់ផ្លូវការ និងមិនផ្លូវការ ដោយប្រើសម្ភារ ឬបច្ចេកវិជ្ជាតិចតួចបំផុត។ អ្នកសម្របសម្រួល គួរតែអានឯកសារបណ្តុះបណ្តាលឱ្យបានយល់ច្បាស់ មុនពេលបង្រៀន និងប្រើឯកសារនេះដើម្បីជួយដល់ ការរៀបចំបង្រៀន។ អ្នកសម្របសម្រួលអាចបត់បែន ឬថែមថយសម្ភារ ដើម្បីឱ្យសមស្របជាមួយអ្នកចូលរួម។ គេអាចទាញយកឯកសារបណ្តុះបណ្តាលនេះពីគេហទំព័រ: http://www.childsafetourism.org និង http://wvi.org/asiapacific/childsafetourism.

[1] កិច្ចការពារកុមារពីការរំលោភបំពាន គឺជាការទទួលខុសត្រូវ របស់មនុស្សពេញវ័យទាំងអស់គ្នា។ លទ្ធភា និង សមត្ថភាពរបស់កុមារ ក្នុងការកត់សំគាល់ ការការពារ និងបញ្ឈប់ការរំលោភបំពាន មិនអាចប្រៀបធៀប ទៅនឹងមនុស្សពេញវ័យបានទេ។ ដូច្នេះការកំណត់ព្រំដែនសមត្ថភាពរបស់កុមារត្រូវបាន ពិចារណា។ ការអប់រំកុមារ ពីគ្រោះថ្នាក់ និងឥរិយាបថ ការពារ គឺជាផ្នែកនៃការទទួលខុសត្រូវរបស់មនុស្សពេញវ័យ ក្នុងកិច្ចការពារកុមារពីការរំលោភបំពាន។

# របៀបប្រើប្រាស់កញ្ចប់ឧបករណ៍

កញ្ចប់ឧបករណ៍នេះមានបីផ្នែក:

## ផ្នែកទី១៖ ការចាប់ផ្តើម

ផ្នែកនេះមានព័ត៌មានលម្អិត សម្រាប់អ្នកសម្របសម្រួលមុនពេលបង្រៀន។ វាបានផ្តល់នូវដំបូន្មានដែលមានប្រយោជន៍ អំពីបុគ្គលដែលអាចសម្របសម្រួលវគ្គសិក្សា តើអ្នកណាខ្លះ ដែលគួរតែអញ្ជើញមកចូលរួម តួនាទីរបស់ឪពុកម្តាយ និងអ្នកថែទាំកុមារ ការទទួលបានការយល់ព្រមពីឪពុកម្តាយ ការរៀបចំទីកន្លែង និងសម្ភារ ការត្រួតពិនិត្យនិងវាយតម្លៃវគ្គ ព្រមទាំងផ្តល់ការណែនាំជាពិសេស ក្នុងការធ្វើការជាមួយកុមារ និងការលើកឡើងពីប្រធានបទដ៏រសើបនៃការរំលោភបំពានផ្លូវភេទកុមារ។

## ផ្នែកទី២៖ ផែនការវគ្គបណ្តុះបណ្តាល

ផ្នែកនេះ ផ្តល់ការណែនាំជាជំហានៗ ដើម្បីផ្តល់នូវទិដ្ឋភាពទាំងមូលនៃការបណ្តុះបណ្តាល រួមទាំង សេចក្តីផ្តើម ការពន្យល់ ការពិភាក្សាក្រុម និងសកម្មភាព ក៏ដូចជាការណែនាំ ស្តីពីការត្រួតពិនិត្យ និងការវាយតម្លៃ។ ផែនការមេរៀននេះ ចែកចេញជាបីក្រុមអាយុ៖ គឺអាយុពី៥-៧ឆ្នាំ អាយុពី៨-១០ឆ្នាំ និងអាយុពី១១-១៧ឆ្នាំ។ ចំពោះក្រុមសិក្ខាកាមអាយុពី១១-១៧ឆ្នាំ គួរត្រូវបានបែងចែកជាក្រុមតូចៗទៀត (ខ្លឹមសារគឺដូចគ្នាដដែល)។ ក្រុមអាយុនេះ គួរត្រូវបានចែក ទៅតាមអាយុ ពី១១-១៣ឆ្នាំ និងពី១៤-១៧ឆ្នាំ។"ផែនការមេរៀនខ្លី"មួយ សម្រាប់សកម្មភាពរយៈពេលមួយម៉ោង គឺត្រូវបានរាប់បញ្ចូលក្រុមអាយុនីមួយៗ ហើយផែនការលម្អិតនៃ ប្រធានបទសំខាន់ៗ ក៏បានបញ្ចូលសម្រាប់ធ្វើសកម្មភាពរយៈពេលកន្លះថ្ងៃ ឬរយៈពេលវែងជាងនេះ។

## ផ្នែកទី៣៖ ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ មានរៀបរាប់ពីធនធានបន្ថែមដើម្បីរៀបចំវគ្គបណ្តុះបណ្តាល រួមមានកាតយកតាមខ្លួនឯកសារថតចម្លង ឯកសារទម្រង់គំរូ និងទម្រង់វាយតម្លៃ។ បើទោះជាឯកសារទាំងនេះ ស្ថិតក្នុងទម្រង់សរសេរក៏ដោយ វាក៏អាច ត្រូវបានបង្រៀនដល់កុមារតាមរយៈការពន្យល់ផ្ទាល់មាត់ ឬវិធីសាស្ត្រផ្សេងៗទៀត ដែលធានាថាកុមារ និងមនុស្សវ័យក្មេងទាំងអស់ បានទទួលនូវចំណេះដឹងអំពីឯកសារទាំងនេះ។

## ផ្នែកទីមួយ៖

# ការចាប់ផ្ដើម



# ការចាប់ផ្ដើម

## នរណាអាចសម្របសម្រួលវគ្គនេះបាន ?

សម្ភារបណ្ដុះបណ្ដាល **ការរក្សាសុវត្ថិភាពកុមារពីការរំលោភបំពាន** ដោះស្រាយបញ្ហារសើបនៃការរំលោភ បំពានផ្លូវភេទ ក្នុងវិធីមួយយ៉ាងសមស្របសម្រាប់កុមារនិងមនុស្សវ័យក្មេង។ វាមានសារៈសំខាន់ក្នុងការជ្រើសរើសអ្នកសម្របសម្រួល ដែលមានសមត្ថភាពនិងបទពិសោធន៍ ដើម្បីសម្របសម្រួលវគ្គបណ្ដុះ បណ្ដាលនេះ។ ការសម្របសម្រួលវគ្គសិក្សាទាំងនេះ ដោយអ្នកសម្របសម្រួល ដែលគ្មានជំនាញច្បាស់លាស់ឬអ្នកដែលមានទស្សនៈរើសអើង អាចបង្កើនគ្រោះថ្នាក់និងផលវិបាកនៃការរំលោភបំពានលើកុមារ។ ដោយសារប្រធានបទមានលក្ខណៈរសើប និងដើម្បីធានានូវសុខុមាលភាពរបស់កុមារ ព្រមទាំងភាពចាំបាច់ក្នុងការតាមដាន វគ្គនេះត្រូវសម្របសម្រួលដោយមនុស្សយ៉ាងហោចណាស់ក៏**ពីរនាក់**ដែរ។ យើងផ្ដល់យោបល់ថា អ្នកសម្របសម្រួលគឺជាមនុស្សដែលមានភេទដូចគ្នាទៅនឹងសិក្ខាកាម ជាពិសេសនៅពេលដែលសិក្ខាកាម ត្រូវបានបែងចែកតាមយេនឌ័រ ( ឧ. អ្នកសម្របសម្រួលជាស្រីជាមួយកុមារី និងអ្នកសម្របសម្រួលប្រុសជាមួយកុមារា )។

អ្នកសម្របសម្រួលវគ្គនេះត្រូវមាន៖

- ចំណេះដឹងច្បាស់លាស់ពីកិច្ចការពារកុមារជាពិសេសការរំលោភបំពានផ្លូវភេទ។ វាជាការល្អដែលអ្នកសម្របសម្រួល គួរតែមានជំនាញការអភិវឌ្ឍន៍ផ្នែកចិត្តសង្គមរបស់កុមារ។
- បទពិសោធន៍គ្រប់គ្រាន់ក្នុងការបង្រៀននិងធ្វើការជាមួយកុមារ និងមនុស្សវ័យក្មេង ដោយរាប់ បញ្ចូលទាំងកុមារងាយរងគ្រោះ និងកុមារដែលគេមិនសូវយកចិត្តទុកដាក់។
- មានការយល់ដឹងទូលំទូលាយអំពីនិតិវិធីដែលត្រូវអនុវត្ត ក្នុងស្ថានភាពដែលគួរឱ្យសង្ស័យនៃការរំលោភបំពានកុមារ ឬក៏នៅពេលកុមាររបង្ហាញឱ្យដឹងពីការរំលោភបំពានផ្លូវភេទ។
- ការយល់ដឹងពីរបៀបជួយកុមារឱ្យមានការរីកចំរើន និងអភិវឌ្ឍចំណេះដឹង និងជំនាញ ដើម្បីធ្វើឱ្យកុមារអាចរួចផុតពីការរំលោភបំពានផ្លូវភេទដែលអាចនឹងកើតឡើង។

អ្នកសម្របសម្រួលត្រូវមានលិខិតបញ្ជាក់ថ្កោលទោសនិងការត្រួតពិនិត្យចាំបាច់ផ្សេងៗទៀត ដើម្បីធានាថាពួកគេសមស្របចំពោះការងារជាមួយកុមារ និងមនុស្សវ័យក្មេង។

ដោយសារប្រធានបទនៃការអប់រំនេះ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបញ្ហារំលោភបំពានផ្លូវភេទ វាផ្ដោតទៅលើទំនាក់ទំនងផ្លូវភេទរវាងមនុស្ស ដោយមានការយល់ព្រម និងការមិនយល់ព្រម។ ការយកចិត្តទុកដាក់ប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ គឺចាំបាច់ត្រូវតែមាន ដើម្បីធានាថា អ្នកសម្របសម្រួលមិនប្រើអាកប្បកិរិយារើសអើងដោយផ្ទាល់ឬដោយប្រយោល រួមទាំងទំនោរផ្លូវភេទនិងអត្តសញ្ញាណយេនឌ័រ។ ការ រើសអើងខាងយេនឌ័រ ផ្លូវភេទ ពូជសាសន៍។ល។ គឺមិនអនុលោមតាមគោលការណ៍សិទ្ធិអន្តរជាតិរបស់កុមារទេ ហើយអាចរួមចំណែកទៅនឹងភាពងាយរងគ្រោះ ដែលដាក់កុមារឱ្យប្រថុយទៅនឹងការរំលោភបំពាន។ គោលការណ៍ណែនាំជាពិសេសពីការបណ្ដុះបណ្ដាលស្ដីអំពីការការពារកុមារ ក៏មាននៅក្នុងឯកសារនេះដែរ។



# តើនរណាគួរចូលរួមវគ្គនេះ?

កញ្ចប់ឧបករណ៍ស្តីពីការរក្សាសុវត្ថិភាពកុមារ ពីការរំលោភបំពាន អាចចូលរួមបានទាំងកុមារា និងកុមារី ក្នុងក្រុមអាយុដូចតទៅ៖ អាយុ៥-៧ឆ្នាំ អាយុ៨-១០ឆ្នាំ និងអាយុ១១-១៧ឆ្នាំ។ សិក្ខាកាម គប្បីចែកជាក្រុម ទៅតាមក្រុមអាយុទាំងនេះ ។ សម្រាប់ក្រុមកុមារអាយុច្រើន ពួកគេគប្បីត្រូវបានបែងចែកជាក្រុម បន្តទៀត៖ អាយុ១១-១៣ឆ្នាំ និងអាយុ១៤-១៧ឆ្នាំ។ នៅក្នុង កាលៈទេសៈខ្លះ អ្នកសម្របសម្រួលអាចប្រើសកម្មភាព របស់កុមារក្នុងក្រុម អាយុតិចជាង មកប្រើជាមួយកុមារក្នុងក្រុមអាយុច្រើន ប្រសិនបើគោលគំនិតទាំងនោះ មិនទាន់ត្រូវបានបង្រៀនដល់ពួកគេ ពីមុនមក។

ប្រសិនបើអ្នកត្រូវធ្វើការជាមួយកុមារដែលមានបញ្ហាលំបាកក្នុង ការរៀនសូត្រ ឬមានការអភិវឌ្ឍន៍បញ្ញាខ្សោយ គេត្រូវពិចារណា ប្រើឯកសារតាមអាយុនៃកម្រិតអភិវឌ្ឍ បញ្ញារបស់កុមារ ជាជាង តាមលំដាប់លំដោយអាយុរបស់ពួកគេ។ កុមារនិងមនុស្សវ័យក្មេង គួរត្រូវបានបែងចែកតាមក្រុមភេទ ប្រសិនបើអាច[2]។ ការកែសម្រួលគួរតែមាន សម្រាប់កុមារពិការ និងជាពិសេស កុមារដែលគេមិនសូវយក ចិត្តទុកដាក់កុមារងាយរងគ្រោះ ឬកុមារដែលធ្លាប់ បានទទួលការរំលោភបំពាន ក្នុងរូបភាពណាមួយរួចមកហើយ។ វាសំខាន់ណាស់ដែលអ្នកសម្របសម្រួល ត្រូវ ពិចារណាដោយប្រុងប្រយ័ត្ន ពីតម្រូវការ និងសាវតារបស់ក្រុម នីមួយៗ និងរៀបចំមាតិកានិងសកម្មភាពដោយសមគួរ មុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល។

ក្នុងឧទាហរណ៍មួយចំនួន យើង អាចប្រើសកម្មភាពពីក្រុមអាយុ តិចជាង សំរាប់ក្រុមដែលមាន អាយុច្រើនជាងនៅពេលដែល គំនិតនេះមិនត្រូវបានបង្រៀន ពីមុន ។
បើសិនជាកុមារមានពិការភាព ក្នុងការសិក្សាឬការលូតលាស់យឺត បញ្ហានេះ ត្រូវពិចារណាជាជាង លំដាប់លំដោយនៃអាយុ។

[2] ការស្រាវជ្រាវបង្ហាញថាជាទូទៅការបែងចែកទៅតាមភេទនៅរវាងអាយុ៦-១២ឆ្នាំ ដោយកុមារាចូលចិត្តលេងជាមួយកុមារាដូចគ្នា ហើយកុមារីក៏ចូលចិត្តលេងជាមួយកុមារីដូចគ្នា។ ចំណុចនេះមានដូចគ្នាចំពោះវប្បធម៌ផ្សេងៗគ្នាជុំវិញពិភពលោកបើតាម ៖ Harkness និង Super (១៩៨៥) បរិបទវប្បធម៌នៃការបែងចែកតាមភេទនៃការចងក្រងជាក្រុមរបស់កុមារ

# តើលទ្ធផលរំពឹងទុកនៃការសិក្សាមានអ្វីខ្លះ ?

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល កុមារនិងមនុស្សវ័យក្មេង នឹងរៀនពីគោលគំនិត ដែលសមស្របតាមអាយុ និងដំណាក់កាលរបស់គេគឺ:



- ពីអារម្មណ៍ដែលគួរទុកចិត្តនិងសិទ្ធិទទួលបានសុវត្ថិភាព
- ស្គាល់ពីការប៉ះពាល់/ស្ទាប ដែលសមស្រប និងមិនសមស្រប
- ពួកគេមានសិទ្ធិនិយាយថា "ទេ" ទៅមនុស្សដែលប៉ះពាល់/ស្ទាបមិនសមរម្យចំពោះពួកគេ ឬគំរាមកំហែងដល់សុវត្ថិភាពរបស់ពួកគេ។
- វាមានសារៈសំខាន់ក្នុងការប្រាប់ទៅមនុស្សពេញវ័យដែលអាចទុកចិត្ត ពីស្ថានភាពបែបនេះ
- ពួកគេអាចត្រូវបន្តប្រាប់ទៅមនុស្សពេញវ័យជុំវិញខ្លួនពីស្ថានភាពដែលមិនល្អចំពោះពួកគេ រហូតដល់គេជឿអំពីរឿងនោះ និង
- ពួកគេអាចទទួលបានជំនួយនៅក្នុងសហគមន៍របស់ពួកគេ[3] ។

[3] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញូវសោតវែល លេខាធិការដ្ឋានសុខុមាលភាពសិស្ស (១៩៩៧) ការអប់រំស្តីពីការការពារកុមារ ៖ ឯកសារ កម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ

## តើធ្វើយ៉ាងណា ទើបទទួលបាន ទម្រង់យល់ព្រមចូលរួមពីកុមារ និងមនុស្សវ័យក្មេង ?[4]

រាល់ការចូលរួមក្នុងវគ្គបណ្តុះបណ្តាល គប្បីធ្វើឡើងដោយស្មគ្រ័ចិត្ត។ ការចូលរួមដោយស្មគ្រ័ចិត្តមាន ន័យថា សិក្ខាកាមទាំងអស់ត្រូវផ្តល់ “**ទម្រង់យល់ព្រមចូលរួម**” សម្រាប់ការចូលរួមក្នុងវគ្គ បណ្តុះបណ្តាល។ ដោយសារសិក្ខាកាមមាន អាយុក្រោម១៨ឆ្នាំសមត្ថភាព ទំនាក់ទំនង និងការយល់ ដឹងរបស់ពួកគ គើខុសៗគ្នា ដូចនេះវាចាំបាច់ ដែលត្រូវទទួល បានការ យល់ព្រម ពីឪពុកម្តាយ/អ្នកថែទាំកុមារ[5] និងការ យល់ ព្រមពីកុមារ ផងដែរ សម្រាប់ការចូលរួមក្នុងវគ្គបណ្តុះ បណ្តាល។ ការទទួលបានការយល់ព្រមពីឪពុកម្តាយ/អ្នក ថែទាំកុមារ អាចមានភាពស្មុគស្មាញ។ ឪពុកម្តាយ/អ្នក ថែទាំកុមារ អាចព្រួយបារម្ភពីអាយុរបស់កុមារ និងមានការ ជឿជាក់តិច ឬច្រើន លើការគិតថា កូនរបស់ពួកគេគប្បីដឹង ឬត្រូវតែ ដឹងអំពីការរំលោភបំពានផ្លូវភេទ។ **ឧបសម្ព័ន្ធទី១** មាន សំបុត្រគំរូសម្រាប់ឪពុកម្តាយ/អ្នកថែទាំកុមារ ដែលអាច ប្រើដើម្បី ចែករំលែកព័ត៌មានសមស្របស្តីពីគោលបំណងនៃ វគ្គបណ្តុះបណ្តាលនេះ និងទទួលបាន “ទម្រង់យល់ព្រមចូល រួម”ជាមុន។

**“ទម្រង់យល់ព្រមចូលរួម”** មានន័យថា កុមារបានយល់ព្រមដោយបើកចំហថា ចូលរួមក្នុងសកម្មភាពមួយ បន្ទាប់ពី ទទួលព័ត៌មានជាមុនអំពីរបៀបដែលពួក គេអាចយល់ពីចំណុចដូចតទៅ៖

- គោលបំណង និងអត្ថប្រយោជន៍ ឬលទ្ធផលរំពឹងទុកនៃសកម្មភាព ចូលរួមរបស់កុមារ
- គ្រោះភ័យ និងផលវិបាកសំខាន់ៗនៃ ការចូលរួម
- ការចំណាយពេលវេលា និងក្តីរំពឹង ផ្សេងៗទៀតពីអ្នកចូលរួម
- លទ្ធភាពនៃការបដិសេធមិនចូលរួម ឬដកខ្លួនចេញពីសកម្មភាពនៅពេល ណាមួយក៏បាន។

## តើមាតាបិតា គ្រួសារ និងសហគមន៍ មានតួនាទីអ្វីខ្លះ ?

ការស្រាវជ្រាវបង្ហាញថា សូម្បីតែកុមារតូចៗ ក៏អាចរៀនចេះពីរបៀបការពារខ្លួនឯងពីការរំលោភបំពានបានដែរ។ តែទោះជាយ៉ាងនេះក្តី ប្រការនេះមិនអាចបន្ថយការទទួលខុសត្រូវចម្បង របស់មនុស្សពេញវ័យ ក្នុងការការពារនិង ថែទាំកុមារនោះទេ។ កុមារពឹងលើមនុស្សពេញវ័យដែលមានទំនួលខុសត្រូវ ក្នុងការធ្វើអន្តរាគមន៍ និងជួយពួកគេ។ ដោយហេតុនេះ និងបើអាចធ្វើបាន ឪពុកម្តាយ/អ្នកថែទាំកុមារ និងអ្នកតំណាងសហគមន៍ គប្បីត្រូវបានអញ្ជើញឱ្យ ចូលរួមក្នុងវគ្គបណ្តុះបណ្តាល ដើម្បីបង្ការការរំលោភបំពានផ្លូវភេទលើកុមារ[6] ។ តាមរយៈវិធីនេះ មនុស្សពេញវ័យ ដែលមានទំនួលខុសត្រូវ ដែលនៅជិតកុមារអាចធ្វើការឆ្លើយតបយ៉ាងសមស្របចំពោះយោបល់និងសំណួរ របស់កុមារ ពង្រឹងបន្ថែមចំពោះគោលគំនិត និងបំណិនដែលបានបង្រៀនដល់កុមារ ព្រមទាំងអនុវត្ត សកម្មភាពសមស្របដើម្បីបញ្ឈប់ការរំលោភបំពាន និងគាំទ្រដល់ជនរងគ្រោះ ប្រសិនបើមានការរកឃើញ ឬសង្ស័យថាជា ករណីរំលោភបំពាន។

---

[4] កែសម្រួលចេញពី គោលការណ៍ណែនាំរបស់អង្គការទស្សនៈពិភពលោក សម្រាប់ការបង្ការ និងឆ្លើយតបចំពោះទុក្ខកង្វល់ក្នុងរាល់សកម្មភាពចូលរួមរបស់កុមារ (២០១២)

[5] ប្រសិនបើមិនអាចទាក់ទងមាតាបិតា/អ្នកថែទាំបាន (ឧទាហរណ៍ ករណីកុមាររស់នៅតាមចិញ្ចើមថ្នល់) នោះជួនកាលគេក៏អាចប្រើការយល់ព្រមពីមនុស្ស ពេញវ័យផ្សេងទៀតដែលទទួលខុសត្រូវថែទាំកុមារនោះ ដូចជាគ្រូបង្រៀន ឬបុគ្គលិកសង្គម។ អ្នកសម្របសម្រួលគប្បីយល់ដឹង និងអនុវត្តតាមច្បាប់ និង ការតម្រូវរបស់ប្រទេសនោះ។

[6] ឯកសារស្តីពីការរក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ ៖ វេទិកាពិភាក្សាសម្រាប់មាតាបិតា និងអ្នកថែទាំ និងឯកសារស្តីពី ការរក្សាសុវត្ថិភាពកុមារពីការ រំលោភបំពានផ្លូវភេទ ៖ វេទិកាសម្រាប់អ្នកតំណាងសហគមន៍ អាចទាញយកបានពីគេហទំព័រ http://www.childsafetourism.org ឬ http://wvi.org/asiapacific/childsafetourism.

# ចំណុចគន្លឹះសម្រាប់ធ្វើការងារជាមួយកុមារ និងមនុស្សវ័យក្មេង

នៅពេលធ្វើការងារជាមួយកុមារ និងមនុស្សវ័យក្មេង អ្នកសម្របសម្រួលគប្បីមានភាពស្មោះត្រង់ និងច្បាស់លាស់ និងមិនត្រូវសន្យាអ្វី ដែលពួកគេមិនអាចធ្វើបាននោះទេ។ អ្នកសម្របសម្រួលល្អ ត្រូវមានភាពអំណត់ និងមានគំនិតច្នៃប្រឌិត។ គោលការណ៍ណែនាំសំខាន់ៗមួយចំនួនសម្រាប់ការធ្វើការជាមួយកុមាររួមមាន៖[7]

| ត្រូវធ្វើ: | មិនត្រូវធ្វើ: |
|---|---|
| • ណែនាំខ្លួនអ្នក<br>• ប្រើភាសាសាមញ្ញៗ<br>• អំណត់<br>• ត្រូវប្រាកដថាអ្នកមានឯកជនភាពគ្រប់គ្រាន់<br>• ត្រូវយល់ពីអារម្មណ៍របស់កុមារ<br>• សូមការអនុញ្ញាតពីកុមារ<br>• រក្សារឿងសម្ងាត់ចំពោះទស្សនៈនិងចម្លើយរបស់កុមារ<br>• ចេះបត់បែននិងមានគំនិតច្នៃប្រឌិតធ្វើឱ្យកុមាររីករាយ<br>• ស្តាប់ និងគោរពទស្សនៈរបស់កុមារ<br>• ឱ្យតម្លៃកុមារជាដៃគូស្មើគ្នា<br>• ពេលនិយាយ ត្រូវនិយាយក្នុងនាមកុមារ និងមនុស្សវ័យ ក្មេង<br>• ត្រូវចេះពិចារណាចំពោះទង្វើខ្លួនឯង ឆ្លុះបញ្ចាំងពីអាកប្បកិរិយារបស់ខ្លួនចំពោះកុមារ<br>• បង្ហាញចំណាប់អារម្មណ៍និងការគោរព ចំពោះយោបល់ចំណេះដឹង និងបំណិន របស់កុមារ និងមនុស្សវ័យក្មេង។<br>• អនុញ្ញាតឱ្យកុមារធ្វើកិច្ចការខ្លួនឯង តាមរបៀបផ្ទាល់ខ្លួនរបស់ពួកគេ<br>• ស្គាល់តម្រូវការខុសៗគ្នារវាងកុមារីនិងកុមារា កុមារពិការ និងកុមារមានជាតិសាសន៍ ផ្សេងៗគ្នា និងដោយការប្រព្រឹត្តិស្មើភាពចំពោះកុមារទាំងអស់។<br>• ប្រើវិធីសាស្ត្រដែលអនុញ្ញាតិឱ្យកុមារ និងមនុស្សវ័យក្មេង បានបង្ហាញពីទស្សនៈ ចំណេះដឹង និងបំណិនរបស់ពួកគេ។<br>• បង្កើតនូវបរិយាកាសដែលនាំឱ្យកុមារខិតខំគិតបែបស្ថាបនា និងសមស្របតាមអារម្មណ៍របស់ពួកគេ។ | • បង្រៀន<br>• ប្រញាប់ប្រញាល់<br>• រិះគន់ ឬផ្តល់យោបល់ជាលក្ខណៈអវិជ្ជមាន<br>• និយាយកាត់កុមារ<br>• គ្របដណ្តប់លើកុមារ<br>• ធ្វើឱ្យកុមារភ័យដោយដាក់ឱ្យមានអ្នកសម្របសម្រួលជាមនុស្សពេញវ័យច្រើននាក់<br>• ធ្វើឱ្យកុមារអាម៉ាស់ ឬសើចចំអកឱ្យពួកគេ<br>• បកស្រាយឡើងវិញនូវអ្វីដែលកុមារនិយាយរួចហើយ<br>• និយាយមើលងាយកុមារ<br>• ឈរឬអង្គុយខ្ពស់ នៅពេលកុមារឈរឬអង្គុយទាបជាង ខ្លួន<br>• សង្ស័យចំពោះការរួមចំណែករបស់កុមារ ឬធ្វើឱ្យពួកគេ មានអារម្មណ៍ថា ពួកគេ កំពុងត្រូវបានអ្នកដទៃវិនិច្ឆ័យ<br>• ប្រៀបធៀបកុមារមួយចំនួនថាអន់ជាង កុមារឯទៀត<br>• ប្រព្រឹត្តិមិនស្មើភាពចំពោះកុម រា ឬកុមារី ដែលបានរៀនច្រើន ឬកុមារដែលមាន ជាតិសាសន៍ផ្សេងគ្នា<br>• ដាក់ម៉ោងសិក្សាវែងពេក នៅពេលដែល កុមារនឿយហត់ និងមិនចាប់អារម្មណ៍ |

[7] កែសម្រួលចេញពី គោលការណ៍ណែនាំរបស់អង្គការទស្សនៈពិភពលោកសម្រាប់ការបង្ការ និងឆ្លើយតបចំពោះទុក្ខកង្វល់ក្នុងរាល់សកម្មភាពចូលរួមរបស់កុមារ (២០១២)

# ការពិចារណាសំខាន់ៗ សម្រាប់វគ្គបណ្តុះបណ្តាលស្តីពីការការពារកុមារ

អាស្រ័យដោយភាពរសើបនៃប្រធានបទនេះ អ្នកសម្របសម្រួលចាំបាច់ត្រូវធានាឱ្យបាថា កុមារ និងមនុស្សវ័យក្មេងដែលចូលរួមនៅក្នុងវគ្គនេះមានអារម្មណ៍ថាមានសុវត្ថិភាព និងទទួលបានការគាំទ្រ។ អ្នកសម្របសម្រួល ចាំបាច់ត្រូវប្រុងប្រយ័ត្ន ចំពោះប្រតិកម្មរបស់អ្នកចូលរួម និងសង្កេតតាមដានដោយយកចិត្តទុកដាក់ថា តើសកម្មភាពទាំងឡាយ ជះឥទ្ធិពលដូចម្តេចខ្លះលើអ្នកចូលរួមម្នាក់ៗ និងអ្នកចូលរួមទាំងអស់។ **មុនពេលបង្រៀនវគ្គណាមួយ** អ្នកសម្របសម្រួល **ចាំបាច់ត្រូវតែ** ធានាឱ្យមានសេវាសមស្រប ដើម្បីឆ្លើយតបក្នុងករណីកុមារ ឬមនុស្សវ័យក្មេងណាម្នាក់កើតមានអារម្មណ៍តានតឹង ឬលាតត្រដាងពីការរំលោភបំពាន។ យើងខ្ញុំសូមផ្តល់យុទ្ធសាស្ត្រជាក់លាក់ដូចខាងក្រោមនេះ[8]

## ត្រៀមជាស្រេចនូវព័ត៌មានសម្រាប់ទំនាក់ទំនងទៅកាន់សេវាបញ្ជូននានា ក្នុងករណីកុមារមានការតានតឹងផ្លូវចិត្ត ឬប្រាប់អំពីបទពិសោធន៍នៃការរំលោភបំពាន

មុនពេលចាប់ផ្តើមដំណើរការមេរៀន អ្នកសម្របសម្រួលចាំបាច់ ត្រូវដឹងពីសេវាគាំទ្រនានា ដែលមានដើម្បីឆ្លើយតប ក្នុងករណីកុមារណាម្នាក់កើតមានការតានតឹងផ្លូវចិត្ត ឬបង្ហាញប្រាប់អំពីបទពិសោធនៃការ រំលោភបំពាន។ ប្រសិនបើមានការលាតត្រដាងការពិតណាមួយ ចាំបាច់ត្រូវតែបញ្ជូនទៅកាន់យន្តការបញ្ជូនសមស្របសម្រាប់ការការពារ កុមារក្នុងមូលដ្ឋាន និង/ឬទីភ្នាក់ងារនានា (រួមមានអង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន)។ **រាល់ការប្រាប់ការពិតទាំងអស់ ត្រូវរាយការជាបន្ទាន់។**

## ការឆ្លើយតបនៅពេលកុមារប្រាប់ពីការរំលោភបំពាន

អាចមានករណីដែលកុមារ ឬមនុស្សវ័យក្មេងប្រាប់ ឬចាប់ផ្តើមប្រាប់ពីបទពិសោធន៍នៃការរំលោភបំពាន ក្នុងពេលមានវគ្គមានអ្នកចូលរួមដទៃទៀត។ ប្រសិនបើមានករណីបែបនេះកើតឡើង វាជាការសំខាន់ណាស់ក្នុងការការពារភាពឯកជនរបស់កុមារ។ វិធីសាស្ត្រមួយដែលអាចយកមកប្រើបាន គឺ“ការបង្អាក់ក្នុងលក្ខណៈវិជ្ជមាន”។ អ្នកអាចធ្វើបែបនេះបានតាមរយៈ៖

- ទទួលស្គាល់ថា អ្នកបានឮសម្តីកុមារ ហើយបញ្ឈប់គាត់កុំឱ្យបង្ហាញប្រាប់តទៅទៀត
- សម្តែងការគាំទ្រដោយសុភាពរាបសារថា តែសូមបង្អាក់កុំឱ្យគាត់បន្តនិយាយប្រាប់អ្នកទៀត
- រៀបចំជួបជាមួយកុមារ ឬមនុស្សវ័យក្មេងនោះដោយស្ងាត់ៗ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន។ ប្រសិនបើកុមារចាប់ផ្តើមលាតត្រដាងពីការពិតប្រាប់អ្នកនៅក្នុងទីកន្លែងផ្ទាល់ខ្លួន៖
- ស្តាប់សម្តីកុមារដោយយកចិត្តទុកដាក់បំផុត។
- ធ្វើឱ្យកុមារប្រាកដក្នុងចិត្តថា ការចែករំលែករឿងរបស់ពួកគេគឺជាការល្អ ហើយពួកគេនឹងមិនត្រូវទទួលខុសត្រូវ ឬរងការស្តីបន្ទោសណាមួយ ចំពោះស្ថានភាពដែលបានកើតឡើងឡើយ។
- ពន្យល់ប្រាប់ថា អ្នកចាំបាច់ត្រូវចែករំលែកព័ត៌មាននោះជាមួយមនុស្សដែលពាក់ព័ន្ធ ដើម្បីរក្សាសុវត្ថិភាពកុមារ (សូមកុំសន្យាថាអ្នកនឹងរក្សាព័ត៌មាននោះជាព័ត៌មានសម្ងាត់)។
- សូមកុំធ្វើខ្លួនជាអ្នកស៊ើបអង្កេត លើកលែងតែអ្នកជាបុគ្គលិកសង្គមកិច្ច ឬមន្ត្រីប៉ូលីស ព្រោះអ្នកគ្មានតួនាទីផ្នែកស៊ើបអង្កេតឡើយ។
- អ្នកអាចសួរសំណួរបាន ប៉ុន្តែមិនគួរសួរសំណួរនាំមុខ (ពោលគឺជាសំណួរដែលជម្រុញ ឬលើកទឹកចិត្តឱ្យឈានទៅដល់ចម្លើយជាក់លាក់ណាមួយ)។

[8] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញ៉ូវសោតវែល លេខាធិការដ្ឋានសុខុមាលភាពសិស្ស (១៩៩៧) ការអប់រំស្តីពីការការពារកុមារ ៖ ឯកសារកម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ និង គោលការណ៍ណែនាំរបស់អង្គការទស្សនៈពិភពលោកសម្រាប់ការបង្ការ និងឆ្លើយតបចំពោះទុក្ខកង្វល់ក្នុងរាល់សកម្មភាពចូលរួមរបស់កុមារ (២០១២)

- ធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរពីអ្វីដែលអ្នកបានឮ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាននៅក្រោយពេលកិច្ចសន្ទនាចប់។ វាជាការសំខាន់ណាស់ ដែលអ្នកមិនត្រូវសរសេររបាយការណ៍នេះនៅចំពោះមុខកុមារឡើយ។ ដើម្បីជៀសវាងរាល់ការភាន់ច្រឡំ ភាពខ្វល់ខ្វាយ ឬអារម្មណ៍មិនស្រួល កុមារមិនគួរឮអ្នកដទៃទៀតកំពុងតែជជែកគ្នាពីការលាតត្រដាងពីការពិតរបស់ពួកគេឡើយ។
- ត្រូវយកចិត្តទុកដាក់បំផុតចំពោះការលាតត្រដាងពីការពិត ដោយត្រូវរក្សារឿងសម្ងាត់ និងធ្វើការឆ្លើយតបឱ្យទាន់ពេលវេលា ប្រសិនបើកុមារកំពុងប្រឈមនឹងគ្រោះថ្នាក់។ សូមចែករំលែកព័ត៌មានជាមួយតែអ្នកដែលមានវិជ្ជាជីវៈសមស្របប៉ុណ្ណោះ។
- មិនត្រូវមើលស្រាលចំពោះសារៈសំខាន់របស់ខ្លួនអ្នកឡើយ ប៉ុន្តែក៏ត្រូវជៀសវាងកុំទទួលខុសត្រូវ**តែម្នាក់ឯង**ក្នុងការឆ្លើយតបចំពោះស្ថានភាពនោះដែរ។
- ត្រូវកត់ត្រាទុកព័ត៌មានស្ដីពីគ្រោះថ្នាក់ ដែលអាចកើតមានភ្លាមចំពោះកុមារ ដូចជាកុមារត្រូវនៅផ្ទះ ឬនៅកៀកនឹងអ្នកដែលមានបំណងរំលោភបំពានលើកុមារជាដើម។
- សូមពិចារណាមើលថា តើអាចមានកុមារដទៃទៀត ដែលត្រូវប្រឈមគ្រោះថ្នាក់ ពាក់ព័ន្ធនឹងព័ត៌មានដែលត្រូវបានចែករំលែកនេះដែរឬទេ ។
- អ្នកត្រូវបញ្ជូនព័ត៌មានទៅឱ្យអ្នកប្រកបវិជ្ជាជីវៈដែលអាចជួយសម្រួលដល់ស្ថានភាពនេះបាន។ ទីភ្នាក់ងារវិជ្ជាជីវៈ (រួមទាំងសេវាសុខភាព ប៉ូលីស ជម្រកបណ្ដោះអាសន្ន អង្គការសប្បុរសធម៌ និងសេវា សង្គមកិច្ចនានា ) អាចបានទទួលព័ត៌មានអំពីសុវត្ថិភាពកុមារនេះរួចហើយ។ ការបង្ហាញប្រាប់របស់កុមារ អាចបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់នូវគ្រោះថ្នាក់ ដែលអាចប៉ះពាល់ដល់សុវត្ថិភាពរបស់កុមារ។ ប្រសិនបើព័ត៌មានមិនត្រូវបានចែករំលែកទៅកាន់អ្នកប្រកបវិជ្ជាជីវៈដែលពាក់ព័ន្ធដទៃទៀតទេនោះ កុមារអាចស្ថិតក្នុងស្ថានភាពដែលគ្មានសុវត្ថិភាព ដែលអាចមានគ្រោះថ្នាក់អន្តរាយដល់កុមារ ។
- កុមារ ឬគ្រួសាររបស់គេ មិនគួរទទួលរងការស្ដីបន្ទោស ឬរើសអើង ដោយសារតែការរំលោភបំពានផ្លូវភេទនោះឡើយ។ គួរចាត់គ្រប់វិធានការដើម្បីរក្សាឱ្យមានការគោរព និងការយកចិត្តទុកដាក់ចំពោះកុមារ។
- **សូមចងចាំថា សុវត្ថិភាពរបស់កុមារគឺជាក្ដីកង្វល់ចម្បងបំផុត។**



ត្រូវចាត់វិធានការករណីនីមួយៗដោយប្រុងប្រយ័ត្ន ផ្អែកលើដំណើររឿងផ្ទាល់ទាំងនោះ ដោយត្រូវពិចារណាលើបរិបទទាំងមូល និងយោបល់ពីអ្នកជំនាញផ្នែកច្បាប់ និងការគាំទ្រផ្នែកសង្គម។ ប្រសិនបើអ្នកសង្ស័យថា កុមារណាម្នាក់រងការរំលោភបំពាន សុវត្ថិភាពរបស់កុមារនោះគឺជាអាទិភាពចម្បង ហើយអ្នកចាំបាច់ត្រូវតែប្រុងប្រយ័ត្នធ្វើយ៉ាងណាកុំដាក់កុមារឱ្យប្រឈមនឹងគ្រោះថ្នាក់បន្ថែមទៀត។[9]

## បង្កើតបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព ដើម្បីឱ្យកុមារមានអារម្មណ៍ថាទទួលបានការគាំទ្រ និងការគោរព

ខ្លឹមសាររបស់កញ្ចប់ឧបករណ៍នេះ ត្រូវបានតាក់តែងឡើង យ៉ាងប្រុងប្រយ័ត្នធ្វើយ៉ាងណា ដើម្បីកុំឱ្យមាន ការកើនឡើងនូវក្តីខ្វល់ខ្វាយឬការភ័យខ្លាច។ ផ្ទុយទៅវិញ តាមរយៈការប្រើកញ្ចប់ឧបករណ៍នេះ កុមារនិងមនុស្សវ័យក្មេងគួរបានដឹង និងត្រូវបានពង្រឹងសិទ្ធិអំណាច តាមរយៈការចូលរួមរបស់ខ្លួន។ អ្នកសម្របសម្រួលមានតួនាទីសំខាន់ដើម្បីបង្កើតបរិស្ថានរៀនសូត្រប្រកបដោយសុវត្ថិភាព និងការទុកចិត្តគ្នា។ យើងលើកទឹកចិត្តឱ្យអ្នកសម្របសម្រួលបង្កើតច្បាប់មូលដ្ឋានមួយចំនួនជាមួយក្រុមអ្នកចូលរួម ដោយប្រើភាសាសមស្របទៅតាមអាយុ និងដំណាក់កាលអភិវឌ្ឍន៍របស់ពួកគេ នៅពេលចាប់ផ្តើមវគ្គសិក្សានីមួយៗ ដើម្បីឱ្យអ្នកចូលរួមមានអារម្មណ៍សុវត្ថិភាពក្នុងការនិយាយ។ ឧទាហរណ៍៖

- ត្រូវគោរពគ្នាទៅវិញទៅមក
- ត្រូវអនុញ្ញាតឱ្យអ្នកដទៃនិយាយដោយមិននិយាយកាត់ ឬចំអក
- ពេលវេលាសម្រាប់វគ្គសិក្សា ឬការពិភាក្សាក្រុម
- ទីនេះពុំមែនជាកន្លែងសម្រាប់លាតត្រដាងពីការពិតនៃរឿងផ្ទាល់ខ្លួននោះទេ និង
- អ្នកចូលរួមអាចនិយាយទៅកាន់អ្នកសម្របសម្រួល ណាម្នាក់ដោយឡែកបាន ប្រសិនបើអ្វីដែលនិយាយនោះធ្វើឱ្យពួកគេបារម្ភ ឬអាក់អន់ចិត្ត ហើយពួកគេពុំចង់ ឬពុំមានអារម្មណ៍ថាខ្លួនអាចនិយាយនៅក្នុងក្រុមបាន។

នៅក្នុងក្រុមដែលកុមារពុំទាន់ស្គាល់គ្នាទៅវិញទៅមក អ្នកអាចយកសកម្មភាព “**សាងភាពស្និទ្ធស្នាល**” និង “**ការបង្កើតទំនុកចិត្ត**” មកប្រើ (សូមមើល**ឧបសម្ព័ន្ធទី៣**) ដើម្បីជម្រុញបរិយាកាសប្រកបដោយសុវត្ថិភាពនេះ។ កុមារ និងមនុស្សវ័យក្មេងម្នាក់ៗគួរមានអារម្មណ៍ថា ខ្លួនបានទទួលការគាំទ្រ និងការគោរពនៅក្នុងក្រុម ព្រមទាំងមានទស្សនៈវិជ្ជមានចំពោះខ្លួនឯង និងចំពោះសកម្មភាពដែលកំពុងធ្វើឡើង។

## សម្របសម្រួលសកម្មភាពសិក្សាដែលដោះស្រាយយ៉ាងសមស្របជាមួយការរំលោភបំពាន

អ្នកសម្របសម្រួលមិនគួរបង្កើនភាពខ្វល់ខ្វាយ ឬជម្រុញឱ្យមានការភ័យខ្លាច ដែលមិនចាំបាច់នោះ ទេ។ សកម្មភាព និងការណែនាំនៅក្នុងកញ្ចប់ឧបករណ៍នេះត្រូវបានតាក់តែងឡើងដោយប្រុងប្រយ័ត្នដើម្បីកុំឱ្យមានរឿងនេះកើតឡើង។ អ្នកសម្របសម្រួលត្រូវយល់ច្បាស់ពីខ្លឹមសារនៅក្នុងផែនការមេរៀនវគ្គនីមួយៗ ហើយត្រូវជម្រុញការចូលរួមរបស់កុមារដោយប្រុងប្រយ័ត្ន។ ស្របពេលជាមួយគ្នានោះ ត្រូវអនុញ្ញាតឱ្យកុមាររក្សាទុកនូវព័ត៌មានបើសិនជាពួកគេចង់និយាយ។ វិធីមួយចំនួនដើម្បីធ្វើការងារនេះមានដូចជា៖

- ប្រើប្រាស់ឧទាហរណ៍ប្រឌិតដូចជា “*តើមានអ្វីកើតឡើង ប្រសិនបើ... ?*”
- ប្រឌិតស្ថានភាពឡើង ដូចជា “*ឧបមាថារឿងនេះកើតឡើង...*”
- ប្រើប្រាស់ភាសាបែបលក្ខខណ្ឌនៅពេលអ្នកចូលរួមពិចារណាទៅលើផលវិបាកនៃសកម្មភាពដូចជា ”... *ប្រហែលកើតឡើង*” ឬ “*អាចនឹងកើតឡើង*”។

អ្នកសម្របសម្រួលគួរប្រើប្រាស់សកម្មភាពនៅក្នុងកញ្ចប់ឧបករណ៍នេះ ព្រោះថាសកម្មភាពទាំងនេះ

[9] ករណីមួយអាចពាក់ព័ន្ធជាមួយកុមារលើសពីម្នាក់។

ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវលក្ខណៈសម្បត្តិដែលពាក់ព័ន្ធ និងយន្តការនៃការរំលោភបំពានកុមារ។[10] ក្នុងពេលអនុវត្តសកម្មភាព ជានិច្ចកាលអ្នកសម្របសម្រួល គួរគូសបញ្ជាក់ពីការឆ្លើយតបសមស្របចំពោះស្ថាន ភាព និងទទួលស្គាល់ការលំបាកក្នុងការអនុវត្តសកម្មភាពមួយចំនួន ជាពិសេសប្រសិនបើកុមារ ឬមនុស្សវ័យក្មេងពុំបញ្ជាក់សកម្មភាពទទួលខុសត្រូវក្នុងអំឡុងពេលពិភាក្សានេះ។

## សង្កេតកុមារដោយប្រុងប្រយ័ត្ន និងផ្តល់ឱកាសឱ្យពួកគេ “ពិភាក្សាសង្ខេបឡើងវិញ” ប្រសិនបើចាំបាច់

អ្នកសម្របសម្រួលគួរសង្កេតអ្នកចូលរួម ពេលពួកគេកំពុងសិក្សាដោយប្រុងប្រយ័ត្ន។ គួរត្រៀមអ្នកសម្របសម្រួលទីពីរ/សហអ្នកសម្របសម្រួល (ឬ“អ្នកឃ្លាំមើល”) ដើម្បីកំណត់ក្រែងមានបញ្ហាណាមួយលេចឡើង។ សកម្មភាពនានាក្នុងសៀវភៅណែនាំ ត្រូវបានតាក់តែងឡើង ដើម្បីលើកកម្ពស់ការយល់ដឹង និងការអប់រំ ក្នុងបរិយាកាសប្រកបដោយសុវត្ថិភាព និងសមស្រប ហើយគួរត្រូវបានកែសម្រួលឱ្យស្របទៅតាមក្រុមអាយុ ជាក់លាក់ដើម្បីធ្វើយ៉ាងណា កុំឱ្យអ្នកចូលរួមមានអារម្មណ៍មិនស្រួល ឬអារម្មណ៍តានតឹង។ ប៉ុន្តែ ប្រសិនបើសកម្មភាពនោះជម្រុញឱ្យមានមនោសញ្ចេតនាខ្លាំងក្លាណាមួយកើតឡើង អ្នកសម្របសម្រួលគួរផ្តល់ឱកាសឱ្យកុមារ និងមនុស្សវ័យក្មេង “ពិភាក្សាដោយសង្ខេបឡើងវិញ”។ គោលបំណងនៃការពិភាក្សាដោយសង្ខេបឡើងវិញនេះ គឺដើម្បីជួយសម្រួលអារម្មណ៍របស់អ្នកចូលរួមណាម្នាក់ដែលធ្លាប់ជួបប្រទះ ស្របពេលដែលពិភាក្សាជាមួយមនុស្សផ្សេងទៀត ឬចងចាំនឹងនឹកឃើញនូវព្រឹត្តិការណ៍កាលពីអតីតកាល ហើយទាញកុមារឱ្យត្រឡប់ទៅកាន់អត្តសញ្ញាណរបស់ខ្លួន ឬស្ថានភាពបច្ចុប្បន្នរបស់ខ្លួនវិញ។ វិធីមួយដើម្បីធ្វើការងារនេះជាមួយកុមារដែលមានអាយុច្រើន គឺត្រូវសួរសំណួរឧទាហរណ៍៖ *“តើអ្នកមានអារម្មណ៍ដូចម្តេចក្រោយពីសកម្មភាព/ការពិភាក្សានោះ? តើមានអ្វីផ្សេងទៀតដែលអ្នកចង់និយាយឬទេ?”*

ក្នុងកាលៈទេសៈមួយចំនួន អ្នកសម្របសម្រួល អាចជួបករណីកុមារបង្ហាញអាកប្បកិរិយារំខាន(ចូលចិត្តឈ្លោះប្រកែកនិយាយឥតឈប់ ឥរិយាបទអវិជ្ជមាន ឬចូលចិត្តរំខាន)។ សូមចងចាំថា កុមារអាច “ប្រចេងប្រចាង” ក្នុង បំណងដើម្បីទាក់ទាញការចាប់អារម្មណ៍មកលើគេ។ សូមព្យាយាមកុំមានប្រតិកម្មជ្រុលចំពោះ អាកប្បកិរិយារំខាននោះ ហើយ ព្យាយាមកំណត់ពីមូលហេតុនៃអាកប្បកិរិយា។ អ្នកសម្របសម្រួលត្រូវចងចាំថា មិនត្រូវភ្លេចអ្នកចូលរួមដទៃទៀត ដោយសារតែអាកប្បកិរិយារំខានរបស់កុមារម្នាក់ក្តី ប៉ុន្តែវាអាចជាសញ្ញាបញ្ជាក់ថា ស្ថានភាពរបស់កុមារដែលរំខាន នោះ ត្រូវការការយកចិត្តទុកដាក់បន្ថែមទៀត ពីអ្នក ជំនាញ។ សូមស្វែងរកជំនួយពីអ្នកសម្របសម្រួលទីពីរ/សហការី ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើក្រុមទាំងមូល។ ម្យ៉ាងទៀត វាអាចថាអាកប្បកិរិយារំខានរបស់កុមារម្នាក់ ឬកុមារមួយក្រុម អាចជាការបញ្ជូនសញ្ញាបង្ហាញ ពីអារម្មណ៍ខ្វល់ខ្វាយទូទៅក្នុងក្រុម។ ក្នុងករណីបែបនេះ វាប្រហែលជាការចាំបាច់ ដែលត្រូវធ្វើយ៉ាងណាឱ្យក្រុម បែរទៅរកអារម្មណ៍ស្ងប់ស្ងៀមវិញ ហើយព្យាយាមយល់ពីក្រុម និងបន្ធូរបន្ថយនូវក្តីភ័យខ្លាច ឬក្តីកង្វល់ដែលពួកគេអាចកំពុងកើតមាន។

## តើធ្វើយ៉ាងណាប្រសិនបើកុមារចង់និយាយអំពីប្រធានបទដែលរសើបណាមួយ ដូចជានិន្នាការផ្លូវភេទ ឬអត្តសញ្ញាណភេទ ឬបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ?

សំណួរជាច្រើនអាចត្រូវបានលើកឡើង ស្តីពីនិន្នាការផ្លូវភេទ និងអត្តសញ្ញាណភេទ។ អ្នកសម្របសម្រួលគួរត្រៀមខ្លួនដើម្បីឆ្លើយតបចំពោះការពិភាក្សាប្រភេទនេះនៅក្នុងអាកប្បកិរិយាច្បាស់លាស់ បើកចំហ និងត្រង់ទៅត្រង់មក។ អ្នកសម្របសម្រួលគួរសង្កត់ធ្ងន់ថា កុមារទាំងអស់មានសិទ្ធិទទួលបានការការពារ មិនថាគេ មាននិន្នាការផ្លូវភេទ និង/ឬអត្តសញ្ញាណភេទណាមួយឡើយ ហើយការស្អប់ខ្ពើម ការរើសអើង ឬ ការមិននិយាយស្តីពីនិន្នាការផ្លូវភេទ និងអត្តសញ្ញាណភេទ អាចរុញច្រានកុមារមួយចំនួន ឱ្យធ្លាក់ទៅក្នុងស្ថានភាពងាយរងគ្រោះ ប្រសិនបើពួកគេមិនបានទទួលការគាំទ្រនៅក្នុងសហគមន៍។

[10] អ្នកសម្របសម្រួលត្រូវបានលើកទឹកចិត្តឱ្យចែករំលែកយោបល់ត្រលប់អំពីការប្រើប្រាស់កញ្ចប់ឧបករណ៍ជាមួយអង្គការទស្សនៈពិភពលោក ដើម្បីឱ្យយើងអាចពិនិត្យខ្លឹមសារឡើងវិញ ដើម្បីដាក់បញ្ចូលឧបករណ៍ថ្មី ឬឧបករណ៍ជាជម្រើសផ្សេងទៀត។

អ្នកសម្របសម្រួលគួរធានាឱ្យបានថា រាល់ប្រយោគទាំងឡាយដែលកុមារ និងមនុស្សវ័យក្មេងលើកឡើង ដែលអាចធ្វើឱ្យសាយភាយនូវជំនឿខុសឆ្គង ឬដែលពុំមានលក្ខណៈអំណោយផល ត្រូវបានឆ្លើយតបដោយយកចិត្តទុកដាក់ ហើយពុំត្រូវធ្វើព្រងើយកន្តើយនោះឡើយ។ ឧទាហរណ៍ យោបល់អំពីសម្លៀកបំពាក់របស់កុមារីគឺមិនពាក់ព័ន្ធចំពោះការពិភាក្សានោះឡើយ ហើយអាចជាការសាបព្រួសឥរិយាបទលម្អៀងផ្អែកភេទ ដែល "បន្ទោសជនរងគ្រោះ"។ អ្នកសម្របសម្រួលមិនគួរលើកទឹកចិត្តឱ្យមានការពិភាក្សាប្រភេទនេះឡើយ ហើយជំនួសមកវិញ គាត់គួរផ្តោតការយកចិត្តទុកដាក់លើសារសំខាន់ៗដែលត្រូវបានសង្កត់ធ្ងន់នៅក្នុងឯកសារទាំងមូល។ គ្រប់ពេលទាំងអស់ ចាំបាច់ត្រូវរំឭកអ្នកចូលរួមថា ប្រសិនបើកុមារជួបប្រទះការរំលោភបំពាន នោះ មិនមែនជាកំហុសរបស់កុមារឡើយ ហើយកុមារមិនគួរទទួលរងការស្តីបន្ទោសដោយសារតែខ្លួនបានក្លាយជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទទេ។

សូមចងចាំថា ប្រធានបទនេះអាចមានលក្ខណៈលំបាក ជាពិសេសសម្រាប់កុមារ ឬយុវជនដែលធ្លាប់មានបទពិសោធន៍ជួបបញ្ហា។ អ្នកសម្របសម្រួលមិនគួរលើកទឹកចិត្ត ចំពោះការលាតត្រដាងពីព័ត៌មានផ្ទាល់ខ្លួនដែលមានលក្ខណៈរសើបណាមួយ ដែលអ្នកចូលរួមអាចនឹងស្តាយក្រោយនោះទេ។ អ្នកសម្របសម្រួល អាចធ្វើការងារនេះបានតាមរយៈការប្រើប្រាស់យុទ្ធសាស្រ្ត "ការបង្អាក់សេចក្តីក្នុងលក្ខណៈជាវិជ្ជមាន" ដែលបានពន្យល់ខាងលើ។

ប្រសិនបើកុមារ ឬមនុស្សវ័យក្មេងលាតត្រដាងពីព័ត៌មានរសើប ត្រូវធានាឱ្យបានថាពួកគេទទួល បានការគោរព។ ប្រសិនបើអ្នកមានអារម្មណ៍ថា កុមារឬមនុស្សវ័យក្មេងត្រូវការជំនួយ អ្នកអាចស្នើក្នុងលក្ខណៈ ជាឯកជនថាអ្នករីករាយនឹងនិយាយជាមួយគាត់ អំពីស្ថានភាពជាក់លាក់នោះ នៅក្រោយម៉ោងសិក្សា។ ការបញ្ជូនទៅរកអ្នកប្រឹក្សាយោបល់[11] ឬអ្នកគាំទ្រដទៃទៀត ក៏អាចជាការសមស្រប ផងដែរ។ សូមចងចាំថា ប្រសិនបើមានការលាតត្រដាងប្រាប់ពីការពិតនូវព័ត៌មានរសើបណាមួយ ព័ត៌មាននោះក៏ប្រហែលជា ប៉ះពាល់ដល់សមាជិកដទៃទៀតនៅក្នុងក្រុមផងដែរ។ ការគាំទ្រសម្រាប់កុមារ ឬមនុស្សវ័យក្មេងដទៃទៀត អាចត្រូវការចាំបាច់។

## ជានិច្ចកាលត្រូវបិទវគ្គសិក្សាក្នុងលក្ខណៈវិជ្ជមាន

អ្នកសម្របសម្រួល គួរសរុបវគ្គនីមួយៗក្នុងលក្ខណៈជាវិជ្ជមាន។ ការពិភាក្សាលើចំណុចរសើបគួរធ្វើឡើងឱ្យចប់រួចរាល់មុនពេលបញ្ចប់វគ្គនីមួយៗ។ លំហាត់ស្វាងអារម្មណ៍ អាចជួយបន្ធូរបន្ថយភាពតានតឹង ដែលអាចកើតឡើងពីការពិភាក្សាបញ្ហាងាយរសើប។ ស្រដៀងគ្នានេះដែរ ល្បែងស្វាងអារម្មណ៍ អាចជួយបន្ធូរភាពតានតឹង បណ្តេញអារម្មណ៍មិនល្អ និងជួយជម្រុញទំនាក់ទំនងល្អនៅក្នុងវគ្គសិក្សា។ កញ្ចប់ឧបករណ៍នេះរួមបញ្ចូល "ល្បែងស្វាងអារម្មណ៍" ជាច្រើន ( **ឧបសម្ព័ន្ធទី៤** ) ព្រមទាំងគំនិតនានា ដែលអាចប្រើនៅពេលបិទវគ្គ។

[11] យោងទៅតាមបរិបទ អ្នកអាចរកអ្នកប្រឹក្សាយោបល់ និងសេវាមួយចំនួនទៀតបានតាមរយៈបណ្តាញទូរស័ព្ទជំនួយកុមារថ្នាក់ជាតិ អាជ្ញាធរមូលដ្ឋាន ឬអង្គការតាមសហគមន៍នានា

# តើខ្ញុំត្រូវការអ្វីខ្លះ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលនេះបាន ?

## សិក្ខាកាម

- ឯកសារនេះបានបង្ហាញនៅក្នុងកញ្ចប់ឧបករណ៍ដែលសមស្របបំផុតសម្រាប់កុមារ ឬមនុស្សវ័យក្មេង ១០-១៥ នាក់ក្នុងមួយក្រុម។
- ទំហំក្រុមសមល្មមអាចគ្រប់គ្រងបាន គឺសំខាន់ណាស់។ ដោយសារប្រធានបទនេះមាន លក្ខណៈងាយរំជួលចិត្ត ចាំបាច់ត្រូវតាមដានត្រួតពិនិត្យ និងធានាដល់សុខុមាល-ភាពរបស់កុមារផង និងសម្របសម្រួលកិច្ចពិភាក្សាផង។ ប្រសិនបើក្រុមមានទំហំធំពេក នឹងមានការលំបាកក្នុងការសង្កេតឱ្យបានគ្រប់ជ្រុងជ្រោយ ដែលជាហេតុនាំកុមារមួយក្រុម ត្រូវបានមើលរំលង រើសអើង ឬមានទុក្ខកង្វល់។ បើសិនជា ការមានក្រុមធំជាការចាំបាច់ វគ្គមានមនុស្សពេញវ័យត្រូវតែបន្ថែមដើម្បីជួយសម្របសម្រួល។ ជាគោលការណ៍ទូទៅ សម្រាប់កុមារ១៥នាក់ ត្រូវការអ្នកសម្របសម្រួលយ៉ាងតិចពីរនាក់។
- ការបែងចែកវគ្គបណ្តុះបណ្តាលសម្រាប់កុមារា និងកុមារីក៏ត្រូវបានផ្តល់យោបល់ផងដែរ។ ជាពិសេស អ្នកសម្របសម្រួលគួរតែមានភេទដូចគ្នាជាមួយនឹងអ្នកចូលរួម។ ឧទាហរណ៍ អ្នកសម្របសម្រួលភេទស្រីសម្រាប់កុមារី និងអ្នកសម្របសម្រួលភេទប្រុសសម្រាប់កុមារា )។

## ទីកន្លែង

- បើអាច ត្រូវរៀបចំកន្លែងអង្គុយនៃវគ្គបណ្តុះបណ្តាល ឱ្យមានផាសុខភាព ជារាង “រង្វង់” ឬ “អក្សរអ៊ុយ”។ ការរៀបចំបែបនេះគឺងាយដល់ការពិភាក្សាបានផុសផុល។ មិនគួរប្រើតុទេ។ ក្នុងករណីខ្លះ កុមារអាចអង្គុយផ្ទាល់នៅលើឥដ្ឋ។ ភាពសាមញ្ញបែបនេះ ធ្វើឱ្យវគ្គបណ្តុះបណ្តាលអាចដំណើរការបានក្នុងទីតាំងក្នុងភូមិជនបទ។







- បើទោះជាករណីខ្លះ វគ្គបណ្តុះបណ្តាលចាំបាច់ត្រូវរៀបចំនៅទីវាល វាជាការប្រសើរ ដែលការបណ្តុះបណ្តាលនេះធ្វើឡើង នៅកន្លែងដែលមានភាពឯកជន និងដាច់ដោយឡែក។
- អ្នកសម្របសម្រួលគួរតែយកចិត្តទុកដាក់បំពេញនូវតម្រូវការជាពិសេសរបស់អ្នកចូលរួមដែលមានពិការភាព។ ការរាប់បញ្ចូលប្រភេទដែលកុមារពិការទាំងនេះមានដូចជា ពិការភាពផ្លូវកាយ ពិការភាពខាងវិញ្ញាណ។  ឧទាហរណ៍ ការស្តាប់ឮ ឬការមើលឃើញមានភាពកំសោយ ) កំសោយបញ្ញា និងកំសោយខាងចិត្តវិកល។

## ពេលវេលា

- សារគន្លឹះសំខាន់ៗអាចត្រូវបានបែងចែក ជាវគ្គបណ្តុះបណ្តាលរយៈពេលមួយម៉ោង ( *មើលផែនការវគ្គខ្លី* ឬផែនការវគ្គលម្អិតបន្ថែមដែលបានបែងចែក ដោយប្រធានបទដែលបានប្រើ ដើម្បីសម្របសម្រួលព្រឹត្តការណ៍រួមបញ្ចូលរយៈពេលកន្លះថ្ងៃ ឬត្រូវបានបែងចែកជាវគ្គៗ។  ឧទាហរណ៍ បង្រៀនតាមប្រធានបទ សម្រាប់វគ្គបណ្តុះបណ្តាលខ្លីៗ។
- បើមានពេល គេអាចបញ្ចូលសកម្មភាពបន្ថែមតាមជម្រើសផ្សេងទៀតផងដែរ។ សកម្មភាពទាំងនេះ មានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសៀវភៅណែនាំវគ្គបណ្តុះបណ្តាល។

## សម្ភារ

- ផែនការវគ្គបណ្តុះបណ្តាលនីមួយៗ បានរៀបរាប់យ៉ាងច្បាស់នូវសម្ភារមួយចំនួនដែលត្រូវការ។
- ឯកសារបណ្តុះបណ្តាលនេះ ផ្តោតលើការបណ្តុះបណ្តាលដោយការពន្យល់ផ្ទាល់ ដើម្បីឱ្យកុមារ និងមនុស្សវ័យក្មេងមកពីប្រភពផ្សេងៗគ្នាអាចទទួលបានចំណេះដឹងនេះ និងអាចប្រើបានសម្រាប់អប់រំក្នុងទីតាំងផ្លូវការ និងមិនផ្លូវការ។
- បើទោះជាឯកសារនេះអាចប្រើបានដោយមិនចាំបាច់ត្រូវការបច្ចេកវិជ្ជាខ្ពស់ក៏ដោយ ក៏អ្នកសម្របសម្រួល អាចប្រើប្រាស់ឯកសារជំនួយជារូបភាព ឬសកម្មភាពជំនួយការសិក្សាបន្ថែមទៀតប្រសិនបើមានធនធាន និង/ឬបច្ចេកវិជ្ជាទាំងនោះ។
**វាគឺជាការសំខាន់ដែលធនធានផ្សេងមួយ ចំនួនទៀត ប្រើប្រាស់សម្រាប់អាយុដែលសមស្រប និងមិនធ្វើឱ្យកើនឡើងនូវការធុញថប់ អារម្មណ៍ ឬការភ័យខ្លាច។**
- *កាតអប់រំ* ត្រូវបានដាក់បញ្ចូលនៅក្នុង **ឧបសម្ព័ន្ធទី២** ដែលអាចថតចំលង និងរៀបចំជូនសិក្ខាកាមម្នាក់ៗ។ កាតទាំងនេះត្រូវបង្កើតឡើងដោយប្រុងប្រយ័ត្ន និងកែលម្អ ដោយដាក់បញ្ចូលសារគន្លឹះសំខាន់ៗមួយចំនួន ដែលអាចចែករំលែកជាមួយសិក្ខាកាមគ្រប់យេនឌ័រនិងក្រុមអាយុ។ *កាតអប់រំ* អាចបោះពុម្ពលើក្រដាសផ្ទាំងធំ ឬកាតដែលត្រូវបានប្រើដោយអ្នកសម្របសម្រួលដើម្បីជាជំនួយក្នុងការបង្រៀន។



# តើគេអាចវាយតម្លៃដំណើរការវគ្គបណ្ដុះបណ្ដាល ដោយរបៀបណា ?

ការវាយតម្លៃជាធាតុផ្សំដ៏សំខាន់ក្នុងការកំណត់ថា តើគេសម្រេចបាន ឬមិនបានសម្រេចតាមគោលបំណងនៃការសិក្សា។ ដោយសារតែវគ្គបណ្ដុះបណ្ដាលនេះ រៀបចំឡើងដើម្បីជួយការពារកុមារពីការរំលោភបំពានផ្លូវភេទ លទ្ធផលជាក់ស្ដែងនឹងអាចឃើញបានតាមការស្រាវជ្រាវរយៈពេលវែង។ ទោះជាកញ្ចប់ឧបករណ៍នេះមានលក្ខណៈកុមារមេត្រី ហើយសាមញ្ញ គេអាចប្រើប្រាស់វាដើម្បីវាស់វែងពីប្រតិកម្ម លទ្ធផលសិក្សា និងការផ្លាស់ប្ដូរឥរិយាបថរបស់កុមារ និងមនុស្សវ័យក្មេង[1]។ ទីមួយ៖ ផែនការម៉ោងសិក្សានីមួយៗមានបញ្ចូលនូវ ផ្នែក "ការសង្កេត" ដែលអ្នកសម្របសម្រួលគប្បីប្រើ ដើម្បីវាយតម្លៃលទ្ធផលសិក្សា ក្នុងទម្រង់ជាការរំលឹកមេរៀនឡើងវិញ។ ទីពីរ៖**ឧបសម្ព័ន្ធទី១០** មានរៀបរាប់ពី*ទម្រង់វាយតម្លៃ* ដ៏សាមញ្ញ ដើម្បីប្រមូលព័ត៌មានត្រឡប់ និងការផ្លាស់ប្ដូរឥរិយាបថ ទាំងក្នុងទម្រង់សរសេរ ឬនិយាយផ្ទាល់មាត់។ ម្យ៉ាងវិញទៀត អ្នកសម្របសម្រួលគប្បីសង្កេតពីរបៀបដែលសិក្ខាកាមឆ្លើយសំណួរ និងរបៀបចូលរួមក្នុងសកម្មភាពក្រុម ថា តើពួកគេចាប់អារម្មណ៍ឬមិនចាប់អារម្មណ៍ និងថា តើពួកគេបានសួរសំណួរបណ្ដុះការគិតដែរឬទេ។ល។ ការវាយតម្លៃនេះ អាចធ្វើឱ្យអ្នកសម្របសម្រួល កែលំអរបៀបសម្របសម្រួលរបស់ខ្លួន ឱ្យបានសមស្របតាម វគ្គបណ្ដុះបណ្ដាល។

អ្នកសម្របសម្រួលទទួលបន្ទុកលើការប្រមូល និងចងក្រងឯកសារនៃព័ត៌មានពីប្រតិកម្ម ការសិក្សា និងការផ្លាស់ប្ដូរឥរិយាបថរបស់កុមារ ត្រូវចែករំលែកព័ត៌មាននេះជាមួយដៃគូពាក់ព័ន្ធ (រួមមានអង្គការទស្សនៈពិភពលោក) ដើម្បីគាំទ្រដល់ការកែលម្អជាប្រចាំ នៃការអប់រំពីវិធីបង្ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើកុមារក្នុងអនុតំបន់ទន្លេមេគង្គ។ ទម្រង់*របាយការណ៍អ្នកសម្របសម្រួល*មាននៅក្នុង **ឧបសម្ពន្ធ័ទី១៤**។



[1] ដូចមានរៀបរាប់ក្នុង ៖ Kirkpatrick, D. & Kirkpatrick, J. (២០០៦), ការវាយតម្លៃកម្មវិធីបណ្ដុះបណ្ដាល - បោះពុម្ពលើកទី៣ ដោយរោងពុម្ព Berrett-Koehler សហរដ្ឋអាមេរិក

# កត់ចំណាំ

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

# ផ្នែកទី២៖

# ផែនការវគ្គបណ្តុះបណ្តាល



# គម្រោងមេរៀនសំរាប់វគ្គរយៈពេលកន្លះថ្ងៃ

សម្រាប់វគ្គរយៈពេលកន្លះថ្ងៃ ឬវគ្គដែលមានរយៈពេលវែងជាងនេះ ប្រធានបទខាងក្រោមគឺត្រូវបានដាក់បញ្ចូល។ សូមមើល **"ផែនការវគ្គបណ្ដុះបណ្ដាលខ្លី"** សម្រាប់ក្រុមអាយុណាមួយ ដើម្បីដឹងថាត្រូវបង្ហាញអ្វីសម្រាប់រយៈពេលមួយ (រយៈពេលមួយម៉ោង) តែប៉ុណ្ណោះ។

| | អាយុ៥-៧ឆ្នាំ | អាយុ៨-១០ឆ្នាំ | អាយុ១១-១៧ឆ្នាំ[13] |
|---|---|---|---|
| សេចក្ដីផ្ដើម | ការស្វាគមន៍<br>សេចក្ដីផ្ដើម<br>តើយើងនឹងនិយាយពីអ្វីនៅថ្ងៃនេះ ?<br>អ្វីជាការការពារកុមារ ការរំលោភបំពានលើកុមារ និងសិទ្ធិកុមារ ? | ការស្វាគមន៍<br>សេចក្ដីផ្ដើម<br>តើយើងនឹងនិយាយពីអ្វីនៅថ្ងៃនេះ ?<br>អ្វីជាការការពារកុមារការរំលោភបំពានលើកុមារនិងសិទ្ធិកុមារ ? | ការស្វាគមន៍<br>សេចក្ដីផ្ដើម<br>តើយើងនឹងនិយាយពីអ្វីនៅថ្ងៃនេះ ?<br>អ្វីជាការការពារកុមារ ការរំលោភបំពានលើកុមារ និងសិទ្ធិកុមារ ? |
| ការសម្គាល់ការរំលោភបំពាន | រាងកាយខ្ញុំ<br>ប្រភេទនៃការប៉ះរាងកាយ | រាងកាយខ្ញុំ<br>អារម្មណ៍គឺជាសញ្ញាព្រមាន<br>អ្វីជាការរំលោភបំពានផ្លូវភេទ ?<br>សំណួក និងការគំរាម | ការពិតស្ដីពីការរំលោភបំពានផ្លូវភេទ<br>ការកំណត់ និងការជៀសចេញពីស្ថានភាពដែលគ្មានសុវត្ថិភាព<br>សំណូក និងការគំរាម |
| យុទ្ធសាស្ត្រទប់ស្កាត់ | ទេ ទៅ ប្រាប់<br>មនុស្សពេញវ័យមានសុវត្ថិភាពដែលអាចជួយខ្ញុំ<br>រឿងសម្ងាត់រីករាយ និងក្រៀមក្រំ | ទេ ទៅ ប្រាប់<br>មនុស្សពេញវ័យមានសុវត្ថិភាពដែលអាចជួយខ្ញុំ<br>ទេ ទៅ - យុទ្ធសាស្ត្រផ្សេងទៀត (តាមជម្រើស)<br>រឿងសម្ងាត់ | ការចៀសវាងស្ថានភាពដែល គ្មានសុវត្ថិភាពនៅក្នុងប្រព័ន្ធបច្ចេកវិជ្ជា និងទំនាក់ទំនង<br>ជៀសវាង និងកាត់បន្ថយហានិភ័យ (ជម្រើស-ការអនុវត្តបន្ថែម)<br>បណ្ដាញរបស់ខ្ញុំ<br>ការគាំទ្រពីសហគមន៍ |
| ការបញ្ចប់មេរៀន | តើខ្ញុំមានផែនការអ្វីខ្លះ ?<br>ការវាយតម្លៃ<br>ការបញ្ចប់សកម្មភាព | តើខ្ញុំមានផែនការអ្វីខ្លះ ?<br>ការវាយតម្លៃ<br>ការបញ្ចប់សកម្មភាព | តើខ្ញុំមានផែនការអ្វីខ្លះ ?<br>ការវាយតម្លៃ<br>ការបញ្ចប់សកម្មភាព |

[12] ក្រុមអាយុនេះគប្បីចែកក្រុមបន្តទៀតជាក្រុមអាយុពី១១-១៣ឆ្នាំ និងអាយុពី១៤-១៨ឆ្នាំ សម្រាប់ការផ្ដល់ការបណ្ដុះបណ្ដាល ប៉ុន្ដែ គេអាចប្រើប្រាស់ឯកសារដដែលបាន។

# កត់ចំណាំ

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................

........................................................................................................................................................................................



# អាយុ ៥-៧ ឆ្នាំ

# ប្លង់វគ្គសិក្សាខ្លី អាយុ ៥-៧ ឆ្នាំ

## រយៈពេល៖ មួយម៉ោង

## សង្ខេប

ប្លង់វគ្គសិក្សាខ្លីនេះ គូសបញ្ជាក់នូវសារសំខាន់ៗសម្រាប់វគ្គរយៈពេលមួយម៉ោង ក្នុងស្ថានភាពដែលអាចបង្រៀនបានតែមួយដងគត់។ ប្លង់មេរៀននេះគូសបញ្ជាក់នូវសារសំខាន់ៗ និងជម្រុញ នូវសកម្មភាព ដែលអ្នកសម្របសម្រួលគួរចាត់ជាអាទិភាព។

## សារៈសំខាន់ៗ

- វាជារាងកាយរបស់ខ្ញុំ។
- ប្រសិនបើនរណាម្នាក់ប៉ះពាល់ខ្ញុំក្នុងលក្ខណៈមួយដែលធ្វើឱ្យខ្ញុំបារម្ភ ឬភ័យខ្លាច ឬធ្វើឱ្យខ្ញុំឈឺចាប់នោះ ខ្ញុំមានសិទ្ធិក្នុងការនិយាយថាទេ មានសិទ្ធិក្នុងការទៅ និងមានសិទ្ធិក្នុងការប្រាប់ដល់មនុស្សធំដែលមានសុវត្ថិភាពណាម្នាក់។
- ខ្ញុំអាចទៅរកមនុស្សធំដែលមានសុវត្ថិភាពណាម្នាក់ ដែលខ្ញុំទុកចិត្តដើម្បីជជែកអំពីកង្វល់របស់ខ្ញុំ។

## សម្ភារ

- **ឧបសម្ព័ន្ធទី២៖** កាតយកតាមខ្លួន (អ្នកអាចបោះពុម្ពកាតនេះសម្រាប់អ្នកចូលរួមម្នាក់ៗ ឬអ្នក សម្របសម្រួលអាចបោះពុម្ពដាក់ក្រដាសផ្ទាំងធំ ឬកាតដើម្បីប្រើប្រាស់ជាសម្ភារជំនួយការ មើលឃើញ)
- **ឧបសម្ព័ន្ធទី៥៖** រូបភាពអំពីរាងកាយរបស់កុមារី និងកុមារា (អាចបញ្ចាំងនៅលើស្លាយ ឬហ្វូតូចតចម្លងដាក់លើក្រដាសផ្ទាំងធំ)
- ក្រដាសទំហំA4 មួយសន្លឹកសម្រាប់កុមារម្នាក់
- ប៊ិចពណ៌ ខ្មៅដៃ ឬខ្មៅដៃពណ៌

## ការណែនាំ

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល (៥ នាទី)**

ស្វាគមន៍អ្នកចូលរួមទាំងអស់មកកាន់វគ្គសិក្សា។ ណែនាំខ្លួនឯង និងដាក់ចេញនូវវិន័យដើម្បី ឱ្យគ្រប់គ្នាមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការនិយាយ។ ឧទាហរណ៍៖ គោរពគ្នាទៅវិញទៅមក អនុញ្ញាត ឱ្យអ្នកដទៃនិយាយដោយមិននិយាយកាត់ ឬចំអក។ រយៈពេលនៃវគ្គសិក្សានេះ បញ្ជាក់ថា អ្នកអាចនិយាយទៅកាន់ អ្នកសម្របសម្រួលណាម្នាក់ ដាច់ដោយឡែកប្រសិនបើមានអ្វីដែលធ្វើឱ្យអ្នកបារម្ភ ឬអាក់អន់ចិត្ត (រួមទាំងអ្វីដែលនឹងត្រូវនិយាយក្នុងវគ្គសិក្សានេះ)។ សូមពន្យល់ប្រាប់ថា៖ ថ្ងៃនេះយើងនឹងហ្វឹកហាត់ពីវិធីមួយចំនួនដើម្បីធ្វើឱ្យយើងមានសុវត្ថិភាព។ មុនពេលយើងចាប់ផ្តើម យើងត្រូវស្គាល់គ្នាជាមុនសិន។

**សកម្មភាព (១០ នាទី)**

ជ្រើសរើសរកល្បែងស្វាងអារម្មណ៍ណាមួយពីក្នុង**ឧបសម្ព័ន្ធទី៣៖ ល្បែងស្វាងអារម្មណ៍ និងកសាង ទំនុកចិត្ត**។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល ( ៥ នាទី )

សូមពន្យល់ពាក្យ "ការរំលោភបំពាន"។ សូមពន្យល់ថា៖ ពេលខ្លះកុមារអាចត្រូវគេធ្វើបាប ឬធ្វើឱ្យស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។ ប្រសិនបើនរណាម្នាក់ *រងការធ្វើបាប ឬត្រូវបានគេទុកឱ្យស្ថិត ក្នុងស្ថានភាពគ្រោះថ្នាក់ ដែលពុំមែនជាការចៃដន្យនោះ យើងហៅថា ជា "ការរំលោភបំពាន"*។ សូមពន្យល់ ប្រាប់ថាពាក្យផ្ទុយជាមួយការរំលោភបំពានគឺ*ការយកចិត្តទុកដាក់* ឬ*ការការពារ*។

### ការពិភាក្សាក្រុម ( ១០ នាទី )

សូមប្រើរូបភាពអំពីរាងកាយរបស់កុមារា និងកុមារី ( **ឧបសម្ព័ន្ធទី៥** ) ចង្អុលទៅកាន់ផ្នែកនៃរាង កាយ ហើយសួរឈ្មោះផ្នែកនោះ។ ពេលដែលកុមារឆ្លើយ សូមដាក់ឈ្មោះនៅលើផ្នែកនៃរាងកាយទាំងនោះ ឱ្យបានសមស្រប។ អ្នកសម្របសម្រួល គួរជាអ្នកនិយាយ និងសរសេរឈ្មោះពាក្យកាយ វិភាគសាស្ត្រចំៗសម្រាប់សម្គាល់បរិវេណប្រដាប់បន្តពូជ។

អ្នកសម្របសម្រួលគួរពន្យល់ប្រាប់ថា ផ្នែកទាំងអស់នៃរាងកាយរបស់មនុស្ស គឺជាផ្នែក "ឯកជន" ( *"ឯកជន"* មានន័យថា "សម្រាប់ខ្ញុំ" )។ ពេលដែលកុមារកាន់តែធំ វាពុំមែនជារឿងត្រឹមត្រូវទេ ដែលអ្នកដទៃត្រូវឃើញ ឬ ប៉ះផ្នែកឯកជននៃរាងកាយរបស់កុមារ លើកលែងតែពេលពួកគេ ឈឺ មានរបួស ឬត្រូវការជំនួយដើម្បីអាចថែទាំខ្លួនឯង។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល ( ១០ នាទី )

ពន្យល់ប្រាប់ថា ប្រសិនបើមាននរណាម្នាក់ប៉ះពាល់រាងកាយរបស់យើង ឬធ្វើឱ្យយើងមានក្តីបារម្ភ ឬភ័យខ្លាច ឬឈឺចាប់នោះ យើងអាចធ្វើសកម្មភាពឆ្លើយតបបាន។ សូមណែនាំពីវិធីសាស្ត្រ **ទេ ទៅ ប្រាប់**។ សូមពន្យល់ប្រាប់ថា នៅក្នុងស្ថានភាពមួយចំនួនដែល យើងមានអារម្មណ៍ថាបារម្ភ ឬភ័យខ្លាច យើងចាំបាច់ត្រូវតែនិយាយថាទេ ។ យើងប្រហែលជាចង់ "ទៅ"ឱ្យឆ្ងាយពីស្ថានភាពនេះ។ ប្រសិនបើយើងមានអារម្មណ៍ភាន់ភាំង ឬបារម្ភពីស្ថានភាពណាមួយ យើងគួរតែ "ប្រាប់" ទៅកាន់មនុស្សពេញវ័យណាម្នាក់ដែលអ្នកទុកចិត្ត។ ពេលខ្លះវាអាច ជាការពិបាកក្នុងការនិយាយថា "ទេ" និងក្នុងការ "ទៅ" ឱ្យឆ្ងាយពីស្ថានភាពលំបាក ប៉ុន្តែជានិច្ចកាល យើងត្រូវព្យាយាម "ប្រាប់" នរណាម្នាក់អំពីស្ថានភាពនេះ។




*( សូមមើលឧទាហរណ៍ស្តីអំពី ទេ ទៅ ប្រាប់ នៅលើកាតយកតាមខ្លួនក្នុង**ឧបសម្ព័ន្ធទី២** )*

### សកម្មភាព (១៥ នាទី)

១. សូមសួរទៅកុមារថា តើពួកគេនឹងទៅរកនរណាឱ្យជួយគេប្រសិនបើគេវង្វេង ភ័យខ្លាច ឬព្រួយបារម្ភ។ អាស្រ័យលើបរិបទរបស់កុមារ សូមសួរពួកគេថា តើពួកគេនឹងទៅសូមឱ្យនរណាជួយប្រសិនបើពួកគេ i) នៅក្នុងសាលារៀន ii) នៅក្រៅផ្ទះ/គ្រួសារ ii)នៅតាមផ្លូវ/ភូមិ?

២. សូមឱ្យកុមារជ្រើសរើសមនុស្សពេញវ័យដែលពួកគេទុកចិត្ត ៥នាក់ និងបង្កើតរូបតំណាងបែបរូបី ឧទាហរណ៍៖




- គូសរូបប៉េងប៉ោងចំនួន៥។ នៅក្នុងប៉េងប៉ោងនីមួយៗ សូមសរសេរឈ្មោះមនុស្សធំម្នាក់ដែលពួកគេអាចនិយាយប្រាប់អំពីបញ្ហារបស់អ្នក។
- កាត់ក្រដាសជាទងផ្កា។កាត់ស្នូលកណ្តាល នៃផ្កាមួយ ហើយសរសេរឈ្មោះរបស់អ្នកដាក់ក្នុង នោះ។ កាត់ស្រទាប់ផ្កាចំនួន ៥ ហើយនៅ លើស្រទាប់នីមួយៗសូមសរសេរ ឈ្មោះ មនុស្សធំ ម្នាក់ដែលអ្នកអាចនិយាយអំពី បញ្ហា របស់អ្នកប្រាប់គេ។
- គូរូបដៃតាមរូបដៃរបស់អ្នក។ នៅលើគំនូសម្រាម ដៃនិងមេដៃ សូមសរសេរ ឈ្មោះមនុស្សពេញវ័យ ប្រាំនាក់ ដែលអ្នកអាចនិយាយរឿងរបស់អ្នក ប្រាប់គេ។

*(ប្រសិនបើ **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន** ត្រូវបានបោះពុម្ព សម្រាប់អ្នកចូលរួមម្នាក់ៗ នោះកុមារអាចសរសេរនៅលើទំព័រ "មនុស្សពេញវ័យប្រាំនាក់ដែលខ្ញុំអាចទុកចិត្តបាន")។*

៣. សូមឱ្យកុមារដាក់ព័ត៌មានលម្អិតឱ្យបានច្រើនបំផុត តាមអ្វីដែលគេដឹងអំពីមនុស្សពេញវ័យនីមួយៗ ឧទាហរណ៍ ឈ្មោះ ទំនាក់ទំនង (ឧទាហរណ៍ ជាមិត្តភក្តិ និងអ្នកជិតខាង) អាសយដ្ឋាន និងលេខទូរស័ព្ទ។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល (៥ នាទី)

សូមអរគុណកុមារសម្រាប់ការចូលរួម ហើយឱ្យពួកគេបាន ដឹងអំពីលេខទំនាក់ទំនងក្នុងសហគមន៍ និងនៅថ្នាក់ជាតិ (ឧ. បណ្តាញទូរស័ព្ទជំនួយកុមារជាដើម) ប្រសិនបើគេមានសំណួរ ឬក្តីបារម្ភណាមួយ។

# សេចក្តីផ្តើម អាយុ៥-៧ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

### សង្ខេប

សេចក្តីផ្តើមគប្បីបង្កើតនូវបរិយាកាសជឿទុកចិត្ត ដែលកុមារមានអារម្មណ៍សុខស្រួល និងវិជ្ជមានចំពោះខ្លួនឯង និងសកម្មភាពនានា។ កុមារគប្បីត្រូវបានណែនាំឱ្យស្គាល់ពីគោលគំនិតនៃការការពារកុមារពីការរំលោភបំពានលើកុមារនិងសិទ្ធិកុមារ។ ចំណេះដឹងនេះគឺជាមូលដ្ឋានគ្រឹះ ដើម្បីឱ្យកុមារអាចនិយាយចេញនៅពេលដែលពួកគេមានអារម្មណ៍ថា រងការគំរាមកំហែង ឬគ្មានសុវត្ថិភាព។

### សារសំខាន់ៗ

ខ្ញុំអាចរងការឈឺចាប់។ បើការឈឺចាប់កើតឡើងខុសពីភាពចៃដន្យ នោះគេហៅថាការរំលោភបំពាន។ ការការពារមានន័យថាការទទួលបានសុវត្ថិភាពពីការធ្វើបាប ឬគ្រោះថ្នាក់។
ខ្ញុំមានសិទ្ធិទទួលបានការយកចិត្តទុកដាក់ និងសុវត្ថិភាព។ ខ្ញុំអាចបង្ហាញពីការយកចិត្តទុកដាក់ចំពោះអ្នកដទៃ។
**ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន** (អ្នកអាចបោះពុម្ពកាតនេះសម្រាប់អ្នកចូលរួមម្នាក់ៗ ឬអ្នកសម្របសម្រួល អាចបោះពុម្ពដាក់ក្រដាសផ្ទាំងធំ ឬកាតដើម្បីប្រើប្រាស់ជាសម្ភារជំនួយការមើលឃើញ) ប៊ិច ឬខ្មៅដៃពណ៌ (តាមជម្រើស)

### សម្ភារ

- **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន** (អ្នកអាចបោះពុម្ពកាតនេះសម្រាប់អ្នកចូលរួមម្នាក់ៗ ឬអ្នកសម្របសម្រួលអាចបោះពុម្ពដាក់ក្រដាសផ្ទាំងធំ ឬកាតដើម្បីប្រើប្រាស់ជាសម្ភារជំនួយការមើលឃើញ)
- ប៊ិច ឬខ្មៅដៃពណ៌ (តាមជម្រើស)

### ការណែនាំ

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល (១៥ នាទី)

សូមស្វាគមន៍អ្នករាល់គ្នាមកកាន់ម៉ោងសិក្សាថ្ងៃនេះ។ សូមណែនាំខ្លួនអ្នក និងដាក់ចេញនូវវិន័យគោល (ដើម្បីឱ្យកុមារមានអារម្មណ៍ថាគួរទុកចិត្តក្នុងការនិយាយ។ ឧទាហរណ៍ ត្រូវគោរពគ្នាទៅវិញទៅមក ទុកឱ្យអ្នកដទៃនិយាយ ដោយមិននិយាយកាត់ ឬសើចចំអក ការកំណត់ពេលវេលាសម្រាប់ថ្នាក់សិក្សា ឬការពិភាក្សាជាក្រុមដោយពន្យល់ថា ទីនេះមិនមែនជាកន្លែងសម្រាប់លាតត្រដាងប្រាប់ពីរឿងផ្ទាល់ខ្លួនទេ ហើយពួកគេអាចនិយាយរឿងនោះជាមួយអ្នកសម្របសម្រួលណាម្នាក់ដោយឡែក ប្រសិនបើអ្វីដែល បាននិយាយឡើងធ្វើឱ្យពួកគេព្រួយបារម្ភ ឬអាក់អន់ចិត្ត ហើយពួកគេមិនចង់ ឬមិនអាចនិយាយចេញ ពេលនៅជាមួយក្រុមទាំងមូល។) សូមពន្យល់ថា៖ *ថ្ងៃនេះ យើងនឹងអនុវត្តពីវិធីមួយចំនួនដើម្បីរក្សា សុវត្ថិភាពខ្លួនឯង។ មុនពេលយើងចាប់ផ្តើម តោះយើងណែនាំខ្លួនឱ្យគ្នាស្គាល់ទៅវិញទៅមកសិន។*

#### សកម្មភាព

សូមជ្រើសរើសល្បែងស្វាងអារម្មណ៍មួយឬច្រើនចេញពី **ឧបសម្ព័ន្ធទី៣ ៖ ការណែនាំឱ្យស្គាល់គ្នា និងល្បែងបង្កើនទំនុកចិត្ត។**

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ពាក្យ "ការរំលោភបំពាន"។ សូមពន្យល់ថា *ជួនកាល កុមារអាចរងការឈឺចាប់ និងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។ ប្រសិនបើនរណាម្នាក់រងការឈឺចាប់ និងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ក្រៅ ពីកើតឡើងដោយចៃដន្យនោះ យើងហៅថា "ការរំលោភបំពាន"។ សូមពន្យល់ថាពាក្យផ្ទុយនឹង "ការរំលោភបំពាន" គឺការយកចិត្តទុកដាក់ និងការការពារ។*

*សូមពន្យល់ថា ៖ ក្តីស្រឡាញ់ ការយកចិត្តទុកដាក់ អាហារ ថ្នាំពេទ្យ ការអប់រំ ការលេងកំសាន្ត និង សុវត្ថិភាព គឺជារបស់គ្រប់យ៉ាងដែលកុមារគប្បីមាន។ ទាំងនេះជាសិទ្ធិ។ សិទ្ធិមានន័យថា គ្មាន"សំណួរ" ឬ"ពាក្យថាប្រហែលជា" ស្តីពីចំណុចទាំងនេះទេ គឺកុមារគប្បីមានរបស់ទាំងនេះតែម្តង។*

### សកម្មភាព (តាមជម្រើស)

ធ្វើការលើកំណែកុមារមេត្រី នៃ *អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ* [14]។




### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមនិយាយឡើងវិញពីសារគន្លឹះៗ។ សូមពន្យល់ថា ការដឹងពីព័ត៌មានសមស្រប អាចជួយការពារពួកយើង។ ចំណុចនេះផ្សារភ្ជាប់នឹងការដឹងពី "ផ្នែកឯកជន" និងការប៉ះពាល់រាងកាយដែលសមរម្យ និងមិនសមរម្យ។ នេះជាចំណុចដែលយើងនឹងពិភាក្សានៅថ្ងៃនេះ។

---

## ការសង្កេត

តើកុមារអាចសម្គាល់បានថា ពួកគេត្រូវការការរក្សាសុវត្ថិភាពដែរឬទេ ? ✔

---

13 អនុសញ្ញាស្តីពីសិទ្ធិកុមារបែបកុមារមេត្រីមាននៅក្នុងកាតដាក់តាមខ្លួន ឧបសម្ព័ន្ធ២ឬColor it Rights:ការបង្ហាត់កុមារអំពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារក៏គួរមើល (សូមចូលទៅកាន់ http://teachunicef.org/sites/default/files/sites/default/files/documents/color_it_rights_coloring_book.pdf)

# ប្រធានបទទី១ រាងកាយខ្ញុំ អាយុ៥-៧ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

## សង្ខេប

ប្រធានបទនេះ បង្រៀនពីផ្នែកផ្សេងៗនៃរាងកាយ រួមទាំងប្រដាប់ភេទ។ វាជួយ កុមារឱ្យដឹងពីរាងកាយទាំងមូល និងផ្តល់ឱ្យពួកគេនូវពាក្យគ្រប់គ្រាន់ សម្រាប់ព័ណនាពីស្ថានភាពបំពានធ្ងន់ធ្ងរ។ **អាស្រ័យដោយប្រធានបទជាទូទៅមានភាពរំជួលចិត្ត កុមារី និងកុមារាគប្បីរៀនពីប្រធានបទនេះក្នុងក្រុមដាច់ដោយឡែកពីគ្នា។ អ្នកសម្របសម្រួលគួរតែមានភេទដូចអ្នកចូលរួម។**

## សារសំខាន់ៗ

- ផ្នែកខ្លះនៃរាងកាយ របស់ខ្ញុំគឺមានលក្ខណៈឯកជន
- នៅពេលដែលខ្ញុំកាន់តែធំ វាមិនសមរម្យទេ ដែលអ្នកដទៃមើលឃើញ ឬប៉ះ ពាល់ផ្នែកឯកជនរបស់ខ្ញុំ លុះត្រាខ្ញុំឈឺ មានរបួស ឬចាំបាច់ត្រូវការជួយថែទាំ

## សម្ភារ

- ដីស ឬហ្វឺត និងក្រដាសផ្ទាំងធំ
- **ឧបសម្ព័ន្ធទី៥៖ ផ្នែកផ្សេងៗនៃរាងកាយរបស់កុមារា កុមារី** ( នេះអាចបញ្ចាំង លើស្លាយ ឬគូសនៅលើផ្ទាំងក្រដាសធំ )។

## ការណែនាំ

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ពាក្យ *"ឯកជន"* និង *"សាធារណៈ"*។ សូមពន្យល់ថា"ឯកជន" មានន័យថា *"សម្រាប់ខ្ញុំ"*។ ហើយពាក្យសាធារណៈ *"សម្រាប់អ្នករាល់គ្នា"*។ សូមពិភាក្សាពីឧទាហរណ៍នៃរបស់ដែលមានលក្ខណៈឯកជន *(ឧទាហណ៍ តុក្កតាសណព្វចិត្ត ឬសៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់អ្នក។ល។)* របស់ដែលមានលក្ខណៈសាធារណៈ *(ឧទាហរណ៍ ឡានក្រុង សួនកុមារ បណ្ណាល័យឯកជន កាសែត។ល។)*

### សកម្មភាព

សូមបែងចែកកុមារឱ្យធ្វើការជាគូ ដោយបែងចែកតាមភេទ និងសូមឱ្យពួកគេគូរូបរាងកាយរបស់ពួកគេដោយប្រើដីសនៅលើឥដ្ឋ ឬប្រើហ្វឺតនៅលើក្រដាសផ្ទាំងធំ។ (ប្រសិនបើក្រុមមានមនុស្សច្រើនអ្នកអាចដាក់កុមារឱ្យធ្វើការក្នុងក្រុមដែលមានសមាជិក៤ឬ៦ នាក់ ហើយគ្រាន់តែគូររូបរាងកាយសមាជិកម្នាក់ប៉ុណ្ណោះ។ ក្រុមត្រូវតែធ្វើការដោយបែងចែកតាមភេទ ពោលគឺកុមារីនៅជាមួយកុមារី និងកុមារានៅជាមួយកុមារា។)

### ការពិភាក្សាក្រុម

យោងលើ**ឧបសម្ពន្ធ័ទី៥៖ ផ្នែកផ្សេងៗនៃរាងកាយកុមារា និងកុមារី** អ្នកសម្របសម្រួល គួរតែចង្អុល ទៅផ្នែកមួយនៃរាងកាយហើយសួរឈ្មោះនៃរាងកាយនោះ។ នៅពេលដែលកុមារឆ្លើយតបអ្នកសម្របសម្រួលគម្បីដាក់ឈ្មោះផ្នែកនៃរាងកាយនោះ ជាពាក្យបច្ចេកទេសកាយវិភាគសាស្ត្រឱ្យបានត្រឹមត្រូវ ដូចជាលិង្គ យោនី រន្ធគូទ ហើយបើសិនជាករណីចាំបាច់ សូមគូសរង្វង់ ជុំវិញកន្លែងនោះឱ្យបានត្រឹមត្រូវ ។

សូមចង្អុលទៅប្រដាប់ភេទ ទ្រូង និងគូទ ហើយសួរថា៖

- ហេតុអ្វីបានជាអ្នកគិតថាកន្លែងទាំងនេះជាផ្នែកឯកជននៃរាងកាយ ?
  *(វាមានលក្ខណៈផ្ទាល់ខ្លួន និងត្រូវបានបិទបាំងដោយសម្លៀកបំពាក់នៅពេលដែលយើងនៅជាមួយអ្នកដទៃ។)*
- តើនៅពេលណា ដែលយើងមិនចាំបាច់បិទបាំងផ្នែកឯកជននៃរាងកាយរបស់យើង ?
  *(នៅពេលយើងនៅតែឯង និងនៅពេលយើងងូតទឹកសម្អាតខ្លួន ឬស្លៀកពាក់។)*
- នរណាអាចប៉ះផ្នែកឯកជននៃរាងកាយយើងបាន ?
  *(យើងអាចប៉ះផ្នែកឯកជននៃរាងកាយយើង បាននៅពេលយើងនៅតែឯង។ ឪពុកម្តាយ និង អ្នកថែទាំ ត្រូវការប៉ះពាល់ផ្នែកឯកជននៃរាងកាយរបស់ទារក និងកុមារតូចៗ នៅពេលថែទាំពួកគេ។ នៅពេលកុមារកាន់តែធំ ពួកគេអាចថែទាំរាងកាយដោយខ្លួនឯងបាន។ ប្រសិនបើពួកគេមានជម្ងឺ មានរបួស ឬពិការនោះ អ្នកថែទាំ វេជ្ជបណ្ឌិត ឬគិលានុប្បដ្ឋាយិកា អាចចាំបាច់ត្រូវប៉ះពាល់ផ្នែកឯកជននៃរាងកាយពួកគេ។)*

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកឡើងវិញពីសារគន្លឹះ។

### សកម្មភាព

សូមជ្រើសរើសល្បែងថាមពលមួយចេញពី ***ឧបសម្ព័ន្ធទី៣៖ ល្បែងស្វាងអារម្មណ៍*** ដើម្បីកាត់បន្ថយភាពតានតឹងចិត្ត។

## ការសង្កេត

តើកុមារអាចកំណត់បាននូវផ្នែកមួយចំនួននៃរាងកាយ ដែលមានលក្ខណៈឯកជនដែរឬទេ ? ✔

# ប្រធានបទទី២– ប្រភេទនៃការប៉ះពាល់ អាយុ៥-៧ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

| | |
|---|---|
| **សង្ខេប** | ប្រធានបទនេះណែនាំឱ្យស្គាល់ពីប្រភេទផ្សេងៗនៃការប៉ះពាល់រាងកាយ និងរបៀបដែលការប៉ះពាល់រាងកាយ ធ្វើឱ្យយើងមានអារម្មណ៍។ ប្រធានបទនេះ ក៏ណែនាំឱ្យស្គាល់ពីគោលគំនិតនៃការអនុញ្ញាត។ ចំណុចនេះអាចជួយកុមារឱ្យយល់បានថាពេលណា ដែលពួកគេត្រូវការកិច្ចការពារ។ |
| **សារសំខាន់ៗ** | • នេះជារាងកាយខ្ញុំ។ អ្នកដទៃត្រូវសូមការអនុញ្ញាត មុននឹងអាចប៉ះរាងកាយខ្ញុំបាន។<br>• ប្រសិនបើការប៉ះពាល់រាងកាយធ្វើឱ្យខ្ញុំព្រួយបារម្ភ ឬភ័យខ្លាច ឬធ្វើឱ្យខ្ញុំឈឺ ខ្ញុំមានសិទ្ធិនិយាយថា "ទេ" មានសិទ្ធិ "ទៅ" និងមានសិទ្ធិ "ប្រាប់" អ្នកដទៃដែលមានសុវត្ថិភាព។ |
| **សម្ភារ** | • ខ្មៅដៃ ឬប្រដាប់លេងទន់ៗ (តាមជម្រើស) |

**ការណែនាំ**

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ថា ជាធម្មតាយើងអាចដឹងបានថា ការប៉ះរាងកាយមានលក្ខណៈសមរម្យ ឬមិនសមរម្យ តាមរយៈសញ្ញាដែលរាងកាយយើងប្រាប់យើង នៅពេលអ្នកដទៃប៉ះពាល់រាងកាយយើង។ យើងក៏អាចដឹងបានថាការប៉ះរាងកាយមានលក្ខណៈសមរម្យ ឬមិនសមរម្យ តាមរយៈការមើលពីរបៀបនៃការប៉ះពាល់រាងកាយនោះ។ សូមពិភាក្សាពីរបៀបដែលមនុស្សអាចប៉ះពាល់រាងកាយ ឧ. ដោយថ្នមៗ ដោយហិង្សា។

### សកម្មភាព (តាមជម្រើស)

សូមឱ្យកុមារបង្ហាញម្នាក់ម្តងៗពីរបៀបដែលមនុស្សប៉ះពាល់រាងកាយគ្នាទៅវិញទៅមក ដោយ ប្រើខ្មៅដៃ ឬប្រដាប់លេង។ សូមសួរសិក្ខាកាមថា តើពួកគេអាចបែងចែកបានឬទេ រវាងការប៉ះពាល់រាងកាយដែលសមរម្យ និងការប៉ះពាល់រាងកាយដែលមិនសមរម្យ? ព្រោះអ្វី?

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ដល់សិក្ខាកាមថា ពាក្យថា "**សមរម្យ**" និង "**មិនសមរម្យ**" អាស្រ័យទៅលើចំណុចដូចជា ៖

- **នរណា**កំពុងប៉ះរាងកាយអ្នក? *(ឧ. ពូ មីង បងប្អូនស្រី មិត្តភក្តិ គ្រូពេទ្យ អ្នកជិតខាង ឬមនុស្សចម្លែក)*
- តើពួកគេកំពុងប៉ះពាល់លើ**ផ្នែកណា**នៃរាងកាយអ្នក? *(ឧ. ដៃ ជើង មុខ ជើង ប្រដាប់ភេទ)*
- **នៅពេលណា**ដែលពួកគេប៉ះរាងកាយអ្នក? *(ឧ.ក្នុងខណៈពេលពិនិត្យជម្ងឺ)*
- តើអ្នកកំពុងនៅទីណានៅពេលពួកគេប៉ះរាងកាយអ្នក *(នៅកន្លែងជប់លៀង នៅមុខមិត្តភក្តិ ក្រុមគ្រួសារ ពេលនៅតែឯង)*?
- តើពួកគេប៉ះរាងកាយអ្នកក្នុង**របៀបបែបណា** *(ដោយហិង្សា ដោយថ្នមៗ)*?

សូមណែនាំឱ្យស្គាល់ពីគោលគំនិតនៃ *"ការសូមអនុញ្ញាត"*។ សូមពន្យល់ថា ជួនកាលមនុស្សមិនសូមអនុញ្ញាតទេ  មុនពេលធ្វើអ្វីមួយ បើទោះជាពួកគេគួរតែសូមក៏ដោយ។

## ការពិភាក្សាក្រុម

សូមពិភាក្សាពីសំណួរដូចតទៅ ៖

- ហេតុអ្វីចាំបាច់ត្រូវសូមការអនុញ្ញាត? *(ដើម្បីកុំឱ្យអ្នកធ្វើបាបដល់ការគិត និងអារម្មណ៍របស់នរណាម្នាក់ និងដើម្បីកុំឱ្យអ្នកធ្វើអ្វីមួយដែលអាចគ្មានសុវត្ថិភាព)*
- តើនរណាដែលអាចផ្តល់ការអនុញ្ញាតឱ្យអ្នកប្រើប្រដាប់លេងរបស់មិត្តអ្នកបាន? *(គឺមិត្តអ្នក)*
- តើនរណាដែលអាចផ្តល់ការអនុញ្ញាតឱ្យអ្នកប្រើបាល់របស់សាលាបាន? *(គឺគ្រូអ្នក ឬនាយកសាលា)*
- តើនរណាដែលអាចផ្តល់ការអនុញ្ញាតឱ្យអ្នក និងគ្រួសារអ្នកប្រើកន្លែងលេងរបស់សហគមន៍បាន?  *(គឺអ្នកដឹកនាំសហគមន៍)*
- តើនរណាដែលអាចផ្តល់ការអនុញ្ញាតឱ្យនរណាម្នាក់ផ្សេងទៀតប៉ះ ឬមើលផ្នែកឯកជននៃរាងកាយអ្នកបាន? *(គឺអ្នក)*
- តើនរណា ដែលអ្នកអាចផ្តល់ការអនុញ្ញាតឱ្យប៉ះរាងកាយអ្នកបាន? *(គឺវេជ្ជបណ្ឌិត គិលានុប្បដ្ឋាយិកា ម្តាយឪពុក និងអ្នកថែទាំរបស់អ្នក)*
- តើមូលហេតុអ្វីខ្លះដែលអ្នកអាចផ្តល់ការអនុញ្ញាតឱ្យនរណាម្នាក់ប៉ះ ឬមើលផ្នែក ឯកជនណាមួយនៃរាងកាយអ្នក? *(ប្រសិនបើអ្នកមានជម្ងឺ ឈឺចាប់ ឬត្រូវការការជួយមើលថែ។)*
- តើអ្នកត្រូវធ្វើយ៉ាងណា ប្រសិនបើនរណាម្នាក់មិនសូមការអនុញ្ញាត? *(សូមប្រើវិធីសាស្ត្រ ទេ ទៅ ប្រាប់)*

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកឡើងវិញពីសារគន្លឹះ មុនពេលបន្តទៅប្រធានបទបន្ទាប់។

## ការសង្កេត

- តើកុមារអាចពណ៌នាពីរបៀបផ្សេងៗ ដែលមនុស្សប៉ះពាល់រាងកាយគ្នាទៅវិញទៅមកបានដែរឬទេ? ✓
- តើកុមារអាចសំដែងចេញថាតើនរណាអាចប៉ះពាល់ពួកគេបាន ហើយនៅពេលណា? ✓

# ប្រធានបទទី៣៖ ទេ ទៅ ប្រាប់ អាយុ៥-៧ឆ្នាំ

## រយៈពេលអប្បបរមា៖ ១៥នាទី

### សង្ខេប

ប្រធានបទនេះ ផ្តល់ឱ្យកុមារនូវឱកាសអនុវត្តយុទ្ធសាស្ត្រ ទេ ទៅ ប្រាប់។ ការប្រើប្រាស់ភាសាកាយវិការ និងការនិយាយថា “ទេ” ក្នុងជំហរឹងមាំ អាចជាបំណិនដ៏លំបាកសម្រាប់កុមារនៅដំណាក់កាលនេះ។ ការសំខាន់ ពួកគេត្រូវមានឱកាសញឹកញាប់ ក្នុងការសាកល្បងអនុវត្តជំនាញនេះ ដើម្បីឱ្យពួកគេអាចប្រើជំនាញនេះបានក្នុងស្ថានភាពគ្មានសុវត្ថិភាព ឬប្រឈមនឹងការរំលោភបំពាន។

### សារសំខាន់ៗ

- ប្រសិនបើខ្ញុំស្ថិតក្នុងស្ថានភាពដែលធ្វើឱ្យខ្ញុំព្រួយបារម្ភ ឬភ័យខ្លាច ខ្ញុំចាំបាច់ត្រូវនិយាយថា “ទេ” និង “ទៅ” ហើយប្រាប់នរណាម្នាក់អំពីរឿងនេះ។

### សម្ភារ

- ដៃតុក្កតា ប្រដាប់ក្មេងលេងដើម្បីបង្ហាញពី “ទេ” “ទៅ” និងប្រាប់ *(តាមជម្រើស)*

### ការណែនាំ

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមណែនាំឱ្យស្គាល់ពីគោលគំនិតនៃយុទ្ធសាស្ត្រ ទេ ទៅ ប្រាប់។ សូមពន្យល់ថា ក្នុងស្ថានភាពមួយចំនួនដែលយើងព្រួយបារម្ភ ឬភ័យខ្លាច យើងចាំបាច់ត្រូវនិយាយថា “ទេ”។ យើងអាច “ទៅ” ឱ្យឆ្ងាយពីស្ថានភាពនោះ។ ប្រសិនបើយើងមិនយល់ ឬព្រួយបារម្ភពីស្ថានភាពនោះ យើងគប្បី “ប្រាប់” រឿងនោះដល់មនុស្សពេញវ័យដែលអាចទុកចិត្តបាន។ ជួនកាល វាអាចជាការលំបាកខ្លាំងណាស់ក្នុងការនិយាយថា “ទេ” ហើយ “ទៅ” ឱ្យឆ្ងាយពីស្ថានភាពគ្រោះថ្នាក់ ប៉ុន្តែយើងគប្បីព្យាយាម “ប្រាប់” នរណាម្នាក់ពីស្ថានភាពនោះជានិច្ច។

#### សកម្មភាព

សូមពន្យល់ថា ដើម្បីនិយាយ “ទេ” ដោយម៉ឺងម៉ាត់ និងច្បាស់ យើងចាំបាច់ត្រូវប្រើភាសាកាយវិកាដើម្បីនិយាយថា “ទេ” ឱ្យច្បាស់។ សូមធ្វើការជាក្រុម ហើយអនុវត្តការនិយាយថា បាទ/ចាស ឬ “ទេ” ចំពោះស្ថានភាព “ឧបមាថា” ដូចតទៅ។ សូមឱ្យសិក្ខាកាមឆ្លើយតបដោយម៉ឺងម៉ាត់ និងច្បាស់តាមដែលពួកគេអាចធ្វើបាន។

- *ឧបមាថា ក្មេងមាឌធំម្នាក់និយាយមកកាន់អ្នកថា “ឱ្យលុយឯងមកយើង!”*
- *ឧបមាថា មិត្តអ្នកនិយាយថា “ហេ លោតចុះពីលើស្ពានមក!”*
- *ឧបមាថា ម្តាយអ្នកសួរអ្នកថា “ថ្ងៃស្អែក តើកូនចង់ទៅមើលកុនទេ?”*
- *ឧបមាថា បងប្អូនជីដូនមួយអ្នក ប្រាប់ឱ្យអ្នកទៅស្ទាបឆ្កែដ៏ធំដែលកំពុងគ្រហឹម?*
- *ឧបមាថា ខ្ញុំឱ្យផ្លែឈើទៅអ្នក?*

### សកម្មភាព (តាមជម្រើស)

សូមពន្យល់ថា មានវិធីជាច្រើនដើម្បីនិយាយថា "ទេ"។ សូមបង្កើតជាល្បែងកំសាន្ត ដែលសិក្ខាកាមត្រូវបង្កើតរបៀបផ្សេងៗគ្នា ដើម្បីនិយាយថា "ទេ" ។ ឧទាហរណ៍ ក្នុងសម្លេងស្រទន់ ក្នុងសម្លេងស្រួយ និយាយបណ្តើរសើចបណ្តើរ ទេ ទេ ទេ និយាយថា "ទេ" បណ្តើរ គ្រវីក្បាលបណ្តើរ ឬញាក់ភ្នែកចុះឡើងបណ្តើរ។ល។

### សកម្មភាព (តាមជម្រើស)

សូមពិភាក្សា និងអនុវត្តការនិយាយថា "ទេ" ជាគូ ក្នុងស្ថានភាពដូចតទៅ។ សូមទទួលស្គាល់ថាជួន កាលវាជាការលំបាកក្នុងការនិយាយថា "ទេ" ទៅកាន់អ្នកដទៃ។

- មិត្តមួយចំនួនរបស់អ្នក ចង់ឱ្យអ្នកទៅលេងផ្ទះពួកគេ។ ម្តាយឪពុកអ្នក ប្រាប់ឱ្យអ្នកមកផ្ទះភ្លាម បន្ទាប់ចេញពីសាលារៀន។
- បងប្រុសអ្នក ចង់ឱ្យអ្នកជិះកង់នៅក្នុងទីធ្លារត់លេងក្នុងសាលា ប៉ុន្តែនាយកសាលា និយាយប្រាប់អ្នកថា អ្នកមិនអនុញ្ញាតឱ្យធ្វើបែបនោះទេ។
- ពូរបស់អ្នកចង់ឱ្យអ្នកអង្គុយលើភ្លៅគាត់ ហើយអោបថើបគាត់។ អ្នកមិនចូលចិត្ត ពុកចង្ការឹងៗរបស់គាត់ទេ។
- បងស្រីរបស់អ្នក ចង់ឱ្យអ្នកមើលរឿងកុនភ័យខ្លាច។ អ្នកមិនចង់មើលទេ។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកឡើងវិញពីសារគន្លឹះ មុនពេលបន្តទៅប្រធានបទបន្ទាប់។

---

## ការសង្កេត

តើកុមារអាចពណ៌នាពីសកម្មភាព (ទេ ទៅ ប្រាប់) ដែលពួកគេអាចធ្វើវាបាន ប្រសិនបើពួកគេព្រួយបារម្ភ ឬភ័យខ្លាចអំពីស្ថានភាពមួយដែរឬទេ ? ✔

---

# ប្រធានបទទី៤៖ មនុស្សពេញវ័យដែលអាចទុកចិត្តបាន

## អាយុ៥-៧ឆ្នាំ

## រយៈពេលអប្បបរមា៖ ២៥នាទី

## សង្ខេប

ប្រធានបទនេះ ណែនាំកុមារឱ្យស្គាល់ពីលក្ខណៈសម្បត្តិនៃមនុស្សពេញវ័យអាចទុកចិត្ត ដែលកុមារអាចនិយាយជាមួយ នៅពេលពួកគេត្រូវការជំនួយ ឬព្រួយបារម្ភ ឬភ័យខ្លាច។

## សារសំខាន់ៗ

- ខ្ញុំអាចទៅរកមនុស្សពេញវ័យ ដែលខ្ញុំជឿទុកចិត្តក្នុងការនិយាយពីការព្រួយបារម្ភរបស់ខ្ញុំ។
- **មនុស្សពេញវ័យទាំងនេះនៅចាំជួយ និងគាំទ្រខ្ញុំជានិច្ច។**

## សម្ភារ

- ក្រដាសទំហំ A4 មួយសន្លឹកសម្រាប់កុមារម្នាក់ៗ
- ប៊ិច ឬខ្មៅដៃពណ៌
- ក្រដាសពណ៌មួយដុំ
- កន្ត្រៃសម្រាប់កុមារប្រើរួមគ្នា
- ស្កត់ ឬជ័របិទសម្រាប់កុមារប្រើរួមគ្នា

## ការណែនាំ

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ថា៖ *យើងត្រូវដឹងឱ្យច្បាស់ថា នរណាដែលយើងអាចជឿទុកចិត្តបាន នៅពេលយើងព្រួយបារម្ភភ័យខ្លាច មានអ្វីមួយ ឬនរណាម្នាក់ធ្វើបាបយើង។ ពួកយើងមានមនុស្សមួយក្រុម ដែលយើងជឿទុកចិត្ត ហើយយើងអាចនិយាយជាមួយពួកគេបាន។*
*អ្នកសម្របសម្រួលមិនគួរ ស្នើមនុស្សពេញវ័យណាម្នាក់ឱ្យកុមារទេ។* កុមារគួរត្រូវបានផ្តល់ឱកាសក្នុងការគិតពីមនុស្សពេញវ័យ ដែលពួកគេមានអារម្មណ៍ថាអាចទុកចិត្ត បើសិនជាពួកគេមានអារម្មណ៍ព្រួយបារម្ភ ឬភ័យខ្លាច។

### សកម្មភាព

1. សាកសួរកុមារថា តើនរណាដែលពួកគេនឹងទៅរកឱ្យជួយ នៅពេលដែលពួកគេមិនដឹងថាត្រូវធ្វើអ្វី ពេលភ័យខ្លាច ឬព្រួយបារម្ភ។ បើមានលក្ខណៈសមសម្របសម្រាប់កុមារ សូមសួរកុមារថា តើពួកគេនឹងរកនរណាឱ្យជួយ ក). ពេលនៅសាលា ខ). នៅក្រៅផ្ទះ/ឆ្ងាយពីអ្នកផ្ទះ គ). នៅតាមផ្លូវ/ក្នុងភូមិ?

2. សូមឱ្យកុមារជ្រើសរើសមនុស្សពេញវ័យដែលអាចទុកចិត្តបានចំនួនប្រាំនាក់ និងគូររូបភាពតំណាង ឧទាហរណ៍ដូចជា គូររូបប៉េងប៉ោងប្រាំ
   - សរសេរឈ្មោះមនុស្សពេញវ័យម្នាក់ ដែលកុមារអាចប្រាប់ពីបញ្ហារបស់ពួកគេបាន នៅលើប៉េងប៉ោងនីមួយៗ។
   - កាត់រូបកញ្ចុំផ្កាក្រដាស។ កាត់ចន្លោះនៅចំណុចកណ្តាលកញ្ចុំផ្កា ហើយសរសេរឈ្មោះរបស់កុមារ។ កាត់ស្លឹកជាប់ត្របកផ្កាចំនួនប្រាំ ហើយសរសេរឈ្មោះមនុស្សពេញវ័យទាំង៥ នៅលើស្លឹកនីមួយៗ។

- គូររូបបាតដៃរបស់អ្នក។ សរសេរឈ្មោះមនុស្សពេញវ័យម្នាក់ដែលអ្នកអាចប្រាប់ពី បញ្ហារបស់អ្នកបាននៅលើម្រាមដៃនីមួយៗ។ *(**ឧបសម្ព័ន្ធទី២៖** កាតយកតាមខ្លួន ត្រូវបានបោះពុម្ពសម្រាប់អ្នកចូលរួម ម្នាក់ៗ កុមារអាចសរសេរនៅលើកាតនោះ “មនុស្សចំនួន ប្រាំនាក់ដែលខ្ញុំជឿទុកចិត្ត”)*




3. សូមឱ្យកុមារសរសេរលម្អិតពីមនុស្សពេញវ័យម្នាក់ៗ ឧ. ឈ្មោះរបស់គាត់ ទំនាក់ ទំនង (ឧ.ជាមិត្តភក្តិ និងអ្នកជិតខាងខ្ញុំ) អាសយដ្ឋាន និងលេខទូរស័ព្ទ។

## សកម្មភាព (តាមជម្រើស)

សូមឱ្យកុមារណែនាំឱ្យក្រុម (អាចជាក្រុមតូច ឬ ក្រុមទាំងមូល) ស្គាល់ពីមនុស្សពេញវ័យដែលគេអាចទុកចិត្តបាន។ សូមលើកទឹកចិត្តឱ្យកុមារណែនាំជាផ្លូវការ ដូចជា *“គាត់ឈ្មោះសំ។ គាត់ជាអ្នកជិតខាងខ្ញុំ។ គាត់រស់នៅជាប់ផ្ទះខ្ញុំ។ ខ្ញុំជ្រើសរើសគាត់ ព្រោះគាត់ចិត្តល្អ និងស្តាប់ខ្ញុំពេលខ្ញុំនិយាយ។”*

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកឡើងវិញពីសារគន្លឹះ មុនពេលបន្តទៅប្រធានបទបន្ទាប់។

## ការសង្កេត

តើកុមារអាចកំណត់បានមនុស្សពេញវ័យ បានចំនួន៥នាក់ ដែលពួកគេអាចសូមឱ្យជួយបានដែរឬទេ? ✔

# ប្រធានបទទី ៥៖ រឿងសម្ងាត់ដែលរីករាយ និងមិនគួរឱ្យរីករាយ អាយុ៥-៧ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

## សង្ខេប

ការរំលោភបំពានកុមារកម្រជាទង្វើ "ដែលកើតតែម្តងហើយចប់ទេ។ អ្នករំលោភបំពានពឹងផ្អែកលើការបន្តលាក់រឿងសម្ងាត់ ដើម្បីបន្តការរំលោភបំពានរបស់ខ្លួន។ វាជាការសំខាន់ណាស់ ដែលត្រូវបង្រៀនកុមារឱ្យចេះបែងចែករវាងរឿងសម្ងាត់ "ដែលរីករាយ" និង "មិនគួរឱ្យរីករាយ" ហើយជានិច្ចកាលត្រូវ ប្រាប់ អំពីរឿងសម្ងាត់ "មិនគួរឱ្យរីករាយ"។

## សារសំខាន់ៗ

- រឿងសម្ងាត់មួយចំនួនធ្វើឱ្យខ្ញុំខ្វល់ខ្វាយ ដែលមិនគួរលាក់ទុកក្នុងចិត្ត។
- រឿងសម្ងាត់វានៅតែជារឿងសម្ងាត់ដដែល ប្រសិនបើខ្ញុំចែករំលែករឿងនោះជាមួយមនុស្សពេញវ័យដែលខ្ញុំទុកចិត្ត
- មានមនុស្សជាច្រើនដែលខ្ញុំអាចនិយាយប្រាប់បាន ប្រសិនបើខ្ញុំមានរឿងសម្ងាត់មិនគួរឱ្យរីករាយ។ មនុស្សមួយចំនួននោះនឹងអាចជួយខ្ញុំបាន។

## សម្ភារ

- ក្រដាស A4 មួយសន្លឹក *(អាចជ្រើសរើសពណ៌បាន)* សម្រាប់កុមារម្នាក់ៗ
- ប៊ិចពណ៌ ខ្មៅដៃ ឬខ្មៅដៃពណ៌

## ការណែនាំ

### ការពិភាក្សាក្រុម

មានរឿងសម្ងាត់មួយចំនួន ដែលមិនមានសុវត្ថិភាពសម្រាប់កុមារ។ សូមពិភាក្សាលើរឿងសម្ងាត់បីប្រភេទដែលមិនមានសុវត្ថិភាព i) រឿងសម្ងាត់ដែលពាក់ព័ន្ធជាមួយការប៉ះពាល់ដែលធ្វើឱ្យអ្នកមាន ក្តីបារម្ភ ឬ ភ័យខ្លាច ii) រឿងសម្ងាត់ពាក់ព័ន្ធជាមួយហ្គេម ដែលអាចធ្វើឱ្យអ្នកមិនមានសុវត្ថិភាព និងធ្វើឱ្យនរណាម្នាក់មានការឈឺចាប់ iii) រឿងសម្ងាត់ដែលពាក់ព័ន្ធជាមួយអំណោយដែលមនុស្សដទៃទៀតផ្តល់ឱ្យអ្នក ឬ ក្នុងបំណងចង់ឱ្យអ្នកធ្វើអ្វីមួយដល់គេ។

សូមអានរឿងសម្ងាត់ដែលបានស្នើឡើងមួយចំនួនដូចខាងក្រោម រួចសួរសំណួរជាបន្តបន្ទាប់ពីរឿងសម្ងាត់នីមួយៗ។

- តើនេះជា៖
  - រឿងសម្ងាត់ដែលរីករាយ (មានអារម្មណ៍ល្អដែលត្រូវរក្សាទុក)....(ឱ្យកុមារញញឹម និងដាក់ម្រាមដៃលើបបូរមាត់របស់គេ) ឬ
  - ការសម្ងាត់មិនគួរឱ្យរីករាយ (ធ្វើឱ្យអ្នកខ្វល់ខ្វាយ ហើយអ្នកគួរតែប្រាប់ដល់នរណាម្នាក់) .... (សូមឱ្យកុមារលើកដៃគ្រវី)។
- *តើអ្នកមានអារម្មណ៍ល្អក្នុងការរក្សារឿងសម្ងាត់នេះឬទេ?* អ្នកសម្របសម្រួលគួរពន្យល់ឱ្យច្បាស់ថា កុមារគួរនិយាយប្រាប់មនុស្សពេញវ័យដែលពួកគេទុកចិត្ត អំពីរឿងសម្ងាត់ណាមួយដែលធ្វើឱ្យពួកគេខ្វល់ខ្វាយ ដែលក្លាយជាបន្ទុកសម្រាប់ពួកគេ បើសិនពួកគេនៅបន្តលាក់ទុករឿងសម្ងាត់នោះ។

រឿងសម្ងាត់ដែលត្រូវបានស្នើឡើង៖

- *កាដូសម្រាប់ប៉ា គឺជាអាវថ្មីគួរឱ្យស្រឡាញ់មួយ។ កុំប្រាប់គាត់ណា។*
- *មិនដឹងនរណាទេទាញទុយោបង្ហូន់ ឥឡូវនេះវាហូរទឹកពាសពេញ។ កុំប្រាប់នរណាម្នាក់អីណា។*
- *ខ្ញុំដាក់ដីចូលបាយថ្ងៃត្រង់របស់ក្មេងតូចនោះព្រឹកមិញនេះ។ កុំប្រាប់នរណាម្នាក់អីណា។*
- *ប្អូនស្រីខ្ញុំតែងខ្លួនដើម្បីសម្តែងជាតួតុ្កកសម្រាប់ពិធីជប់លៀង។ កុំប្រាប់នរណា អីណា។*
- *ឯងនឹងត្រូវគេវាយបន្ទាប់ពីចេញពីរៀន។ កុំប្រាប់នរណា អីណា។*

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សង្ខេបសារសំខាន់ៗឡើងវិញ

## ការសង្កេត

- តើកុមារអាចកំណត់បានទេថា ពួកគេគួរតែប្រាប់រឿងសម្ងាត់ ដល់មនុស្សពេញវ័យ ដែលគេទុកចិត្តឬទេ ? តើពួកគេមានអារម្មណ៍ល្អក្នុងការនិយាយប្រាប់រឿងសម្ងាត់ដល់មនុស្សធំទាំងនោះឬទេ? ✔

# សន្និដ្ឋាន អាយុ៥-៧ឆ្នាំ

## រយៈពេលអប្បបរមា៖ ៣០នាទី

## សង្ខេប

សេចក្តីសន្និដ្ឋាន គឺជាឱកាសសម្រាប់រំលឹកឡើងវិញពីសារគន្លឹះ ឆ្លើយនឹងសំណួររបស់កុមារបើសិនជាពួកគេមាន និងសូមព័ត៌មានត្រឡប់ពីកុមារ។ វាជាការសំខាន់ ដែលវគ្គសិក្សា ត្រូវបានបញ្ចប់ដោយ ក្តីសប្បាយរីករាយ។

## សារសំខាន់ៗ

- ខ្ញុំមានផែនការដែលអាចប្រើ ដើម្បីជួយខ្លួនឯងនៅពេលខ្ញុំព្រួយបារម្ភ ឬភ័យខ្លាច។

## សម្ភារ

- សៀវភៅកិច្ចការ និង សម្ភាររបស់សិក្ខាកាម
- **ឧបសម្ព័ន្ធទី៥ ៖ កាតយកតាមខ្លួន** (រូបភាពផ្កា)

## ការណែនាំ

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមមើលសម្ភារដែលកុមារបានបង្កើត និងរំលឹកឡើងវិញពីសារគន្លឹះនៃប្រធានបទនីមួយៗ៖

- ខ្ញុំត្រូវដឹងថាផ្នែកមួយចំនួននៃរាងកាយខ្ញុំមានលក្ខណៈឯកជន។ នៅពេលខ្ញុំកាន់តែធំ វាមិនសមរម្យ"ទេ" ដែលអ្នកដទៃមើលឃើញ ឬប៉ះផ្នែកឯកជននៃរាងកាយខ្ញុំ លើកលែងតែពេលដែលខ្ញុំមានជម្ងឺ មានរបួស ឬត្រូវការការជួយមើលថែ។
- នេះជារាងកាយខ្ញុំ។ អ្នកដទៃត្រូវសូមអនុញ្ញាត មុននឹងអាចប៉ះរាងកាយខ្ញុំបាន។ ប្រសិនបើ ការប៉ះរាងកាយធ្វើឱ្យខ្ញុំព្រួយបារម្ភ ភ័យខ្លាច ឬធ្វើឱ្យខ្ញុំឈឺ ខ្ញុំមានសិទ្ធិនិយាយថា "ទេ" មាន សិទ្ធិ "ទៅ" និង មានសិទ្ធិ "ប្រាប់" មនុស្សពេញវ័យដែលខ្ញុំទុកចិត្តអំពីរឿងនេះ។
- ប្រសិនបើខ្ញុំស្ថិតក្នុងស្ថានភាពដែលធ្វើឱ្យខ្ញុំព្រួយបារម្ភ ឬភ័យខ្លាច ខ្ញុំចាំបាច់ត្រូវនិយាយ ថា "ទេ" និង "ទៅ" ហើយ "ប្រាប់" មនុស្សពេញវ័យដែលខ្ញុំទុកចិត្តអំពីរឿងនេះ។
- ការដែលមានមនុស្សពេញវ័យដែលគួរទុកចិត្ត ពិតជាមានសារៈសំខាន់ណាស់។ ខ្ញុំអាចទៅរកពួកគាត់ ដើម្បីនិយាយពីការព្រួយបារម្ភរបស់ខ្ញុំ។ មនុស្សពេញវ័យដែលគួរទុកចិត្តទាំងនេះ នឹងជួយគាំទ្រដល់ខ្ញុំ។
- រឿងសម្ងាត់មួយចំនួនមិនគប្បីលាក់ទុកនោះទេ។ មានមនុស្សជាច្រើន ដែលខ្ញុំអាចប្រាប់ប្រសិនបើខ្ញុំមានរឿងសម្ងាត់ ដែលធ្វើឱ្យខ្ញុំក្រៀមក្រំ នោះពួកគេនឹងអាចជួយខ្ញុំ។
- នៅក្នុងករណីមួយចំនួន រឿងសម្ងាត់នៅតែជារឿងសម្ងាត់ប្រសិនបើខ្ញុំចែករំលែកព័ត៌មាននៃរឿងរ៉ាវទាំងនេះ ជាមួយមនុស្សពេញវ័យដែលខ្ញុំទុកចិត្ត។
- ការប្រាប់ទៅកាន់មនុស្សដែលខ្ញុំទុកចិត្ត អាចជួយខ្ញុំ នៅពេលដែលខ្ញុំមានអារម្មណ៍ថាព្រួយបារម្ភ ឬភ័យខ្លាច។

## ការពិភាក្សាក្រុម

ដើម្បីវាយតម្លៃវគ្គសិក្សា សូមសួរកុមារនូវសំណួរដូចតទៅ និងកត់ត្រាចម្លើយរបស់ពួកគេ៖

- តើអ្នកបានរៀនចេះពីរបៀបរក្សាសុវត្ថិភាពខ្លួនឯងដែរឬទេ ? (ស្នើកុមារលើកដៃបើអ្នកបានរៀន)
- តើអ្នករៀនបានអ្វីដែលសំខាន់បំផុតដើម្បីរក្សាខ្លួនឱ្យគួរទុកចិត្ត?
- តើអ្នកចង់រៀនបន្ថែមពីអ្វីទៀតនូវរបៀបរក្សាខ្លួនឱ្យគួរទុកចិត្ត?
- តើអ្នកនឹងធ្វើអ្វីប្រសិនបើអ្នកព្រួយបារម្ភ ឬភ័យខ្លាច?

## សកម្មភាព

សូមចែករូបភាពផ្កា (**ឧបសម្ពន្ធ័ទី២៖ កាតយកតាមខ្លួន**) និងស្នើឱ្យកុមារផាត់ពណ៌ ឬ តុបតែងលក្ខណ: សមស្របទៅតាមជីវិតរស់នៅរបស់ពួកគេ ដូចជា *ខ្ញុំពូកែខាង.............។ មនុស្សដែលស្រលាញ់ខ្ញុំបំផុតគឺ...........។ ខ្ញុំមានអារម្មណ៍ថាគួរទុកចិត្ត............។ សុភមង្គលដែលខ្ញុំចងចាំបំផុតគឺ......................។ អ្វីដែលខ្ញុំចូលចិត្តបំផុតអំពីភូមិរបស់ខ្ញុំគឺ.........។* ជម្រើសផ្សេងទៀត ដូចជាកុមារអាចគូររូបភាពមួយនៃរឿងរ៉ាវដែលមានលក្ខណ:សមស្រប (ដូចជាឆ័ត្រ មួយ ឬ បាតដៃ)




## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមអរគុណដល់កុមារសម្រាប់ការចូលរួមរបស់ពួកគេ និងប្រាប់ឱ្យពួកគេបានដឹងពីរបៀបទាក់ទងសេវាកម្មក្នុងសហគមន៍ពួកគេ និងសេវាកម្មថ្នាក់ជាតិ (ដូចជាបណ្តាញទូរស័ព្ទជំនួយកុមារ) ប្រសិនបើពួកគេមានសំណួរ ឬការព្រួយបារម្ភ។ នាចុងបញ្ចប់វគ្គសិក្សា សូមអញ្ជើញកុមារ និងអ្នកសម្របសម្រួល ផ្តល់ការទះដៃសរសើរខ្លាំងៗទាំងអស់គ្នា។



# អាយុពី ៨-១០ឆ្នាំ

# ផែនការវគ្គខ្លី អាយុ៨-១០ឆ្នាំ

## រយៈពេល៖ ១ម៉ោង

### សង្ខេប

ប្លង់វគ្គសិក្សាខ្លីនេះ គូសបញ្ជាក់នូវសារសំខាន់ៗសម្រាប់វគ្គរយៈពេលមួយម៉ោង ក្នុងស្ថានភាពដែលអាចបង្រៀនបានតែមួយដងគត់។ ប្លង់មេរៀននេះគូសបញ្ជាក់នូវសារសំខាន់ៗ និងជម្រុញនូវសកម្មភាព ដែលអ្នកសម្របសម្រួលគួរចាត់ជាអាទិភាព។

### សារសំខាន់ៗ

- រាងកាយខ្ញុំ ចិត្តខ្ញុំ និងការគិតខ្ញុំអាចត្រូវបានគេធ្វើបាប។ មនុស្សពេញវ័យទទួលខុសត្រូវ ក្នុងការការពារកុមារពីការធ្វើបាប។ នៅពេលខ្ញុំកាន់តែធំខ្ញុំក៏អាចការពារខ្លួនឯងបានដែរ។
- វាមិនសមរម្យ"ទេ" ដែលអ្នកដទៃមើលឃើញ ឬប៉ះពាល់ផ្នែកឯកជននៃរាងកាយខ្ញុំ លើកលែងតែពេលដែលខ្ញុំមានរបួស ឬខ្ញុំចាំបាច់ត្រូវការការជួយមើលថែ
- ប្រសិនបើខ្ញុំមានអារម្មណ៍ថារងការគំរាមកំហែង ឬមិនគួរទុកចិត្ត ខ្ញុំគួរតែនិយាយថា "ទេ" "ទៅ" និង "ប្រាប់" ទៅមនុស្សពេញវ័យដែលខ្ញុំទុកចិត្ត ពីអារម្មណ៍ និងស្ថានភាពទាំងនេះ។
- ខ្ញុំអាចទៅរកមនុស្សពេញវ័យដែលខ្ញុំទុកចិត្ត ដើម្បីសុំជំនួយ និងការគាំទ្រ។ ពួកគេអាចជួយការពារខ្ញុំពីគ្រោះថ្នាក់ ឬការរំលោភបំពានបាន។

### សម្ភារ

- **ឧបសម្ពន្ធទី២៖ កាតយកតាមខ្លួន**
  (កាតទាំងនេះអាចបោះពុម្ពសម្រាប់អ្នកចូលរួម ឬ អ្នកសម្របសម្រួលអាចសរសេរនៅលើក្រដាសផ្ទាំងធំ ឬ កាតដែលប្រើ សម្រាប់ជាជំនួយ មើលឃើញ។
- **ឧបសម្ពន្ធទី៥៖ ការបង្ហាញរូបភាពរាងកាយកុមារា និងកុមារី** (នេះអាចជាការបញ្ចាំងស្លាយ ឬថតចម្លងនៅលើក្រដាសផ្ទាំងធំ)
- ក្រដាសទំហំA4 ១សន្លឹក សម្រាប់កុមារម្នាក់
- ប៊ិចពណ៌ ខ្មៅដៃ ឬ គូលវទៀន

### ការណែនាំ

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល (៥នាទី)

សូមស្វាគមន៍អ្នករាល់គ្នាមកកាន់ម៉ោងសិក្សាថ្ងៃនេះ។ សូមណែនាំខ្លួនអ្នក និងដាក់ចេញនូវវិន័យគោល (ដើម្បីឱ្យកុមារមានអារម្មណ៍ថាគួរទុកចិត្តក្នុងការនិយាយ។ ឧទាហរណ៍៖ ត្រូវគោរពគ្នាទៅវិញទៅមក ទុកឱ្យអ្នកដទៃនិយាយ ដោយមិននិយាយកាត់ ឬសើចចំអក ការកំណត់ពេលវេលាសម្រាប់ថ្នាក់សិក្សា ឬការពិភាក្សាជាក្រុម ដោយពន្យល់ថា ទីនេះមិនមែនជាកន្លែងសម្រាប់បង្ហាញប្រាប់ពីរឿងផ្ទាល់ខ្លួនទេ ហើយពួកគេអាចនិយាយរឿងនោះជាមួយអ្នកសម្របសម្រួលណាម្នាក់ដោយឡែក ប្រសិនបើអ្វីដែលបាននិយាយឡើង ធ្វើឱ្យពួកគេព្រួយបារម្ភ ឬអាក់អន់ចិត្ត ហើយពួកគេមិនចង់ ឬមិនអាចនិយាយចេញពេល នៅជាមួយក្រុមទាំងមូល)។ សូមពន្យល់ថា៖ *ថ្ងៃនេះ យើងនឹងអនុវត្តពីវិធីមួយចំនួនដើម្បីរក្សាសុវត្ថិភាពខ្លួនឯង។ មុនពេល យើងចាប់ផ្តើម តោះយើងចាប់ផ្តើមណែនាំខ្លួនឱ្យគ្នាស្គាល់សិន។*

#### សកម្មភាព (៥នាទី)

សូមជ្រើសរើសសកម្មភាពណែនាំឱ្យស្គាល់គ្នាមួយ ឬ ច្រើនចេញពី **ឧបសម្ព័ន្ធទី៣៖ ការណែនាំឱ្យស្គាល់គ្នា និងល្បែងបង្កើនទំនុកចិត្ត។**

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល (៥នាទី)

សូមពន្យល់ពាក្យ"**សិទ្ធិកុមារ**" ។ *(សិទ្ធិគឺជារបស់គ្រប់យ៉ាងដែលកុមារគប្បីមាន។ សិទ្ធិមានន័យថា មិនត្រូវមាន "សំណួរ" ឬ ពាក្យថា"ប្រហែលជា" ស្តីពីចំណុចទាំងនេះទេ ពោលគឺកុមារ គប្បីមានរបស់ទាំងនេះតែម្តង)*។ សូមពន្យល់ថា កុមារគ្រប់រូបមានសិទ្ធិទទួលបានសុវត្ថិភាពការគោរព ចំពោះរាងកាយ ការគិត និងអារម្មណ៍របស់ពួកគេ និងមានសិទ្ធិទទួលបានការប្រព្រឹត្តចំពោះខ្លួនដោយស្មើភាព។

សូមពន្យល់ពាក្យ "**ការការពារ**"។ សូមពន្យល់ថា ៖ *ការការពារ គឺជាការរក្សាសុវត្ថិភាពពីការធ្វើបាប ឬគ្រោះថ្នាក់ តាមដែលអាចធ្វើបាន*។ សូមពន្យល់ថា នៅពេលកុមារឈឺចាប់ រងរបួសលើរាងកាយ លើអារម្មណ៍ ឬលើចិត្ត ហើយបើវាមិនមែនកើតឡើងដោយចៃដន្យ នោះគឺហៅថា "ការរំលោភបំពាន"។ សូមពិភាក្សាពីនិយមន័យនៃ ពាក្យថា "ការរំលោភបំពាន" ៖*សកម្មភាពទាំងឡាយណាដែលបង្ករឱ្យឈឺចាប់ ឬរបួស ដែលមិនមែនកើតឡើងដោយចៃដន្យ គេហៅថា "ការរំលោភបំពាន"*។ សូមពន្យល់ពាក្យផ្ទុយនឹងការរំលោភបំពាន គឺការយកចិត្តទុកដាក់ និងការការពារ។

## សកម្មភាព (១០នាទី)

យោងលើ **ឧបសម្ព័ន្ធទី៥៖ ការបង្ហាញរូបភាពរាងកាយកុមារី និងកុមារា** ពន្យល់កុមារ ថា ផ្នែកមួយចំនួននៃរាងកាយ គឺទទួលស្គាល់ជាទូទៅដោយមនុស្សទាំងអស់ជា "ផ្នែកឯកជន"។ ផ្នែកនៃរាងកាយទាំងនេះជាអវយវៈភេទ។ អវៈយវៈភេទបុរស និងស្ត្រីមានភាពខុសគ្នា ។

ដោយប្រើប្រាស់រូបភាពរាងកាយ អ្នកសម្របសម្រួលគួរតែស្នើអ្នកចូលរួម កំណត់ និងដាក់ឈ្មោះអវយវៈភេទ ដោយចង្អុលឲ្យចំរូបភាពទាំងនោះ និងផ្តល់ឈ្មោះតាមកាយវិភាគសាស្ត្រឱ្យបានត្រឹមត្រូវ។ សូមដាក់ឈ្មោះនៅលើផ្នែកទាំងនោះ ដោយហ្វឺតពណ៌។ សូមដាក់ឈ្មោះផ្នែកផ្សេងៗនៃរាងកាយ ដែលកុមារថាជាផ្នែកឯកជន (ឧ.សក់ ដៃ ជើង) ដោយហ្វឺតពណ៌ខុសៗគ្នា។

## ការពិភាក្សាក្រុម (១០នាទី)

សូមពិភាក្សាថាតើ "នរណា" អាចប៉ះពាល់អវយវៈភេទនៃរាងកាយរបស់យើង? នៅពេលណា? *(ពួកយើងអាចប៉ះពាល់អវយវៈភេទរបស់យើង។ គ្រូពេទ្យ គិលានុប្បដ្ឋាក ឪពុកម្តាយ ឬអ្នកថៃទាំអាចប៉ះពាល់អវយវៈភេទនៃរាងកាយរបស់យើង ប្រសិនបើយើងមាន កន្ទួលរមាស់ ជម្ងឺ របួសស្នាម ឬចាំបាច់ត្រូវការជំនួយដើម្បីមើលថែខ្លួនរបស់យើង)*

បញ្ជាក់ថាការរំលោភបំពានផ្លូវភេទគឺជារឿងខុសឆ្គង។ វាមិនមែនជាកំហុសរបស់កុមារទេ បើសិនគាត់ ឬនាងត្រូវបានគេរំលោភបំពានផ្លូវភេទ។ កុមារគ្រប់រូប មិនគួរត្រូវបានស្តីបន្ទោសដោយសាររងនូវការរំលោភបំពានផ្លូវភេទនោះទេ។

សូមពន្យល់ថាការរំលោភបំពានផ្លូវភេទរាប់បញ្ចូលទាំង៖

- ប្រសិនបើមនុស្សម្នាក់ ប៉ះពាល់អវយវៈភេទនៃរាងកាយរបស់ខ្ញុំ តាមវិធីដែលមិនសមរម្យ ឬស្នើឱ្យខ្ញុំប៉ះពាល់អវយវៈភេទរបស់ពួកគេ។
- ប្រសិនជាមនុស្សម្នាក់បង្ហាញឱ្យខ្ញុំមើលរូបភាព ឬវីដេអូអំពីអវយវៈភេទ ឬនិយាយអំពី អវយវៈភេទដោយមិនសមរម្យ។
- ប្រសិនបើមនុស្សម្នាក់ឱ្យខ្ញុំប៉ះពាល់អវយវៈភេទរបស់ខ្ញុំ ឬឱ្យខ្ញុំប៉ះពាល់អវយវៈភេទរបស់នរណាម្នាក់ផ្សេងទៀត។

បញ្ជាក់ថាការរំលោភបំពានផ្លូវភេទគឺជារឿងខុសឆ្គង។ វាមិនមែនជាកំហុសរបស់កុមារទេ បើសិន គាត់ ឬនាងត្រូវបានគេរំលោភបំពានផ្លូវភេទ។ កុមារគ្រប់រូប មិនគួរត្រូវបានស្តីបន្ទោស ដោយសាររងនូវការរំលោភបំពានផ្លូវភេទនោះទេ។

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល (៥ នាទី)

ណែនាំយុទ្ធសាស្ត្រ "ទេ" "ទៅ" "ប្រាប់"

- "ទេ"៖ បើសិននរណាម្នាក់ ធ្វើសកម្មភាពដែលមិនគោរពសិទ្ធិទទួលបានសុវត្ថិភាព ហើយគ្មានការគោរពទៅដល់រាងកាយរបស់អ្នក អ្នកអាចនិយាយថា "ទេ" "ឈប់ធ្វើសកម្មភាពនេះទៀត" "អ្នកមិនគួរធ្វើដូច្នេះទេ" "ខ្ញុំមិនចង់ឱ្យអ្នកធ្វើដូច្នេះទេ"
- "ទៅ"៖ ប្រសិនបើអ្នកអាច អ្នកគួរតែ "ទៅ" ពីស្ថានភាព ឬរៀបផែនការដែលអ្នកអាច "ទៅ" ។ អ្នកគួរតែទៅកាន់ទីកន្លែងមួយ ឬទៅរកមនុស្សពេញវ័យដែលអ្នកទុកចិត្ត។
- "ប្រាប់"៖ ប្រសិនបើអ្នកបានរងគ្រោះ ឬមានអារម្មណ៍ថាមិនគួរទុកចិត្ត អ្នកគួរតែ"ប្រាប់" រឿងនោះទៅមនុស្សពេញវ័យដែលអ្នកទុកចិត្តអំពីស្ថានភាពនោះ។ ប្រាប់ទៅអ្នកដទៃឱ្យបានរឹតតែឆាប់ គឺរឹតតែងាយស្រួលក្នុងការនិយាយប្រាប់ និងកាត់បន្ថយស្ថានភាពគ្រោះថ្នាក់របស់អ្នក។

សូមពន្យល់ថា ពេលខ្លះពួកយើងអាចមាន"អារម្មណ៍"ថា មិនគួរទុកចិត្ត *(អារម្មណ៍គឺជាប្រតិកម្មតបក្នុងរាងកាយរបស់យើងទៅនឹងមនុស្ស ទីកន្លែង បទពិសោធន៍ ឬវត្ថុផ្សេងៗ)* រាងកាយរបស់យើង អាចផ្តល់សញ្ញាមួយប្រសិនបើមានអ្វីមិនស្រួល។ *(សញ្ញាមានន័យថាជាអ្វីដែលផ្តល់ឱ្យយើងនូវសារមួយ)* ។ ឧទាហរណ៍ នៅពេលដែលអ្នកមានអារម្មណ៍ថា ក្តៅ រាងកាយរបស់អ្នកមានប្រតិកម្មតបយ៉ាងដូចម្តេច? *(ខ្ញុំឃើញមានបែកញើសនៅលើស្បែក)* នៅពេលដែលអ្នកមានអារម្មណ៍ថាត្រជាក់ តើរាងកាយរបស់អ្នកមានប្រតិកម្មតបយ៉ាងដូចម្តេច? *(ខ្ញុំព្រឺសម្បុរគីង្គក់ ហើយរោមបះឡើង)* នៅពេលដែលអ្នករត់លឿន រាងកាយរបស់អ្នកមានប្រតិកម្មតបយ៉ាងដូចម្តេច? *(បេះដូងរបស់ខ្ញុំលោតលឿន ខ្ញុំដកដង្ហើមញាប់)*។ល។ ពួកយើងត្រូវយល់ និងធ្វើសកម្មភាពឆ្លើយតបនឹងសារទាំងនេះ ជាពិសេសនៅពេលពួកយើងមានអារម្មណ៍ថាមិនស្រួល ឬក៏កំពុងច្របូកច្របល់។ ពួកយើងគួរតែប្រាប់មនុស្សពេញវ័យ/មិត្តភ័ក្រដែលយើងទុកចិត្តអំពីរឿងរ៉ាវទាំងនេះ។

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល (៥នាទី)

សូមពិភាក្សាអំពី*មនុស្សពេញវ័យដែលអ្នកទុកចិត្ត (មនុស្សពេញវ័យដែលអ្នកទុកចិត្ត ជាអ្នកទាំងឡាយណាដែលអ្នកជួប និយាយជាមួយជាប្រចាំ និងជឿជាក់លើគាត់ថា គាត់នឹងស្តាប់ និងយកចិត្តទុកដាក់ចំពោះយើង។ ពួកគាត់គួរជាអ្នក ដែលអាចជួយការពារយើងឱ្យមានសុវត្ថិភាពពីការធ្វើបាប និងរំលោភបំពានផ្សេងៗ)*។ ដោយមនុស្សពេញវ័យមានអំណាចជាងកុមារ យើងត្រូវរកមនុស្សពេញវ័យជាជាងរកកុមារឱ្យជួយ។ យើងមិនចង់ធ្វើឱ្យកុមារដទៃស្ថិតក្នុងស្ថានភាពគ្មានសុវត្ថិភាពនោះទេ។ ឧទាហរណ៍ មនុស្សពេញវ័យ មានមាឌធំហើយខ្លាំងជាងកុមារ ដូចនេះពួកគាត់អាចជួយកុមារក្នុងស្ថានភាពផ្សេងៗដែលកុមារមិនអាចជួយបាន។

## សកម្មភាព( ១០នាទី )

១. សូមឱ្យកុមារធ្វើបញ្ជីឈ្មោះមនុស្សពេញវ័យដែលគេអាចប្រាប់ ពេលគេព្រួយបារម្ភអំពីរឿងអ្វីមួយ។

២. សូមឱ្យកុមារជ្រើសរើសមនុស្សពេញវ័យដែលគេទុកចិត្តចំនួន៥នាក់ រួចបង្ហាញ។

- គូរប៉េងប៉ោង៥ ។ សរសេរឈ្មោះមនុស្សទាំង៥នាក់ ដែលគេគិតថាអាចទុកចិត្តនិងអាចប្រាប់អំពីបញ្ហានៅក្នុងប៉េងប៉ោងទាំង៥នោះ។
- កាត់ផ្កាក្រដាស១ទង។ បោះកណ្តាលផ្កា រួចសរសេរឈ្មោះរបស់អ្នក។ កាត់ស្រទាប់ផ្កាចំនួន៥ រួចហើយសរសេរឈ្មោះមនុស្សពេញវ័យដែលគេទុកចិត្តនៅលើស្រទាប់ផ្កានីមួយៗ។
- គូជុំវិញដៃរបស់អ្នក។ សរសេរឈ្មោះមនុស្សពេញវ័យទាំង៥ នៅលើម្រាមដៃនិងមេដៃដែលពួកគេបានគូរ។ *( បើសិន **ឧបសម្ព័ន្ធ២៖** កាតយកតាមខ្លួន ត្រូវបានបោះពុម្ពសម្រាប់អ្នកចូលរួមម្នាក់ៗ កុមារអាចសរសេរឈ្មោះមនុស្សពេញវ័យ ដែលគេទុកចិត្តនៅលើកាតទាំងនោះ )*

៣. សូមឱ្យកុមារដាក់ព័ត៌មានលម្អិត អំពីមនុស្សទាំងនោះតាមដែលអាចធ្វើបាន ដូចជាឈ្មោះទំនាក់ទំនង នៅលើទំព័រមនុស្សពេញវ័យទាំង៥ដែលខ្ញុំជឿជាក់នេះបាន

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល ( ៥នាទី )

សូមអរគុណកុមារសម្រាប់ការចូលរួមរបស់គេ និងប្រាប់ពួកគេអំពីលេខនិងអាសយដ្ឋានទំនាក់ទំនងនានានៅក្នុងសហគមន៍ និងសេវាថ្នាក់ជាតិផ្សេងៗ *( ដូចជាទូរស័ព្ទជំនួយកុមារ ) បើសិនជាពួកគេមានសំនួរ ឬក្តីបារម្ភ។ កុមារក៏អាចសរសេររឿងរ៉ាវទាំងនេះលើកាត ដែលមានក្នុង( **ឧបសម្ព័ន្ធ២៖ កាតយកតាមខ្លួន** )។*






# សេចក្តីផ្តើម អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

### សង្ខេប

នៅពេលចាប់ផ្តើម អ្នកសម្របសម្រួលគប្បីបង្កើតនូវបរិយាកាសជឿទុកចិត្ត ដែលកុមារមានអារម្មណ៍ល្អចំពោះខ្លួនឯង និងពេញចិត្តសកម្មភាពនានានៃវគ្គសិក្សា។ កុមារក៏គប្បីត្រូវបានណែនាំឱ្យស្គាល់ពីពាក្យ "ការការពារកុមារ" "ការរំលោភបំពានលើកុមារ" និង "សិទ្ធិកុមារ"។ ចំណេះដឹងនេះគឺជាមូលដ្ឋានគ្រឹះ ដែលអាចញ៉ាំងឱ្យកុមារអាចនិយាយចេញ នៅពេលដែលពួកគេមានអារម្មណ៍ថារងការគំរាមកំហែង ឬគ្មានសុវត្ថិភាព។

### សារសំខាន់ៗ

- រាងកាយ ចិត្ត និងការគិតរបស់ខ្ញុំអាចត្រូវបានធ្វើបាប។ មនុស្សពេញវ័យទទួលខុសត្រូវក្នុងការការពារកុមារពីការធ្វើបាប។ នៅពេលខ្ញុំកាន់តែធំ ខ្ញុំក៏អាចការពារខ្លួនឯងបានដែរ។

### សម្ភារ

- **ឧបសម្ពន្ធ័ ទី២ -កាតយកតាមខ្លួន** ទាំងនេះអាចបោះពុម្ពសម្រាប់អ្នកចូលរួមម្នាក់ៗ ឬ អ្នកសម្របសម្រួលអាចសរសេរនៅលើផ្ទាំងក្រដាសធំ ឬកាតដែលត្រូវបានប្រើជាជំនួយមើលឃើញ។

### ការណែនាំ

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

សូមស្វាគមន៍អ្នករាល់គ្នាមកកាន់ម៉ោងសិក្សាថ្ងៃនេះ។ សូមណែនាំខ្លួនអ្នក និងដាក់ចេញនូវវិន័យគោល (ដើម្បីឱ្យកុមារមានអារម្មណ៍ថាគួរទុកចិត្តក្នុងការនិយាយ។ ឧទាហរណ៍ ត្រូវគោរពគ្នាទៅវិញទៅមក ទុកឱ្យអ្នកដទៃនិយាយដោយមិននិយាយកាត់ ឬសើចចំអក ការកំណត់ពេលវេលាសម្រាប់ថ្នាក់សិក្សា ឬការពិភាក្សាជាក្រុម ដោយពន្យល់ថា ទីនេះមិនមែនជាកន្លែងសម្រាប់បង្ហាញប្រាប់ពីរឿងផ្ទាល់ខ្លួនទេ ហើយពួកគេអាចនិយាយរឿងនោះជាមួយអ្នកសម្របសម្រួលណាម្នាក់ដោយឡែក ប្រសិនបើអ្វីដែលបាននិយាយឡើង ធ្វើឱ្យពួកគេព្រួយបារម្ភ ឬអាក់អន់ចិត្ត ហើយពួកគេមិនចង់ ឬមិនអាចនិយាយចេញពេលនៅជាមួយក្រុមទាំងមូល)។ សូមពន្យល់ថា ថ្ងៃនេះយើងនឹងអនុវត្តពីវិធីមួយចំនួនដើម្បីរក្សាសុវត្ថិភាពខ្លួនឯង។ មុនពេលយើងចាប់ផ្តើម តោះយើងណែនាំខ្លួនឱ្យស្គាល់គ្នាសិន។

**សកម្មភាព**

សូមជ្រើសរើសសកម្មភាពណែនាំឱ្យស្គាល់គ្នាមួយ ឬច្រើនចេញពី **ឧបសម្ព័ន្ធទី៣៖ ការណែនាំឱ្យស្គាល់គ្នា និង ល្បែងបង្កើនទំនុកចិត្ត។**

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

សូមសួរកុមារថា តើពួកគេដឹងពីនិយមន័យនៃពាក្យថាសិទ្ធិដែរឬទេ ។ (សិទ្ធិគឺជារបស់គ្រប់យ៉ាងដែលកុមារគប្បីមាន។ សិទ្ធិមានន័យថាគ្មាន "សំណួរ" ឬ ពាក្យថា "ប្រហែលជា" ស្តីពីចំណុចទាំងនេះទេ គឺកុមារគប្បីមានរបស់ទាំងនេះតែម្តង)។ សូមពន្យល់ថា កុមារគ្រប់រូបមានសិទ្ធិទទួលបានសុវត្ថិ-ភាព ទទួលបានការគោរព ចំពោះរាងកាយ ការគិត និងអារម្មណ៍របស់ពួកគេ និងមានសិទ្ធិទទួលបានការប្រព្រឹត្តចំពោះពួកគេដោយស្មើភាព។



អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

"សិទ្ធិ" គឺអ្វីដែលកុមារម្នាក់ៗគួរទទួលបាន ឬអាចប្រើប្រាស់បាន។ កុមារគ្រប់រូបមានសិទ្ធិស្មើគ្នា។

មាត្រា ១
មនុស្សគ្រប់រូបដែលមានអាយុក្រោម១៨ឆ្នាំ ទទួលបានសិទ្ធិទាំងនេះ ។

មាត្រា ២
កុមារគ្រប់រូបសុទ្ធតែទទួលបានសិទ្ធិទាំងនេះ ទោះបីជាពួកគាត់ជាអ្នកណារស់នៅទីកន្លែងណាឬមានឪពុកម្តាយជាអ្នកប្រកបមុខរបរអ្វីក៏ដោយ ទោះជាពួកគាត់និយាយភាសាអ្វី ឬកាន់សាសនាអ្វីក៏ដោយមិនប្រកាន់ថាជាកុមារា ឬកុមារីទេទោះជាពួកគាត់មានវប្បធម៌បែបណាក្តី ពិការបែបណាក្តី ឬទោះបីមានក្តី ក្រក្តី។ គ្មានកុមារណាម្នាក់ត្រូវទទួលរងអំពើអយុត្តិធម៌ឡើយទោះបីស្ថិតក្នុងរូបភាពបែបណាក៏ដោយ។

មាត្រា ៣
មនុស្សពេញវ័យគ្រប់រូប គួរតែធ្វើអ្វីដែលមានប្រយោជន៍បំផុតសម្រាប់កុមារ។ នៅពេលមនុស្សពេញវ័យធ្វើការសម្រេចចិត្តនានា ពួកគេគួរគិតថា តើការសម្រេចចិត្តរបស់ខ្លួនមានផលប៉ះពាល់ដូចម្តេចខ្លះចំពោះកុមារ ។

មាត្រា ៤
រាជរដ្ឋាភិបាលទទួលខុសត្រូវធានាថាសិទ្ធិរបស់កុមារពិតជាទទួលបានការការពារ។ រដ្ឋាភិបាលត្រូវតែជួយក្រុមគ្រួសាររបស់កុមារដើម្បីការពារ សិទ្ធិរបស់កុមារ និងបង្កើតជាមជ្ឈដ្ឋានមួយដែលអាចឲ្យកុមារធំលូតលាស់ និងអាចធ្វើអ្វីៗបានអស់ពីលទ្ធភាពរបស់ពួកគាត់ ។

មាត្រា ៥
ក្រុមគ្រួសាររបស់កុមារទទួលបន្ទុកជួយឲ្យកុមារចេះប្រើប្រាស់សិទ្ធិរបស់ពួកខ្លួន និងធានាថាសិទ្ធិទាំងនេះទទួលបាននូវការការពារ។

មាត្រា ៦
កុមារទទួលបានសិទ្ធិរស់រានមានជីវិត។

មាត្រា ៧
កុមារមានសិទ្ធិទទួលបានការដាក់ឈ្មោះ ហើយការដាក់ឈ្មោះនេះគួរមានការទទួលស្គាល់ជាផ្លូវការពីរដ្ឋាភិបាល។ កុមារក៏មានសិទ្ធិទទួលបាននូវសញ្ជាតិរបស់ខ្លួន( ជាពលរដ្ឋរបស់ប្រទេសមួយ )។

មាត្រា ៨
កុមារមានសិទ្ធិទទួលបានអត្តសញ្ញាណដែលជាបញ្ជីកត់ត្រាជាផ្លូវការនូវអត្តសញ្ញាណរបស់កុមារ។ គ្មាននរណាម្នាក់អាចដកហូតសិទ្ធិនេះពីកុមារបានឡើយ ។

មាត្រា ៩
កុមារមានសិទ្ធិរស់នៅជាមួយឪពុក ឬម្តាយរបស់ខ្លួន បើការរស់នៅនោះមិនជះផលអាក្រក់ចំពោះកុមារទេ។ កុមារមានសិទ្ធិរស់នៅក្នុងគ្រួសារដែលថែទាំពួកគេ។

មាត្រា ១០
បើកុមាររស់នៅប្រទេសមួយផ្សេងពីប្រទេសដែលឪពុក/ម្តាយខ្លួនរស់នៅ កុមារមានសិទ្ធិនៅជាមួយឪពុកម្តាយនៅទីកន្លែងតែមួយ។

មាត្រា ១១
កុមារមានសិទ្ធិទទួលបានការការពារពីការចាប់ជំរិត។

មាត្រា ១២
កុមារមានសិទ្ធិសម្តែងមតិរបស់ខ្លួន ឲ្យមនុស្សពេញវ័យស្តាប់និងយកចិត្តទុកដាក់ទៅលើមតិទាំងនោះ ។

មាត្រា ១៣
កុមារមានសិទ្ធិស្វែងយល់ពីអ្វីមួយ និងយកអ្វីដែលខ្លួនគិត ទៅប្រាប់អ្នកដទៃតាមរយៈការនិយាយ គូរ សរសេរ ឬវិធីផ្សេងៗទៀត បើទង្វើទាំងនោះមិននាំឲ្យគ្រោះថ្នាក់ ឬបើមិនមានការខុសឆ្គងចំពោះអ្នកដទៃទេ ។

មាត្រា ១៤
កុមារមានសិទ្ធិជ្រើសរើសសាសនា និងជំនឿផ្ទាល់ខ្លួន ។ ឪពុកម្តាយរបស់កុមារ គួរជួយកុមារក្នុងការសម្រេចចិត្តទៅលើអ្វីដែលខុស អ្វីដែលត្រូវ អ្វីដែលល្អបំផុតសម្រាប់កុមារ។

មាត្រា ១៥
កុមារមានសិទ្ធិរាប់អានមិត្តភក្តិផ្ទាល់ខ្លួន និងចូលរួម ឬបង្កើតជាក្រុម បើសកម្មភាពបែបនេះមិនប៉ះពាល់ដល់អ្នកដទៃទេ។

មាត្រា ១៦
កុមារមានសិទ្ធិឯកជនរបស់ខ្លួន។

មាត្រា១៧
កុមារមានសិទ្ធិទទួលបានព័ត៌មាន ដែលមានសារៈសំខាន់សម្រាប់សុខុមាលភាពរបស់ខ្លួនពីវិទ្យុ កាសែត សៀវភៅ កុំព្យូទ័រ និងប្រភពផ្សេងទៀត។ មនុស្សពេញវ័យត្រូវតែធ្វើយ៉ាងណាឲ្យរាល់ព័ត៌មានដែលកុមារទទួលបាននោះ មិនប៉ះពាល់ដល់កុមារ និងជួយកុមារស្វែងរក និងឲ្យបានយល់ដឹងពីព័ត៌មានដែលកុមារត្រូវការ ។

មាត្រា១៨
កុមារមានសិទ្ធិទទួលបានការចិញ្ចឹមបីបាច់ថែរក្សាពីឪពុកម្តាយរបស់ខ្លួន បើអាចធ្វើទៅបាន។

មាត្រា ១៩
កុមារមានសិទ្ធិទទួលបានការការពារឲ្យរួចផុតពីការធ្វើឲ្យឈឺចាប់ និងរងទុក្ខលើរាងកាយនិងផ្លូវចិត្ត។

មាត្រា ២០
កុមារមានសិទ្ធិទទួលបានការថែទាំ និងជំនួយ ពិសេស ក្នុងករណីមិនអាចរស់នៅជាមួយឪពុកម្តាយខ្លួនបាន ។

មាត្រា ២១
កុមារមានសិទ្ធិទទួលបានការថែទាំ និងការពារ បើពួកគាត់ត្រូវបានគេសុំយកទៅចិញ្ចឹម ឬរស់នៅជាមួយគ្រួសារធម៌។

មាត្រា ២២
កុមារមានសិទ្ធិទទួលបានការការពារ និងជំនួយពិសេស ក្នុងករណីពួកគាត់ ជាជនភៀសខ្លួន (បើកុមារត្រូវបានបង្ខំឲ្យចាកចេញពីប្រទេសកំណើតរបស់ខ្លួនទៅរស់នៅប្រទេសមួយទៀត ) ព្រមទាំងសិទ្ធិទាំងអស់ដែលមាននៅក្នុងអនុសញ្ញានេះ។

## សកម្មភាព (តាមជម្រើស)

សិក្សារួមគ្នាពីចំណុចនៅក្នុងឯកសារ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ បែបកុមារមេត្រី។[15]

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ពាក្យ"ការការពារ"។ សូមពន្យល់ថាការការពារគឺជាការរក្សាសុវត្ថិភាពពីការធ្វើបាប ឬគ្រោះថ្នាក់ តាមដែលអាចធ្វើបាន។ សូមពន្យល់ពីរបៀបផ្សេងៗ ដែលកុមារអាចត្រូវបានគេធ្វើបាប ៖

- លើរាងកាយ៖ រាងកាយពួកគេអាចត្រូវបានធ្វើបាប
- លើអារម្មណ៍៖ អារម្មណ៍ពួកគេអាចត្រូវបានធ្វើបាប
- លើចិត្ត៖ ការគិត/គំនិតពួកគេ អាចប្រឈមនឹងការធ្វើបាប (អ្នកសម្របសម្រួលអាចផ្តល់ឧទាហរណ៍នៃផលប៉ះពាល់លើចិត្តដូចជា ដេកមិនលក់ យល់សប្តិអាក្រក់ ឬឈឺក្បាល ទប់ចិត្តមិនឱ្យគិតដដែលៗមិនបាន គិតថាខ្លួនឯងមិនល្អ ។ល។)

សូមពន្យល់ថា នៅពេលកុមារឈឺចាប់ រងរបួសលើរាងកាយ អារម្មណ៍ ឬចិត្ត ហើយបើវាមិនមែនកើតឡើងដោយចៃដន្យ នោះគឺហៅថាការរំលោភបំពាន។ សូមពិភាក្សាពីនិយមន័យ នៃពាក្យថា "ការរំលោភបំពាន"៖ សកម្មភាពទាំងឡាយណាដែលបង្កឱ្យឈឺចាប់ ឬរបួសដែលមិនមែនកើតឡើងដោយចៃដន្យ គេហៅថាការរំលោភបំពាន។ សូមពន្យល់ថា ពាក្យផ្ទុយនឹងការរំលោភបំពានគឺការយកចិត្តទុកដាក់ និងការការពារ។

## ការពិភាក្សាក្រុម

សូមពិភាក្សាពីសំណួរដូចតទៅ ៖

- តើនរណាទទួលខុសត្រូវការពារកុមារ? (ម្តាយឪពុក ម្តាយឪពុកចិញ្ចឹម តា យាយ សាច់ញាតិ គ្រូបង្រៀន នាយកសាលា អ្នកមើលថែទារក ប៉ូលីស) ។ល។
- តើមនុស្សពេញវ័យទាំងនេះនៅក្បែរអ្នកដើម្បីការពារអ្នកជានិច្ចឬ? (បាទ/ចាស/ទេ )
- តើអ្នកត្រូវធ្វើដូចម្តេចដើម្បីគួរទុកចិត្ត នៅពេលដែលពួកគាត់មិននៅក្បែរអ្នក? (ប្រើប្រាស់ព័ត៌មាន និងផែនការសុវត្ថិភាពដើម្បីរក្សាសុវត្ថិភាព។ សូមការ ជួយពីមនុស្សពេញវ័យដែលអ្នកទុកចិត្ត)។

---

14 អនុសញ្ញាស្តីពីសិទ្ធិកុមារបែបកុមារមេត្រីមាននៅក្នុងកាតដាក់តាមខ្លួន ឧបសម្ព័ន្ធ២ ឬ Color it Rights:ការបង្ហាត់កុមារអំពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារក៏គួរមើល (សូមចូលទៅកាន់ http://teachunicef.org/sites/default/files/sites/default/files/documents/color_it_rights_coloring_book.pdf)

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកឡើងវិញពីសារគន្លឹះ។ សូមពន្យល់ថាការដឹងពីព័ត៌មានសមស្រប និងផែនការសុវត្ថិភាពអាចការពារយើងបាន។ នេះជាអ្វីដែលយើងនឹងត្រូវស្វែងយល់បន្ថែមនៅថ្ងៃនេះ។

## ការសង្កេត

- តើកុមារអាចដឹងបានថាតើមនុស្សពេញវ័យណាខ្លះដែលទទួលខុសត្រូវក្នុងការការពារកុមារពីការធ្វើបាបដែរឬទេ ? ✓
- តើកុមារអាចកំណត់បានពីទម្រង់គ្រោះថ្នាក់ដែលកុមារអាចជួបប្រទះដែរឬទេ ? ✓

# ប្រធានបទទី១-រាងកាយខ្ញុំ អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

### សង្ខេប

ប្រធានបទនេះបង្រៀនពីផ្នែកផ្សេងៗនៃរាងកាយរួមទាំងប្រដាប់ភេទផងដែរ។ វាជួយកុមារឱ្យដឹងពីរាងកាយទាំងមូល និងផ្តល់ឱ្យពួកគេនូវពាក្យគ្រប់គ្រាន់សម្រាប់ពណ៌នាពីស្ថានភាពរំលោភបំពានធ្ងន់ធ្ងរ។ **កុមារី និងកុមារា គប្បីរៀនពីប្រធានបទនេះក្នុងក្រុមដាច់ដោយឡែកពីគ្នា។**

### សារសំខាន់ៗ

- ខ្ញុំស្គាល់ឈ្មោះផ្នែកឯកជននៃរាងកាយខ្ញុំ។
- វាមិនសមរម្យទេ ដែលអ្នកដទៃមើលឃើញ ឬ ប៉ះផ្នែកឯកជននៃរាងកាយខ្ញុំ លើកលែងតែពេលដែលខ្ញុំមានរបួស ឬ ត្រូវការការជួយដើម្បីសម្អាតផ្នែកទាំងនោះ។

### សម្ភារ

- ដីស ឬហ្វឺត និងក្រដាសផ្ទាំងធំ
- **ឧបសម្ព័ន្ធទី៥-រូបភាពនៃរាងកាយរបស់កុមារី និងកុមារា** (រូបភាពនេះអាចបញ្ចាំងស្លាយ ឬថតចម្លងលើផ្ទាំងក្រដាសធំ)។

### ការណែនាំ

#### សកម្មភាព

សូមបែងចែកកុមារឱ្យធ្វើការជាគូ ដោយបែងចែកតាមភេទ និងសូមឱ្យពួកគេគូររូបរាងកាយរបស់ពួកគេ ដោយប្រើដីសនៅលើឥដ្ឋ ឬ ប្រើហ្វឺតនៅលើក្រដាសផ្ទាំងធំ។ (ប្រសិនបើក្រុមមានមនុស្សច្រើន អ្នកអាចដាក់កុមារឱ្យធ្វើការក្នុងក្រុមដែលមានសមាជិក៤នាក់ឬ៦នាក់ ហើយមានតែសមាជិកម្នាក់ប៉ុណ្ណោះ ដែលស្ម័គ្រចិត្តឱ្យគេគូររូបរបស់គេ។ ក្រុមត្រូវតែធ្វើការដោយបែងចែកតាមភេទ ពោលគឺកុមារីនៅជាមួយកុមារី និងកុមារានៅជាមួយកុមារា)។

សូមឱ្យកុមារកំណត់ពីផ្នែក*"ឯកជន"*នៃរាងកាយដោយគូររង្វង់ ឬប្រអប់ជុំវិញផ្នែកនៃរាងកាយ។ សូមរំលឹកប្រាប់កុមារថា ពាក្យថាឯកជនមានន័យថា *"សម្រាប់ខ្ញុំ"* ហើយពាក្យថា សាធារណៈ មានន័យថា *"សម្រាប់អ្នករាល់គ្នា"*។ សូមពិភាក្សាពីចំណុចនេះក្នុងក្រុមទាំងមូល។

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់កុមារថា ផ្នែកមួយចំនួននៃរាងកាយ ត្រូវបានមនុស្សគ្រប់គ្នាទទួលស្គាល់ថាជាផ្នែកឯកជន។ ទាំងនេះជា*អវយវៈភេទ*។ អវយវៈភេទ មានភាពខុសគ្នារវាងមនុស្សប្រុស និងមនុស្សស្រី។

#### សកម្មភាព

យោងលើ **ឧបសម្ព័ន្ធទី៥៖រូបភាពរូបរាងកាយកុមារា និងកុមារី** អ្នកសម្របសម្រួលគប្បី ត្រៀមរូបភាពកុមារាមួយនិងកុមារីមួយ។ ដោយប្រើរូបភាពរាងកាយនេះ អ្នកសម្របសម្រួលគប្បីសូមឱ្យសិក្ខាកាមកំណត់ និងដាក់ឈ្មោះអវយវៈភេទ ដោយចង្អុលទៅកាន់ផ្នែកទាំងនោះ និងដាក់ឈ្មោះជាពាក្យបច្ចេកទេសកាយវិភាគសាស្ត្រឱ្យបានត្រឹមត្រូវដូចជា លិង្គ យោនី រន្ធគូទ។ សូមប្រើហ្វឺតពណ៌ដើម្បីគូសពណ៌ចំណាំកន្លែងទាំងនេះ។

សូមគូសពណ៌ចំណាំផ្នែកផ្សេងទៀត នៃរាងកាយដែលកុមារយល់ថាជាផ្នែកឯកជនដែរ (សក់ ដៃ ជើង) ដោយប្រើហ្វឺតពណ៌ផ្សេងគ្នា។[15]

### ការពិភាក្សាក្រុម

សូមពិភាក្សាពីសំណួរដូចតទៅ ៖

- ហេតុអ្វីបានជាចាំបាច់ត្រូវដឹង និងប្រើឈ្មោះឱ្យបានត្រឹមត្រូវសម្រាប់ផ្នែកឯកជនទាំងនេះនៃរាងកាយ? *(អ្នកដទៃអាចយល់ច្បាស់ពីអ្វីដែលយើងនិយាយ ហើយទាំងនេះគឺឈ្មោះត្រឹមត្រូវរបស់ផ្នែកទាំងនោះ )។*
- តើវាជាការសមរម្យដែរឬទេក្នុងការនិយាយ ឬហៅឈ្មោះផ្នែកឯកជននៃរាងកាយ? *(វាជាការសមរម្យជានិច្ចក្នុងការប្រើឈ្មោះផ្នែកទាំងនេះឱ្យបានត្រឹមត្រូវ។ មនុស្សមួយចំនួនអាចមាន អារម្មណ៍ខ្មាស នៅពេលពួកគេឮពាក្យទាំងនេះ។ ការអៀនខ្មាស់នេះមិនមែនបណ្ដាលមកពីពាក្យដែលយើងប្រើនោះទេ ពាក្យទាំងនេះមានលក្ខណៈសមរម្យ)។*
- ហេតុអ្វីបានជាផ្នែកឯកជននៃរាងកាយយើងត្រូវបានចាត់ទុកថាមានលក្ខណៈឯកជន? *( ទាំងនេះជាផ្នែកពិសេស ដែលជារបស់យើង។ ជាការសំខាន់ត្រូវរក្សាផ្នែកទាំងនេះ ឱ្យមានសុវត្ថិភាព និងមានលក្ខណៈឯកជនរហូតដល់ពេលយើងធំឡើង និងជួបមនុស្សពិសេសដែលយើងអាចចែករំលែកផ្នែកទាំងនេះជាមួយគ្នា។ យើងអាចប៉ះផ្នែកឯកជននៃរាងកាយយើងបាន ដោយមិនចាំបាច់ចែករំលែកផ្នែកឯកជននៃរាងកាយយើងទេ មុនពេលយើងជួបមនុស្សពិសេសនោះ)។*

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកសារគន្លឹះឡើងវិញ។

### សកម្មភាព

សូមជ្រើសរើសល្បែងស្ទាំងគំនិតចេញពី **ឧបសម្ព័ន្ធទី៣ ៖ សកម្មភាពបង្កើនថាមពល** ដើម្បីកាត់បន្ថយភាពតានតឹងចិត្ត។

---

## ការសង្កេត

- តើកុមារអាចប្រើពាក្យបច្ចេកទេសកាយវិភាគសាស្ត្រដើម្បីដាក់ឈ្មោះប្រដាប់ភេទរបស់មនុស្សប្រុស និងមនុស្សស្រីបានដែរឬទេ? ✔
- តើកុមារអាចកំណត់បាននូវផ្នែកមួយចំនួននៃរាងកាយដែលមានលក្ខណៈឯកជនដែរឬទេ? ✔
- តើកុមារអាចពន្យល់បាននូវស្ថានភាពមួយចំនួនដែលចាំបាច់ត្រូវឱ្យអ្នកដទៃមើល ឬប៉ះផ្នែកឯកជននៃរាងកាយរបស់ពួកគេដែរឬទេ? ✔

---

15 យោងលើ *ផ្នែក១:ការចាប់ផ្ដើម* ដើម្បីដោះស្រាយជាមួយអាកប្បកិរិយាពីបាកក្នុងករណីកុមារចាប់ផ្ដើមប្រើពាក្យមិនសមរម្យ។

# ប្រធានបទទី២-អារម្មណ៍ និងសញ្ញាព្រមាន អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

## សង្ខេប

ប្រធានបទនេះជួយឱ្យកុមារយល់ដឹងកាន់តែច្បាស់ពីអារម្មណ៍ និង សញ្ញាព្រមាននៃរាងកាយពួកគេ(រួមនឹងអារម្មណ៍ផ្លាស់ប្តូរនិងប្រេហ្វូកប្រហល់)។ ការដឹងបាន និងឆ្លើយតបចំពោះអារម្មណ៍ និងសញ្ញាព្រមាននៃរាងកាយ អាចជួយកុមារឱ្យយល់បានថាពេលណាដែលពួកគេត្រូវការការការពារ។

## សារសំខាន់ៗ

- អារម្មណ៍និងសញ្ញាព្រមានផ្តល់នូវសារអំពីសុវត្ថិភាព។
- ខ្ញុំត្រូវយល់និងធ្វើសកម្មភាពតបចំពោះសារទាំងនេះ ជាពិសេសនៅពេល ដែលពួកវាមានលក្ខណៈមិនសុខស្រួល ឬប្រេហ្វូកប្រហល់ និង និយាយជាមួយមនុស្សពេញវ័យដែលខ្ញុំទុកចិត្ត ឬមិត្តភក្តិអំពីរឿងរ៉ាវទាំងនេះ។

## សម្ភារ

- ប៊ិចហ្វឺត និងក្រដាសផ្ទាំងធំ
- ឯកសារថតចម្លងនៃ **ឧបសម្ព័ន្ធទី៦ ៖ អារម្មណ៍អាចផ្លាស់ប្តូរ - សាច់រឿង** សម្រាប់ក្រុមតូចៗនីមួយៗ

## ការណែនាំ

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ថាសញ្ញាមានន័យថា*អ្វីដែលផ្តល់ឱ្យយើងនូវសារមួយ*។

សូមពន្យល់ថា រាងកាយយើងមានសញ្ញាដែលផ្តល់ឱ្យយើងនូវសារពិសេស។

### ការពិភាក្សាក្រុម

ដោយប្រើក្រដាសផ្ទាំងធំ សូមឱ្យកុមារសរសេរនូវសញ្ញាមួយចំនួនដែលរាងកាយអាចមាន។ សម្រាប់ជាឧទាហរណ៍ នៅពេលអ្នកមានអារម្មណ៍ថាក្តៅ តើរាងកាយ អ្នកមានប្រតិកម្មយ៉ាងដូចម្តេច? *(ខ្ញុំឃើញមានញើសនៅលើស្បែកខ្ញុំ)*។ នៅពេលអ្នកមានអារម្មណ៍ថា រងា តើរាងកាយអ្នកធ្វើសកម្មភាពបែបណា? *(ខ្ញុំឃើញកន្ទួលតូចៗនៅលើស្បែកខ្ញុំ ហើយរោមលើរាងកាយខ្ញុំក៏បះឡើង )*។ នៅពេលអ្នករត់លឿន តើរាងកាយអ្នកមានប្រតិកម្មយ៉ាងដូចម្តេច? *(បេះដូងខ្ញុំលោតញាប់ ខ្ញុំដកដង្ហើមខ្លីៗ )*។

សូមពិភាក្សាពីអត្ថន័យនៃសារដែលសញ្ញាទាំងនេះអាចផ្ញើចេញ។ ឧទាហរណ៍ដូចជាបែកញើសបាតដៃ អាចជាការប្រេហ្វូកប្រហល់ក្នុងចិត្ត ឬភ័យខ្លាច។ សូមកំណត់នូវសញ្ញាមួយចំនួនដែលអាចចាត់ថ្នាក់ថាជាសញ្ញាព្រមាន *(សញ្ញាព្រមាន គឺជាសញ្ញាដែលកើតឡើងនៅពេលដែលយើងមានអារម្មណ៍ណាមួយដែលយើងមិនចូលចិត្ត )*។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមទទួលស្គាល់ថា សញ្ញារាងកាយ មិនមែនសុទ្ធតែមានអត្ថន័យដូចគ្នាគ្រប់ពេល នោះទេ ពោលគឺ សញ្ញារាងកាយតែមួយអាចមានអត្ថន័យផ្សេងៗគ្នាទៅតាមបរិបទផ្សេងៗគ្នា។

### ការពិភាក្សាក្រុម

សូមពិភាក្សាពីសំណួរដូចតទៅ ៖

- អ្វីជាអារម្មណ៍ ? *(អារម្មណ៍គឺជាប្រតិកម្មក្នុងរាងកាយចំពោះអ្នកដទៃ ទីកន្លែង បទពិសោធន៍ ឬរឿងអ្វីមួយ )*។
- តើប្រតិកម្មរាងកាយយើងចំពោះអារម្មណ៍ គេហៅថាអ្វី ? *( សញ្ញារាងកាយ )*
- តើសញ្ញារាងកាយយើងប្រាប់យើងពីអ្វីខ្លះ ? *( ពួកវាប្រាប់យើងថា អារម្មណ៍យើងមានសារៈសំខាន់ ហើយយើងចាំបាច់ត្រូវគិតពីអត្ថន័យនៃអារម្មណ៍ទាំងនោះ )*។
- តើយើងអាចមើលឃើញអារម្មណ៍ដែរឬទេ ? *( ទេ ! ពួកវាស្ថិតនៅខាងក្នុង។ ជួនកាល យើងអាចមើលឃើញប្រតិកម្មខាងក្រៅរបស់យើងចំពោះអារម្មណ៍។ ឧ. ការឡើងកន្ទួលតូចៗ ឬមុខឡើងក្រហម )*។
- តើពាក្យថាខាងក្នុង និងខាងក្រៅ មានន័យបែបណា ? *( ខាងក្នុងសំដៅលើអ្វីដែលនៅខាងក្នុង ដែលមិនអាចមើលឃើញ។ ខាងក្រៅ សំដៅលើអ្វីដែលនៅខាងក្រៅ ដែលយើងអាចមើលឃើញ )*។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ថា ជួនកាលអារម្មណ៍និងសញ្ញារាងកាយអាចផ្លាស់ប្ដូរ។ ជួនកាលការផ្លាស់ប្ដូរនេះអាចកើតឡើងយ៉ាងលឿន។ ជាការសំខាន់ត្រូវកត់ចំណាំពីអារម្មណ៍ដែលផ្លាស់ប្ដូរនោះ។

### សកម្មភាព

សូមឱ្យកុមារធ្វើការជាក្រុមតូចៗ ដើម្បីពិភាក្សាពីសាច់រឿងក្នុង**ឧបសម្ព័ន្ធទី៦**។ សូមឱ្យកុមារកំណត់ថា តើតួអង្គមានអារម្មណ៍បែបណានៅពេលដំបូង ហើយអារម្មណ៍នោះផ្លាស់ប្ដូរដូចម្ដេច។ សូមឱ្យពួកគេកត់ត្រាអារម្មណ៍ និងសញ្ញាផ្លូវកាយដែលកើតឡើងព្រមគ្នា និងដែលអាចផ្លាស់ប្ដូរ។ បន្ទាប់មកសូមឱ្យពួកគេពិភាក្សាក្នុងក្រុមទាំងមូល។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកឡើងវិញពីសារគន្លឹះមុនពេលបន្តទៅប្រធានបទបន្ទាប់។

## ការសង្កេត

- តើកុមារអាចដឹងបានពីរបៀបដែលរាងកាយពួកគេមានប្រតិកម្មតប និងរបៀបដែលពួកគេអាចមានអារម្មណ៍នៅក្នុងស្ថានភាពគួរទុកចិត្ត និងគ្មានសុវត្ថិភាពដែរឬទេ ? ✔
- តើកុមារអាចដឹងថាអារម្មណ៍អាចផ្លាស់ប្ដូរ ឬច្របូកច្របល់ចូលគ្នា នៅក្នុងស្ថានភាពគួរទុកចិត្ត និងគ្មានសុវត្ថិភាពដែរឬទេ ? ✔

# ប្រធានបទទី ៣៖ តើការរំលោភបំពានផ្លូវភេទជាអ្វី? អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

### សង្ខេប

ប្រធានបទនេះផ្តល់ព័ត៌មានអំពីការរំលោភបំពានផ្លូវភេទ និងផ្តល់ឱកាសឱ្យកុមាររៀនសូត្រ ដើម្បីចេះបែងចែករវាងការប៉ះពាល់សមស្រប និងការរំលោភបំពាន។

### សារសំខាន់ៗ

- ការរំលោភបំពានផ្លូវភេទគឺជារឿងខុស។
- ជានិច្ចកាល កុមារមិនមែនជាអ្នកខុសទេ ប្រសិនបើគេរងនូវការរំលោភបំពានផ្លូវភេទ។ មិនគួរបន្ទោសកុមារនោះឡើយ។
- ការរំលោភបំពានផ្លូវភេទរួមមាន៖
  - ប្រសិនបើនរណាម្នាក់ប៉ះពាល់អវយវៈភេទរបស់ខ្ញុំក្នុងលក្ខណៈមួយដែលមិនអាចទទួលយកបាន ឬសូមឱ្យខ្ញុំប៉ះពាល់អវយវៈភេទរបស់ពួកគេ។
  - ប្រសិនបើនរណាម្នាក់បង្ហាញរូបភាព ឬវីដេអូស្តីពីអវយវៈភេទ ឬនិយាយពីអវយវៈភេទជាមួយខ្ញុំ ក្នុងលក្ខណៈមួយដែលមិនអាចទទួលយកបាន។
  - ប្រសិនបើមនុស្សម្នាក់ឱ្យខ្ញុំប៉ះពាល់អវយវៈភេទរបស់ខ្ញុំ ឬអវៈយវៈភេទរបស់មនុស្សដទៃ។

### សម្ភារ

- ថតចម្លង **ឧបសម្ព័ន្ធទី៧៖ ការប៉ះពាល់សមស្រប ឬការរំលោភបំពានផ្លូវភេទ–កាតសេណារីយ៉ូ** សម្រាប់ក្រុមតូចៗ

### ការណែនាំ

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

ពន្យល់អំពីអត្ថន័យនៃអវយវៈភេទ *(ផ្នែកនៃរាងកាយដែលមានលក្ខណៈឯកជន ដែលខុសគ្នារវាងមនុស្សប្រុស និងមនុស្សស្រី ហើយដែលជាសញ្ញាកំណត់អំពីយេនឌ័រ ឬភេទរបស់ពួកគេ)*។

ពិភាក្សាគ្នាថាតើនរណាអាចប៉ះពាល់អវយវៈភេទរបស់យើងបាន? នៅពេលណា? *(យើងអាចប៉ះពាល់អវយវៈភេទរបស់យើងបាននៅក្នុងទីកន្លែងឯកជន។ វេជ្ជបណ្ឌិត គិលានុបដ្ឋាក ឪពុកម្តាយ អ្នកថែទាំ ប្រហែលជាចាំបាច់ត្រូវប៉ះពាល់អវយវៈភេទរបស់យើង ប្រសិនបើយើងកើតកន្ទួលរមាស់ មានដំបៅ រងរបួស ឬត្រូវការឱ្យគេជួយដើម្បីថែទាំខ្លួនយើង)*។

**សកម្មភាព**

បែងកុមារទៅជាក្រុមតូចៗ ដើម្បីពិភាក្សាស្ថានភាពក្នុង**ឧបសម្ព័ន្ធទី ៦៖ ការប៉ះពាល់សមស្រប ឬការរំលោភបំពានផ្លូវភេទ–កាតសេណារីយ៉ូ**។ សូមឱ្យកុមារសម្រេចចិត្តថាតើសកម្មភាពនោះជាការប៉ះពាល់សមស្រប ឬជាការរំលោភបំពានផ្លូវភេទ។

### ការពិភាក្សាក្រុម

ពិភាក្សាលើសំណួរខាងក្រោម៖

- តើអ្វីដែលជួយអ្នកឱ្យសម្រេចចិត្តថា តើស្ថានភាពនេះគឺជាការប៉ះពាល់ដែលមិនបង្កជាបញ្ហា ឬការរំលោភបំពានផ្លូវភេទ ?
- តើមានស្ថានភាពមួយចំនួនដែលអ្នកមិនច្បាស់ក្នុងចិត្តឬទេ ? ហេតុអ្វី?
- ប្រសិនបើកុមារស្ថិតក្នុងស្ថានភាពដែលពួកគេពុំច្បាស់ ដូច្នេះ តើពួកគេអាចធ្វើអ្វីខ្លះ? *(ណែនាំអំពីយុទ្ធសាស្ត្រ **ទេ ទៅ ប្រាប់**៖ និយាយថា "ទេ" (ប្រសិនបើពួកគេអាច) "**ទៅ**" (ប្រសិនបើពួកគេអាច) ហើយជានិច្ចកាលត្រូវ "**ប្រាប់**" ដល់មនុស្សធំដែលពួកគេ ទុកចិត្តណាម្នាក់អំពីស្ថានភាព ដែលមានលក្ខណៈច្របូកច្របល់ ឬដែលមិនអាចទទួលយកបាន។ សូមសង្កត់ធ្ងន់ថា កុមារនៅក្នុងស្ថានភាពទាំងអស់នេះ គឺពុំមែនជាអ្នកត្រូវទទួលការស្តីបន្ទោសនោះទេ។ វាពុំមែនជាកំហុសរបស់ពួកគេឡើយ)។* អ្នកសម្របសម្រួលគួរសរសេរ យុទ្ធសាស្ត្រ **ទេ ទៅ ប្រាប់** នៅលើជញ្ជាំង ឬនៅលើក្រដាសផ្ទាំងធំ ដើម្បីកុមារអាចមើល បន្ថែម។ អ្នកសម្របសម្រួលក៏អាចប្រើកាតយកតាមខ្លួនបានដែរ (**ឧបសម្ព័ន្ធទី២**)។

### សកម្មភាព

សង្ខេបឡើងវិញលើសារសំខាន់ៗ ហើយលេងល្បែងស្វាងអារម្មណ៍ ដែលយកចេញពី **ឧបសម្ព័ន្ធទី៤៖ ល្បែងស្វាងគំនិត** ដើម្បីធ្វើឱ្យវគ្គសិក្សាកាន់តែមានភាពរីករាយសម្រាប់កុមារ ក៏ដូចជាដើម្បីបន្ថយភាពតានតឹង។

---

## ការសង្កេត

- តើកុមារអាចបែងចែករវាងស្ថានភាពដែលការប៉ះពាល់សមស្រប និងមិនសមស្រប ឬទេ? ✓
- តើកុមារអាចកំណត់អំពីអាកប្បកិរិយាមួយចំនួនជាការរំលោភបំពានផ្លូវភេទឬទេ? ✓

---

# ប្រធានបទទី៤៖ សំណូក និងការគំរាម អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

---

### សង្ខេប

ការរំលោភបំពានផ្លូវភេទលើកុមារកម្រកើតឡើង "តែម្តងហើយចប់"ណាស់។ ជារឿយៗ វាអាចបន្តកើតឡើងជាច្រើនខែឆ្នាំ។ អ្នករំលោភបំពានផ្លូវភេទលើកុមារ តែងតែប្រើប្រាស់សំណូក និងការគំរាម ដើម្បីចូលទៅក្បែរកុមារ និងដើម្បីបន្តធ្វើការរំលោភបំពាន ជាបន្តទៀត។ ការបង្រៀនកុមារឱ្យចេះញែករវាងអំណោយពិតប្រាកដ និងសំណូក អាចជួយកុមារឱ្យយល់បានថា ពេលណាដែលពួកគេត្រូវការការពារ និងស្វែងរកជំនួយ។

---

### សារសំខាន់ៗ

- ខ្ញុំដឹងពេលដែលខ្ញុំទទួលអំណោយពិតប្រាកដ។
- ខ្ញុំត្រូវយល់ថា ពេលណាដែលអំណោយត្រូវបានប្រើជាសំណូក។ មនុស្សម្នាក់អាចប្រើប្រាស់សំណូក ឬការគំរាម និងរំពឹងឱ្យខ្ញុំធ្វើអ្វីដែលមិនសមរម្យជាកិច្ចឆ្លើយតប។
- ខ្ញុំគប្បីប្រាប់ដល់អ្នកដទៃជានិច្ច ប្រសិនបើខ្ញុំត្រូវបានការផ្តល់សំណូក ឬគំរាម។

---

### សម្ភារ

- ប៊ិចហ្វឺត និងក្រដាសផ្ទាំងធំ

---

### ការណែនាំ

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

- សូមពន្យល់ពាក្យ "ការគំរាម" *(ការគំរាម គឺជាពាក្យសម្តី ឬសកម្មភាពទាំងឡាយណាដែលសំដៅបង្ខំអ្នកដទៃឱ្យធ្វើ ឬមិនឱ្យធ្វើអ្វីមួយ។ ការគំរាម ជារឿយៗមាន ន័យថា គេនឹងធ្វើឱ្យឈឺចាប់ ប្រសិនបើមនុស្សនោះមិនធ្វើតាមគេ)*។
- សូមពន្យល់ពីពាក្យថា "សំណូក" *(សំណូក គឺជារបស់អ្វីមួយដូចជាប្រាក់ ឬអំណោយដែលគេឱ្យទៅនរណាម្នាក់ ដើម្បីដាក់សម្ពាធលើមនុស្សនោះឱ្យធ្វើសកម្មភាពអ្វីមួយ)*។
- សូមពន្យល់ភាពខុសគ្នារវាង "**សំណូក**" និង "**រង្វាន់**"។ សំណូក គឺផ្តល់ឱ្យក្នុងការព្យាយាមដើម្បីឱ្យអ្នក*ធ្វើអ្វីមួយ*។ "**រង្វាន់**" គឺជាការផ្តល់ឱ្យ នៅពេលដែលអ្នកធ្វើអ្វីមួយសមនឹងទទួលបានការសរសើរ ឬទទួលស្គាល់។
- អ្នកគួរតែប្រាប់ទៅកាន់មនុស្សពេញវ័យដែលអ្នកទុកចិត្ត ប្រសិនបើអ្នកត្រូវបានគេស្នើសូមផ្តល់អំណោយ ឬលុយកាក់ ដើម្បីធ្វើអ្វីមួយដែលអ្នកគិតថា មិនសមរម្យ។

#### ការពិភាក្សាក្រុម

សូមពិភាក្សាជាក្រុមនូវសំណួរដូចតទៅ៖

- អ្វីជាអំណោយ? *(ប្រដាប់ក្មេងលេង ការជួយ ម្ហូបអាហារដ៏ឆ្ងាញ់ របស់របរប្រើប្រាស់ ការសរសើរ ការចេញទៅបរិភោគនៅខាងក្រៅ)*។
- ហេតុអ្វីបានជាគេឱ្យអំណោយ? *(វាអាចជាឱកាសពិសេស ដូចជាពិធីខួបកំណើត ដើម្បីជាការថ្លែងអំណរគុណ ក្នុងឱកាសជម្រាបលា ឬដើម្បីស្វាគមន៍ ឬអំណោយត្រូវបានផ្តល់នៅពេលនរណាម្នាក់មានជម្ងឺ)*។

- តើអ្នកដទៃរំពឹងថា អ្នកនឹងធ្វើអ្វីមួយ នៅពេលដែលគេឱ្យអំណោយដល់អ្នក? បើមាន តើជាអ្វី? *(អ្នកដទៃអាចរំពឹងថាយើងឆ្លើយតបវិញដោយសុភាពរាបសារ)*។ អ្នកសម្របសម្រួលអាចពន្យល់ថា វាជាការសុភាពរាបសារ ដែលអ្នកត្រូវចេះនិយាយថាអរគុណ នៅពេលអ្នកទទួលអំណោយអ្វីមួយ។
- ជួនកាល កុមារត្រូវបានរំពឹងឱ្យសម្តែងការអរគុណក្នុងរបៀបដែលពួកគេមានអារម្មណ៍មិនស្រួលក្នុងចិត្ត។ តើអ្វីខ្លះដែលធ្វើឱ្យមានអារម្មណ៍មិនស្រួលក្នុងចិត្ត? ( *ការថើបមាត់ ឬអោបរឹត* )។
- តើអ្នកគួរធ្វើយ៉ាងណា ប្រសិនបើការរំពឹងទុកនោះ ធ្វើឱ្យអ្នកមានអារម្មណ៍ មិនស្រួលក្នុងចិត្ត ឬគ្មានសុវត្ថិភាព? *(សូមនិយាយប្រាប់មនុស្សពេញវ័យដែលអ្នកទុកចិត្តពីរឿងនេះ។ អ្នកមានសិទ្ធិទទួលបានសុវត្ថិភាព និងទទួលបានការគោរព ចំពោះរាងកាយ និងអារម្មណ៍អ្នក)*។
- តើវាជាការសមរម្យ ឬត្រឹមត្រូវដែរឬទេ នៅពេលដែលអ្នកទទួលអំណោយ ហើយត្រូវបានរំពឹងឱ្យជូនអំណោយទៅវិញ ឬធ្វើអ្វីមួយឱ្យគេ? *(អំណោយពិតប្រាកដត្រូវបានជូនដោយគ្មានលក្ខខណ្ឌ ឬការរំពឹងឱ្យតបស្នងនោះទេ។ វាមិនមែនជាការសមរម្យ ឬត្រឹមត្រូវទេ ប្រសិនបើនរណាម្នាក់ទាមទារឱ្យកុមារផ្តល់ឱ្យ អំណោយផ្សេងតប ឬធ្វើអ្វីមួយតបទៅវិញ)*។ បើសមស្រប អ្នកសម្របសម្រួលអាចពិភាក្សា និងទទួលស្គាល់ពីប្រពៃណីផ្សេងៗក្នុងការផ្តល់ និងទទួលអំណោយ ប៉ុន្តែសូមបញ្ជាក់ឱ្យច្បាស់ថា ស្ថានភាពមិនសមស្របទាល់តែសោះក្នុងការផ្តល់/ទទួលអំណោយ។
- ប្រសិនបើនរណាម្នាក់សន្យាថាពួកគេនឹងផ្តល់អំណោយដល់អ្នក ប៉ុន្តែទាល់តែអ្នកធ្វើអ្វីមួយឱ្យគេ តើនេះពិតជាអំណោយមែនឬទេ ? *(ទេ ។ វាមិនមែនជាអំណោយទេ ពីព្រោះអំណោយត្រូវបានផ្តល់ជូនដោយមិនចង់បានអ្វីតបស្នងវិញឡើយ។ មិនគួរមានលក្ខខណ្ឌ ឬការរំពឹងទុកមុនពេលដែលអ្នកទទួលបានអំណោយនោះ)*។

## ការពិភាក្សាក្រុម

សូមពិភាក្សាចំពោះស្ថានភាព "ឧបមាថា" ដូចតទៅ៖

- ឧបមាថាមនុស្សម្នាក់ឱ្យអំណោយដល់អ្នក និងរំពឹងឱ្យអ្នកក្លាយជាមិត្តរបស់គេ តើនោះជារឿងត្រឹមត្រូវដែរឬទេ ?
- ឧបមាថាមនុស្សម្នាក់បានឱ្យអំណោយអ្នក សូមឱ្យអ្នកធ្វើអ្វីមួយដែលមិនសមរម្យ ឬគ្មានសុវត្ថិភាព? តើអ្នកគួរធ្វើតាមអ្វីដែលបានសូមនោះដែរឬទេ ?
- ឧបមាថាមនុស្សម្នាក់បានឱ្យអំណោយអ្នក ហើយសូមឱ្យអ្នកទៅហូបអីខាងក្រៅជាមួយគាត់ តើអ្នកព្រមទៅជាមួយគាត់ដែរឬទេ ?
- តើអ្នកអាចនិយាយថា"ទេ" បានដែរឬទេ ? *(ពិតជាបាន! វាជាការសមរម្យក្នុងការនិយាយថា"ទេ" ។ នៅពេលអ្នកទទួលអំណោយ អ្នកត្រូវបានរំពឹងឱ្យធ្វើត្រឹមអ្វីដែលម្តាយឪពុករបស់អ្នកបានបង្រៀនដល់អ្នក ដូចជានិយាយថាអរគុណ ឬសម្តែងភាពរីករាយ។ បើអ្នកត្រូវបានរំពឹងឱ្យធ្វើលើសពីនេះ អំណោយនោះអាចហៅបានថា "**សំណូក**")*។ វាសមស្របក្នុងការនិយាយថា "ទេ" ចំពោះការទទួលអំណោយបែប នេះ។

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

សូមរំលឹកឡើងវិញពីសារគន្លឹះមុនពេលបន្តទៅប្រធានបទបន្ទាប់។

| | |
|---|---|
| **ការសង្កេត** | • តើកុមារដឹងថាមានភាពខុសគ្នារវាងអំណោយ និងសំណូកដែរឬទេ ? ✔ |

# ប្រធានបទទី៥- ទេ ទៅ ប្រាប់ អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

| | |
|---|---|
| **សង្ខេប** | ប្រធានបទនេះផ្ដល់ឱ្យកុមារនូវឱកាសអនុវត្តយុទ្ធសាស្ត្រ "ទេ" "**ទៅ**" និង "**ប្រាប់**"។ ជារឿយៗ គេពិបាកនឹងប្រើប្រាស់យុទ្ធសាស្ត្រ "ទេ" "**ទៅ**" និង **ប្រាប់** ពិសេសពេលស្ថិតក្នុងស្ថានភាពប្រឈមខ្លាំងនឹងការរំលោភបំពាន ឬពេលកំពុងស្ថិតក្នុងការរំលោភបំពានជាក់ស្តែង។ វាជាការសំខាន់ ដែលយុទ្ធសាស្ត្រទាំងនេះត្រូវបានអនុវត្ត និងរំលឹកឡើងវិញឱ្យញឹកញាប់ ដើម្បីឱ្យពួកវាក្លាយទៅជាការឆ្លើយតប "ស្វ័យប្រវត្តិ"នៅក្នុងស្ថានភាពតានតឹងខ្លាំង។ |
| **សារសំខាន់ៗ** | • ប្រសិនបើខ្ញុំមានអារម្មណ៍ថារងការគំរាម ឬគ្មានសុវត្ថិភាព ខ្ញុំគួរនិយាយថា "ទេ" បើខ្ញុំអាច ហើយ"**ទៅ**" បើខ្ញុំអាច និង "**ប្រាប់**" មនុស្សពេញវ័យដែលខ្ញុំទុកចិត្តពីអារម្មណ៍របស់ខ្ញុំ និងស្ថានភាពដែលខ្ញុំបានជួប។ |
| **សម្ភារ** | • ប៊ិចហ្វឺត និងក្រដាសផ្ទាំងធំ<br>• សម្ភារសម្រាប់ធ្វើបដា ដូចជាប័ណ្ណ ថ្នាំពណ៌ *(តាមជម្រើស)*<br>• **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន** |

## ការណែនាំ

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពិភាក្សាពីយុទ្ធសាស្ត្រ "ទេ" "ទៅ" "ប្រាប់" *(ផ្អែកលើយុទ្ធសាស្ត្រ "ទេ" "ទៅ" "ប្រាប់ " ក្នុង **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន**។)*




- "ទេ" ៖ ប្រសិនបើនរណាម្នាក់ធ្វើសកម្មភាពណាមួយ ដែលមិនគោរពសិទ្ធិទទួលបានសុវត្ថិភាព និងមិនគោរពចំពោះរាងកាយរបស់អ្នក អ្នកអាចនិយាយថា *"ទេ" "ឈប់ធ្វើបែបនេះភ្លាម" "អ្នកមិនគួរធ្វើបែបនេះទេ" "ខ្ញុំមិនចង់ឱ្យអ្នកធ្វើបែបនេះទេ"*។
- "ទៅ" ៖ បើអ្នកអាចអ្នកគប្បី "ទៅ" ពីស្ថានភាពនោះ ឬរៀបផែនការពីរបៀប ដែលអ្នកអាច"ទៅ" ពីស្ថានភាពនោះ។ អ្នកគប្បីទៅកាន់ទីកន្លែងគួរទុកចិត្ត ឬទៅរកមនុស្សពេញវ័យដែលអ្នកទុកចិត្ត។
- "ប្រាប់" ៖ ប្រសិនបើអ្នកត្រូវបានធ្វើបាប ឬនៅតែមានអារម្មណ៍ថាគ្មានសុវត្ថិភាព អ្នកគប្បី "ប្រាប់" ដល់មនុស្សពេញវ័យដែលអ្នកទុកចិត្តបានជានិច្ច ពីស្ថានភាពនោះ។ ការប្រាប់ភ្លាមៗ អាចជួយឱ្យការប្រាប់នោះមានលក្ខណៈងាយស្រួល និងអាចកាត់បន្ថយគ្រោះថ្នាក់ពីស្ថានភាពមិនគួរទុកចិត្ត។

### សកម្មភាព

សូមធ្វើការជាក្រុម រំលឹក ឬទន្ទេញពីយុទ្ធសាស្ត្រនេះម្តងហើយម្តងទៀតដើម្បីឱ្យចាំ។ កុមារអាចប្រើមេដៃចង្អុល និងដៃកណ្តាលដើម្បីជួយចំណាំពាក្យទាំងបីនេះ ដោយម្រាមដៃមួយតំណាងឱ្យពាក្យមួយ។

### សកម្មភាព

សូមឱ្យកុមារចាប់ដៃគូ និងដើរតួម្តងម្នាក់ក្នុងការឆ្លើយតបថា "ទេ"  និង "ទៅ"  ប្រកបដោយភាពម៉ឺងម៉ាត់ និងច្បាស់លាស់ ចំពោះស្ថានភាពដែលអ្នកសម្របសម្រួលអាន។ សូមឱ្យកុមារម្នាក់ៗឆ្លើយតបរួច "ទៅ"  ពីដៃគូរបស់ពួកគេដោយម៉ឺងម៉ាត់ និងប្រកបដោយការជឿជាក់។ បន្ទាប់ពីកុមារម្នាក់ដើរតួក្នុងការឆ្លើយតបរួចមក កុមារម្នាក់ទៀតផ្តល់ព័ត៌មានត្រឡប់ ចំពោះរបៀបដែលកុមារនោះ"សម្តែងទឹកមុខ" និង"បញ្ចេញសម្លេង" និង "កាយវិការ"ក៏ដូចជាពាក្យសម្តីដែលធ្វើបានល្អ ។ ព័ត៌មានត្រឡប់គប្បីមានលក្ខណៈជាក់លាក់ ឧទាហរណ៍ "អ្នកឈរត្រង់ខ្លួន និងមើលទៅម៉ឺងម៉ាត់" "ពេលអ្នកនិយាយឃើត ធ្វើឱ្យសម្លេងរបស់អ្នកស្តាប់ទៅម៉ឺងម៉ាត់ល្អ" ជាជាងគ្រាន់តែនិយាយថា "ល្អ!" ឬ "ធ្វើបានល្អ!"។

ស្ថានភាពដែលស្នើឡើង ៖

- អ្នកថែទាំរបស់អ្នកចង់ឱ្យអ្នកមកលេងជាមួយគាត់នៅសួនឧទ្យាន។ មេឃចាប់ផ្តើមងងឹត ហើយអ្នកមានអារម្មណ៍ថាគ្មានសុវត្ថិភាពក្នុងការទៅសួននោះទេ។
- មនុស្សម្នាក់ចង់ឱ្យអ្នករក្សារឿងសម្ងាត់ដែលអ្នកមានអារម្មណ៍មិនស្រួលក្នុងចិត្តចំពោះរឿងនោះ។
- មិត្តម្នាក់កំពុងដាក់សម្ពាធឱ្យអ្នកលួចហ្គេមពីហាងលក់កាសែតវីដេអូមួយ។
- មិត្តល្អរបស់អ្នកចង់ចម្លងកិច្ចការសាលារបស់អ្នក ហើយអ្នកយល់ថាការធ្វើបែបនេះមិនត្រឹមត្រូវទេ ។
- ពូរបស់អ្នកទាមទារឱ្យអ្នកទៅលេងនៅខាងក្រៅជាមួយបងជីដូនមួយអ្នក។ បងជីដូនមួយរបស់អ្នក តែងតែសើចចំអកឱ្យអ្នក និងលេងដោយប្រើហិង្សាដាក់អ្នកនៅពេលអ្នក នៅតែឯង។
- អ្នកជិតខាងរបស់អ្នកចង់ឌុបអ្នកជិះម៉ូតូដើរលេង។ គាត់តែងតែជិះលឿនណាស់ ហើយអ្នកភ័យខ្លាចថា គាត់អាចមានគ្រោះថ្នាក់ចរាចរណ៍។

### សកម្មភាព ( តាមជម្រើស )

សូមឱ្យកុមារបង្កើតបដាសម្រាប់យុទ្ធសាស្រ្តនីមួយៗ ( "ទេ"  "ទៅ"  "ប្រាប់" )

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកឡើងវិញពីសារគន្លឹះមុនពេលបន្តទៅប្រធានបទបន្ទាប់។

---

## ការសង្កេត

- តើកុមារអាចសម្គាល់បាននូវឥរិយាបថ និងស្ថានភាពដែលអាចផ្តល់ការគំរាមដែរឬទេ ? ✓
- តើកុមារអាចកំណត់បាននូវយុទ្ធសាស្រ្តសុវត្ថិភាព ( "ទេ"  "ទៅ"  "ប្រាប់"  )ដែលអាចប្រើបានដែរឬទេ ? ✓

# ប្រធានបទទី៦៖ មនុស្សពេញវ័យដែលអាចទុកចិត្តនិងអាចជួយខ្ញុំ អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

### សង្ខេប

ប្រធានបទនេះណែនាំកុមារឱ្យស្គាល់ពីលក្ខណៈសម្បត្តិនៃមនុស្សពេញវ័យដែលអាចទុកចិត្តដែលកុមារអាចនិយាយជាមួយ នៅពេលពួកគេត្រូវការការជួយ ឬពេលមានអារម្មណ៍ថាគ្មានសុវត្ថិភាព។

### សារសំខាន់ៗ

- ខ្ញុំមានក្រុមមនុស្សពេញវ័យដែលខ្ញុំទុកចិត្ត ហើយខ្ញុំជួបជាទៀងទាត់។
- ខ្ញុំអាចទៅរកពួកគាត់ដើម្បីសូមការជួយនិងការគាំទ្រ។ ពួកគាត់អាចជួយការពារខ្ញុំពីការធ្វើបាប ឬការរំលោភបំពាន។
- មនុស្សពេញវ័យទាំងនេះអាចផ្លាស់ប្តូរ (ទៅតាមពេលវេលា)។

### សម្ភារ

- **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន**
- ក្រដាសទំហំ A4 មួយសន្លឹកសម្រាប់កុមារម្នាក់ៗ
- ប៊ិច ឬខ្មៅដៃពណ៌
- ក្រដាសពណ៌មួយដុំ
- កន្ត្រៃសម្រាប់កុមារប្រើរួមគ្នា
- ស្កុត ឬដ័របិទសម្រាប់កុមារប្រើរួមគ្នា

### ការណែនាំ

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

សូមពិភាក្សាពីលក្ខណៈសម្បត្តិនៃពាក្យថាមនុស្សពេញវ័យដែលគួរទុកចិត្ត។ (*មនុស្សពេញវ័យដែលគួរទុកចិត្ត គឺជាមនុស្សពេញវ័យដែលយើងជួប ឬនិយាយជាមួយទៀងទាត់ យើងជឿទុកចិត្ត និងជាមនុស្សដែលស្តាប់យើងនិយាយ ពីព្រោះពួកគាត់យកចិត្តទុកដាក់ចំពោះយើង។ ពួកគាត់ក៏គួរជាជនដែលស្ថិតក្នុងតួនាទីដែលអាចជួយយើងបាន*)។ យើងចាំបាច់ត្រូវកំណត់ឱ្យច្បាស់ថា មនុស្សពេញវ័យដែលគួរទុកចិត្ត គឺខុសពីកុមារដែលគួរទុកចិត្ត ដើម្បីកុំឱ្យយើងដាក់កុមារដទៃ ទៅក្នុងស្ថានភាពដែលគ្មានសុវត្ថិភាព។ ឧទាហរណ៍ មនុស្សពេញវ័យមានមាឌធំនិងមានកម្លាំងខ្លាំងជាង និងអាចជួយយើងនៅក្នុងស្ថានភាពខ្លះដែលកុមារដទៃមិនអាចជួយយើងបាន។

**សកម្មភាព**

១. សូមឱ្យកុមារម្នាក់ៗរាយនាមរាល់មនុស្សពេញវ័យ ដែលគេអាចនិយាយរឿងប្រាប់នៅពេលគេព្រួយបារម្ភអំពីរឿងអ្វីមួយ។

២. សូមឱ្យកុមារគូសសញ្ញា √ នៅពីលើឈ្មោះមនុស្សពេញវ័យ ដែលបំពេញតាមលក្ខខណ្ឌដូចតទៅ ៖

- តើមនុស្សពេញវ័យមួយណាក្នុងឈ្មោះខាងលើដែលជាអ្នកពូកែស្តាប់អ្នកនិយាយ? (គូសសញ្ញា √)
- ប្រសិនបើអ្នកប្រាប់មនុស្សពេញវ័យក្នុងឈ្មោះខាងលើអំពីបញ្ហាអ្វីមួយ តើអ្នកជឿថាគាត់ជឿអ្នកដែរឬទេ ? (គូសសញ្ញា √)

- តើអ្នកយល់ថា គាត់នឹងជួយអ្នកដែរឬទេ នៅពេលដែលអ្នកត្រូវការ?(គូសសញ្ញា √)
- តើអ្នកងាយស្រួលទាក់ទងគាត់ដែរឬទេ ? (គូសសញ្ញា √)

៣. សូមឱ្យកុមារជ្រើសរើសមនុស្សពេញវ័យ៥នាក់ដែលទទួលបានសញ្ញា √ ច្រើនជាងគេ រួចគូររូបភាពតំណាង ឧទាហរណ៍៖

- គូររូបប៉េងប៉ោង៥។ សរសេរឈ្មោះមនុស្សពេញវ័យម្នាក់ ដែលអ្នកអាចប្រាប់ពីបញ្ហារបស់ អ្នកបាននៅក្នុងប៉េងប៉ោងនីមួយៗ។
- កាត់រូបកញ្ចុំផ្កាក្រដាស។ កាត់ចន្លោះនៅចំណុចកណ្តាលកញ្ចុំផ្កាហើយសរសេរឈ្មោះ របស់អ្នក។កាត់ស្លឹកជាប់ត្របកផ្កាចំនួន៥ ហើយសរសេរឈ្មោះមនុស្សពេញវ័យម្នាក់ដែលអ្នកអាចប្រាប់ពីបញ្ហារបស់អ្នកបាននៅលើ ស្លឹកនីមួយៗ។
- គូររូបបាតដៃរបស់អ្នក។ សរសេរឈ្មោះមនុស្សពេញវ័យប្រាំនាក់ ដែលអ្នកអាចប្រាប់ពីបញ្ហារបស់អ្នកបាន នៅលើម្រាមដៃនីមួយៗ។ (**ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន** ត្រូវបានបោះពុម្ព ដើម្បីកុមារអាចសសេរមនុស្សពេញវ័យចំនួនប្រាំនាក់នោះ)។




៤. សូមឱ្យកុមារសរសេរលម្អិតពីមនុស្សពេញវ័យម្នាក់ៗ ឧទាហរណ៍ ឈ្មោះរបស់គាត់ ទំនាក់ទំនង (ឧ.ជាមិត្តភក្តិ និងអ្នកជិតខាងខ្ញុំ) អាសយដ្ឋាន និងលេខទូរស័ព្ទ។

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកប្រាប់កុមារថា ដោយសារទំនាក់ទំនងតែងតែផ្លាស់ប្តូរ នោះមនុស្សពេញវ័យដែលគួរទុកចិត្តរបស់យើងក៏អាចផ្លាស់ប្តូរបានដែរ។ ជួនកាល ជាការសំខាន់ដែលត្រូវលុបឈ្មោះមនុស្សណាម្នាក់ ចេញពីបញ្ជីរាយនាមឈ្មោះមនុស្សពេញវ័យដែលគួរទុកចិត្តរបស់អ្នក ហើយថែមឈ្មោះថ្មីជំនួសវិញ (ឧ.គាត់អាចប្តូរទៅរស់នៅកន្លែងផ្សេង គាត់លែងសូវស្តាប់អ្នកនិយាយ ឬមិនជឿអ្នកនៅពេលអ្នកព្យាយាមប្រាប់គាត់ពីរឿងអ្វីមួយ ឬធ្វើឱ្យអ្នកអាក់អន់ចិត្ត ឬគាត់អាចរវល់ខ្លាំង។ ប្រសិនបើមនុស្សនៅក្នុងបញ្ជីនោះធ្វើមិនសមរម្យដាក់ ឬក៏មិនគោរពសិទ្ធិអ្នក នោះការទុកឈ្មោះគាត់នៅក្នុងបញ្ជីឈ្មោះនេះ មិនអាចរក្សាសុវត្ថិភាពរបស់អ្នកបានទេ)។

## សកម្មភាព (តាមជម្រើស)

សូមប្រាប់កុមារថា ជួនកាលអាចជាការលំបាកក្នុងការនិយាយប្រាប់មនុស្សពេញវ័យ (បើទោះបីជាគាត់ស្ថិតក្នុងបញ្ជីឈ្មោះរបស់អ្នកក៏ដោយ) ពីបញ្ហា ឬបទពិសោធន៍ដែលគ្មានសុវត្ថិភាព ឬមិនសមរម្យ។ នៅក្នុងក្រុមតូចៗ សូមឲ្យកុមារកត់ត្រាពីរបៀប ដើម្បីប្រាប់មនុស្សពេញវ័យពីបញ្ហាមួយ។ កុមារអាចកត់ត្រាពីអ្វីដែលពួកគេអាចនិយាយ។ ឧទាហរណ៍ *"លោកពូ តើខ្ញុំអាចសួរពូបានទេ? ម៉ែ កូនគិតថាកូនមានបញ្ហាមួយ...."*។ *"អ្នកមីង តើអ្នកមីងអាចជួយខ្ញុំបានទេ? ខ្ញុំមិនយល់ពី..."*។

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

សូមរំលឹកឡើងវិញពីសារគន្លឹះមុនពេលបន្តទៅប្រធានបទបន្ទាប់។

| | |
|---|---|
| **ការសង្កេត** | • តើកុមារអាចកំណត់បានមនុស្សពេញវ័យដែលគួរឱ្យទុកចិត្តចំនួន៥នាក់ ដែលពួកគេអាចសូមដំបូន្មាន និងការគាំទ្រដែរឬទេ ? ✔ |

# ប្រធានបទទី៧៖ ទេ ទៅ - យុទ្ធសាស្ត្រផ្សេងទៀត (តាមជម្រើស) អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

## សង្ខេប

នេះជាប្រធានបទតាមជម្រើសមួយបើសិនមានពេលវេលាគ្រប់គ្រាន់។ បើសិនជាវគ្គត្រូវបានបណ្តុះបណ្តាលជាច្រើនថ្ងៃ ឬសប្តាហ៍)។ វារៀបរាប់បន្ថែមលើប្រធានបទពីមុន និងផ្តល់នូវយុទ្ធសាស្ត្រផ្សេងទៀតសម្រាប់កុមារដើម្បីរក្សាសុវត្ថិភាព។

## សារសំខាន់ៗ

- វាជាការលំបាកក្នុងការនិយាយថា "ទេ" ។ ខ្ញុំអាចប្រើប្រាស់វិធីផ្សេងទៀតដើម្បីជួយរក្សាសុវត្ថិភាពខ្លួនឯង។

## សម្ភារ

- ថតចម្លងនៃ **ឧបសម្ព័ន្ធទី៨ ៖ ក្រដាសវាយតម្លៃខ្លួនឯង** សម្រាប់កុមារម្នាក់ៗ

## ការណែនាំ

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ថា ៖ *ជួនកាលជនណាម្នាក់អាចធ្វើសកម្មភាពដែលមិនគោរពដល់សិទ្ធិកុមារ។ នេះមិនមែនជាការសមរម្យទេ ។ វាជាការសមរម្យសម្រាប់កុមារក្នុងការមានការជឿជាក់ នឹងការនិយាយថា "ទេ" ឬ "ទៅ" ពីស្ថានភាព ដែលសិទ្ធិរបស់ពួកគេមិនត្រូវបានគោរព។ ប៉ុន្តែ ជួនកាលវាអាចជាការលំបាកដើម្បីនិយាយពីរឺធី ថា "ទេ" និង "ទៅ" ។*

### សកម្មភាព

សូមចែកឯកសារថតចម្លងនៃក្រដាសវាយតម្លៃខ្លួនឯង (**ឧបសម្ព័ន្ធទី៨**) មួយច្បាប់សម្រាប់កុមារម្នាក់ៗ។ អ្នកសម្របសម្រួលគប្បីសួរសំណួរ និងសូមឱ្យកុមារឆ្លើយតប ដោយផាត់ពណ៌លើ ជម្រើសដែលសក្តិសមបំផុតសម្រាប់ពណ៌នាពីអារម្មណ៍របស់ពួកគេ ចំពោះការជឿជាក់លើខ្លួនឯងក្នុងការឆ្លើយថា "ទេ" និង "ទៅ" ពីស្ថានភាពគ្មានសុវត្ថិភាព។ សូមឱ្យកុមារកត់ត្រានូវមូលហេតុមួយចំនួន ដែលធ្វើឱ្យពួកគេលំបាកក្នុងការនិយាយថា "ទេ" ប្រកបដោយការជឿជាក់ *(ឧ. ធ្វើឱ្យអ្នកដទៃខឹងអ្នក ហាក់ដូចជាមិនសុភាព ឬមិនចេះគោរពអ្នកដទៃ ម្តាយឪពុកស្តីបន្ទោសដោយសារការប្រព្រឹត្តបែបនេះ)*។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមទទួលស្គាល់ថា វាអាចជាការលំបាកខ្លាំងក្នុងការនិយាយថា"ទេ" ជាពិសេស ប្រសិនបើអ្នកដទៃគឺជាមនុស្សពេញវ័យដែលអ្នក ឬគ្រួសារអ្នកមានទំនាក់ទំនងជិតស្និទ្ធជាមួយ។ ជួនកាល ក្នុងស្ថានភាពដែលអ្នកមានអារម្មណ៍ថាគ្មានសុវត្ថិភាព និង ច្របូកច្របល់ អ្នកអាចគ្មានលទ្ធភាពនិយាយថា "ទេ" ប្រកបដោយការជឿជាក់ឡើយ។ អ្នកត្រូវប្រើការវិនិច្ឆ័យដោយខ្លួនឯង ថាតើអ្វីជាសកម្មភាពល្អបំផុតដែលអ្នកអាចធ្វើបាន។ ឧទាហរណ៍ ប្រសិនបើអ្នកមិនអាចនិយាយថា "ទេ" ប្រកបដោយការជឿជាក់ទេ យុទ្ធសាស្ត្រល្អមួយទៀតគឺត្រូវប្រើលេស និងបន្តនិយាយដដែល ដើម្បីអាចឱ្យអ្នកអាច "ទៅ" *(ឧ. "ខ្ញុំត្រូវទៅផ្ទះហើយ")*។

ជាការសំខាន់ ដែលត្រូវធ្វើវាប្រកបដោយការជឿជាក់ បើទោះជាអ្នកកំពុងមានអារម្មណ៍ប្រេះប្រួលក្រប៉ូក

ច្របល់ ឬភ័យខ្លាចក៏ដោយ។ មិនត្រូវស្តីបន្ទោសឱ្យខ្លួនឯងចំពោះស្ថានភាពដែលកើតឡើង ព្រោះអ្នកមិនមែនជាអ្នកទទួលខុសត្រូវចំពោះអ្នកដទៃផ្សេងទៀតដែលធ្វើឱ្យអ្នកឈឺចាប់ ឬធ្វើឱ្យអ្នកមានអារម្មណ៍ថាមិនគួរទុកចិត្តនោះទេ។

## ការសង្កេត

- តើកុមារអាចសម្គាល់បានពីស្ថានភាពដែលការនិយាយថា "ទេ"  មិនមែនជាសកម្មភាពដែលអាចរក្សាសុវត្ថិភាពដែរឬទេ ? ✔
- តើសិក្ខាកាមអាចកំណត់បានពីរបៀបដែលពួកគេអាចការពារខ្លួនឯងពីការធ្វើបាបដែរឬទេ ? ✔

# ប្រធានបទទី៨៖ រឿងសម្ងាត់ អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

## សង្ខេប

ការរំលោភបំពានលើកុមារកម្រកើតឡើង "តែម្តងហើយចប់" ណាស់។សកម្មភាពនេះច្រើនតែបន្តអស់រយៈពេលជាច្រើនខែឆ្នាំ។ អ្នករំលោភបំពានពឹងផ្អែកលើការលាក់រឿងសម្ងាត់ដើម្បីបន្តការរំលោភបំពាន។ ប្រធានបទនេះបង្រៀនកុមារឱ្យចេះបែងចែករវាងរឿងសម្ងាត់ "រីករាយ" និង "មិនរីករាយ" ហើយជានិច្ចកាលត្រូវប្រាប់អំពីរឿងសម្ងាត់ "មិនរីករាយ" នោះ។

## សារសំខាន់ៗ

- ប្រសិនបើមានរឿងសម្ងាត់ណាមួយ ដែលធ្វើឱ្យខ្ញុំមានអារម្មណ៍មិនសប្បាយចិត្ត ឬមិនមានសុវត្ថិភាព ខ្ញុំគួរប្រាប់រឿងនេះទៅដល់មនុស្សធំដែលមានសុវត្ថិភាពណាម្នាក់។
- រឿងសម្ងាត់នៅតែជារឿងសម្ងាត់ប្រសិនបើខ្ញុំប្រាប់ដល់មនុស្សធំដែលខ្ញុំទុកចិត្ត។

## សម្ភារ

- ហ្វឺត/ដីស និងក្រដាសផ្ទាំងធំ ឬក្តារខៀនសរសេរដីស
- សំណៅ **ឧបសម្ព័ន្ធទី៩៖ កាតរឿងសម្ងាត់** សម្រាប់ក្រុមតូចនីមួយៗ

## ការណែនាំ

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមឱ្យកុមារពន្យល់ថាតើរឿងសម្ងាត់រីករាយគឺអ្វី។ ប្រមូលគំនិត ហើយសរសេររឿងសម្ងាត់រីករាយទាំងនោះ (ឧទាហរណ៍ ពិធីជប់លៀងធ្វើឱ្យភ្ញាក់ផ្អើល ឬកាដូធ្វើឱ្យភ្ញាក់ផ្អើល ព័ត៌មានពិសេស ភ្ញៀវដែលមកដោយមិនបានប្រាប់ នំដែលមិនបានរំពឹងទុក ឬផ្កាមួយបាច់ជាដើម)។

សូមពន្យល់ថា ពេលខ្លះការរក្សារឿងសម្ងាត់អាចនាំឱ្យមានអារម្មណ៍មិនល្អឬមិនមានសុវត្ថិភាព។ មានរឿងសម្ងាត់មួយចំនួនដែលមិនមានសុវត្ថិភាពសម្រាប់កុមារ។ សូមពិភាក្សាលើរឿងសម្ងាត់ចំនួនបីប្រភេទដែលមិនមានសុវត្ថិភាព៖

- រឿងសម្ងាត់ពាក់ព័ន្ធជាមួយនឹងការប៉ះពាល់/ស្ទាប ដែលធ្វើឱ្យអ្នកបារម្ភ ឬភ័យខ្លាច
- រឿងសម្ងាត់ដែលពាក់ព័ន្ធជាមួយល្បែង ដែលអាចបង្អាក់វិធានសុវត្ថិភាពរបស់អ្នក ឬអាចធ្វើឱ្យអ្នកណាម្នាក់ឈឺចាប់
- រឿងសម្ងាត់ដែលពាក់ព័ន្ធ ជាមួយអំណោយដែលមនុស្សដទៃឱ្យដល់អ្នក ឬសាគុណដែលពួកគេអាចនឹងធ្វើចំពោះអ្នក កុមារចាំបាច់ត្រូវតែប្រាប់ដល់មនុស្សធំដែលមានសុវត្ថិភាពអំពីរឿងសម្ងាត់ទាំងនេះ។

សូមពន្យល់ប្រាប់ថា សញ្ញាតឿនអាសន្នផ្នែកអារម្មណ៍ ផ្នែករាងកាយ និងសញ្ញាតឿនអាសន្នផ្នែកខាងក្រៅ អាចជួយអ្នកឱ្យសម្គាល់បាននូវរឿងសម្ងាត់ដែលមិនគួររក្សាទុក។

### សកម្មភាព

ប្រាប់អ្នកចូលរួមឱ្យគិតអំពីសញ្ញា ដែលអាចជួយគេក្នុងការសម្គាល់រឿងសម្ងាត ់ទាំងឡាយណា ដែលពួកគេគួរប្រាប់ដល់នរណាម្នាក់ផ្សេងទៀត។ ចងក្រងសញ្ញាទាំងអស់នេះនៅក្នុងបញ្ជីសម្រាប់ក្រុម។ ឧទាហរណ៍៖

អ្នកអាចកត់សម្គាល់ថារឿងសម្ងាត់មួយជារឿងសម្ងាត់ដែលមិនគួររក្សាទុកប្រសិនបើ៖

- អ្នកមានអារម្មណ៍មិនច្បាស់លាស់ ឬអារម្មណ៍របស់អ្នកផ្លាស់ប្ដូរចុះឡើងអំពីរឿងនោះ
- អ្នកមានអារម្មណ៍មិនសប្បាយចិត្ត បារម្ភ មានកំហុស ភ័យខ្លាច ឬមិនមានសុវត្ថិភាពនៅពេលអ្នកគិតអំពីរឿងនោះ
- អ្នកចាំបាច់ត្រូវតែរក្សារឿងសម្ងាត់នោះជារៀងរហូត
- រាងកាយរបស់អ្នកផ្ដល់សញ្ញាតឿនអាសន្នដូចជា មានអារម្មណ៍ថាឈឺ ឆ្អើម ញាប់ញ័រ បេះដូងលោតញាប់ កួរពោះ។ល។
- អ្នកគឺជាមនុស្សតែម្នាក់គត់ដែលដឹងពីរឿងសម្ងាត់នេះ
- រឿងសម្ងាត់នោះធ្វើឱ្យអ្នកឈឺចាប់នៅពេលដែលអ្នកគិត ហើយវាលេចឡើងដដែលៗនៅក្នុងខួរក្បាលរបស់អ្នក
- អ្នកពិតជាចង់ប្រាប់ដល់មនុស្សពេញវ័យដែលអ្នកទុកចិត្តអំពីរឿងនេះ ប៉ុន្តែវាហាក់ដូចជាពិបាកខ្លាំងណាស់
- មាននរណាម្នាក់សូក ឬគំរាមអ្នកឱ្យរក្សារឿងសម្ងាត់នោះ
- អ្នកចាំបាច់ត្រូវតែកុហកដើម្បីរក្សារឿងសម្ងាត់នោះ
- រឿងនោះជារឿងពាក់ព័ន្ធនឹងអ្វីដែលមិនមានសុវត្ថិភាព
- វាជារឿងអំពីអ្វីម្យ៉ាងដែលមិនអាចទទួលយកបាន
- វាជារឿងអំពីការរំលោភបំពាន

### សកម្មភាព (តាមជម្រើស)

ចែកកុមារទៅតាមក្រុម ដែលមានគ្នា ៤នាក់។ ក្រុមនីមួយៗទទួលបានកាតរឿងសម្ងាត់ (**ឧបសម្ព័ន្ធទី៩**) មួយឈុត។ កុមារប្ដូរវេនគ្នាអានកាត ហើយចែកកាតនោះទៅជាពីរក្រុម គឺក្រុម "មានអារម្មណ៍ល្អក្នុងការរក្សា" និង "មានអារម្មណ៍មិនល្អ បើសិនជាអ្នកបន្តលាក់ទុកក្នុងចិត្ត" ។ អ្នកសម្របសម្រួលគួរសរសេរចម្លើយត្រឹមត្រូវនៅលើក្ដារខៀនសរសេរដីស ឬក្រដាសផ្ទាំងធំ ដើម្បីឱ្យក្រុមអាចត្រួតពិនិត្យចម្លើយរបស់ខ្លួនថាត្រូវ ឬខុស។ (មានអារម្មណ៍ល្អក្នុងការរក្សា ១ ២ ៤ ៥ ៦ ធ្វើមានអារម្មណ៍មិនល្អ បើសិនជាអ្នកបន្តលាក់ទុកក្នុងចិត្ត ៣ ៧ ៨)។ ក្រុមតូចៗគួរពិភាក្សាគ្នាថា តើរឿងសម្ងាត់នីមួយៗធ្វើឱ្យពួកគេមានអារម្មណ៍ដូចម្ដេច និងថា តើពួកគេត្រូវការប្រាប់ដល់មនុស្សពេញវ័យដែលគួរទុកចិត្តណាម្នាក់ អំពីរឿងសម្ងាត់នោះឬទេ។ បន្ទាប់មកក្រុមអាចរាយការណ៍ត្រឡប់ទៅកាន់ក្រុមធំទាំងមូលវិញដើម្បីជួយពិភាក្សាគ្នា។

អ្នកសម្របសម្រួលគួរគូសបញ្ជាក់ចំណុចខាងក្រោមនៅក្នុងអំឡុងពេលពិភាក្សា៖

- កាតទី១៖ ទាំងអស់គ្នានឹងដឹងអំពីរឿងទារកនោះឆាប់ៗ។ ពួកគេប្រាកដជានឹងរីករាយព្រមទាំងភ្ញាក់ផ្អើលនៅពេលគេដឹងព័ត៌មាននេះ។
- កាតទី២៖ មនុស្សជាច្រើនដឹងអំពីពិធីជប់លៀងនោះ។ លោកគ្រូប្រាកដជានឹងភ្ញាក់ផ្អើល ហើយរីករាយនៅពេលគាត់ដឹងរឿងនេះ។

- កាតទី៣៖ សេណារីយ៉ូនេះគឺជាការរំលោភបំពានផ្លូវភេទ។ គេបានប្រាប់អ្នកថា មិនត្រូវប្រាប់នរណាម្នាក់ជាដាច់ខាត។ រឿងសម្ងាត់នេះនឹងអាចរំខានដល់អ្នក ឬធ្វើឱ្យមានអារម្មណ៍មិនល្អ បើសិនជាអ្នកបន្តលាក់ទុកក្នុងចិត្ត ហើយអ្នកគួរប្រាប់មនុស្សពេញវ័យដែលគួរទុកចិត្តអំពីរឿងនេះ។ វានឹងនៅតែជារឿងសម្ងាត់ប្រសិនបើអ្នកប្រាប់ដល់មនុស្សពេញវ័យដែលគួរទុកចិត្ត។
- កាតទី៤៖ ស្ត្រីដែលនៅជាប់ផ្ទះរបស់អ្នក ពុំធ្វើឱ្យនរណាម្នាក់មិនសប្បាយចិត្ត ឬធ្វើឱ្យនរណាម្នាក់ឈឺចាប់ ដោយសារគាត់និយាយទៅកាន់ដើមឈើនោះឡើយ។ គ្រួសារទាំងមូលរបស់អ្នកនិយាយអំពីរឿងនេះ។ មិត្តភក្តិរបស់អ្នកប្រហែលជាគិតថា វាគឺជារឿងចម្លែកបន្តិច ប៉ុន្តែពួកគេមិនខ្វល់ចិត្តទេ ប្រសិនបើពួកគេដឹងអំពីទម្លាប់និយាយជាមួយដើមឈើរបស់គាត់។
- កាតទី៥៖ មិត្តភក្តិដែលមានជម្ងឺរបស់អ្នកនឹងទទួលបានកាតនោះនាពេលឆាប់ៗ ហើយគាត់ប្រាកដជាភ្ញាក់ផ្អើល និងរីករាយ។
- កាតទី៦៖ ភេសជ្ជៈដែលលោកតារបស់អ្នកចូលចិត្ត មិនធ្វើឱ្យនរណាម្នាក់ឈឺចាប់ ឬធ្វើឱ្យនរណាម្នាក់មិនសប្បាយចិត្តឡើយ។ គ្រួសារទាំងមូលរបស់អ្នកដឹងអំពីរឿងនេះ។ មនុស្សផ្សេងទៀតប្រហែលជាគិតថានេះជារឿងគួរឱ្យអស់សំណើច ប៉ុន្តែពួកគេច្បាស់ជាមិនខឹង ឬតូចចិត្តឡើយប្រសិនបើពួកគេដឹងរឿងនេះ។
- កាតទី៧៖ សេណារីយ៉ូនេះ គឺជាការរំលោភបំពានផ្នែករាងកាយ។ ប្រសិនបើអ្នកត្រូវបានគេគំរាមមិនឱ្យនិយាយរឿងនេះប្រាប់នរណា រឿងសម្ងាត់នេះនឹងរំខានអ្នក ឬធ្វើឱ្យមានអារម្មណ៍មិនល្អ បើសិនជាអ្នកបន្តលាក់ទុកក្នុងចិត្ត។ អ្នកគួរប្រាប់ដល់មនុស្សពេញវ័យណាម្នាក់ ដែលអ្នកទុកចិត្តអំពីរឿងនោះ ដើម្បីធ្វើឱ្យការរំលោភបំពាននោះអាចត្រូវទប់ស្កាត់បាន។
- កាតទី៨៖ សេណារីយ៉ូនេះគឺជាការរំលោភបំពានផ្លូវភេទ។ អ្នក និងមិត្តភក្តិរបស់អ្នកត្រូវបានគេគំរាមមិនឱ្យនិយាយអំពីគ្រូកីឡារបស់អ្នកប្រាប់ដល់នរណាម្នាក់។ ថ្វីបើមានកុមារច្រើននាក់ពាក់ព័ន្ធក្នុងរឿងសម្ងាត់នេះក្តី ក៏រឿងនេះនៅតែមិនអាចទទួលយកបាន។ វាជាបន្ទុកដែលត្រូវរក្សា។ នរណាម្នាក់គួរប្រាប់ដល់មនុស្សពេញវ័យណាម្នាក់ ដែលអ្នកទុកចិត្តអំពីរឿងនេះ។

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល**

សង្ខេបឡើងវិញនូវសារសំខាន់ៗ មុនពេលបន្តទៅកាន់ប្រធានបទបន្ទាប់ទៀត។

---

## ការសង្កេត

- តើកុមារអាចស្គាល់រឿងសម្ងាត់ដែលគេគួរប្រាប់ដល់មនុស្សពេញវ័យណាម្នាក់ ដែលអ្នកទុកចិត្តឬទេ? ✔

# សន្និដ្ឋាន អាយុ៨-១០ឆ្នាំ

## រយៈពេលអប្បបរមា៖ ២០នាទី

### សង្ខេប

ម៉ោងសរុបសេចក្តីគឺជាឱកាសសម្រាប់រំលឹកឡើងវិញពី សារគន្លឹះ ឆ្លើយនឹងសំណួរ ដែលកុមារអាចមាន និងសុំព័ត៌មានត្រឡប់ពីកុមារ។ ជាការសំខាន់ត្រូវបញ្ចប់វគ្គសិក្សាប្រកបដោយបរិយាកាសរីករាយ។

### សារសំខាន់ៗ

- ខ្ញុំអាចប្រើប្រាស់យុទ្ធសាស្ត្រជាច្រើនដើម្បីជួយការពារខ្លួនខ្ញុំ ប្រសិនបើខ្ញុំមានអារម្មណ៍ថាគ្មានសុវត្ថិភាព ត្រូវបានធ្វើបាប ឬរំលោភបំពាន។

### សម្ភារ

- ឯកសារថតចម្លងនៃ **ឧបសម្ព័ន្ធទី១០៖ ទម្រង់វាយតម្លៃ** សម្រាប់កុមារម្នាក់ៗ

### ការណែនាំ

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមមើលសម្ភារដែលកុមារបានបង្កើត។ សូមពិភាក្សាពីសកម្មភាពដែលកុមារចូលចិត្ត ឬគួរឱ្យចងចាំមួយចំនួន។ លើកទឹកចិត្តឱ្យកុមារចែករំលែកចំណេះដឹងដែលពួកគេឱ្យតម្លៃ ឬចងចាំច្រើនបំផុតពីម៉ោងសិក្សានេះ។

រំលឹកពីយុទ្ធសាស្ត្រសុវត្ថិភាព **ទេ ទៅ ប្រាប់** និងផ្សាភ្ជាប់ទៅនឹងយុទ្ធសាស្ត្រផ្សេងទៀត ដូចជា៖

- ការដឹងពីឈ្មោះត្រឹមត្រូវរបស់ផ្នែកផ្សេងៗនៃរាងកាយរួមបញ្ចូលទាំងប្រដាប់ភេទ
- ការទទួលស្គាល់ និងឆ្លើយតបចំពោះអារម្មណ៍ និងសញ្ញាព្រមានខាងក្នុង
- ការទទួលស្គាល់ និងឆ្លើយតបចំពោះសញ្ញាព្រមានខាងក្រៅ
- ការមានការជឿជាក់លើខ្លួនឯង (ឬធ្វើសកម្មភាពប្រកបដោយការជឿជាក់លើខ្លួនឯង) នៅក្នុងស្ថានភាពគ្មានសុវត្ថិភាព
- ការបង្កើតនិងប្រើប្រាស់បញ្ជីយ៉ាងហោចណាស់ចំនួនមនុស្សពេញវ័យដែលគួរទុកចិត្តចំនួន៥នាក់ដែលខ្ញុំអាចទៅរក ប្រសិនបើខ្ញុំត្រូវការការជួយ និង ពេលមានអារម្មណ៍គ្មានសុវត្ថិភាព។

#### សកម្មភាព

សូមឱ្យសិក្ខាកាមបំពេញ *ទម្រង់វាយតម្លៃ* (**ឧបសម្ព័ន្ធទី១០**)។ ប្រសិនបើពេលវេលាសមស្របសម្រាប់ក្រុមអ្នកសម្របសម្រួលអាចធ្វើកិច្ចពិភាក្សាជាក្រុមចំពោះសំណួរទាំងនោះ និងកត់ត្រានូវចម្លើយរបស់ពួកគេ។

#### សកម្មភាព

សូមប្រើប្រាស់រូបភាពផ្កាដែលមានក្នុង (**ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន**) សូមឱ្យកុមារផាត់ពណ៌ ឬតុបតែង និងសរសេរល្បះដែលចង្អុលបង្ហាញ ពីទិដ្ឋភាពវិជ្ជមាននៃជីវិតរបស់កុមារ ដូចជា *ខ្ញុំពូកែខាង... មនុស្សដែលខ្ញុំស្រឡាញ់បំផុតគឺ... ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាព... អនុស្សាវរីយ៍រីករាយបំផុតរបស់ខ្ញុំគឺ... អ្នកគាំទ្រខ្ញុំខ្លាំងជាងគេគឺ... ចំណុចដែលខ្ញុំចូលចិត្តភូមិខ្ញុំជាងគេគឺ...*។ ម៉្យាងវិញទៀត កុមារអាចគូសរូបភាពអ្វីមួយផ្សេង ដែលមានលក្ខណៈសមស្របទៅតាមវប្បធម៌សង្គមនីមួយៗ (ដូចជារូបផ្ទៃ ឬបាតដៃ)។

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

ថ្លែងអំណរគុណចំពោះកុមារសម្រាប់ការចូលរួមរបស់ពួកគេ និងអនុញ្ញាតឱ្យពួកគេដឹង ពីការលេខទូរស័ព្ទទំនាក់ទំនងក្នុងសហគមន៍ និងសេវាកម្មថ្នាក់ជាតិមួយចំនួន ( ដូចជាបណ្តាញជំនួយកុមារម្ពុជា ) បើសិនជាពួកគេមានសំណួរ ឬចម្ងល់។ កុមារអាចសសេររឿងរ៉ាវទាំងនេះទៅក្នុង **កាតយកតាមខ្លួន ( ឧបសម្ពន្ធ័ទី២ )**។






# កត់ចំណាំ




# អាយុ ១១-១៧ឆ្នាំ

# ប្លង់វគ្គសិក្សាខ្លី អាយុ ១១-១៧ ឆ្នាំ*

## រយៈពេល៖ មួយម៉ោង

### សង្ខេប

ប្លង់វគ្គសិក្សាខ្លីនេះ គូសបញ្ជាក់នូវសារសំខាន់ៗសម្រាប់វគ្គរយៈពេលមួយម៉ោង ក្នុងស្ថានភាពដែលអាចបង្រៀនបានតែមួយដងគត់។ ប្លង់មេរៀននេះគូសបញ្ជាក់នូវសារសំខាន់ៗ និងជម្រុញនូវសកម្មភាព ដែលអ្នកសម្របសម្រួលគួរចាត់ជាអាទិភាព។

### សារសំខាន់ៗ

- កុមារ និងមនុស្សវ័យក្មេងចាំបាច់ ត្រូវទទួលបានការការពារពីការរំលោភបំពាន និងមានសិទ្ធិទទួលបានការការពារសុវត្ថិភាព។
- ការរំលោភបំពានផ្លូវភេទលើកុមារ ជារឿងដែលមិនអាចទទួលយកបានជាដាច់ខាត។ វាពុំមែនជាកំហុសរបស់កុមារ (ឬមនុស្សវ័យក្មេង) នោះ"ទេ" ប្រសិនបើគេទទួលរងការរំលោភបំពានផ្លូវភេទ។ កុមារ/មនុស្សវ័យក្មេង មិនគួរទទួលបានការស្តីបន្ទោសនោះឡើយ។
- ការរំលោភបំពានផ្លូវភេទកុមារអាចរួមមានការប៉ះពាល់ ឬការមិនប៉ះពាល់ទាល់តែសោះ។ ទាំងកុមារី និងកុមារា អាចជាគោលដៅរបស់អ្នករំលោភបំពានផ្លូវភេទកុមារ។ គេមិន អាចកំណត់បានជាមុនថា "អ្នករំលោភបំពាន"ជាមនុស្សប្រភេទណាឡើយ។ ពុំមានក្រុមមនុស្សណាមួយ ដែលត្រូវបានចាត់ទុកថា ជា"អ្នករំលោភបំពាន"នោះឡើយ។ អ្នករំលោភ បំពានអាចជានរណាក៏បាន។
- ខ្ញុំដឹងអំពីប្រតិកម្មផ្នែកអារម្មណ៍ គំនិត និងរាងកាយរបស់ខ្ញុំ និងសញ្ញាតឿនអាសន្នផ្នែកខាងក្រៅដើម្បីវាយតម្លៃថា តើស្ថានភាពនេះមានសុវត្ថិភាព ឬគ្មានសុវត្ថិភាពសម្រាប់ខ្ញុំ។
- បណ្តាញគាំទ្ររបស់ខ្ញុំ គឺជាក្រុមមនុស្សពេញវ័យមួយក្រុម ដែលខ្ញុំស្គាល់ ជួបជាប្រចាំ ហើយខ្ញុំទុកចិត្ត។ ខ្ញុំអាចទៅរកមនុស្សទាំងនេះ ដើម្បីឱ្យជួយ និងគាំទ្រខ្ញុំ។ ពួកគេអាចជួយការពារខ្ញុំពីគ្រោះថ្នាក់ ឬការរំលោភបំពាន។
- ខ្ញុំដឹងថា មានជំនួយសម្រាប់ខ្ញុំនៅក្នុងសហគមន៍ខ្ញុំ ដើម្បីរក្សាខ្ញុំឱ្យមានសុវត្ថិភាពរួចផុតពីការរំលោភបំពានគ្រប់ទម្រង់។

### សម្ភារ

- **ឧបសម្ព័ន្ធទី២៖ ការយកតាមខ្លួន** (អាចបោះពុម្ពកាតទាំងនេះ សម្រាប់អ្នកចូលរួមគ្រប់គ្នា ឬអ្នកសម្របសម្រួលអាចសរសេរដាក់លើក្រដាសផ្ទាំងធំ ឬលើកាត ដើម្បីយកទៅប្រើជាជំនួយក្នុងការមើលឃើញ)
- ក្រដាសផ្ទាំងធំ និងហ្វឺត
- សំណៅ**ឧសម្ព័ន្ធទី១២៖ សន្លឹកកិច្ចការសញ្ញាតឿនអាសន្ន** សម្រាប់អ្នកចូលរួមគ្រប់គ្នា។

### ការណែនាំ

**កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល (៥ នាទី)**

ស្វាគមន៍អ្នកចូលរួមទាំងអស់មកកាន់វគ្គសិក្សា។ ណែនាំខ្លួនឯង និងវិន័យក្រុម ដើម្បីឱ្យកុមារមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការនិយាយ។ ឧទាហរណ៍ គោរពគ្នាទៅវិញទៅមក អនុញ្ញាតឱ្យអ្នកដទៃនិយាយដោយមិនរំខាន ឬចំអក វគ្គសិក្សានឹងរយៈពេល អ្នកចូលរួមអាច និយាយទៅកាន់អ្នកសម្របសម្រួលណាម្នាក់ដាច់ដោយឡែក ប្រសិនបើមានអ្វីម៉្យាងធ្វើឱ្យគេបារម្ភ ឬធ្វើឱ្យគេអាក់អន់ចិត្ត (រួមទាំងអំពីអ្វីម៉្យាងដែលត្រូវបានលើកឡើងក្នុងវគ្គសិក្សានេះផងដែរ)។

* គួរបន្តចែកក្រុមនេះទៅជាក្រុមអាយុ ១១-១៣ ឆ្នាំ និង ១៤-១៧ ឆ្នាំ សម្រាប់ផ្តល់ការបណ្តុះបណ្តាល ប៉ុន្តែអាចប្រើសម្ភារដូចគ្នាបាន។.

សូមពន្យល់ថា៖ *ថ្ងៃនេះយើងនឹងពិភាក្សាអំពីវិធីជាក់ស្តែងមួយចំនួន ដែលយើងអាចរក្សាខ្លួន និងមិត្តភក្តិរបស់យើងឱ្យមានសុវត្ថិភាព។* មុនពេលយើងចាប់ផ្តើម *សូមយើងស្គាល់គ្នាជាមុនសិន។*

### សកម្មភាព ( ៥នាទី )

ជ្រើសរើសល្បែងថាមពលណាមួយពី *ឧបសម្ព័ន្ធទី៣៖ ល្បែងស្វាងអារម្មណ៍ និងកសាងទំនុកចិត្ត។*

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល ( ១៥ នាទី )

សូមសួរទៅអ្នកចូលរួមថា តើពួកគេស្គាល់និយមន័យពាក្យសិទ្ធិឬទេ? *( សិទ្ធិគឺជាអ្វីៗទាំងឡាយដែលកុមារទាំងអស់គួរតែមាន។ ពុំមាន "សំណួរ" ឬ "ប្រហែលជា" អំពីសិទ្ធិនេះឡើយ ពោលគឺកុមារគួរតែមាន របស់ទាំងនេះ )*។ សូមពន្យល់ថា កុមារទាំងអស់មានសិទ្ធិទទួលបានសុវត្ថិភាព ទទួលបានសិទ្ធិគោរពចំពោះរាងកាយខ្លួន មានសិទ្ធិទទួលបានការគោរពចំពោះគំនិត និងអារម្មណ៍ និងមានសិទ្ធិទទួលបានការប្រព្រឹត្តិដោយយុត្តិធម៌ចំពោះខ្លួន។ សួរទៅក្រុមអ្នកចូលរួមថា តើពួកគេអាចប្រាប់ឈ្មោះឯកសារអន្តរជាតិដែល មានចែងអំពីគោលការណ៍ណែនាំពាក់ព័ន្ធនឹងសិទ្ធិកុមារឬទេ *( អនុសញ្ញាអង្គការសហប្រជាជាតិស្តីពី សិទ្ធិកុមារ )* ។ សូមប្រើឯកសារអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលមានលក្ខណៈកុមារមេត្រីនៅក្នុង **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន**។




សូមពន្យល់ប្រាប់ថា ថ្ងៃនេះយើងនឹងផ្តោតការយកចិត្តទុកដាក់លើការការពារកុមារ និងមនុស្សវ័យក្មេង ឱ្យរួចផុតពីការរំលោភបំពាន។ សូមឱ្យអ្នកចូលរួមកំណត់និយមន័យការរំលោភបំពាន *( សកម្មភាពទាំងឡាយណាដែលបង្កគ្រោះថ្នាក់ ឬរបួសដែលពុំមែនជារឿងចៃដន្យនោះ គឺហៅថាការរំលោភបំពាន )*។ សូមសួរទៅអ្នកចូលរួមថា តើហេតុអ្វីបានជាការរំលោភបំពានជារឿង មិនអាចទទួលយកបាន *( វាធ្វើឱ្យមនុស្សឈឺចាប់ វាពុំគោរពសិទ្ធិអ្នកដទៃក្នុងការទទួលបានសុវត្ថិភាព និងការគោរព វាមិនយុត្តិធម៌។ វាបំផ្លាញសហគមន៍មួយដ៏មានសុវត្ថិភាព ព្រោះមនុស្សនៅក្នុងសហគមន៍នោះមានអារម្មណ៍ថាវង្វេងការគំរាមកំហែង )*។

ចែករំលែកនិយមន័យអំពី ទម្រង់ផ្សេងៗ នៃការរំលោភបំពាននៅលើក្រដាសផ្ទាំងធំ ឬស្លាយ។ អ្នកសម្របសម្រួលក៏អាចប្រើឧទាហរណ៍អំពី "តើអ្វីជាការរំលោភបំពានលើកុមារ" នៅក្នុង **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួនបានដែរ។**






## ការរំលោភបំពានផ្លូវកាយ

ការរំលោភបំពានផ្លូវកាយ កើតមាននៅពេលណាមនុស្សម្នាក់បង្ករបួស ឬគំរាមថា នឹងបង្ករបួសដល់កុមារណាម្នាក់ដោយចេតនា។ ឧទាហរណ៍មួយចំនួនដូចជា៖ វាយ ដាល់ អង្រន់ ជាក់ ដុត ប្រាន ធ្វើឱ្យថប់ដង្ហើម សង្កត់/ចង បំពុល ឬកំហិតលើបម្លាស់ទីរបស់កុមារ។

## ការរំលោភបំពានផ្លូវចិត្ត

ការរំលោភបំពានផ្លូវចិត្ត គឺជាសកម្មភាពទាំងឡាយណា ដែលប៉ះពាល់ដល់អារម្មណ៍អស់រយៈពេលយូរ និងធ្ងន់ធ្ងរ។ វាធ្វើឱ្យប៉ះទង្គិចធ្ងន់ធ្ងរ ចំពោះគុណតម្លៃរបស់កុមារ។
ឧទាហរណ៍មួយចំនួនដូចជា៖ ជេរកុមារដោយពាក្យថោកទាប ឬធ្វើឱ្យឈឺចាប់ គំរាមចំអក បំភិតបំភ័យ ឬបំបែកកុមារឱ្យនៅតែឯកឯង។ រាល់ទម្រង់នៃការរំលោភបំពានលើកុមារ សុទ្ធតែមានផលប៉ះពាល់ផ្នែកអារម្មណ៍។

## ការរំលោភបំពានផ្លូវភេទ

ការរំលោភបំពានផ្លូវភេទកើតឡើងនៅពេល ដែលមាននរណាម្នាក់ឱ្យកុមារចូលរួម នៅក្នុងសកម្មភាពផ្លូវភេទ តាមរយៈការប្រើប្រាស់អំណាចរបស់ខ្លួនទៅលើកុមារ ឬការទាញប្រយោជន៍ពីការទុកចិត្តរបស់កុមារ។ ការរំលោភបំពានផ្លូវភេទកុមាររួមមានគ្រប់ទម្រង់នៃអាកប្បកិរិយាផ្លូវភេទ ដែលកុមារមិនត្រូវការ។ ទង្វើនេះអាចរួមមានទាំងការប៉ះពាល់ ឬការ មិន ប៉ះពាល់ទាល់តែសោះក៏បាន។ ឧទាហរណ៍មួយចំនួនដូចជា៖ ការប៉ះពាល់ ការធ្វើរូបភាព/រូបថត/វីដេអូអំពីកុមារដែលមានលក្ខណៈរំលោភបំពាន បង្ខំកុមារឱ្យមើលឬចូលរួមក្នុងសកម្មភាពផ្លូវភេទ ឬបង្ខំកុមារ ឱ្យរួមភេទឬចូលរួមក្នុងសកម្មភាពផ្លូវភេទជាមួយកុមារដទៃ ឬជាមួយមនុស្សពេញវ័យ។ ជារឿយៗ ការរំលោភបំពានផ្លូវភេទ អាចចាប់ផ្តើម ពីទង្វើតូចៗដូចជា កិច្ចសន្ទនាផ្លូវភេទ ដែលមិនសមស្រប និងឈានឡើងបន្តិចម្តងៗ ទៅដល់ការរំលោភបំពាន ដែលប៉ះផ្ទាល់ជាមួយរាងកាយ។

## ការមិនអើពើ

ការមិនយកចិត្តទុកដាក់កន្តើយ គឺជាការខកខានធ្ងន់ធ្ងរ ក្នុងការផ្តល់ឱ្យកុមារនូវការ ថែទាំសំខាន់ៗដែលចាំបាច់។ ឧទាហរណ៍មួយចំនួនដូចជា មិនការពារកុមារពីការប៉ះពាល់ជាមួយគ្រោះថ្នាក់ ឬមិន ផ្តល់ការយកចិត្តទុកដាក់ ផ្នែកវេជ្ជសាស្ត្រ ឬមិនផ្តល់ឱ្យកុមារនូវវត្ថុជាមូលដ្ឋាន ដែលចាំបាច់សម្រាប់ការលូតលាស់ និងការអភិវឌ្ឍន៍ ដូចជាអាហារ ជម្រក ឬការយកចិត្តទុកដាក់ផ្នែកអារម្មណ៍។

### ការពិភាក្សាក្រុម ( ១០ នាទី )

សូមពិភាក្សាលើសំណួរខាងក្រោមនេះជាក្រុម៖

- តើនរណាជាអ្នកធ្វើបាប/រំលោភបំពានកុមារ និងមនុស្សវ័យក្មេង ? ហេតុអ្វី ?
- តើមនុស្សទាំងនេះមានរូបរាង យ៉ាងដូចម្តេច ? *( គោលបំណងចម្បងរបស់សំណួរនេះគឺដើម្បីប្រានចោលរាល់គោលគំនិតដែលមនុស្សវ័យក្មេងអាចនឹងមានស្តីអំពី "អ្នករំលោភបំពាន" និងជួយដល់ក្រុមពិភាក្សាឱ្យឈានទៅដល់សេចក្តីសន្និដ្ឋានថា អ្នករំលោភបំពាន អាចជានរណាម្នាក់ក៏បាន។ អ្នករំលោភបំពានអាចជាអ្នកជិតខាង សាច់ញាតិ អ្នករកស៊ីនៅផ្សារ គ្រូបង្រៀន អ្នកថែទាំ អ្នកដឹកនាំផ្នែកសាសនា។ អ្នករំលោភបំពានក៏អាចជាមនុស្សប្រុស ឬមនុស្សស្រីផងដែរ។ ប្រសិនបើមានស្ថិតិថ្នាក់ជាតិ ឬនិន្នាការណាមួយជាក់ស្តែង នោះជាការល្អក្នុងការចែករំលែកព័ត៌មានទាំងនេះ ដើម្បីឱ្យអ្នកចូលរួមយល់អំពីស្ថានភាពក្នុងប្រទេស )។*
- តើមនុស្សទាំងនេះ មានអាយុប៉ុន្មាន ? *( គោលបំណងនៃសំណួរនេះ គឺដើម្បីជាការពិភាក្សាបន្តទៅលើស្តេរ៉េអូថាយពាក់ព័ន្ធជាមួយនឹងថា តើនរណាជាអ្នករំលោភបំពាន។ សំខាន់ជាងនេះទៅទៀត ចំណុចនេះក៏លើកកម្ពស់ការយល់ដឹងអំពីថាតើក្មេង ឬមនុស្សវ័យក្មេងដទៃទៀតក៏អាចជាអ្នករំលោភបំពានដែរ )។*
- តើនរណាដែលត្រូវការកិច្ចការពារ ពីការរំលោភបំពាន ? *( ប្រសិនបើគ្រប់គ្នាសុទ្ធតែអាចជាគោលដៅសម្រាប់ការរំលោភបំពាននោះ គ្រប់គ្នាចាំបាច់ត្រូវទទួលការការពារ )។*
- តើនរណាដែលមានអារម្មណ៍ថាខ្លួនឯងសក្តិសមនឹងទទួលរងការរំលោភបំពាន ? *( កុមារដែលមានពិការភាព ឬក្មេងស្រី និងក្មេងប្រុសដែលត្រូវបានគេប្រាប់ថាជាមនុស្សគ្មានតម្លៃ ឬអាចជាអ្នកដែលរងការរំលោភបំពានផ្លូវចិត្ត ឬអ្នកដែលត្រូវបានគេប្រាប់ថាជាមនុស្ស "អាក្រក់" ឬដោយសារតែពួកគេធ្លាប់ត្រូវបានរំលោភបំពានពីមុនមក )។*
- តើនរណាដែលអាច មានគំនិតប្រឆាំងនឹងពាក្យដែលថា ពួកគេប្រហែលជាត្រូវការការពារពីការរំលោភបំពាន ? ( កុមារា និងបុរស មនុស្សវ័យក្មេង មនុស្សដែលស្ថិតតួនាទីអំណាច មនុស្សដែលមានរូបភាព ជាមនុស្ស"តឹងរ៉ឹង" មនុស្សដែលជឿថា គេអាចដោះស្រាយរឿងទាំងឡាយដោយខ្លួនឯងបាន )។
- តើហេតុអ្វី បានជាពួកគេត្រូវប្រឆាំង ? ( បុរសអាចមានអារម្មណ៍ថា ទទួលសម្ពាធពីសហគមន៍ និងសង្គម ដែលតម្រូវឱ្យគេត្រូវតែ ជាមនុស្ស "ឯករាជ្យ" "រឹងមាំ" "មិនបង្ហាញភាពទន់ខ្សោយ និងអាចដោះស្រាយអ្វីៗគ្រប់យ៉ាង"។ មនុស្សវ័យក្មេងប្រហែលជាចង់ផ្តល់អំណះអំណាងឱ្យអ្នកដទៃឃើញថា "ពួកគេអាចដោះស្រាយរឿងគ្រប់យ៉ាងបាន"។ មនុស្សស្ថិតក្នុងតួនាទីធំៗ ប្រហែលជាមានអារម្មណ៍ថាពួកគេគួរតែ "អាចគ្រប់គ្រង" លើអ្វីគ្រប់យ៉ាង និងទទួលការគោរពពីមនុស្សគ្រប់គ្នា។ អ្នកទាំងឡាយណាដែលឱ្យតម្លៃលើភាព "តឹងរ៉ឹង" "រឹងមាំ" "គ្មានអ្វីអាចប៉ះពាល់ខ្ញុំបាន" អាចមិនចង់ទទួលស្គាល់ថាពួកគេប្រហែលជាមានភាពងាយរងគ្រោះចំពោះការរំលោភបំពាន ហើយប្រហែលជាត្រូវការគេជួយ។

- *មនុស្សដែលពុំចង់ទាញចំណាប់អារម្មណ៍ចំពោះខ្លួនឯង ឬមិនចង់បង្ករភាពរញ៉េរញ៉ៃ អាចទ្រាំទ្រជាមួយការរំលោភបំពាន ឬជៀសវាងមិនស្វែងរកជំនួយ។)*
- តើលក្ខណៈនេះអាចបង្ករឱ្យមានលទ្ធផលដូចម្ដេចខ្លះ ? *(មនុស្សទាំងនេះ ប្រហែលជាមានភាពងាយរងគ្រោះច្រើនចំពោះការរំលោភបំពានប្រសិនបើពួកគេមិនចាប់អារម្មណ៍ចំពោះរឿងនេះ។ ម៉្យាងទៀត អាចមានការលំបាកសម្រាប់មនុស្សទាំងនេះក្នុងការស្វែងរកជំនួយដោយសារសេម្ពាធ ឬការរំពឹងទុកពីសហគមន៍/សង្គមរបស់ពួកគេ។ ម៉្យាងវិញទៀត អាចមានការលំបាកផងដែរសម្រាប់មនុស្សទាំងនេះ ក្នុងការដោះស្រាយជាមួយការរំលោភបំពាន ព្រោះគេពុំទាន់បានបង្កើតវិធីដើម្បីជជែកអំពីបញ្ហាទាំងនេះ)។*

## សកម្មភាព (១០នាទី)

ពន្យល់ប្រាប់ថាប្រតិកម្មផ្នែករាងកាយ និងអារម្មណ៍ គឺជាសូចនាករដ៏ល្អស្ដីពីស្ថានភាពមិនមានសុវត្ថិភាព។ សូមចែកសំណៅ*សន្លឹកកិច្ចការសញ្ញាគ្រោះអាសន្ន* (**ឧបសម្ព័ន្ធទី១២**) ដល់អ្នកចូលរួមម្នាក់ៗ និងអានអំពីស្ថានភាពទាំងនោះឱ្យឮៗ។ សូមឱ្យអ្នកចូលរួមកំណត់អារម្មណ៍របស់មនុស្សវ័យក្មេងនីមួយៗថា តើពួកគេទំនងជាមានអារម្មណ៍ដូចម្ដេចក្នុងសេណារីយ៉ូនីមួយៗ ហើយសូមឱ្យគេកត់ត្រាទុកអំពីអារម្មណ៍ទាំងអស់នេះនៅលើសន្លឹកកិច្ចការរបស់ខ្លួន។ សូមពិភាក្សា ជាក្រុមដោយគូសបញ្ជាក់នូវប្រតិកម្មផ្សេងៗជាច្រើន។ សូមគូសបញ្ជាក់ថាអ្នកចូលរួមនីមួយៗ  ចាំបាច់ត្រូវរៀនសូត្រដើម្បីស្វែងយល់ប្រតិកម្មរបស់ខ្លួនផ្ទាល់ និងបង្កើតជាយុទ្ធសាស្រ្តផ្ទាល់ខ្លួន  ដើម្បីវាយតម្លៃថាតើខ្លួនឯងមានសុវត្ថិភាពឬទេ ។

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល (៥ នាទី)

សូមពន្យល់ពាក្យ "បណ្ដាញគាំទ្រ"។ បណ្ដាញគាំទ្រ គឺជាមនុស្សមួយក្រុម ដែលមនុស្ស វ័យក្មេងអាចទៅរកដើម្បីទទួលការគាំទ្រ។ ជារឿយៗមនុស្សវ័យក្មេងអាស្រ័យច្រើន លើមិត្តភក្តិក្នុងក្រុមរបស់គេដើម្បីទទួល បានមិត្តភាពនិងការគាំទ្រ។ ទោះបីជាមិត្តភក្តិក្នុងក្រុមរបស់អ្នកជាបណ្ដាញគាំទ្រដ៏សំខាន់ ក៏វាជាការចាំបាច់ ក្នុងការកសាង"បណ្ដាញគាំទ្រ" ដែលមានការចូលរួមពី**មនុស្សពេញវ័យ** ដែលអ្នកទុកចិត្តជឿលើអ្នក និងជាជនដែលនឹងជួយអ្នក ប្រសិនបើអ្នកមាន អារម្មណ៍ថាគ្មានសុវត្ថិភាព។




ប្រាប់អ្នកចូលរួមឱ្យគិត និងសរសេរចេញមកនូវឈ្មោះមនុស្សពេញវ័យ ៥នាក់ដែលអាចគាំទ្រពួកគេ។ *(ប្រសិនបើ**ឧបសម្ព័ន្ធទី២**៖ កាតយកតាមខ្លួនត្រូវបានបោះពុម្ពសម្រាប់អ្នកចូលរួមម្នាក់ៗ ពួកគេអាចសរសេរព័ត៌មានលំអិតលើកាតនោះបាន។)*

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល ( ៥ នាទី )




ប្រសិនបើមានពេល សូមអញ្ជើញអ្នកចូលរួមឱ្យផ្តល់ជាដ្យាក្រាម ឬផែនទីគំនិតជាក្រុមមួយ អំពីប្រភេទសេវាគាំទ្រដែលមាននៅក្នុងសហគមន៍សម្រាប់មនុស្សដែលចាប់អារម្មណ៍ ឬធ្លាប់មានបទពិសោធរងការរំលោភបំពានប្រភេទណាមួយ។

បើពុំនោះទេ សូមប្រាប់ពួកគេឱ្យដឹង អំពីអាស័យដ្ឋានទំនាក់ទំនងដែលមាន ក្នុងសហគមន៍មូលដ្ឋាន និងសេវាថ្នាក់ជាតិទាំងឡាយណា ដែលមាន ( ដូចជាបណ្តាញទូរស័ព្ទជំនួយសម្រាប់កុមារ ជាដើម )

ប្រសិនបើពួកគេមានសំណួរ ឬក្តីបារម្ភណាមួយ។ *( ប្រសិនបើ **ឧបសម្ព័ន្ធទី២៖** កាតយកតាមខ្លួនត្រូវបានបោះពុម្ពសម្រាប់អ្នកចូលរួមម្នាក់ៗ កុមារអាចសរសេរព័ត៌មានលម្អិតនៅលើកាតដែលពាក់ព័ន្ធ។ )*

ថ្លែងអំណរគុណកុមារដែលបានចូលរួម។

# សេចក្ដីផ្ដើម អាយុ ១១-១៧ ឆ្នាំ*

## រយៈពេលអប្បបរមា៖ ១៥នាទី

### សង្ខេប

សេចក្ដីផ្ដើម គប្បីបង្កើតនូវបរិយាកាសប្រកបដោយការជឿទុកចិត្ត ដែលកុមារមានអារម្មណ៍ល្អ និងវិជ្ជមានចំពោះខ្លួនពួកគេ និងសកម្មភាពនានា។ មនុស្សវ័យក្មេង ក៏គប្បីត្រូវបានណែនាំឱ្យស្គាល់ពីគោលគំនិតនៃការការពារកុមារ ការរំលោភបំពានលើកុមារ និងសិទ្ធិកុមារ។

### សារសំខាន់ៗ

- ការរំលោភបំពានផ្លូវភេទ ផ្លូវកាយ និងផ្លូវចិត្ត និងការមិនយកចិត្តទុកដាក់ប៉ះពាល់យ៉ាងខ្លាំងចំពោះការរីកចំរើននិងអភិវឌ្ឍរបស់កុមារនិងមនុស្សវ័យក្មេង ហើយវាអាចជះឥទ្ធិពលដល់ជីវិតនាពេលអនគតរបស់ពួកគេ ។
- កុមារនិងមនុស្សវ័យក្មេងត្រូវការការពារ។ កុមារមានសិទ្ធិក្នុងការទទួលបានសុវត្ថិភាព។

### សម្ភារ

- **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន** (កាតទាំងនេះអាចបោះពុម្ពសម្រាប់អ្នកចូលរួមម្នាក់ ឬបោះពុម្ពដោយអ្នកសម្របសម្រួលនៅលើផ្ទាំងក្រដាសធំ ឬកាតដែលត្រូវបានប្រើជាជំនួយក្នុងការមើលឃើញ)។

### ការណែនាំ

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមស្វាគមន៍អ្នករាល់គ្នា មកកាន់ម៉ោងសិក្សាថ្ងៃនេះ។ សូមណែនាំខ្លួនអ្នក និងវិន័យក្រុម (ដើម្បីឱ្យ កុមារមានអារម្មណ៍ថាគួរទុកចិត្តក្នុងការនិយាយ។ ឧទាហរណ៍ ត្រូវគោរពគ្នាទៅវិញទៅមកទុកឱ្យអ្នកដទៃនិយាយ ដោយមិននិយាយកាត់ ឬសើចចំអក ការកំណត់ពេលវេលាសម្រាប់ថ្នាក់ សិក្សាកិច្ចពិភាក្សាជាក្រុម។ សូមពន្យល់ថា ទីនេះមិនមែនជាកន្លែង សម្រាប់លាតត្រដាងប្រាប់ ពីរឿងផ្ទាល់ខ្លួនទេ ហើយពួកគេអាចនិយាយរឿងនោះ ជាមួយអ្នកសម្របសម្រួលណាម្នាក់ដោយឡែក ប្រសិនបើអ្វីដែលបាននិយាយឡើង ធ្វើឱ្យពួកគេព្រួយបារម្ភ ឬអាក់អន់ចិត្ត ហើយពួកគេមិនចង់ ឬមិនអាចនិយាយចេញ ពេលនៅជាមួយក្រុមទាំងមូល)។ សូមពន្យល់ថា *ថ្ងៃនេះយើងនឹងអនុវត្ត ពីវិធីមួយចំនួនដើម្បីរក្សាសុវត្ថិភាពខ្លួនឯង។មុនពេលយើងចាប់ផ្ដើមតោះយើងណែនាំ ខ្លួនឱ្យស្គាល់គ្នាជាមុនសិន។*

#### សកម្មភាព

សូមជ្រើសរើសសកម្មភាពណែនាំឱ្យស្គាល់គ្នាមួយ ឬច្រើនចេញពី **ឧបសម្ព័ន្ធទី៣៖ ការណែនាំឱ្យស្គាល់គ្នា និងល្បែងបង្កើនទំនុកចិត្ត**។

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមសួរសិក្ខាកាមថា តើពួកគេដឹងពីនិយមន័យនៃពាក្យថា **សិទ្ធិ** ដែរឬទេ។ *(សិទ្ធិគឺជារបស់គ្រប់យ៉ាងដែលកុមារគប្បីមាន។ សិទ្ធិមានន័យថា គ្មាន "សំណួរ" ឬ "ពាក្យថាប្រហែលជា"ស្ដីពីចំណុចទាំងនេះ"ទេ" គឺកុមារគប្បីមានរបស់ទាំងនេះតែម្ដង)*។ សូមពន្យល់ថាកុមារគ្រប់រូបមានសិទ្ធិទទួលបានសុវត្ថិភាព ទទួលបានការគោរពចំពោះរាងកាយ ការគិត និង អារម្មណ៍របស់ពួកគេ និងមានសិទ្ធិទទួលបានការប្រព្រឹត្តចំពោះ ខ្លួនដោយស្មើភាព។

* គួរបន្តចែកក្រុមនេះទៅជាក្រុមអាយុ ១១-១៣ ឆ្នាំ និង ១៤-១៧ ឆ្នាំ សម្រាប់ផ្ដល់ការបណ្ដុះបណ្ដាល ប៉ុន្តែអាចប្រើសម្ភារដូចគ្នាបាន។

សួរក្រុមទាំងមូល ថាតើពួកគេអាចប្រាប់ឈ្មោះឯកសារអន្តរជាតិ ដែលរៀបរាប់ពីគោលការណ៍ណែនាំទាក់ទង នឹងសិទ្ធិកុមារដែរឬទេ *(អនុសញ្ញាអង្គការ សហប្រជាជាតិស្តីពីសិទ្ធិកុមារ)*។ បើសិនជាមានកុមារអាយុច្រើនជាងក្នុងក្រុម អ្នក សម្របសម្រួល ក៏អាចលើកឡើងថាទោះបីជាពួកយើងមិនអាចកំណត់ពួកគេ ឱ្យដូចជា "កុមារ" ពួកគេត្រូវបានចាត់ទុកថា ពួកគេកំពុងស្ថិតនៅដំណាក់កាល កំពុងលូតលាស់ពីកុមារភាព ទៅ មនុស្សពេញវ័យ។ ហេតុនេះហើយបានជានៅក្នុងលក្ខខណ្ឌច្បាប់ គេនៅតែហៅថា "កុមារ" ទោះបីជា ពួកគេមាន មាឌធំក៏ដោយ។

## សកម្មភាព (តាមជម្រើស)

***អាចសិក្សាតាមចំណុច*** នៅក្នុងឯកសារកំណែកុមារមេត្រីដទៃ ទៀតនៃអនុសញ្ញា អង្គការ សហប្រជាជាតិស្តីពីសិទ្ធិ កុមារក្នុង **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន**។




## ការពិភាក្សាក្រុម

សូមពន្យល់ថា ថ្ងៃនេះយើង នឹងផ្តោតលើការការពារកុមារ និងមនុស្សវ័យក្មេង ពីការរំលោភបំពាន។ សូមឱ្យសិក្ខាកាមផ្តល់និយមន័យនៃពាក្យថា ការរំលោភបំពាន *(សកម្មភាព ទាំងឡាយណាដែលបង្កឱ្យឈឺចាប់ ឬ របួសដែលមិនមែនកើតឡើង ដោយចៃដន្យ គេហៅថាការរំលោភបំពាន)*។ *ចូរសួរសិក្ខាកាមថា ហេតុអ្វីបានជាការរំលោភបំពាន គឺជារឿងដែលមិនអាចទទួលយកបាន (វាធ្វើឱ្យអ្នកដទៃឈឺចាប់ វាមិនគោរពសិទ្ធិរបស់អ្នកដទៃ ក្នុងការទទួលបានសុវត្ថិភាព និងការគោរព វាមិនស្មើភាព វាធ្វើឱ្យប៉ះពាល់ ដល់សុវត្ថិភាពក្នុងសហគមន៍ ពីព្រោះប្រជាជនក៏មានអារម្មណ៍ថារងការគំរាម)*។

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកឡើងវិញពីសារគន្លឹះ និងពន្យល់ថា ថ្ងៃនេះយើងនឹងពិភាក្សាពីយុទ្ធសាស្ត្រ ការពារមួយចំនួន ដែលមនុស្សវ័យក្មេងអាចយកទៅប្រើប្រាស់ ដើម្បីរក្សាសុវត្ថិភាពពីការ រំលោភបំពាន។

---

**ការសង្កេត** តើសិក្ខាកាមអាចពណ៌នាបានពីគោលគំនិតនៃការរំលោភបំពានដែរឬទេ? ✔

---

# ប្រធានបទទី ១៖ ការពិតអំពីការរំលោភបំពានកុមារ

# អាយុ ១១-១៧ ឆ្នាំ *

## រយៈពេលអប្បបរមា៖ ៣០នាទី

## សង្ខេប

**ប្រធានបទនេះផ្តល់ឱ្យមនុស្សវ័យក្មេងនូវព័ត៌មាន ស្តីពីការរំលោភបំពាន** និងជាពិសេសគឺ ការរំលោភបំពានផ្លូវភេទលើកុមារ។ វាជួយឱ្យមនុស្សវ័យក្មេងយល់បានថា យើងពុំអាចកំណត់បានជាមុន ថានរណាម្នាក់ជា "អ្នករំលោភបំពាន" បាននោះឡើយ។ ប្រធានបទនេះ តម្រូវឱ្យមានការរៀបចំជាមុន និងការយកចិត្តទុកដាក់ខ្ពស់ចំពោះផលប៉ះពាល់ដែលអាចកើតមាន។

អ្នកសម្របសម្រួលត្រូវដឹងថា លំហាត់ប្រភេទនេះអាចមានផលប៉ះពាល់ចំពោះកុមារ ដែលធ្លាប់ជួបការរំលោភបំពាន ឬជាជនរងគ្រោះពីការរំលោភបំពាន។ ពួកគេប្រហែលជាមិនធ្លាប់បានប្រាប់នរណាម្នាក់ឡើយពីមុនមក ហើយពេលនេះ ពួកគេប្រហែលជាអាចមានភាពតានតឹងចិត្ត ឬនឹកឃើញរឿងចាស់។
នេះគឺជាមូលហេតុដែលចាំបាច់ត្រូវមានប្រព័ន្ធគាំទ្រសម្រាប់កុមារ ដែលរង ផលប៉ះពាល់។ ដូចដែលបានគូសបញ្ជាក់ក្នុង ***ផ្នែកទី១៖ ការចាប់ផ្តើម*** រួចហើយថា អ្នកសម្របសម្រួល ត្រូវត្រៀមខ្លួនរួចជាស្រេច និងដឹងរបៀបឆ្លើយតបជាមួយការបង្ហាញប្រាប់របស់កុមារ ឧទាហរណ៍ អ្នកត្រូវដឹងថាតើត្រូវធ្វើដូចម្តេច ប្រសិនបើកុមារម្នាក់បង្ហាញប្រាប់អ្នកថាបច្ចុប្បន្នគេកំពុងរងគ្រោះថ្នាក់ ហើយត្រូវដឹងរបៀបដើម្បីបន្តជានាសុវត្ថិភាពកុមារនោះ។

## សារសំខាន់ៗ

- ការរំលោភបំពានផ្លូវភេទលើកុមារ ជារឿងដែលមិនអាចទទួលយកបានជាដាច់ខាត។
- វាពុំមែនជាកំហុសរបស់កុមារ (ឬមនុស្សវ័យក្មេង) នោះទេ ប្រសិនបើគេទទួលរងការរំលោភបំពានផ្លូវភេទ។ កុមារ/មនុស្សវ័យក្មេងមិនគួរទទួលការស្តីបន្ទោសនោះឡើយ។
- ការរំលោភបំពានផ្លូវភេទកុមារ អាចរាប់បញ្ចូលទាំងការចាប់ប៉ះពាល់ និងមិនមានការប៉ះពាល់សោះក៏មាន។
- កុមារីនិងកុមារា សុទ្ធតែអាចជាគោលដៅរបស់អ្នករំលោភបំពានផ្លូវភេទកុមារ។
- យើងពុំអាចកំណត់បានជាមុនថានរណាម្នាក់ជា "អ្នករំលោភបំពាន" បាននោះឡើយ។ អ្នករំលោភបំពានអាចជានរណាក៏បាន។

## សម្ភារ

- **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន**
- ក្រដាសផ្ទាំងធំ និងហ្វឺត
- ស្ថិតិថ្នាក់ជាតិ ឬនិន្នាការអំពីការរំលោភបំពានផ្លូវភេទលើកុមារ *(ប្រសិនបើមាន)*

## ការណែនាំ

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សួរទៅកាន់ក្រុមថា តើមនុស្សបង្កការឈឺចាប់ដល់កុមារ/មនុស្សវ័យក្មេងដោយរបៀបណា?
*(ចម្លើយ អាចផ្តើមចេញពីឧទាហរណ៍ពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវកាយ និងពាក្យសម្តីដូចជា ការជេរ ឬវាយដំ ហើយក៏អាចជាការមិនយកចិត្តទុកដាក់ ឬដាក់ការងារឱ្យធ្វើជាដើម។*

* គួរបន្តចែកក្រុមនេះទៅជាក្រុមអាយុ ១១-១៣ ឆ្នាំ និង ១៤-១៨ ឆ្នាំ សម្រាប់ផ្តល់ការបណ្តុះបណ្តាល ប៉ុន្តែអាចប្រើសម្ភារដូចគ្នាបាន។

*អ្នកសម្របសម្រួល ត្រូវបន្តដំណើរការ ដោយប្រើប្រាស់វិធីសាស្ត្របែបសួរសំណួរដើម្បីជម្រុញឱ្យមាន ការពិភាក្សា រហូតទាល់តែមាននរណាម្នាក់លើកឡើងអំពីការរំលោភបំពានផ្លូវភេទ )។ ចែករំលែកនិយមន័យស្តីពីទម្រង់ផ្សេងៗនៃការរំលោភបំពាន នៅលើក្រដាសផ្ទាំងធំ ឬស្លាយ។ អ្នកសម្របសម្រួល ក៏អាចប្រើប្រាស់រូបភាពស្តីពី "តើអ្វីជាការរំលោភបំពានលើកុមារ?"* នៅក្នុង **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន ផងដែរ។**

## ការរំលោភបំពានផ្លូវកាយ

ការរំលោភបំពានផ្លូវកាយ កើតមាននៅពេលណាមនុស្សម្នាក់បង្ករបួស ឬគំរាមថា នឹងបង្ករបួសដល់កុមារណាម្នាក់ដោយចេតនា។ ឧទាហរណ៍មួយចំនួនដូចជា វាយ ដាល់ អង្រន់ ជាក់ ដុត ប្រាន ធ្វើឱ្យថប់ដង្ហើប សង្កត់/ចង បំពុល ឬកំហិតបម្លាស់ទីរបស់កុមារ។

## ការរំលោភបំពានផ្លូវចិត្ត

ការរំលោភបំពានផ្លូវចិត្ត គឺជាការប្រព្រឹត្តអាក្រក់ផ្នែកអារម្មណ៍ ដែលបន្តអស់រយៈពេលយូរ និងធ្ងន់ធ្ងរ។ វាវាយប្រហារដល់ការយល់ឃើញ ចំពោះខ្លួនឯងរបស់កុមារ។ ឧទាហរណ៍មួយចំនួនដូចជា ជេរកុមារដោយពាក្យថោកទាប ឬធ្វើឱ្យឈឺចាប់ គំរាម ចំអក បំភិតបំភ័យ ឬបំបែកកុមារឱ្យនៅតែឯកឯង។ រាល់ទម្រង់នៃការរំលោភបំពានលើកុមារ សុទ្ធតែមានផលប៉ះពាល់ផ្នែកអារម្មណ៍។

## ការរំលោភបំពានផ្លូវភេទ

ការរំលោភបំពានផ្លូវភេទកើតឡើង នៅពេលដែលមាននរណាម្នាក់ ឱ្យកុមារចូលរួមនៅក្នុងសកម្មភាពផ្លូវភេទ តាមរយៈការប្រើប្រាស់អំណាចរបស់ខ្លួនទៅលើកុមារ ឬការទាញប្រយោជន៍ពីការទុកចិត្តរបស់កុមារ។ ការរំលោភបំពានផ្លូវភេទកុមាររួមមាន អាកប្បកិរិយាផ្លូវភេទដែលមិនចង់បានគ្រប់ទម្រង់។ ទង្វើនេះអាចរួមមានទាំងការប៉ះពាល់ ឬការមិនប៉ះពាល់ទាល់តែសោះក៏បាន។ ឧទាហរណ៍មួយចំនួនដូចជា ការប៉ះពាល់ ការធ្វើរូបភាព/រូបថត/វីដេអូអំពីកុមារដែលមានលក្ខណៈរំលោភបំពាន បង្ខំកុមារឱ្យមើល ឬចូលរួមក្នុងសកម្មភាពផ្លូវភេទ ឬបង្ខំកុមារឱ្យរួមភេទ ឬចូលរួមក្នុងសកម្មភាពផ្លូវភេទជាមួយកុមារដទៃ ឬជាមួយមនុស្សធំ។ ជារឿយៗ ការរំលោភបំពានផ្លូវភេទអាចចាប់ផ្តើមពីទង្វើតូចៗដូចជា កិច្ចសន្ទនាផ្លូវភេទដែលមិនសមស្រប និងឈានឡើងបន្តិចម្តងៗទៅដល់ការរំលោភបំពានដែលប៉ះផ្ទាល់ជាមួយរាងកាយ។

## ការមិនអើពើ

ការមិនអើពើគឺជាការខកខានធ្ងន់ធ្ងរក្នុងការផ្តល់ឱ្យកុមារនូវទិដ្ឋភាពសំខាន់ៗនៃការថែទាំ។ ឧទាហរណ៍មួយចំនួន ដូចជា មិនការពារកុមារពីការប៉ះពាល់ជាមួយគ្រោះថ្នាក់ ឬមិនផ្តល់ការយក ចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រ ឬមិនផ្តល់ឱ្យកុមារនូវកត្តាចាំបាច់សម្រាប់ការលូតលាស់ និងការ អភិវឌ្ឍន៍ ដូចជាអាហារ ជម្រក ឬការយកចិត្តទុកដាក់ផ្នែកអារម្មណ៍។

## ការពិភាក្សាក្រុម

សូមពិភាក្សាលើសំណួរខាងក្រោមនេះជាក្រុម៖

- តើនរណាជាអ្នកធ្វើបាប/រំលោភបំពានលើកុមារ និងមនុស្សវ័យក្មេង? ហេតុអ្វី?
- តើមនុស្សទាំងនេះមានរូបរាងយ៉ាងដូចម្តេច? *(គោលបំណងចម្បងរបស់សំណួរនេះ គឺដើម្បីប្រានចោលរាល់ស្តេរ៉េអូថាយដែលមនុស្សវ័យក្មេងអាចនឹងមានស្តីអំពី "អ្នករំលោភបំពាន" និង ជួយដល់ក្រុមឱ្យឈានមកដល់សេចក្តីសន្និដ្ឋានថាអ្នករំលោភបំពានមួយអាចជាអ្នកណាក៏បាន។ អ្នករំលោភបំពានអាចជាអ្នកជិតខាង សាច់ញាតិ អ្នករកស៊ីនៅផ្សារ គ្រូបង្រៀន អ្នកថែទាំ អ្នកដឹកនាំផ្នែកជំនឿ។ អ្នករំលោភបំពានក៏អាចជាមនុស្សប្រុស ឬមនុស្សស្រីផងដែរ។ ប្រសិនបើមានស្ថិតិថ្នាក់ជាតិ ឬនិន្នាការណាមួយជាក់ស្តែង នោះជាការល្អក្នុងការចែករំលែកព័ត៌មានទាំងនេះដើម្បីឱ្យអ្នកចូលរួមយល់អំពីស្ថានភាពក្នុងប្រទេស។ វាក៏មានអត្ថប្រយោជន៍ផងដែរក្នុងការពន្យល់ថា ពេលខ្លះអ្នករំលោភបំពានមិនធ្វើការរំលោភបំពានតែម្នាក់ឯងនោះឡើយ។ ពួកគេអាចប្រើប្រាស់មិត្តភក្តិ ឬភ្នាក់ងារណាម្នាក់ឱ្យមកទំនាក់ទំនងជាមួយកុមារ ឬមនុស្សវ័យក្មេង)។*
- តើមនុស្សទាំងនេះមានអាយុប៉ុន្មាន? *(គោលបំណងនៃសំណួរនេះគឺដើម្បីជាការពិភាក្សាបន្តទៅលើស្តេរ៉េអូថាយពាក់ព័ន្ធនឹងថា តើនរណាជាអ្នករំលោភបំពាន។ សំខាន់ជាងនេះទៅទៀត ចំណុចនេះក៏លើកកម្ពស់ការយល់ដឹងថា កុមារ ឬមនុស្សវ័យក្មេងដទៃទៀត ក៏អាចជាអ្នករំលោភបំពានបានដែរ)។*
- តើនរណា ដែលត្រូវការកិច្ចការពារពីការរំលោភបំពាន? *(ប្រសិនបើគ្រប់គ្នាសុទ្ធតែ អាចជាគោលដៅសម្រាប់ ការរំលោភបំពាននោះ គ្រប់គ្នាចាំបាច់ត្រូវទទួលការការពារ)។*
- តើនរណាដែលមានអារម្មណ៍ថាខ្លួនឯងសក្តិសមនឹងទទួលរងការរំលោភបំពាន? *(កុមារដែលមានពិការភាព ឬកុមារី និងកុមារាដែលត្រូវបានគេប្រាប់ថាជាមនុស្សគ្មាន តម្លៃ ឬអាចជាអ្នកដែលរ ងការរំលោភបំពានផ្លូវចិត្ត ឬអ្នកដែលត្រូវបានគេប្រាប់ថាជាមនុស្ស "អាក្រក់" ឬដោយសារតែពួកគេធ្លាប់ត្រូវបានរំលោភបំពានពីមុនមក)។*
- តើនរណា ដែលអាចមានគំនិតប្រឆាំងនឹងគំនិតដែលថា ពួកគេប្រហែលជាត្រូវការការពារពីការ រំលោភបំពាន? *(កុមារា និងបុរស មនុស្សវ័យក្មេង មនុស្សដែលស្ថិតតួនាទីមានអំណាច មនុស្ស ដែលមានរូបភាពជាមនុស្ស"តឹងរ៉ឹង" មនុស្សដែលជឿថាគេអាចដោះស្រាយរឿងទាំងឡាយដោយខ្លួនឯងបាន)។*
- តើហេតុអ្វី បានជាពួកគេត្រូវប្រឆាំង? *(បុរសអាចមានអារម្មណ៍ថា ទទួលសម្ពាធពីសហគមន៍ និងសង្គម ដែលតម្រូវឱ្យគេត្រូវតែជាមនុស្ស"ឯករាជ្យ" "រឹងមាំ" "មិនបង្ហាញភាពទន់ខ្សោយ និងអាចដោះស្រាយអ្វីៗគ្រប់យ៉ាង"។ មនុស្សវ័យក្មេងប្រហែលជាចង់ផ្តល់អំណះអំណាងឱ្យអ្នកដទៃឃើញថា "ពួកគេអាចដោះស្រាយរឿងគ្រប់យ៉ាងបាន"។ មនុស្សស្ថិតក្នុងតួនាទីធំៗ ប្រហែលជាមានអារម្មណ៍ថាពួកគេគួរតែ "អាចគ្រប់គ្រង" លើអ្វីគ្រប់យ៉ាង និងទទួលការគោរពពីមនុស្សគ្រប់គ្នា។ អ្នកទាំងឡាយណាដែលឱ្យតម្លៃលើភាព "តឹងរ៉ឹង" "រឹងមាំ" "គ្មាន អ្វីអាចប៉ះពាល់ខ្ញុំបាន" អាចមិនចង់ទទួលស្គាល់ថាពួកគេប្រហែលជាមានភាព ងាយរង គ្រោះចំពោះការរំលោភបំពាន ហើយប្រហែលជាត្រូវការគេជួយ។ មនុស្សដែលពុំចង់ទាញ ចំណាប់អារម្មណ៍ចំពោះខ្លួនឯង ឬមិនចង់បង្ករភាពរញ៉េរញ៉ៃ អាចទ្រាំទ្រជាមួយការរំលោភបំពាន ឬជៀសវាងមិនស្វែងរកជំនួយ។)*

- តើលក្ខណៈនេះអាចបង្ករឱ្យមានលទ្ធផលដូចម្ដេចខ្លះ ? *( មនុស្សទាំងនេះ ប្រហែលជាមានភាពងាយរងគ្រោះច្រើនចំពោះការរំលោភបំពានប្រសិនបើពួកគេមិនចាប់អារម្មណ៍ចំពោះរឿងនេះ។ ម្យ៉ាងទៀត អាចមានការលំបាកសម្រាប់មនុស្សទាំងនេះក្នុងការស្វែងរកជំនួយ ដោយសារសម្ពាធ ឬការរំពឹងទុកពីសហគមន៍/សង្គមរបស់ពួកគេ។ ម្យ៉ាងវិញទៀត អាចមានការ លំបាកផងដែរសម្រាប់មនុស្សទាំងនេះ ក្នុងការដោះស្រាយជាមួយការរំលោភបំពាន ព្រោះគេពុំទាន់បានបង្កើតវិធីដើម្បីជជែកអំពីបញ្ហាទាំងនេះ )។*

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សង្ខេបឡើងវិញនូវសារសំខាន់ៗមុននឹងបន្តចូលដល់ប្រធានបទបន្ទាប់។

---

## ការសង្កេត

- តើអ្នកចូលរួមយល់ឬទេថា នរណាក៏អាចប្រព្រឹត្តិការរំលោភបំពានផ្លូវភេទកុមារបានដែរ ( យើងពុំអាចកំណត់បានជាមុនថានរណាម្នាក់ជា “អ្នករំលោភបំពាន” បាននោះឡើយ។ ) ✔
- តើអ្នកចូលរួមយល់ឬទេថា ទាំងកុមារី និងកុមារាសុទ្ធតែមានភាពងាយរងគ្រោះចំពោះការរំលោភបំពានផ្លូវភេទ ? ✔

---

# ប្រធានបទទី២៖ ការកំណត់ និងការជៀសវាងពីស្ថានភាពដែលមិនមានសុវត្ថិភាព

**អាយុ ១១-១៧ ឆ្នាំ***

## រយៈពេលអប្បបរមា៖ ៦០នាទី

### សង្ខេប

ប្រធានបទនេះ លើកទឹកចិត្តឱ្យមនុស្សវ័យក្មេងជឿជាក់លើការវិនិច្ឆ័យរបស់ខ្លួន ហើយប្រើប្រាស់ភាពខ្លាំងរបស់ពួកគេ ដើម្បីកសាងយុទ្ធសាស្ត្រការពារខ្លួនយ៉ាងរឹងមាំ ដែលពួកគេអាចយកទៅប្រើប្រាស់បាននាពេលបច្ចុប្បន្ន និងអនាគត។

### សារសំខាន់ៗ

- ខ្ញុំដឹងពីអារម្មណ៍ គំនិត ប្រតិកម្មផ្នែករាងកាយរបស់ខ្ញុំ និងសញ្ញាតឿនអាសន្នពីខាងក្រៅ ដើម្បីអាចវាយតម្លៃថា តើស្ថានភាពមួយគួរទុកចិត្តចំពោះខ្ញុំឬអត់ ។

### សម្ភារ

- **ឧបសម្ព័ន្ធទី១១៖ សន្លឹកកិច្ចការស្ដីពីការកំណត់អាកប្បកិរិយាមិនសមស្រប** សម្រាប់អ្នកចូលរួមនីមួយៗ
- **ឧបសម្ព័ន្ធទី១២៖ សន្លឹកកិច្ចការស្ដីពីសញ្ញាតឿនអាសន្ន** សម្រាប់អ្នកចូលរួមនីមួយៗ
- ហ្វ៊ីត ប៊ិច និងក្រដាសផ្ទាំងធំ (តាមជម្រើស)
- ម៉ាស៊ីនថតវីដេអូ (តាមជម្រើស)
- ម៉ាស៊ីនថតសម្លេង (តាមជម្រើស)
- **ឧបសម្ព័ន្ធទី១៣៖ កាតវាយតម្លៃស្ថានភាព (តាមជម្រើស)** សម្រាប់ក្រុមតូចនីមួយៗ។

### ការណែនាំ

**សកម្មភាព**

ចែក**ឧបសម្ព័ន្ធទី១១៖** សន្លឹកកិច្ចការស្ដីពីការកំណត់អាកប្បកិរិយាមិនសមស្រប ដល់អ្នកចូលរួមនីមួយៗ ហើយអានសាច់រឿងស្ដីពីស្ថានភាពឮៗ។ សូមឱ្យអ្នកចូលរួមពិភាក្សាលើសំណួរជាមួយដៃគូ ហើយរាយការណ៍ទៅកាន់ក្រុមវិញ។ អ្នកសម្របសម្រួលគួរគូសបញ្ជាក់ថា៖

- កុមារ និងមនុស្សវ័យក្មេងមានសិទ្ធិក្នុងការទទួលបានសុវត្ថិភាព
- កុមារ និងមនុស្សវ័យក្មេងគួរជឿជាក់លើអារម្មណ៍របស់ខ្លួន និងអ្វីដែលពួកគេដឹងអំពីអាកប្បកិរិយាសមរម្យ និងមិនសមរម្យ ដើម្បីធ្វើសម្រេចចិត្តថា តើស្ថានភាពមួយមានការគំរាមកំហែងជាសក្ដានុពលចំពោះសុវត្ថិភាពរបស់ពួកគេឬទេ។

* គួរបន្តចែកក្រុមនេះទៅជាក្រុមអាយុ ១១-១៣ ឆ្នាំ និង ១៤-១៨ ឆ្នាំ សម្រាប់ផ្ដល់ការបណ្ដុះបណ្ដាល ប៉ុន្តែអាចប្រើសម្ភារដូចគ្នាបាន។

## ការពិភាក្សាក្រុម

ពន្យល់ពីប្រតិកម្មផ្នែករាងកាយ និងអារម្មណ៍ដែលជាសូចនាករល្អៗរបស់ស្ថានភាពដែលមិនមានសុវត្ថិភាព។ សូមសួរទៅកាន់អ្នកចូលរួមថា៖

- តើរាងកាយរបស់អ្នកមានប្រតិកម្មយ៉ាងដូចម្តេច នៅពេលដែលអ្នកស្ថិតនៅក្នុងស្ថានភាពមួយដែលអាចមើលឃើញយ៉ាងជាក់ច្បាស់ថាមិនមានសុវត្ថិភាព *(ឧទាហរណ៍ ពេលអ្នកជំពប់ជើងដួលនៅជិតប្រាំងថ្ម កំពុងដើរម្នាក់ឯងនៅទីដាច់ស្រយាល ? (បេះដូងលោតញាប់ បែកញើសបាតដៃ បុកពោះ មានអារម្មណ៍ហាក់ដូចជាមិនអាចកម្រើកបាន មិនអាចគ្រប់គ្រងលើការបញ្ហារាងកាយបាន។ល។)*
- តើមានអារម្មណ៍អ្វីខ្លះ នៅពេលដែលបាក្រដក្នុងចិត្តថា អ្នកកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ *(ស្លន់ស្លោ តក់ស្លុត រន្ធត់ ខឹង ទន់ខ្សោយ ភ័យខ្លាច)*។
- តើការស្តាប់ពីអារម្មណ៍របស់អ្នក អាចមានអត្ថប្រយោជន៍ជាក់លាក់នៅពេលណា ? *(ឧទាហរណ៍ ពេលអ្នកមានអារម្មណ៍ថាស្ថានភាពល្អបានក្លាយជាស្ថានភាពមិនស្រួល ពេលអ្នកមានប្រតិកម្មតបយ៉ាងខ្លាំង ចំពោះអ្វីដែលអ្នកដទៃកំពុងស្នើឱ្យអ្នកធ្វើ)*
- តើអ្នកគិតថាមនុស្សគ្រប់រូបមានអារម្មណ៍ដាស់តឿនថា ពេលណាពួកគេអាចនឹងមិនមានសុវត្ថិភាពដែរឬទេ ? *(មនុស្សមួយចំនួនប្រហែលជាមិនអាចកំណត់បានពីអារម្មណ៍ដែលគេកំពុងមាន ឬក៏ពួកគេប្រហែលជាមិនអាចកត់សម្គាល់នូវអារម្មណ៍ ដែលជាសញ្ញាតឿនអាសន្នរបស់ពួកគេអំពីស្ថានភាពដែលមិនមានសុវត្ថិភាព)*
- ប្រសិនបើមនុស្សម្នាក់មិនធ្លាប់មានអារម្មណ៍មិនស្រួល តើគេអាចប្រាប់ ដោយវិធីអ្វីផ្សេងទៀត បើសិនជាគេមិនមានសុវត្ថិភាព ? *(គេអាចសង្កេតតាមរយៈអាកប្បកិរិយារបស់មនុស្ស ផ្សេងទៀតថា តើសមរម្យ ឬមិនសមរម្យ តើវាមិនមានសុវត្ថិភាពឬ ? តើវាមិនស្របច្បាប់ឬ ? តើកំពុងមានការមិនគោរពសិទ្ធិនរណាម្នាក់ឬ ? តើអ្នកជាអ្នកជួយខ្លួនឯងឬ ? តើអ្នកបាន ទទួលជំនួយឬទេ ពេលអ្នកត្រូវការឱ្យគេជួយ ? )*

**ចំណាំ៖** នៅក្នុងកិច្ចពិភាក្សានេះ និងសកម្មភាពខាងក្រោម អ្នកសម្របសម្រួលគួរធានាឱ្យបានថាមានការទទួលយកចម្លើយតបខុសៗគ្នា ហើយអារម្មណ៍ និងគំនិតផ្សេងៗគ្នារបស់អ្នកចូលរួមគឺមានសុពលភាព។

## សកម្មភាព

ចែកសំណៅ **ឧបសម្ព័ន្ធទី ១២៖ សន្លឹកកិច្ចការស្តីពីសញ្ញាតឿនអាសន្នដល់កុមារ** មួយច្បាប់ដល់អ្នកចូលរួមម្នាក់ៗ និងអានអំពីស្ថានភាពទាំងនោះឮៗ។ សូមឱ្យអ្នកចូលរួមកំណត់អារម្មណ៍របស់មនុស្សវ័យក្មេងថា តើទំនងជាមានអារម្មណ៍ដូចម្តេចក្នុងសេណារីយ៉ូនីមួយៗ ហើយសូមឱ្យគេកត់ត្រា ទុកអំពីអារម្មណ៍ទាំងអស់នេះនៅក្នុងសន្លឹកកិច្ចការរបស់ខ្លួន។ សូមពិភាក្សាជាក្រុមដោយគូសបញ្ជាក់ នូវប្រតិកម្មផ្សេងៗជាច្រើន។ សូមសង្កត់ធ្ងន់ថាអ្នកចូលរួមនីមួយៗ ចាំបាច់ត្រូវរៀនសូត្រ ដើម្បីចេះបកស្រាយប្រតិកម្មរបស់ខ្លួនផ្ទាល់ និងបង្កើតជាយុទ្ធសាស្ត្រផ្ទាល់ខ្លួនដើម្បីវាយតម្លៃថា តើខ្លួនឯងមានសុវត្ថិភាពឬទេ។

### សកម្មភាព (តាមជម្រើស)

ស្នើឱ្យអ្នកចូលរួម បង្កើតយុទ្ធនាការផ្សព្វផ្សាយស្តីពីការជួយកុមារ និងមនុស្សវ័យក្មេងដទៃទៀត ក្នុងការកត់សម្គាល់ស្ថានភាពដែលមិនមានសុវត្ថិភាព ដោយធ្វើការជាមួយដៃគូ ឬជាក្រុម។ ជាដំបូង អ្នកចូលរួមនឹងត្រូវសម្រេចចិត្តលើ៖

- មធ្យោបាយផ្សព្វផ្សាយដែលគេនឹងត្រូវប្រើប្រាស់ដើម្បីទំនាក់ទំនង ឧទាហរណ៍ ទូរទស្សន៍ វិទ្យុ អត្ថបទកាសែត ផ្ទាំងរូបភាព វីដេអូ។ល។
- សារដែលគេនឹងផ្សព្វផ្សាយ
- បរិក្ខារដែលគេនឹងត្រូវការ ឧទាហរណ៍ ម៉ាស៊ីនថតវីដេអូ ម៉ាស៊ីនថត តួសម្តែង កុំព្យូទ័រ ថ្នាំពណ៌។ល។
- ផែនការសកម្មភាពសម្រាប់ការបង្កើតយុទ្ធនាការ

អាចត្រូវចំណាយពេលបីបួនវគ្គក្នុងការធ្វើសកម្មភាពនេះ អាស្រ័យលើមធ្យោបាយផ្សព្វផ្សាយដែលបានជ្រើសរើស។ នៅពេលក្រុមបំពេញការងាររួចរាល់ ពួកគេអាចធ្វើបទបង្ហាញពីយុទ្ធនាការរបស់គេដល់ក្រុមទាំងមូល។

### សកម្មភាព (តាមជម្រើស)

បែងចែកអ្នកចូលរួមជាក្រុមតូចៗ។ ចែកកាតវាយតម្លៃស្ថានភាព (**ឧបសម្ព័ន្ធទី១៣**) មួយឈុតដល់ក្រុមនីមួយៗ។ ស្នើឱ្យពួកគេពិភាក្សាលើស្ថានភាពនីមួយៗ និងកំណត់ថា តើពួកគេនឹងត្រូវការព័ត៌មានអ្វីផ្សេងបន្ថែមទៀតដើម្បីកំណត់បានថាមានគ្រោះថ្នាក់ខ្ពស់ ឬមានគ្រោះថ្នាក់ទាប។ ស្នើសូមឱ្យក្រុមនីមួយៗ ជ្រើសរើសកាតមួយ ហើយរាយការណ៍ត្រឡប់ទៅកាន់ក្រុមទាំងមូលវិញ។ សូមពិភាក្សាសំណួរខាងក្រោមជាក្រុម៖

- តើមានកត្តាអ្វីខ្លះដែលធ្វើឱ្យមនុស្សអាចកំណត់បានថាស្ថានភាពមួយមានគ្រោះថ្នាក់ខ្ពស់ ឬមានគ្រោះថ្នាក់ទាប? *(កត្តាខាងក្រៅ ដូចជា៖ តើអ្នកនៅម្នាក់ឯងឬ? តើមានជំនួយឬទេ? តើអ្នកអាចនៅដាច់តែឯងបានដោយងាយស្រួលឬទេ ? តើស្ថានភាពដែលអ្នកកំពុងស្ថិតនៅអាចផ្លាស់ប្តូរភ្លាមៗឬទេ? ឧទាហរណ៍ វត្តមានរបស់ស្រា ថ្នាំញៀន អាវុធ ភាពមិនប្រក្រតីផ្នែកសតិ?)*
- ហេតុអ្វីបានជាអារម្មណ៍ ប្រតិកម្មផ្នែករាងកាយ សញ្ញាតឿនអាសន្ន និងគំនិតមានសារៈសំខាន់ នៅពេលវាយតម្លៃថាស្ថានភាពមានគ្រោះថ្នាក់ខ្ពស់ឬទាប? *(ទាំងអស់នេះគឺជាប្រភពព័ត៌មាន ខាងក្នុង និងខាងក្រៅស្តីពីស្ថានភាព)។*
- ហេតុអ្វីបានជាមនុស្សម្នាក់ៗ ត្រូវបង្កើតយុទ្ធសាស្ត្រផ្ទាល់ខ្លួន ដើម្បីវាយតម្លៃគ្រោះថ្នាក់? *(ក្នុងករណីភាគច្រើន ការសម្រេចចិត្តដ៏តានតឹងទៅលើភាពមិនស្រួល ឬសុវត្ថិភាពនឹងត្រូវធ្វើឡើងជាលក្ខណៈបុគ្គល។ យើងទាំងអស់គ្នាត្រូវទទួលខុសត្រូវលើសុវត្ថិភាពផ្ទាល់ខ្លួន។ យើងអាចរៀនសូត្រពីការសម្រេចចិត្តកាលពីពេលកន្លងទៅ។ ជានិច្ចកាល ស្ថានភាពដែលមិនមានសុវត្ថិភាព តែងតែមានភាពស្មុគស្មាញ ហើយអាចមិនមានដំណោះស្រាយងាយៗក៏ថាបាន។)*

---

## ការសង្កេត

- តើអ្នកចូលរួមអាចកត់សម្គាល់អត្ថប្រយោជន៍របស់អារម្មណ៍ក្នុងការកំណត់ពីស្ថានភាពដែលមិនមានសុវត្ថិភាព ឬដែលមានលក្ខណៈគំរាមកំហែងដែរឬទេ? ✔

---

# ប្រធានបទទី ៣៖ ការជៀសវាងពីស្ថានភាពមិនមានសុវត្ថិភាពក្នុងពិភព និងការប្រាស្រ័យទាក់ទងបែបឌីជីថល អាយុ ១១-១៧ ឆ្នាំ*

## រយៈពេលអប្បបរមា៖ ២០នាទី

### សង្ខេប

ប្រធានបទនេះ ណែនាំជាសង្ខេបអំពីបញ្ហាសុវត្ថិភាព ទាក់ទងនឹងបច្ចេកវិជ្ជាឌីជីថល និងណែនាំអំពីយុទ្ធសាស្ត្រការពារខ្លួន ដើម្បីជៀសវាងពីគ្រោះថ្នាក់នៅក្នុងពិភព និងការប្រាស្រ័យទាក់ទងបែបឌីជីថល។

### សារសំខាន់ៗ

- ខ្ញុំបានដឹងអំពីគ្រោះថ្នាក់ដែលអាចកើតមានតាមរយៈការប្រាស្រ័យទាក់ទងតាមបែបឌីជីថលទាំងអស់របស់ខ្ញុំ និងអាចការពារខ្លួនឯងដោយប្រើយុទ្ធសាស្ត្រសាមញ្ញៗ។

### សម្ភារ

- ក្រដាសផ្ទាំងធំ និងហ្វឺត

### ការណែនាំ

#### ការពិភាក្សាក្រុម

សូមពិភាក្សាសំណួរខាងក្រោមនេះជាក្រុម៖

- តើនរណាមានទូរស័ព្ទដៃ?
- តើនរណាប្រើទូរស័ព្ទដៃដើម្បីហៅទូរស័ព្ទចេញ?
- តើនរណាប្រើទូរស័ព្ទដើម្បីផ្ញើសារជាអក្សរ?
- តើនរណាប្រើទូរស័ព្ទដើម្បីផ្ញើរូបថត និងវីដេអូ?
- តើនរណាធ្លាប់ប្រើមុខងារដទៃទៀតនៅលើទូរស័ព្ទ? តើប្រើបាស្រ់មុខងារអ្វីខ្លះ?
- តើនរណាប្រើអ៊ិនធើណិត?
- តើអ្នកធ្វើយ៉ាងណាដើម្បីបើកអ៊ិនធើណិតបាន? *(តាមទូរស័ព្ទដៃ កុំព្យូទ័ររបស់គ្រួសារ កុំព្យូទ័រផ្ទាល់ខ្លួន អាយផេត កុំព្យូទ័រសាលា ហាងអ៊ិនធើណិត កុំព្យូទ័របណ្ណាល័យ ផ្សេងទៀត?)*
- តើអ្នកធ្វើអ្វីខ្លះ ពេលអ្នកប្រើអ៊ិនធឺណិត? *(ជជែកជាមួយមិត្តភក្តិ ការងារសាលា អ៊ីម៉ែល ការកំសាន្ត ប្លុក វេទិកាពិភាក្សា ហ្គេម ប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជាហ្វេសប៊ុកជាដើម ទិញ/លក់ឥវ៉ាន់ រកផ្លូវ។ល។)*
- តើមានអ្វីខ្លះដែលជាចំណុចល្អរបស់បច្ចេកវិជ្ជាព័ត៌មានវិទ្យា *(ដូចជា បច្ចេកវិជ្ជាទូរស័ព្ទដៃ អ៊ិនធឺណិត។ល។)*? *(អាចរកព័ត៌មានបានលឿន ជួបមនុស្សថ្មីៗនៅទូទាំងពិភពលោក លេងកំសាន្ត រៀនសូត្រអ្វីដែលថ្មី ចំណាយទាប ឬមិនត្រូវចំណាយ។ល។)*

---

* គួរបន្តចែកក្រុមនេះទៅជាក្រុមអាយុ ១១-១៣ ឆ្នាំ និង ១៤-១៨ ឆ្នាំ សម្រាប់ផ្តល់ការបណ្តុះបណ្តាល ប៉ុន្តែអាចប្រើសម្ភារដូចគ្នាបាន។.

- តើមានអ្វីខ្លះ ដែលជាចំណុចមិនសូវល្អ របស់បច្ចេកវិជ្ជាព័ត៌មានវិទ្យា? តើវាអាចបង្កគ្រោះថ្នាក់ឬទេ ? ដោយរបៀបណា? *(ព័ត៌មានផ្ទាល់ខ្លួន និងរូបថតរបស់អ្នក អាចនឹងត្រូវបានចែករំលែក ជាមួយមនុស្សដទៃទៀត ដែលអ្នកមិនចង់ចែករំលែកជាមួយ ជួបមនុស្សដែលអាចបោកប្រាស់អ្នក។ ឧទាហរណ៍ តាមរយៈការធ្វើពុតជានរណាម្នាក់ផ្សេងទៀត មានអ្នកដែលអាចនឹងកំណត់រូបអ្នកជាគោលដៅរបស់គេតាមរយៈអ៊ិនធឺណិត និងបញ្ជូនសារដែលបង្កការឈឺចាប់ គំរាមកំហែង សារដែលមានលក្ខណៈរំលោភបំពានមកអ្នក អ្នកប្រហែលជាអាចឃើញ ឬអានអំពីអ្វីម៉្យាង ដែលធ្វើឱ្យអ្នកមានអារម្មណ៍ថាមិនស្រួល ជួបមនុស្ស ដែលអាចនឹងសួរអ្នកនូវអ្វីដែលអ្នកមិនចូលចិត្ត។ល។)*
- តើអ្នកគួរដឹង និងធ្វើអ្វីខ្លះដើម្បីរក្សាសុវត្ថិភាព នៅពេលអ្នកប្រើបច្ចេកវិជ្ជាឌីជីថល? *អ្នកសម្របសម្រួលគួរសង្កត់ធ្ងន់ថា កុមារគួរចេះគ្រប់គ្រងព័ត៌មានរបស់ខ្លួនឯងបាន រួចផ្តល់ដំបូន្មានអំពីរបៀបប្រើបច្ចេកវិជ្ជាឌីជីថលឱ្យមានសុវត្ថិភាព។ អ្នកសម្របសម្រួលអាចពន្យល់ប្រាប់ថា មានរឿងមួយចំនួន ដែលអ្នកមិនត្រូវធ្វើជាដាច់ខាត ពេលអ្នកកំពុងប្រើបច្ចេកវិជ្ជាឌីជីថល ហើយមានរឿងមួយចំនួនដែលយើងត្រូវតែធ្វើ។ សូមមើលតារាងខាងក្រោម អំពីប្រការត្រូវធ្វើ និងមិនត្រូវធ្វើ៖*

| មិនត្រូវ | ត្រូវ |
|---|---|
| • មានព័ត៌មានដែលនរណាក៏អាចបើកមើលបានជាសាធារណៈ<br>• ផ្តល់ព័ត៌មានផ្ទាល់ខ្លួន (អាយុ លេខទូរស័ព្ទ ព័ត៌មានលំអិតនៃប័ណ្ណសំគាល់ខ្លួន។ល) និងទីតាំង (អាស័យដ្ឋានផ្ទះ សាលារៀន។ល។)<br>• ឆ្លើយតបទៅនឹងសារទាំងឡាយដែលបង្កឱ្យមានការឈឺចាប់ ឬធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អ ឬមិនមានសុវត្ថិភាព។<br>• ជួបមនុស្សដែលអ្នកបានជួបតាមអ៊ិនធឺណិត តែម្នាក់ឯងដោយពុំមានមនុស្សពេញវ័យទៅជាមួយ។<br>• ចែករំលែករូបថត ឬវីដេអូអំពីខ្លួនឯងដែលអ្នកចង់ឱ្យសាធារណៈជនឃើញ។ | • កំណត់ “ភាពជាឯកជន” ខ្ពស់បំផុតនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម និងមុខងារនានាក្នុងទូរស័ព្ទដៃ។<br>• ប្រាប់ដល់មនុស្សធំ ប្រសិនបើអ្នកមានអារម្មណ៍មិនស្រួលតាមរយៈការប្រើបច្ចេកវិជ្ជាឌីជីថល<br>• បិទចោលនូវមនុស្សទាំងឡាយណាដែលអ្នកមិនចង់និយាយជាមួយតាមបច្ចេកវិទ្យាឌីជីថល<br>• រក្សាភស្តុតាងកំណត់ត្រាដែលធ្វើឱ្យឈឺចាប់ ដើម្បីឱ្យមនុស្សពេញវ័យដែលអ្នកទុកចិត្ត អាចយកទៅបង្ហាញដល់អាជ្ញាធរបាន (ប្រសិនបើចាំបាច់) |

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមរំលឹកប្រាប់អ្នកចូលរួមថា ពួកគេអាចធ្វើសកម្មភាពសាមញ្ញៗ ដើម្បីរក្សាសុវត្ថិភាពនៅក្នុងពិភព និងការប្រាស្រ័យទាក់ទងបែបឌីជីថល។ ជានិច្ចកាលពួកគេត្រូវតែចេះគ្រប់គ្រងស្ថានភាព និងប្រាប់ដល់មនុស្សពេញវ័យដែលគេទុកចិត្ត ប្រសិនបើពួកគេមានអារម្មណ៍ថាខ្លួនទទួលរងការគំរាមកំហែង ឬមានអារម្មណ៍មិនស្រួល។

## ការសង្កេត

- តើអ្នកចូលរួមអាចកំណត់អំពីវិធីដើម្បីជៀសវាងពីស្ថានភាពមិនមានសុវត្ថិភាពនៅក្នុងពិភព និងការប្រាស្រ័យទាក់ទងផ្នែកឌីជីថលឬទេ ? ✔

# ប្រធានបទទី៤៖ ការជៀសវាង និងកាត់បន្ថយគ្រោះថ្នាក់ (តាមជម្រើស) — អាយុ ១១-១៧ ឆ្នាំ*

## រយៈពេលអប្បបរមា៖ ៤០នាទី

### សង្ខេប

នេះជាប្រធានបទដែលអាចជ្រើសរើស ប្រសិនបើមានពេល ឧទាហរណ៍ ប្រសិនបើវគ្គសិក្សាត្រូវបានធ្វើឡើងក្នុងរយៈពេលជាច្រើនថ្ងៃ និងសប្តាហ៍។ មេរៀននេះ ផ្តល់ឱកាសបន្ថែមទៀតឱ្យអ្នកចូលរួមហ្វឹកហាត់កំណត់អំពីស្ថានភាពមិនមានសុវត្ថិភាព និងកាត់បន្ថយគ្រោះថ្នាក់ (រួមទាំងយុទ្ធសាស្ត្រការពារខ្លួន ក្នុងការរក្សាខ្លួនឱ្យនៅឆ្ងាយ និងការមានទំនុកចិត្តផងដែរ។

### សារសំខាន់ៗ

- ខ្ញុំទុកចិត្តខ្លួនឯង អារម្មណ៍របស់ខ្ញុំ និងការវិនិច្ឆ័យរបស់ខ្ញុំ
- ខ្ញុំអាចគ្រប់គ្រងលើស្ថានភាពមួយបាន តាមរយៈការរក្សាខ្លួនរបស់ខ្ញុំឱ្យឆ្ងាយពីអ្វីមួយ។
- ខ្ញុំអាចមានទំនុកចិត្ត និងនិយាយអ្វីដែលខ្ញុំចង់និយាយ អ្វីដែលខ្ញុំមានអារម្មណ៍ និងការគិត ហើយស្របពេលនោះដែរ ក៏ត្រូវគោរពសិទ្ធិរបស់អ្នកដទៃដែរ។

### សម្ភារ

- ក្រដាសផ្ទាំងធំ និងហ្វឺត

### ការណែនាំ

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ថា៖ *ការប្រាស្រ័យទាក់ទងគឺសំខាន់ណាស់ សម្រាប់ការអភិវឌ្ឍន៍ និងរក្សាទំនាក់ទំនង។ សំខាន់ជាងនេះទៀត យើងត្រូវប្រាស្រ័យទាក់ទងអំពីការគិត និងអារម្មណ៍របស់យើង ដើម្បីឱ្យយើងមានសុវត្ថិភាព។ ពេលយើងមានអារម្មណ៍ល្អ និង មានសុវត្ថិភាពជាមួយមនុស្សដទៃ នោះគម្លាតរវាងខ្លួនយើង និងអ្នកដទៃ ក៏នៅជិតស្និទ្ធដែរ។ ប៉ុន្តែ ពេលខ្លះទៀត ពោលគឺពេលដែលយើងអាចនឹងមានអារម្មណ៍មិន ស្រួល យើងអាចនឹងស្ថិតនៅឆ្ងាយពីអ្នកដទៃ។ ក្នុងស្ថានភាពដែលយើងមានអារម្មណ៍មិនស្រួល និង មិនមានសុវត្ថិភាព ជារឿយៗយើងតែងរក្សាគម្លាតរបស់យើងពីមនុស្ស  ដែលបង្ករឱ្យយើងមានអាម្មណ៍បែបនេះដោយមិនដឹងខ្លួន។ "ការរក្សាគម្លាត" គឺជាយុទ្ធសាស្ត្រផ្ទាល់ ខ្លួនដ៏មានសារៈប្រយោជន៍។ ពេលខ្លះ យើងប្រហែលជាចាំបាច់ត្រូវតែធ្វើខ្លួនឱ្យឃ្លាតឆ្ងាយដោយ ចេតនា ដើម្បីរក្សាខ្លួនយើងឱ្យមានសុវត្ថិភាព។*

#### ការពិភាក្សាក្រុម

សូមពិភាក្សាលើសំណួរខាងក្រោមនេះ សម្រាប់សេណារីយ៉ូនីមួយៗ៖

- តើហេតុអ្វីបានជាមនុស្សនោះមានអារម្មណ៍ថាមានសុវត្ថិភាព ឬមិនមានសុវត្ថិភាព?
- តើគាត់កំពុងមានអារម្មណ៍ដូចម្តេច?

* គួរបន្តចែកក្រុមនេះទៅជាក្រុមអាយុ ១១-១៣ ឆ្នាំ និង ១៤-១៨ ឆ្នាំ សម្រាប់ផ្តល់ការបណ្តុះបណ្តាល ប៉ុន្តែអាចប្រើសម្ភារដូចគ្នាបាន។.

- តើមនុស្សនោះអាចធ្វើ និងនិយាយអ្វីខ្លះដើម្បីរក្សាគម្លាតរបស់ខ្លួន? (ពេលខ្លះ ការរក្សាគម្លាតអាចតម្រូវឱ្យបុគ្គលនោះត្រូវ "ទៅ" ពីស្ថានភាពមានគ្រោះថ្នាក់ ប៉ុន្តែ ពេលខ្លះគេមិនអាចធ្វើបានគ្រប់ពេលវេលានោះឡើយ។ ប្រសិនបើអ្នកនោះមិនអាច"ចាកចេញ" ពីស្ថានភាពបានទេនោះ គេគួរធ្វើផែនការអំពីអ្វី ដែលត្រូវធ្វើនៅពេលគេអាច"ទៅ" បាន។ ឧទាហរណ៍ ធ្វើផែនការអំពីកន្លែងដែលអាច ទៅ និងមនុស្សដែលអាចនិយាយប្រាប់បាន។

  *សេណារីយ៉ូទី១៖ មិត្តជិតស្និទ្ធរបស់មនុស្សវ័យក្មេងម្នាក់អួតអាងអំពីការរួមភេទ។ មនុស្សវ័យក្មេងនោះ មានអារម្មណ៍ថាខ្លួនស្ថិតក្រោមសំពាធ និងមានអារម្មណ៍មិនស្រួល។*

  *សេណារីយ៉ូទី២៖ មនុស្សវ័យក្មេងម្នាក់កត់សំគាល់ឃើញថា ទំនាក់ទំនងរបស់ខ្លួន ជាមួយមនុស្សធំម្នាក់ដែលជាមិត្តរាប់អានល្អកល្អឹនជាមួយគ្រួសារខ្លួន កំពុងមានការប្រែប្រួល។ មនុស្សធំនោះ សូមគេឱ្យជួយធ្វើរឿងផ្សេងៗ ដូចជាម៉ាស្សាឱ្យគាត់ជាដើម។ មិត្តដែលជាមនុស្សពេញវ័យនោះឱ្យគេសន្យាថា នឹងមិននិយាយប្រាប់នរណាទាំងអស់។*

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

*សូមពន្យល់៖ ដូចយើងបានពិភាក្សាហើយថា ជាការសំខាន់ណាស់ ដែលត្រូវប្រាស្រ័យទាក់ទងការគិត និងអារម្មណ៍របស់យើងឱ្យគេបានដឹង ដើម្បីជួយរក្សាសុវត្ថិភាពរបស់យើង។ កុមារ និងមនុស្សវ័យក្មេង ចាំបាច់ត្រូវតែមានទំនុកចិត្ត ពេលស្ថិតក្នុងស្ថានភាពលំបាក។*

ប្រសិនបើអាច អ្នកសម្របសម្រួលគួរបញ្ជាក់បង្ហាញអំពីកត្តាផ្នែកវប្បធម៌ ដែលអាចធ្វើឱ្យកុមារ និង មនុស្សវ័យក្មេងពិបាកបាប្រ់ និងវាយតម្លៃតម្រូវការរបស់ខ្លួនឯង។ អ្នកសម្របសម្រួលអាចសួរអ្នកចូលរួមថា តើសហគមន៍របស់ពួកគេរំពឹងអ្វីខ្លះពីពួកគេ និងហេតុអ្វី? បន្ទាប់មក ការពិភាក្សាពីពេលវេលាសមស្របដែលត្រូវរឹងមាំ និងវិធីល្អបំផុតដើម្បីធ្វើខ្លួនឱ្យរឹងមាំ។

## ការពិភាក្សាក្រុម

សួរទៅអ្នកចូលរួមថា តើពួកគេធ្វើយ៉ាងណា ដើម្បីអាចបង្ហាញទំនុកចិត្តចេញមកបាន។ សរសេរចម្លើយដាក់លើក្រដាសផ្ទាំងធំ *(ឧ. នៅស្ងប់ស្ងៀម និយាយច្បាស់ពីអ្វីដែលខ្ញុំចង់និយាយ រួមទាំងពាក្យថា "ទេ" ផងដែរ។ និយាយអំពីអ្វីដែលអារម្មណ៍យើងប្រាប់យើង និងពន្យល់មូលហេតុ និយាយសារឡើងវិញម្តងហើយម្តងទៀត ជៀសវាងផ្តល់លេស ស្តាប់អ្វីដែលមនុស្សដទៃនិយាយ)*។

## សកម្មភាព

ចែករំលែកសេណារីយ៉ូខាងក្រោមជាមួយអ្នកចូលរួម ហើយសួរទៅអ្នកចូលរួមថាតើ ____*ស្ត្រី ក* អាចនិយាយ និងធ្វើដូចម្តេច ដើម្បីឱ្យមានការជឿជាក់លើខ្លួនឯង៖

> *______(ស្ត្រី ក) ធ្លាប់តែចូលចិត្តទៅផ្ទះមិត្តរបស់នាង ______ (ស្ត្រី ខ)។ ប៉ុន្តែ ថ្មីៗនេះឪពុករបស់ស្ត្រី B ចាប់ផ្តើមពោលពាក្យទាក់ទងនឹងរូបរាង និងរបៀបស្លៀកពាក់របស់នាង។ គាត់ក៏តែងតែនិយាយលេងសើចជាប្រចាំ ដោយបង្កប់ន័យផ្លូវភេទចំពោះនាងផងដែរ។*
>
> *______ (**ស្ត្រី ក) មានអារម្មណ៍ថាខ្លួនមិនអាចនិយាយអ្វីប្រាប់ទៅ** ______(ស្ត្រី ខ) អំពីឪពុករបស់នាងបានឡើយ។ នាងបានត្រឹមតែព្យាយាមនៅឱ្យឆ្ងាយពីគាត់ តែពេលនេះនាង មានអារម្មណ៍ថានាងទ្រាំលែងបានតទៅទៀតហើយ។*

ក្នុងអំឡុងពេលពិភាក្សា អ្នកសម្របសម្រួលគួរគូសបញ្ជាក់ចំណុចខាងក្រោម៖

- មនុស្សវ័យក្មេងនៅក្នុងរឿងនេះ អាចការពារខ្លួនឯងបាន តាមរយៈការទុកចិត្តទៅលើអារម្មណ៍ គំនិត និងសញ្ញាតឿនអាសន្នរបស់ខ្លួន ការនិយាយទៅកាន់ខ្លួនឯង និងមិត្តភក្តិ មនុស្សពេញវ័យដែលពួកគេទុកចិត្ត និងតាមរយៈការគ្រប់គ្រងលើស្ថានភាពខ្លួនឯងដោយប្រើប្រាស់យុទ្ធសាស្ត្រការពារខ្លួនណាមួយ។
- ពេលខ្លះយើងពិបាកមានទំនុកចិត្តលើខ្លួនឯងណាស់ ជាពិសេស ពេលជួបរឿងជាមួយមនុស្សវ័យចាស់ជាង ឬធំជាងយើង។ មនុស្សយើងមានសិទ្ធិនិយាយពីអាកប្បកិរិយាបៀតបៀន ឬរំលោភបំពាន។

## សកម្មភាព

ឱ្យអ្នកចូលរួមធ្វើការជាដៃគូ ដើម្បីហ្វឹកហាត់អំពីអាកប្បកិរិយាប្រកបដោយទំនុកចិត្ត ដើម្បីឆ្លើយតបចំពោះស្ថានភាពនៅក្នុងសេណារីយ៉ូខាងក្រោម។ ម្នាក់ហាត់សមអំពីអាកប្បកិរិយាប្រកបដោយទំនុកចិត្ត ឯម្នាក់ទៀតជាអ្នកលើកទឹកចិត្ត។

*សេណារីយ៉ូទី ១៖ ____(ស្រី) ទៅបង្គន់ពេលចេញលេង។ ពេលនាងកំពុងប្រើបង្គន់មានកុមារី ពីរនាក់អើតមើលនាងតាមមាត់ទ្វារ។ រឿងនេះបានកើតឡើងមិនមែនតែម្តងនោះទេ។*

*សេណារីយ៉ូទី ២៖ មិត្តរបស់អ្នកម្នាក់បានប្រាប់អ្នកថា គេបានជួបបុរសម្នាក់នៅតាមផ្លូវ ដែលមានចិត្តល្អ និងបានឱ្យលុយគេ ១០ ដុល្លា។ ថ្ងៃបន្ទាប់មក បុរសនោះមកទីនោះម្តងទៀត ហើយចាប់ផ្តើមនិយាយជាមួយមិត្តអ្នក និងបានបបួលមិត្តអ្នកឱ្យទៅជាមួយគេ។ មិត្តអ្នកគិតថា បុរសនោះនឹងឱ្យលុយគេបន្ថែមទៀត ប៉ុន្តែបុរសនោះបានបង្ខំឱ្យគេរួមភេទ ហើយ គំរាមមិត្តរបស់អ្នកថា ប្រសិនបើគេប្រាប់ដល់នរណាម្នាក់អំពីអ្វីដែលបានកើតឡើង នោះ បុរសនោះ នឹងទៅរកគេ ហើយធ្វើបាបគេកាន់តែខ្លាំងទៀត។*

## សកម្មភាព (តាមជម្រើស)

ជ្រើសរើសយកសេណារីយ៉ូណាមួយ ក្នុងចំណោមសេណារីយ៉ូខាងលើ។ សូមពន្យល់ប្រាប់ថា អ្នកនឹងចាប់ផ្តើមប្រយោគ ហើយអ្នកចង់ឱ្យអ្នកចូលរួមម្នាក់ៗ បន្ថែមគំនិតមួយចំនួន ដើម្បីបញ្ចប់ប្រយោគនោះ។

*ប្រសិនបើខ្ញុំត្រូវជួយមនុស្សនៅក្នុងសេណារីយ៉ូនេះឱ្យមានទំនុកចិត្ត ខ្ញុំនឹងលើកចិត្តពួកគេ*

- *ឱ្យធ្វើសកម្មភាពតាមរយៈ ……*
- *ឱ្យប្រាប់ ឬនិយាយជាមួយ …..*
- *ឱ្យធ្វើផែនការសម្រាប់អនាគតតាមរយៈ…..*

*រួចហើយ ខ្ញុំនឹងអបអរសាទរគេ ចំពោះការមានទំនុកចិត្តខ្ពស់របស់ពួកគេ!*

## ការសង្កេត

តើអ្នកចូលរួមអាចជ្រើសរើស និងអនុវត្តយុទ្ធសាស្ត្រដើម្បីការពារខ្លួនក្នុងស្ថានភាពមិនមានសុវត្ថិភាពឬទេ ? ✔

# ប្រធានបទទី៥៖ បណ្តាញគាំទ្ររបស់ខ្ញុំ អាយុ ១១-១៧ ឆ្នាំ*

## រយៈពេលអប្បបរមា៖ ៣០នាទី

### សង្ខេប

ប្រធានបទនេះ ណែនាំឱ្យស្គាល់ពីគោលគំនិតនៃបណ្តាញគាំទ្រ ពីសំណាក់មនុស្សពេញវ័យដែលមនុស្សវ័យ ក្មេងអាចនិយាយជាមួយ នៅពេលពួកគេត្រូវការការជួយ ឬមានអារម្មណ៍ថាគ្មានសុវត្ថិភាព។

### សារសំខាន់ៗ

- បណ្តាញរបស់ខ្ញុំគឺជាមនុស្សពេញវ័យមួយក្រុមដែលខ្ញុំស្គាល់ ជួបជាមួយទៀងទាត់ និងជឿទុកចិត្តបាន។
- ខ្ញុំអាចទៅរកពួកគាត់ដើម្បីសូមការជួយនិងការគាំទ្រ។ពួកគាត់អាចជួយការពារខ្ញុំ ពីការធ្វើបាប ឬការរំលោភបំពាន។
- សមាជិកនៃបណ្តាញរបស់ខ្ញុំអាចផ្លាស់ប្តូរ (ទៅតាមពេលវេលា)។

### សម្ភារ

- **ឧបសម្ពន្ធ័ទី២៖ កាតយកតាមខ្លួន**
- ក្រដាសផ្ទាំងធំ និងហ្វឺត
- ក្រដាស និងប៊ិចសម្រាប់សិក្ខាកាមម្នាក់ៗ
- សម្ភារសម្រាប់ធ្វើបដា ដូចជាប័ណ្ណ ថ្នាំពណ៌ (តាមជម្រើស)

### ការណែនាំ

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពន្យល់ពាក្យ “បណ្តាញគាំទ្រ”។ បណ្តាញគាំទ្រ គឺជាមនុស្សមួយក្រុម ដែលមនុស្ស វ័យក្មេងអាចទៅរកដើម្បីទទួលការគាំទ្រ។ ជារឿយៗមនុស្សវ័យក្មេងអាស្រ័យច្រើន លើមិត្ត ភក្តិក្នុងក្រុមរបស់គេដើម្បីទទួលបានមិត្តភាពនិងការគាំទ្រ។ ទោះបីជា មិត្តភក្តិក្នុងក្រុមរបស់អ្នកជា បណ្តាញគាំទ្រដ៏សំខាន់ ក៏វាជាការចាំបាច់ ក្នុងការកសាង“បណ្តាញគាំទ្រ” ដែលមានការចូលរួម ពីមនុស្សពេញវ័យ ដែលអ្នកទុកចិត្ត ជឿលើអ្នក និង ជាជនដែលនឹងជួយអ្នក ប្រសិនបើអ្នកមានអារម្មណ៍ថាគ្មានសុវត្ថិភាព។

#### ការពិភាក្សាក្រុម

- សូមពិភាក្សាជាក្រុមនូវសំណួរដូចតទៅ ៖
- តើលក្ខណៈសម្បត្តិអ្វីខ្លះដែលបុគ្គលក្នុងបណ្តាញគាំទ្រ“ល្អ”ម្នាក់ត្រូវមាន? *(ងាយជួបអាចជឿទុកចិត្តបាន ជាអ្នកពូកែស្តាប់ ចេះយល់ចិត្ត និងមានពេលវេលាសម្រាប់អ្នក។)*
- ហេតុអ្វីបានជាយើងត្រូវកំណត់បុគ្គលក្នុងបណ្តាញគាំទ្រចេញពីទិដ្ឋភាពផ្សេងៗនៃជីវិតរបស់យើង? *(វាអាចជាការលំបាក ក្នុងការនិយាយពីបញ្ហាមួយចំនួនជាមួយមនុស្សក្នុងក្រុមណាមួយ។)*

* គួរបន្តចែកក្រុមនេះទៅជាក្រុមអាយុ ១១-១៣ ឆ្នាំ និង ១៤-១៨ ឆ្នាំ សម្រាប់ផ្តល់ការបណ្តុះបណ្តាល ប៉ុន្តែអាចប្រើសម្ភារដូចគ្នាបាន។

- ហេតុអ្វីត្រូវបញ្ចូលមនុស្សពេញវ័យមួយចំនួនទៅក្នុងបណ្តាញនេះ? *(មានស្ថានភាពខ្លះ ដែលមនុស្សពេញវ័យចាំបាច់ ត្រូវផ្តល់ការគាំទ្រដើម្បីផ្លាស់ប្តូរស្ថានភាពណាមួយ។ ពួកយើងមិនចង់ដាក់មនុស្សវ័យក្មេងផ្សេងទៀត នៅក្នុងស្ថានភាពដែលគ្មានសុវត្ថិភាព។ នៅពេលដែលមនុស្សពេញវ័យមានអំណាចច្រើន ពួកគេជារឿយៗអាចជួយក្នុងស្ថានភាព មួយចំនួន ដែលកុមារឬមនុស្សពេញវ័យមិនអាចធ្វើបាន)*
- ចុះបើសិនជា មនុស្សវ័យក្មេងណាម្នាក់ មកសុំដំបូន្មានពីអ្នក? *(វាជាការល្អ ដែលអ្នកជួយដល់គាត់ឬនាង ដើម្បីបានជជែកជាមួយមនុស្សពេញវ័យទាំងអស់គ្នា)*

## សកម្មភាព

សូមឱ្យសិក្ខាកាមរកនឹក និងសរសេរឈ្មោះមនុស្ស៥នាក់ដែលអាចក្លាយជាអ្នកគាំទ្រដល់ពួកគេ។ សូមឱ្យសិក្ខាកាមសរសេរឈ្មោះពួកគាត់ និងមូលហេតុដែលជ្រើសរើសពួកគាត់ទាំងនោះ។ *(**ឧបសម្ពន្ធ័ទី២៖ កាតយកតាមខ្លួន** ត្រូវបោះពុម្ពសម្រាប់អ្នកចូលរួមម្នាក់ៗ កុមារអាចសរសេរឈ្មោះមនុស្សពេញវ័យដែលទុកចិត្តចំនួនប្រាំនាក់នៅលើក្រដាស)*




## សកម្មភាព

សូមពន្យល់ថាជាការសំខាន់ត្រូវសាកសួរបុគ្គលទាំងនោះថា ពួកគេយល់ព្រមចូលរួមក្នុងបណ្តាញគាំទ្ររបស់អ្នកដែរឬទេ ។ តាមរយៈការធ្វើការជាក្រុម សូមរកនឹកគំនិតនានាសម្រាប់ សរសេរសំបុត្រ ដែលអាចចែករំលែកជាមួយអ្នកគាំទ្រ។ ឧទាហរណ៍ ៖

*ជូនចំពោះ ______*
*នៅឯ (សាលារៀន/ក្លិបកុមារ) យើងបាននិយាយគ្នាពីចំណុចដែលថាមនុស្សគ្រប់រូបមានសិទ្ធិទទួលបានអារម្មណ៍ថាមានសុវត្ថិភាព និងទទួលបានសុវត្ថិភាព។*
*ខ្ញុំកំពុងបង្កើត "ក្រុមបណ្តាញគាំទ្រ" នៃមនុស្ស ដែលខ្ញុំអាចជឿទុកចិត្ត និងនិយាយជាមួយបាន នៅពេលដែលខ្ញុំព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្ញុំ។*
*មនុស្សក្នុងបណ្តាញ គឺជាមនុស្សដែលខ្ញុំជឿទុកចិត្តថាជាអ្នកស្តាប់ដ៏ល្អ និងផ្តល់នូវយោបល់ល្អៗដល់ខ្ញុំ។*
*ខ្ញុំចង់ឱ្យពូ/មីង ក្លាយជាសមាជិកម្នាក់ក្នុងបណ្តាញគាំទ្ររបស់ខ្ញុំ។*
*បើពូ/មីងយល់ព្រមធ្វើជាបណ្តាញគាំទ្ររបស់ខ្ញុំ សូមមេត្តាអនុញ្ញាតឱ្យខ្ញុំបានដឹង និងប្រាប់ពីវិធីសមស្រេចដែលខ្ញុំអាចទាក់ទងទៅពូ/មីងបាន។*
*សូមអរគុណយ៉ាងខ្លាំង។*
*ហត្ថលេខា ៖ ______*

### ការពិភាក្សាក្រុម

សូមពិភាក្សាជាក្រុមនូវសំណួរដូចតទៅ ៖

- ហេតុអ្វីបានជាចាំបាច់ក្នុងការពិនិត្យបណ្តាញរបស់យើងឡើងវិញជាប្រចាំ? *(ពីព្រោះទំនាក់ទំនងរបស់យើងផ្លាស់ប្តូរ រីឯបរិយាកាសជុំវិញខ្លួនយើងក៏ផ្លាស់ប្តូរដែរ។ ឧទាហរណ៍ កន្លែងដែលយើងរស់នៅ ទៅសាលារៀន ។ល។ យើងក៏ដឹងបានតាមរយៈ បទពិសោធន៍ថា នរណាដែលនឹងធ្វើសកម្មភាព និងជឿលើយើង។)*
- តើបុគ្គលក្នុងបណ្តាញគាំទ្ររបស់អ្នកអាចជួយអ្នកដោយរបៀបណា? *(ស្តាប់ ផ្តល់ការជួយ ផ្តល់ដំបូន្មាន។)*
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីរក្សាការទាក់ទងជាមួយបណ្តាញរបស់អ្នក? *(ការប្រាស្រ័យទាក់ទងជាប្រចាំ ចែករំលែកបទពិសោធន៍ទាំងល្អនិងអាក្រក់ សម្តែងការគោរពចំពោះមនុស្សក្នុងបណ្តាញរបស់អ្នក។)*
- តើអ្នកអាចធ្វើដូចម្តេចបើអ្នកគាំទ្ររបស់អ្នកមិនជឿអ្នក ឬមិនធ្វើសកម្មភាព? *(ការបន្តប្រាប់គឺជាការសំខាន់ណាស់។ ប្រសិនបើគេមិនជឿអ្នកឬជួយអ្នកទេ អ្នកត្រូវប្រាប់ទៅអ្នកគាំទ្រដទៃទៀតក្នុងបណ្តាញរបស់អ្នក រហូតទាល់តែអ្នកទទួលបានការជួយ)។*
- ហេតុអ្វីបានជាការបន្តប្រាប់អ្នកដទៃមានសារៈសំខាន់? *(ដំណើរការប្រាប់អ្នកដទៃ បង្កើនអំណាចដល់មនុស្ស ដែលជាគោលដៅនៃការរំលោភបំពាន និងធ្វើឱ្យអ្នកអាចគ្រប់គ្រង លើរឿងព្រួយបារម្ភដែលកំពុងកើតឡើងជុំវិញពួកគេ។ វាគឺជាការសំខាន់ ដែលត្រូវចងចាំផងដែរ ទោះបីថាមនុស្សពេញវ័យ ក៏មិនអាចយល់នូវរឿងរ៉ាវនានាភ្លាមៗនោះទេ ដូចនេះពួកគេអាចត្រូវការពេលវេលា ដើម្បីយល់)។*

### សកម្មភាព (តាមជម្រើស)

ដោយធ្វើការជាក្រុមតូចៗ សូមឱ្យសិក្ខាកាមបង្កើតបដា ពាក្យស្លោក ឬយុទ្ធនាការដើម្បី ៖

- លើកទឹកចិត្តមនុស្សវ័យក្មេងឱ្យបង្កើតបណ្តាញគាំទ្រដែលល្អសម្រាប់ពួកគេ ឬ
- ក្លាយជាអ្នកគាំទ្រដ៏ល្អ ប្រសិនបើនរណាម្នាក់សូមឱ្យអ្នកក្លាយជាបណ្តាញគាំទ្ររបស់ពួកគេ។

ក្រុមតូចៗនីមួយៗបង្កើតនូវយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់“ការជួយ”របស់ពួកគេចំពោះ សហគមន៍ និង បង្ហាញដល់ក្រុមទាំងមូល។

### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមសង្កត់ធ្ងន់ថាមានហេតុផលល្អៗជាច្រើនដែលត្រូវប្រាប់នរណាម្នាក់អំពីការរំលោភបំពាន ៖

- ដើម្បីជួយបញ្ឈប់ការរំលោភបំពាន
- ដើម្បីកាត់បន្ថយឱកាសដែលអ្នកដទៃអាចជាគោលដៅនៃការរំលោភបំពាន
- ដើម្បីស្វែងយល់ពីជម្រើស ឬយុទ្ធសាស្ត្រសមស្របសម្រាប់ស្ថានភាពនោះ
- ដើម្បីឱ្យអ្នកអាចទទួលបានការគាំទ្រដែលសមស្របដើម្បីគ្រប់គ្រងស្ថានភាពនោះ

---

**ការសង្កេត**

- តើកុមារអាចកំណត់បាននូវមនុស្សពេញវ័យសមស្របចំនួន៥នាក់ ដែលពួកគេអាចប្រាប់ពីការរំលោភបំពាន និងសូមដំបូន្មាន និងការគាំទ្រដែរឬទេ ? ✔

---

# ប្រធានបទទី ៦៖ ការគាំទ្ររបស់សហគមន៍ អាយុ ១១-១៧ ឆ្នាំ*

## រយៈពេលអប្បបរមា៖ ២០នាទី

### សង្ខេប

ប្រធានបទនេះផ្តល់ព័ត៌មានដល់មនុស្សវ័យក្មេងអំពីទីកន្លែងដែលពួកគេអាចទៅរកជំនួយ និងការគាំទ្របាននៅក្នុងសហគមន៍របស់ខ្លួន ទាក់ទងនឹងការធ្វើយ៉ាងណា ដើម្បីរក្សាសុវត្ថិភាពខ្លួនឯងពីការរំលោភបំពានគ្រប់ទម្រង់ទាំងអស់ រួមទាំងការរំលោភបំពានផ្លូវភេទផងដែរ។

### សារសំខាន់ៗ

- មានជំនួយសម្រាប់ខ្ញុំក្នុងសហគមន៍ខ្ញុំ ដើម្បីរក្សាសុវត្ថិភាពខ្ញុំពីការរំលោភបំពានគ្រប់ទម្រង់ទាំងអស់ ជាពិសេសគឺការរំលោភបំពានផ្លូវភេទ។

### សម្ភារ

- ក្រដាសផ្ទាំងធំ និងហ្វឺត

### ការណែនាំ

**សកម្មភាព**

អញ្ជើញអ្នកចូលរួមឱ្យចូលរួមចំណែក ក្នុងគំនូសដ្យាក្រាម ឬផែនទីគំនិត* រួមគ្នាមួយស្តីពីប្រភេទសេវាគាំទ្រដែលមាននៅក្នុងសហគមន៍ សម្រាប់មនុស្សដែលមានកង្វល់ ឬជួបការរំលោភ បំពានប្រភេទណាមួយ។.

*ឧទាហរណ៍:




* គួរបន្តចែកក្រុមនេះទៅជាក្រុមអាយុ ១១-១៣ ឆ្នាំ និង ១៤-១៨ ឆ្នាំ សម្រាប់ផ្តល់ការបណ្តុះបណ្តាល ប៉ុន្តែអាចប្រើសម្ភារដូចគ្នាបាន។

## ការពិភាក្សាក្រុម

ពិភាក្សាជាក្រុមទៅលើសំណួរខាងក្រោម សម្រាប់សេវាគាំទ្រនីមួយៗដែលបានកំណត់ឃើញ៖

- តើសេវាគាំទ្រប្រភេទណាដែលត្រូវបានផ្តល់ឱ្យ?
- តើនរណាខ្លះដែលអាចទទួលអត្ថប្រយោជន៍ពីសេវាគាំទ្រនេះ?
- តើធ្វើយ៉ាងណាទើបអាចមានលទ្ធភាពទទួលបានសេវាគាំទ្រនេះ?
- តើសេវាអាចផ្តល់អ្វីខ្លះ និងតើសេវាគាំទ្រទាំងនោះមានលក្ខខណ្ឌអ្វីខ្លះ?

## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមឱ្យអ្នកចូលរួមបានដឹងពីព័ត៌មានទំនាក់ទំនងក្នុងមូលដ្ឋាន និងសេវាថ្នាក់ជាតិណាដែលមាន *(ដូចជាបណ្តាញទូរស័ព្ទជំនួយសម្រាប់កុមារជាដើម)* ប្រសិនបើពួកគេមានសំណួរ ឬកង្វល់ណាមួយ។ *(**ប្រសិនឧបសម្ព័ន្ធទី២៖** កាតយកតាមខ្លួន ត្រូវបានបោះពុម្ពសម្រាប់អ្នកចូលរួមម្នាក់ៗរួចហើយនោះ កុមារអាចសរសេរលម្អិតនៅលើកាតនោះតែម្តង)។*




## ការសង្កេត

- តើសិក្ខាកាមអាចកំណត់បាននូវសេវាគាំទ្រដែលសមស្របក្នុងសហគមន៍ដែរឬទេ ?

# សន្និដ្ឋាន អាយុ ១១-១៧ ឆ្នាំ*

## រយៈពេលអប្បបរមា៖ ៣០នាទី

### សង្ខេប

វគ្គសិក្សានេះ ផ្ដល់ឱកាសដើម្បីរំលឹកឡើងវិញពីសារគន្លឹះ ឆ្លើយនឹងសំណួរ ដែល កុមារអាចមាន និងសូមព័ត៌មានត្រឡប់ពីកុមារ។ជាការសំខាន់ត្រូវបញ្ចប់វគ្គបណ្ដុះបណ្ដាល ដោយរីករាយនិងប្រកបដោយលក្ខណៈល្អប្រសើរ។

### សារសំខាន់ៗ

- ខ្ញុំអាចប្រើប្រាស់យុទ្ធសាស្ត្រជាច្រើនដើម្បីជួយការពារខ្លួនខ្ញុំ ប្រសិនបើខ្ញុំមានអារម្មណ៍ថាគ្មានសុវត្ថិភាព ត្រូវបានគេធ្វើបាប ឬរំលោភបំពាន។

### សម្ភារ

- ឯកសារថតចម្លងនៃ **ឧបសម្ព័ន្ធទី១០៖** ទម្រង់វាយតម្លៃ សម្រាប់កុមារម្នាក់ៗ

### ការណែនាំ

#### កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

សូមពង្រឹងបន្ថែមនូវចំណុចដូចតទៅ ៖

- អ្នករំលោភបំពានផ្លូវភេទលើកុមារ/មនុស្សវ័យក្មេង ត្រូវទទួលខុសត្រូវចំពោះការរំលោភបំពាននោះ និងផលប៉ះពាល់ដែលពួកគេបានប្រព្រឹត្ត។ កុមារ និងមនុស្សវ័យ ក្មេងមិនត្រូវទទួលបានការស្ដីបន្ទោសទេ។
- សញ្ញាព្រមានដំបូង( ដូចជា បែកញើសបាតដៃនិងបុកពោះ ) ជាសញ្ញាព្រមាននៃរាងកាយ របស់យើង ដែលប្រាប់យើងថា យើងកំពុងមានអារម្មណ៍ថា គ្មានសុវត្ថិភាព។ យើងត្រូវជឿទុកចិត្តលើសញ្ញាទាំងនេះ។
- អ្នករំលោភបំពានអាចជាមនុស្សអាចជានរណាម្នាក់។ អ្នករំលោភបំពានម្នាក់អាចជានរណាម្នាក់ដែលអ្នកស្គាល់ និងជឿទុកចិត្ត។
- វាជាការលំបាកក្នុងការនិយាយថា "ទេ" ប៉ុន្តែវាមិនមែនជាការហួសពេលទេ ក្នុងការប្រាប់អ្នកដទៃ។
- ការប្រាប់អ្នកដទៃមិនមែនជាការងាយស្រួលទេ ប៉ុន្តែវាជាការសំខាន់ណាស់ ដែល ត្រូវនិយាយជាមួយមនុស្សដែលអ្នកមានអារម្មណ៍កក់ក្ដៅក្នុងការនិយាយជាមួយ។
- បណ្ដាញគាំទ្ររបស់អ្នកអាចជួយអ្នក ប្រសិនបើអ្នកមានអារម្មណ៍ថាគ្មានសុវត្ថិភាព
- សូមព្យាយាមបង្កើតផែនការសកម្មភាពផ្ទាល់ខ្លួន។

#### សកម្មភាព

សូមឱ្យសិក្ខាកាមបំពេញទម្រង់វាយតម្លៃ ( **ឧបសម្ព័ន្ធទី៩** )។ ប្រសិនបើពេលវេលាខ្លីអ្នកសម្របសម្រួល អាចធ្វើការពិភាក្សាក្រុម ចំពោះសំណួរទាំងនោះ និងកត់ត្រានូវចម្លើយរបស់ពួកគេ។

* គួរបន្តចែកក្រុមនេះទៅជាក្រុមអាយុ ១១-១៣ ឆ្នាំ និង ១៤-១៨ ឆ្នាំ សម្រាប់ផ្ដល់ការបណ្ដុះបណ្ដាល ប៉ុន្តែអាចប្រើសម្ភារដូចគ្នាបាន។

## សកម្មភាព

សូមប្រើប្រាស់រូបភាពផ្កានៅក្នុង នៅក្នុង**ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន** សូមឱ្យកុមារផាត់ ពណ៌ឬតុបតែង និង សរសេរល្បះដែលចង្អុលបង្ហាញ ពីទិដ្ឋភាពវិជ្ជមាននៃ ជីវិតរបស់កុមារ ដូចជា *ខ្ញុំពូកែខាង... មនុស្សដែល ខ្ញុំស្រឡាញ់បំផុតគឺ... ខ្ញុំមានអារម្មណ៍ថាមាន សុវត្ថិភាព... អនុស្សាវរីយ៍ រីករាយបំផុតរបស់ខ្ញុំគឺ... អ្នកគាំទ្រខ្ញុំខ្លាំងជាងគេគឺ... ចំណុចដែលខ្ញុំចូលចិត្តភូមិខ្ញុំជាងគេគឺ...។ ជម្រើសផ្សេងទៀតកុមារអាចគូសរូបភាព អ្វីមួយផ្សេង ដែលមានលក្ខណៈសមស្របទៅតាមវប្បធម៌ សង្គម នីមួយៗ (ដូចជារូបផ្ទៃ ឬបាតដៃ)។*




## កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

ថ្លែងអំណរគុណចំពោះកុមារ សម្រាប់ការចូលរួមរបស់ពួកគេ និងអនុញ្ញាតឱ្យពួកគេដឹង អាស័យដ្ឋានទំនាក់ទំនងសហគមន៍ក្នុងតំបន់ និងសេវាកម្មថ្នាក់ជាតិមួយចំនួន (ដូចជា បណ្តាញជំនួយកុមារម្ពុជា) បើសិនជាពួកគេមានសំណួរ ឬចម្ងល់។ កុមារអាចសសេររឿងរ៉ាវទាំងនេះ ទៅក្នុងនៅក្នុង **ឧបសម្ព័ន្ធទី២៖ កាតយកតាមខ្លួន** ។

# កត់ចំណាំ

# កត់ចំណាំ

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

..............................................................................................................................................................

# ផ្នែកទី៣

# ឧបសម្ព័ន្ធ



# ឧបសម្ព័ន្ធទី ១៖ គំរូលិខិតសម្រាប់ការចូលរួមដោយស្ម័គ្រចិត្ត

**ការណែនាំ៖** សម្រាប់អ្នកចូលរួមម្នាក់ៗ (មនុស្សអាយុក្រោម ១៨ ឆ្នាំ) ជាការចាំបាច់ណាស់ដែលទទួលបានការយល់ព្រមពីឪពុកម្តាយ/អ្នកថែទាំ និងការយល់ព្រមពីកុមារផង ដើម្បីឱ្យកុមារចូលរួមបាន។ តាមធម្មតា ទម្រង់យល់ព្រមដោយមានព័ត៌មានត្រឹមត្រូវច្រើនតែមានកិច្ចព្រមព្រៀងដែលត្រូវបានចុះហត្ថលេខាដើម្បីចូលរួម លើក លែងតែនោះជារឿងមិនសមស្របតាមវប្បធម៌ មិនមានសុវត្ថិភាព មិនអាចធ្វើបានក្នុងការណីឪពុកម្តាយ/អ្នកមើលថែមានការអប់រំទាប។

ប្រសិនបើមិនអាចទទួលបានការយល់ព្រមដោយមានហត្ថលេខាទេនោះ ចាំបាច់ត្រូវមានការយល់ព្រមដោយផ្ទាល់មាត់។ ក្នុងករណីនេះ អ្នកសម្របសម្រួល ឬអ្នកសម្របសម្រួលគម្រោង ត្រូវចុះហត្ថលេខាលើទម្រង់នេះ ដើម្បីបញ្ជាក់ថាពួកគេបានជម្រាបដល់កុមារដែលជាអ្នកចូលរួម និងឪពុកម្តាយ/អ្នកមើលថែរបស់កុមាររួចហើយ ហើយទាំងកុមារនិងឪពុកម្តាយ/អ្នកមើលថែរបស់ពួកគេបានយល់អំពី៖

- គោលបំណង និងអត្ថប្រយោជន៍រំពឹងទុក ដែលបានមកពីការចូលរួមរបស់កុមារក្នុងសកម្មភាព
- គ្រោះថ្នាក់និងវិបាកចំបងៗនៃការចូលរួម
- ពេលវេលាដែលត្រូវលះបង់ និងការរំពឹងទុកដទៃទៀតរបស់អ្នកចូលរួម និង
- លទ្ធភាពក្នុងការបដិសេធមិនចូលរួម ឬដកខ្លួនចេញពីសកម្មភាពនេះ នៅពេលណាក៏បាន។

អ្នកអាចយកគំរូលិខិតខាងក្រោមនេះ ទៅកែសម្រួលដើម្បីចែករំលែកទៅដល់ឪពុកម្តាយ/អ្នកថែទាំក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬជាទម្រង់ផ្ទាល់មាត់។.

សូមគោរពជូនចំពោះឪពុកម្ដាយ/អ្នកមើលថែជាទីរាប់អាន

កូនរបស់អ្នកត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវគ្គសិក្សាស្តីពី "**រក្សាសុវត្ថិភាពកុមារពីការរំលោភបំពាន**"។ វគ្គសិក្សានេះនឹងត្រូវធ្វើឡើងនៅ [កាលបរិច្ឆេទ] នៅឯ[ទីកន្លែង] ចាប់ពី [ម៉ោង] តទៅ។ សកម្មភាពនេះគឺជាផ្នែកមួយនៃ [ពន្យល់អំពីកម្មវិធីធំដែលគ្របដណ្ដប់លើវគ្គបណ្ដុះបណ្ដាលនេះ ។ ឧទាហរណ៍ ការបណ្ដុះបណ្ដាលអំពីជំនាញជីវិត ក្លឹបកុមារ ទិវាកុមារ។ល។] ដើម្បីជួយការពារសុខភាព និងសេចក្ដីថ្លៃថ្នូររបស់កុមារ ការពារសហគមន៍ រក្សាតម្លៃគ្រួសារ និងតម្លៃវប្បធម៌ សកម្មភាពនេះ នឹងជួយការពារកូនរបស់អ្នកពីការរំលោភបំពាន តាមរយៈការចែករំលែកព័ត៌មានដោយប្រុងប្រយ័ត្ន អំពីការរក្សាខ្លួនឱ្យមានសុវត្ថិភាព។

## តើវគ្គសិក្សានេះ គ្របដណ្តប់លើអ្វីខ្លះ ?

វគ្គសិក្សានេះនឹងគ្របដណ្តប់លើ ១) របៀបដែលកុមារអាចស្គាល់ថា តើស្ថានភាពណាជាស្ថានភាពមិនមានសុវត្ថិភាព និង ២) ផ្ដល់ឱកាសឱ្យកុមារហ្វឹកហាត់យុទ្ធសាស្ត្រផ្សេងៗ ដែលពួកគេអាចយកទៅអនុវត្តបានក្នុងករណីពួក គេមានក្ដីបារម្ភ ឬខ្លាចក្នុងស្ថានភាពណាមួយ។ គោលបំណងរបស់វគ្គសិក្សានេះ **គឺដើម្បីផ្ដល់ព័ត៌មានដែល សមស្របតាមអាយុ និងដំណាក់កាលអភិវឌ្ឍ** ដើម្បីផ្ដល់សិទ្ធិអំណាចដល់ពួកគេ និងជួយពួកគេឱ្យអភិវឌ្ឍការគោរព ចំពោះ ខ្លួនឯង។ វគ្គនេះគឺពុំមែនជាវគ្គអប់រំអំពីភេទនោះឡើយ។

កុមារនឹងបានរៀនសូត្រយ៉ាងសមស្របតាមអាយុ និងដំណាក់កាលរបស់ខ្លួនស្ដីពីៈ

- អារម្មណ៍មានសុវត្ថិភាព និងសិទ្ធិរបស់ពួកគេក្នុងការទទួលបានសុវត្ថិភាព
- ការសម្គាល់ថាតើការប៉ះពាល់ណាជាការប៉ះពាល់សមស្រប ហើយការចាប់ប៉ះមួយណាជាការប៉ះពាល់មិនសមស្រប
- កុមារដឹងថា ពួកគេមានសិទ្ធិនិយាយថា "ទេ" ចំពោះមនុស្សដែលចាប់ប៉ះពួកគេដោយមិនសមស្រប ឬដែលគំរាមដល់សុវត្ថិភាពពួកគេ។
- អំពីសារៈសំខាន់នៃការនិយាយប្រាប់ដល់មនុស្សធំដែលមានសុវត្ថិភាព អំពីស្ថានភាពនោះ
- ឱ្យកុមារដឹងថា ពួកគេត្រូវបន្តនិយាយប្រាប់ដល់មនុស្សធំដែលមានសុវត្ថិភាព រហូតទាល់តែពួកគេជឿ និង
- ឱ្យកុមារដឹងថាមានជំនួយដែលពួកគេអាចរកបាននៅក្នុងសហគមន៍របស់ពួកគេ។

## តើហេតុអ្វីបានជាវគ្គសិក្សានេះមានភាពពាក់ព័ន្ធ ? ( ផ្នែកនេះអាចជាជម្រើសដែលអាចចែករំលែកបានប្រសិនបើចាំបាច់សម្រាប់គ្រូបង្រៀន/សាលារៀន )

ដូចអ្វីដែលអ្នកប្រហែលជាបានដឹងរួចមកហើយថាៈ

- ការរំលោភបំពានអាចរួមមានព្រឹត្តិការណ៍ ដែលកើតឡើងតែមួយដងគត់ ឬអាចជាការរំលោភបំពាន ដែលបន្តកើតមានជារៀងរហូតតាំងពីកុមារនៅតូច រហូតដល់គេពេញជំទង់។
- ករណីលេចធ្លោមួយចំនួនពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទ ដែលយើងតែងឃើញនៅក្នុងសារព័ត៌មាន ឬដែលយើងបានអាននៅក្នុងកាសែត គឺសុទ្ធតែនិយាយអំពីមនុស្សមិនស្គាល់មុខ ដែលជាអ្នករំលោភបំពានមកលើកុមារ។ ប៉ុន្តែទោះយ៉ាងនេះក្ដី ក៏យើងឃើញថា ការរំលោភបំពានផ្លូវភេទចំពោះ កុមារភាគច្រើនតែ ប្រព្រឹត្តិដោយមនុស្សណាម្នាក់ ដែលជនរងគ្រោះធ្លាប់ស្គាល់។ រឿងបែបនេះ កើតមាននៅគ្រប់ស្រទាប់សង្គម-សេដ្ឋកិច្ចសហគមន៍ជាតិពន្ធុ និងនៅក្នុងពូជសាសន៍ទាំងអស់។

- ក្នុងករណីភាគច្រើន កុមារមិនដែលប្រាប់នរណាម្នាក់ អំពីអ្វីដែលបានកើតឡើងចំពោះពួកគេឡើយ។ ហេតុ អ្វី? ព្រោះពួកគេមិនមានអារម្មណ៍ថាមានសុវត្ថិភាព។ ការនិយាយអំពីរឿងភេទ គឺជារឿងដែលគ្រួសារជាច្រើនចាត់ទុកជារឿងមិនគួរគប្បី។ ប្រសិនបើគេមិនដែលនិយាយអំពីរឿងភេទ ឬប្រសិនបើឪពុកម្តាយបានប្រតិកម្មខ្លាំង ចំពោះរាល់ការលើកឡើងអំពីភេទនោះ  កុមារនឹងមានអារម្មណ៍ស្ទាក់ស្ទើរយ៉ាង ខ្លាំងក្នុងការនិយាយប្រាប់ថា ពួកគេធ្លាប់រងការរំលោភបំពាននោះ។ ជាអកុសល ការមិនបានបង្ហាញប្រាប់ គឺការបន្ថែម បន្ទុកទៅលើការប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរ ដែលកុមារត្រូវទ្រាំ ដែលអាចមានរយៈពេលរហូតដល់ពេញមួយជីវិត។
- កុមារត្រូវការព័ត៌មានល្អៗអំពីភេទ ទំនាក់ទំនងផ្លូវភេទ ការបន្តពូជ និងការពន្យាកំណើត ជម្ងឺកាមរោគ និងការរំលោភបំពានផ្លូវភេទ។ ការលាក់បាំងព័ត៌មានអំពីភេទ និងការរំលោភបំពានផ្លូវភេទដែលអាចកើត មាននោះ គឺជាការដាក់កុមារឱ្យប្រឈមនឹងហានិភ័យ។ ការស្រាវជ្រាវនៅថ្នាក់ជាតិបានបង្ហាញឱ្យឃើញថា ប្រសិន បើកុមារបានទទួលព័ត៌មានត្រឹមត្រូវអំពីបញ្ហាពាក់ព័ន្ធនឹងផ្លូវភេទនោះ ពួកគេមិនសូវជាប់ពាក់ព័ន្ធក្នុងទំនាក់ទំនងផ្លូវភេទទេ។
- មានតែតាមរយៈការបើកចំហការពិភាក្សាអំពីភេទ និងចាប់ផ្តើមជជែកជាមួយកុមារតាំងពីគេមានអាយុនៅតិចប៉ុណ្ណោះ ដែលយើងអាចការពារកុមារពីការរំលោភបំពានបាន។ ជាពិសេស ទាល់តែការសន្ទនាអំពីភេទ និងការរំលោភបំពានផ្លូវភេទ ក្លាយជាប្រធានបទសាមញ្ញ ដែលត្រូវបានលើកឡើងក្នុងកិច្ចសន្ទនាទេ ដែលយើងអាចធ្វើឱ្យជនល្មើសបង្កគ្រោះ ថ្នាក់ដល់កុមារត្រូវទទួលខុសត្រូវចំពោះទង្វើខ្លួនបាន។[22]

ក្នុងនាមជាឪពុកម្តាយ/អាណាព្យាបាល អ្នកស្ថិតក្នុងតួនាទីដ៏សំខាន់បំផុត ក្នុងការអប់រំកូនអ្នកស្តីពីការរក្សាខ្លួនឱ្យមានសុវត្ថិភាពរួចផុតពីគ្រោះថ្នាក់។ យើងខ្ញុំសូមស្វាគមន៍ចំពោះការជួយពង្រឹងបន្ថែម នូវគំនិតយោបល់ ដែលកុមារនឹងរៀនសូត្របានពីវគ្គសិក្សានេះ។ ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែមទៀត សូមទំនាក់ទំនងទៅកាន់ [ឈ្មោះអ្នកសម្របសម្រួល/អ្នកសម្របសម្រួលគម្រោង]។ សូមបំពេញទម្រង់ខាងក្រោម ដើម្បីផ្តល់ការយល់ព្រមឱ្យកូនរបស់អ្នកចូលរួម។

សូមទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅបំផុតពីរូបខ្ញុំ

ខ្ញុំអនុញ្ញាតឱ្យកូនរបស់ខ្ញុំទៅចូលរួមវគ្គសិក្សាដែលនឹងគ្របដណ្តប់លើ i) របៀបដែលកុមារអាចស្គាល់ថាតើស្ថានភាព ណាជាស្ថានភាពមិនមានសុវត្ថិភាព និង ii) ផ្តល់ឱកាសឱ្យកុមារហ្វឹកហាត់យុទ្ធសាស្ត្រផ្សេងៗដែលពួកគេ អាចយកទៅអនុវត្តបានក្នុងករណីពួកគេមានក្តីបារម្ភ ឬខ្លាចក្នុងស្ថានភាពណាមួយ។

ហត្ថលេខារបស់ឪពុកម្តាយ/អ្នកថែទាំ៖ ________________________ កាលបរិច្ឆេទ៖ _________________

ឈ្មោះ៖ ___________________________________________________________________________

ហត្ថលេខារបស់កុមារ ប្រសិនបើអាច៖________________________ កាលបរិច្ឆេទ៖__________________

ឈ្មោះ៖ ___________________________________________________________________________

អាសយដ្ឋាន និងលេខទូរស័ព្ទ (ប្រសិនបើមាន)៖

[22] ដកស្រង់ចេញពី Wass, P,ការអប់រំផ្លូវភេទជួយរក្សាសុវត្ថិភាពកុមារពីការរំលោភបំពាន។ ការណែនាំសំរាប់ឪពុកម្តាយដើម្បីបង្រៀនកូនៗអំពីសុវត្ថិភាពផ្ទាល់ខ្លួនក្នុងការកាត់បន្ថយគ្រោះថ្នាក់ពីការរំលោភបំពានផ្លូវភេទ, http://www.smith-lawfirm.com/sex_ed.html

# ឧបសម្ព័ន្ធទី ២៖ កាតយកតាមខ្លួន

**ការណែនាំ៖** អ្នកអាចចម្លងកាតទាំងនេះឱ្យកុមារម្នាក់ៗបាន។ កុមារ និងមនុស្សវ័យក្មេងអាចប្រើប្រាស់កាតទាំងនេះពេលកំពុងរៀន និងយកកាតទាំងនេះទៅតាមខ្លួន ដើម្បីរំលឹកពួកគេអំពីចំណុច សំខាន់ៗដែលពួកគេបានរៀនសូត្ររួច។ មានវិធីជាច្រើនដើម្បីផលិតកាតនេះ។ អ្នកអាចថតចម្លងកាតនេះទៅលើកាតទំហំ A5 ឬ A6 ទាំងសងខាង រួចដាក់បញ្ចូលគ្នាដោយប្រើកងដាក់សោរមួយ។ បើពុំនោះទេ អ្នកអាចបោះពុម្ពកាតពីរសន្លឹក លើក្រដាស A4 រួចហើយបិទការភ្ជាប់គ្នា ដើម្បីបង្កើតជាក្រដាសបង្ហាញចល័ត ឬក្រដាសបញ្ឈរបាន។

# ការរក្សាកុមារឲ្យរួចផុតពី
# ការរំលោភបំពាន



Australian Aid

World Vision

# អនុសញ្ញាអង្គការសហប្រជាជាតិស្តីពី**សិទ្ធិកុមារ**



**"សិទ្ធិ" គឺអ្វីដែលកុមារម្នាក់ៗគួរទទួលបាន ឬអាចប្រើប្រាស់បាន។ កុមារគ្រប់រូបមានសិទ្ធិស្មើគ្នា។**

**មាត្រា ១**
មនុស្សគ្រប់រូបដែលមានអាយុក្រោម១៨ឆ្នាំ ទទួលបានសិទ្ធិទាំងនេះ ។

**មាត្រា ២**
កុមារគ្រប់រូបសុទ្ធតែទទួលបានសិទ្ធិទាំងនេះ ទោះបីជាពួកគាត់ជាអ្នកណារស់នៅទីកន្លែងណាឬមានឪពុកម្តាយជាអ្នកប្រកបមុខរបរអ្វីក៏ដោយ ទោះជាពួកគាត់និយាយភាសាអ្វី ឬកាន់សាសនាអ្វីក៏ដោយមិនប្រកាន់ថាជាកុមារា ឬកុមារីទេទោះជាពួកគាត់មានវប្បធម៌បែណាក្តី ពិការបែបណាក្តី ឬទោះបីមានក្តី ក្រក្តី។ គ្មានកុមារណាម្នាក់ត្រូវទទួលរងអំពើអយុត្តិធម៌ឡើយទោះបីស្ថិតក្នុងរូបភាពបែបណាក៏ដោយ។

**មាត្រា ៣**
មនុស្សពេញវ័យគ្រប់រូប គួរតែធ្វើអ្វីដែលមានប្រយោជន៍បំផុតសម្រាប់កុមារ។ នៅពេលមនុស្សពេញវ័យធ្វើការសម្រេចចិត្តនានា ពួកគេគួរគិតថា តើការសម្រេចចិត្តរបស់ខ្លួនមានផលប៉ះពាល់ដូចម្តេចខ្លះចំពោះកុមារ ។

**មាត្រា ៤**
រាជរដ្ឋាភិបាលទទួលខុសត្រូវធានាថាសិទ្ធិរបស់កុមារពិតជាទទួលបានការការពារ។ រដ្ឋាភិបាលត្រូវតែជួយក្រុមគ្រួសាររបស់កុមារដើម្បីការពារ សិទ្ធិរបស់កុមារ និងបង្កើតជាមជ្ឈដ្ឋានមួយដែលអាចឲ្យកុមារធំលូតលាស់ និងអាចធ្វើអ្វីៗបានអស់ពីលទ្ធភាពរបស់ពួកគាត់ ។

**មាត្រា ៥**
ក្រុមគ្រួសាររបស់កុមារទទួលបន្ទុកជួយឲ្យកុមារចេះប្រើប្រាស់សិទ្ធិរបស់ពួកខ្លួន និងធានាថាសិទ្ធិទាំងនេះទទួលបាននូវការការពារ។

**មាត្រា ៦**
កុមារទទួលបានសិទ្ធិរស់រានមានជីវិត។

**មាត្រា ៧**
កុមារមានសិទ្ធិទទួលបានការដាក់ឈ្មោះ ហើយការដាក់ឈ្មោះនេះគួរមានការទទួលស្គាល់ជាផ្លូវការពីរដ្ឋាភិបាល។ កុមារក៏មានសិទ្ធិទទួលបាននូវសញ្ជាតិរបស់ខ្លួន(ជាពលរដ្ឋរបស់ប្រទេសមួយ)។

**មាត្រា ៨**
កុមារមានសិទ្ធិទទួលបានអត្តសញ្ញាណដែលជាបញ្ជីកត់ត្រាជាផ្លូវការនូវអត្តសញ្ញាណរបស់កុមារ។ គ្មាននរណាម្នាក់អាចដកហូតសិទ្ធិនេះពីកុមារបានឡើយ ។

**មាត្រា ៩**
កុមារមានសិទ្ធិរស់នៅជាមួយឪពុក ឬម្តាយរបស់ខ្លួន បើការរស់នៅនោះមិនជះផលអាក្រក់ចំពោះកុមារទេ។ កុមារមានសិទ្ធិរស់នៅក្នុងគ្រួសារដែលថែទាំពួកគេ។

**មាត្រា ១០**
បើកុមាររស់នៅប្រទេសមួយផ្សេងពីប្រទេសដែលឪពុក/ម្តាយខ្លួនរស់នៅ កុមារមានសិទ្ធិនៅជាមួយឪពុកម្តាយនៅទីកន្លែងតែមួយ។

**មាត្រា ១១**
កុមារមានសិទ្ធិទទួលបានការការពារពីការចាប់ជំរិត។

**មាត្រា ១២**
កុមារមានសិទ្ធិសម្តែងមតិរបស់ខ្លួន ឲ្យមនុស្សពេញវ័យស្តាប់និងយកចិត្តទុកដាក់ទៅលើមតិទាំងនោះ ។

**មាត្រា ១៣**
កុមារមានសិទ្ធិស្វែងយល់ពីអ្វីមួយ និងយកអ្វីដែលខ្លួនគិត ទៅប្រាប់អ្នកដទៃតាមរយៈការនិយាយ គូរ សរសេរ ឬវិធីផ្សេងៗទៀត បើទង្វើទាំងនោះមិននាំឲ្យគ្រោះថ្នាក់ ឬបើមិនមានការខុសឆ្គងចំពោះអ្នកដទៃទេ ។

**មាត្រា ១៤**
កុមារមានសិទ្ធិជ្រើសរើសសាសនា និងជំនឿផ្ទាល់ខ្លួន ។ ឪពុកម្តាយរបស់កុមារ គួរជួយកុមារក្នុងការសម្រេចចិត្តទៅលើអ្វីដែលខុស អ្វីដែលត្រូវ អ្វីដែលល្អបំផុតសម្រាប់កុមារ។

**មាត្រា ១៥**
កុមារមានសិទ្ធិរាប់អានមិត្តភក្តិផ្ទាល់ខ្លួន និងចូលរួម ឬបង្កើតជាក្រុម បើសកម្មភាពបែបនេះមិនប៉ះពាល់ដល់អ្នកដទៃទេ។

**មាត្រា ១៦**
កុមារមានសិទ្ធិឯកជនរបស់ខ្លួន។

**មាត្រា១៧**
កុមារមានសិទ្ធិទទួលបានព័ត៌មាន ដែលមានសារៈសំខាន់សម្រាប់សុខុមាលភាពរបស់ខ្លួនពីវិទ្យុ កាសែត សៀវភៅ កុំព្យូទ័រ និងប្រភពផ្សេងទៀត។ មនុស្សពេញវ័យត្រូវតែធ្វើយ៉ាងណាឲ្យរាល់ព័ត៌មានដែលកុមារទទួលបាននោះ មិនប៉ះពាល់ដល់កុមារ និងជួយកុមារស្វែងរក និងឲ្យបានយល់ដឹងពីព័ត៌មានដែលកុមារត្រូវការ ។

**មាត្រា១៨**
កុមារមានសិទ្ធិទទួលបានការចិញ្ចឹមបីបាច់ថែរក្សាពីឪពុកម្តាយរបស់ខ្លួន បើអាចធ្វើទៅបាន។

**មាត្រា ១៩**
កុមារមានសិទ្ធិទទួលបានការការពារឲ្យរួចផុតពីការធ្វើឲ្យឈឺចាប់ និងរងទុក្ខលើរាងកាយនិងផ្លូវចិត្ត។

**មាត្រា ២០**
កុមារមានសិទ្ធិទទួលបានការថែទាំ និងជំនួយ ពិសេស ក្នុងករណីមិនអាចរស់នៅជាមួយឪពុកម្តាយខ្លួនបាន ។

**មាត្រា ២១**
កុមារមានសិទ្ធិទទួលបានការថែទាំ និងការពារ បើពួកគាត់ត្រូវបានគេសុំយកទៅចិញ្ចឹម ឬរស់នៅជាមួយគ្រួសារធម៌។

**មាត្រា ២២**
កុមារមានសិទ្ធិទទួលបានការការពារ និងជំនួយពិសេស ក្នុងករណីពួកគាត់ ជាជនភៀសខ្លួន (បើកុមារត្រូវបានបង្ខំឲ្យចាកចេញពីប្រទេសកំណើតរបស់ខ្លួនទៅរស់នៅប្រទេសមួយទៀត) ព្រមទាំងសិទ្ធិទាំងអស់ដែលមាននៅក្នុងអនុសញ្ញានេះ។

# អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ



## "សិទ្ធិ" គឺអ្វីដែលកុមារម្នាក់ៗគួរទទួលបាន ឬអាចប្រើប្រាស់បាន។ កុមារគ្រប់រូបមានសិទ្ធិស្មើគ្នា។

**មាត្រា ២៣**
កុមារមានសិទ្ធិទទួលបានការអប់រំ និងការថែទាំពិសេស បើកុមារមានពិការភាព ហើយកុមារមានសិទ្ធិគ្រប់យ៉ាង ដែលមានចែងនៅក្នុងអនុសញ្ញានេះដើម្បីឲ្យកុមារអាចរស់នៅបានដោយពេញលេញ ។

**មាត្រា ២៤**
កុមារមានសិទ្ធិទទួលបានការថែទាំសុខភាពដ៏ប្រសើរបំផុតតាមដែលអាចធ្វើទៅបាន មានទឹក ស្អាតសម្រាប់បរិភោគ អាហារមានជីវជាតិ រស់នៅក្នុងបរិស្ថានស្អាត និងសុវត្ថិភាព និងមានសិទ្ធិទទួលបានព័ត៌មានដែលជួយឲ្យកុមាររស់នៅបានល្អ ។

**មាត្រា ២៥**
ប្រសិនបើកុមាររស់នៅក្រោមការថែទាំ ឬនៅក្នុងស្ថានការណ៍ផ្សេងទៀត ដែលនៅឆ្ងាយពីផ្ទះកុមារមានសិទ្ធិទទួលបានការការត្រួតពិនិត្យយ៉ាងទៀងទាត់ទៅលើការរៀបចំជីវភាពរស់នៅរបស់ខ្លួន ដើម្បីឲ្យដឹងថាតើការរៀបចំទាំងនោះ មានលក្ខណៈសមស្របសម្រាប់បំផុតដែរឬយ៉ាងណា ។

**មាត្រា ២៦**
កុមារមានសិទ្ធិទទួលបានជំនួយពីរដ្ឋាភិបាល ប្រសិនបើពួកគាត់គឺជាកុមារក្រីក្រ ឬត្រូវការជំនួយ ។

**មាត្រា ២៧**
កុមារមានសិទ្ធិទទួលបានចំណីអាហារ សម្លៀកបំពាក់ ទីកន្លែង រស់នៅដោយសុវត្ថិភាព និងតម្រូវការតម្រូវការមូលដ្ឋាន ។ កុមារមិនគួរមានគុណវិបត្តិឡើយ ព្រោះបើមានគុណវិបត្តិ កុមារមិនអាចធ្វើអ្វីៗជាច្រើនទៀត ដែលកុមារដទៃអាចធ្វើបានឡើយ ។

**មាត្រា ២៨**
កុមារមានសិទ្ធិទទួលបានការអប់រំដែលមានគុណភាពល្អ ។ កុមារគួរទទួលបានការលើកទឹកចិត្តឲ្យចូលរៀនរហូតដល់កម្រិតខ្ពស់បំផុត ទៅតាមសមត្ថភាពរបស់គាត់ ។

**មាត្រា ២៩**
ការអប់រំរបស់កុមារ គួរជួយឲ្យកុមារប្រើប្រាស់ និងអភិវឌ្ឍទេពកោសល្យ និងសមត្ថភាពរបស់ខ្លួន។ ការអប់រំ ក៏គួរជួយឲ្យកុមារចេះពីរបៀបរស់នៅដោយសន្តិភាព ចេះការពារបរិស្ថាន និងគោរពអ្នកដទៃ។

**មាត្រា ៣០**
កុមារមានសិទ្ធិប្រកាន់ខ្ជាប់នូវវប្បធម៌ ភាសា និងសាសនា ឬអ្វីមួយផ្សេងទៀតដែលកុមារជ្រើសរើស។ កុមារជាជនជាតិភាគតិច និងជនជាតិដើម ត្រូវទទួលបានការការពារពិសេសចំពោះសិទ្ធិនេះ។

**មាត្រា ៣១**
កុមារមានសិទ្ធិលេង និងសម្រាក ។

**មាត្រា ៣២**
កុមារមានសិទ្ធិទទួលបានការការពារ ពីការធ្វើការងារដែលប៉ះពាល់ដល់ខ្លួនហើយដែលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពនិងការអប់រំរបស់ខ្លួន។ បើកុមារធ្វើការ កុមារមានសិទ្ធិធ្វើការងារ ដែលមានសុវត្ថិភាព និងទទួលបានប្រាក់កំម្រៃសមរម្យ។

**មាត្រា៣៣**
កុមារមានសិទ្ធិទទួលបានការការពារពីគ្រោះថ្នាក់ដោយសារថ្នាំញៀន និងការជួញដូរគ្រឿងញៀន។

**មាត្រា ៣៤**
កុមារមានសិទ្ធិរួចផុតពីការរំលោភផ្លូវភេទ ។

**មាត្រា ៣៥**
គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យចាប់ពង្រត់ ឬលក់កុមារបានឡើយ ។

**មាត្រា ៣៦**
កុមារមានសិទ្ធិទទួលបានការការពារឲ្យរួចផុតពីការកេងប្រវ័ញ្ចទោះក្នុងរូបភាពណាក៏ដោយ (រងការកេងយកផលប្រយោជន៍) ។

**មាត្រា ៣៧**
គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យប្រើវិធីសាហាវ និងគ្រោះថ្នាក់ដើម្បីដាក់ទារុណកម្មលើកុមារឡើយ ។

**មាត្រា ៣៨**
កុមារមានសិទ្ធិទទួលបានការការពារ និងរួចផុតពីសង្គ្រាម ។ កុមារដែលមានអាយុក្រោម ១៥ឆ្នាំ មិនអាចត្រូវបង្ខំឲ្យចូលបម្រើកងទ័ព ឬចូលរួមធ្វើសឹកសង្គ្រាមឡើយ ។

**មាត្រា ៣៩**
កុមារមានសិទ្ធិទទួលបានជំនួយ ក្នុងករណីទទួលរងនូវការឈឺចាប់ ការមិនយកចិត្តទុកដាក់ ឬទទួលរងនូវអំពើអាក្រក់ ។

**មាត្រា ៤០**
កុមារមានសិទ្ធិទទួលបានជំនួយផ្លូវច្បាប់ និងទទួលបានយុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការដែលត្រូវតែគោរពសិទ្ធិកុមារ។

**មាត្រា ៤១**
ប្រសិនបើច្បាប់ប្រទេសរបស់កុមារ បានផ្តល់នូវការការពារ សិទ្ធិរបស់ពួកគាត់ ល្អប្រសើរជាងអនុសញ្ញានេះគួរយកច្បាប់ប្រទេសនោះមកអនុវត្ត ។

**មាត្រា ៤២**
កុមារមានសិទ្ធិស្គាល់ពីសិទ្ធិរបស់ខ្លួន រីឯមនុស្សពេញវ័យគួរដឹងអំពីសិទ្ធិទាំងនេះ ហើយត្រូវជួយឲ្យកុមារមានការយល់ដឹងអំពីសិទ្ធិទាំងនោះដែរ។

**មាត្រា ៤៣ ដល់ ៥៤**
មាត្រាទាំងនេះបានពន្យល់ពីមធ្យោបាយដែលរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដូចជាយូនីសេហ្វ ជាដើមនឹងអនុវត្ត ដើម្បីធានាធ្វើយ៉ាងណាឲ្យកុមារទទួលបានការការពារដោយប្រើប្រាស់សិទ្ធិទាំងនេះ។

# តើអ្វីជាការរំលោភបំពានកុមារ ?



រំលោភបំពានដោយប្រើ
ពាក្យសម្តីមិនល្អចំពោះកុមារ



និយាយលូកលាន់លើកុមារ
ដែលមិនចាំបាច់



ប៉ះពាល់លើកុមារនៅ
ផ្នែកណាមួយនៃរាងកាយ
ដែលកុមារមិនចង់ឲ្យប៉ះ



មិនស្តាប់សំដីកុមារ



នាំឲ្យកុមារឃើញសកម្មភាព
ឬ រូបអាសអាភាសផ្លូវភេទ



បង្ខំកុមារឲ្យប៉ះពាល់ផ្នែក
ណាមួយនៃរាងកាយរបស់ខ្លួន



ធ្វើឲ្យកុមារបាត់បង់
ទំនុកចិត្តលើខ្លួនឯង



វាយដំ ឬធ្វើឲ្យកុមារ
ឈឺចាប់ ជារឿយៗ ដើម្បី
រំសាយកំហឹងខ្លួនឯង



បោកបញ្ឆោតកុមារ



មិនយកចិត្តទុកដាក់ថែទាំកុមារ
ដូចជាមិនសម្អាត ស្លៀកពាក់
និងឲ្យចំណីអាហារ



ប្រើប្រាស់កុមារធ្វើ
ជាអ្នកបម្រើ



មិនយកចិត្តទុកដាក់
លើសេចក្តីត្រូវការផ្នែក
សតិអារម្មណ៍របស់កុមារ



ធ្វើឲ្យកូនរបស់ខ្លួនក្លាយជា
" អ្នកបម្រើ " ដោយមិនឲ្យមាន
ពេលលំហែរ និងសិក្សា



វាយដំ និងសើចចំអក
ឲ្យកុមារនៅសាលារៀន



មិនយកចិត្តទុកដាក់លើ
តម្រូវការផ្នែកសុខភាព
រាងកាយរបស់កុមារ



មិនយកចិត្តទុកដាក់លើ
តម្រូវការផ្នែកអប់រំរបស់កុមារ



ទុកកុមារចោល
គ្មានអ្នកមើលថែ

រូបភាព និងអត្ថបទដកស្រង់ចេញពីផ្ទាំងរូបភាព " តើអ្វីទៅជាការរំលោភបំពានលើកុមារ "
ដែលផលិតដោយ *Childline Thailand Foundation.* ក្នុងគេហទំព័រ *http://childlinethailand.org*

## ទេ !



ផ្នែកខ្លះនៃរាងកាយរបស់ខ្ញុំ គឺមិនអាចប៉ះពាល់បានទេ ។ ប្រសិនបើមានអ្នកណាម្នាក់ប៉ះខ្ញុំ ក្នុងលក្ខណៈមួយធ្វើឲ្យខ្ញុំព្រួយបារម្ភ ភ័យខ្លាច ឬឈឺចាប់ នោះខ្ញុំមានសិទ្ធិនិយាយថា ទេ ។

## ទៅ !



ប្រសិនបើខ្ញុំស្ថិតនៅក្នុងស្ថានភាពមួយ ដែលធ្វើឲ្យខ្ញុំព្រួយបារម្ភ ឬភ័យខ្លាច នោះខ្ញុំត្រូវគេចចេញពីស្ថានភាពនោះ ។

## ប្រាប់!



ប្រសិនបើខ្ញុំមានអារម្មណ៍ភ័យខ្លាច មិនស្រួលក្នុងចិត្ត ឬមិនសប្បាយចិត្តចំពោះស្ថានភាពណាមួយ នោះខ្ញុំត្រូវទៅប្រាប់មនុស្សពេញវ័យដែលគួរឲ្យទុកចិត្ត អំពីកង្វល់របស់ខ្ញុំ ។

មនុស្សពេញវ័យដែលគួរឲ្យទុកចិត្ត គឺស្ថិតនៅជុំវិញខ្លួនខ្ញុំ ដែលអាចជួយ និងគាំទ្រខ្ញុំបាន។ ប្រសិនបើខ្ញុំប្រាប់មនុស្សពេញវ័យដែលគួរឲ្យទុកចិត្ត ហើយគាត់មិនជឿ ឬមិនជួយខ្ញុំ នោះខ្ញុំត្រូវទៅប្រាប់មនុស្សពេញវ័យដែលគួរឲ្យទុកចិត្តម្នាក់ទៀត ។



# មនុស្សពេញវ័យ ៥នាក់ ដែលខ្ញុំអាចជឿទុកចិត្តបាន



ជារឿងល្អ ក្នុងការចែករំលែកនូវអ្វី ដែលធ្វើឲ្យកុមារព្រួយបារម្ភ ជាមួយមនុស្សពេញវ័យដែលអាចនាំឲ្យមាន
សុវត្ថិភាព ឬគួរឲ្យទុកចិត្ត ។ មិនមែនជាកំហុសរបស់អ្នកឡើយ ប្រសិនបើអ្នកបានទទួលរងនូវការរំលោភបំពាន ។

# បើខ្ញុំព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាព របស់អ្នកណាម្នាក់ទៀត នោះខ្ញុំអាច ៖






**1**

ទូរសព្ទ៍ទៅកាន់បណ្តាញទូរសព្ទ៍ជំនួយកុមារកម្ពុជា

**១២៨០**

ឬចូលទៅកាន់គេហទំព័ររបស់ពួកគេ ៖
www.childhelpline.com.kh

**2**

ទាក់ទងអង្គការក្នុងស្រុក ដែលមាននាទីការពារកុមារ

**០៩២ ៣១១ ៥១១**

**3**

សេវាក្នុងស្រុកមួយចំនួនទៀត នៅក្នុងសហគមន៍របស់ខ្ញុំ


ខ្ញុំពូកែខាង
អ្នកដែលស្រឡាញ់ខ្ញុំ
បំផុតនោះគឺ
អ្វីដែលខ្ញុំចូល
ចិត្តបំផុតនៅក្នុងភូមិ/
ទីក្រុងរបស់ខ្ញុំនោះគឺ
ខ្ញុំមានអារម្មណ៍ថា
មានសុវត្ថិភាពនៅពេល
អនុស្សាវរីយ៍ដែលធ្វើឲ្យ
ខ្ញុំសប្បាយចិត្តបំផុតនោះ គឺ

# ឧបសម្ព័ន្ធទី៣ ៖ ការណែនាំឱ្យស្គាល់គ្នា និងល្បែងបង្កើនទំនុកចិត្ត

**ការណែនាំ:** អ្នកសម្របសម្រួលអាចជ្រើសរើសល្បែងកំសាន្តពីជម្រើសខាងក្រោម និង គប្បីកែសម្រួលឱ្យមានលក្ខណៈសមស្រប តាមតម្រូវការអតិវឌ្ឍន៍ខាងបញ្ញា ឬផ្លូវកាយរបស់សិក្ខាកាម។

## សម្រាប់សិក្ខាកាមអាយុលើសពី៥ឆ្នាំ ៖

**ចាប់ផ្តើមស្គាល់អ្នក**

*( ល្បែងកំសាន្ត នេះត្រូវការបាល់មួយ )*

កុមារ ( និងមនុស្សពេញវ័យ ) ឈរជារង្វង់។ មនុស្សពេញវ័យម្នាក់ចាប់ផ្តើមល្បែងនេះ ដោយបោះបាល់ទៅឱ្យនរណាម្នាក់ក្នុងរង្វង់ និង សួរ សំណួរមួយក្នុងពេលជាមួយគ្នានោះដូចជា *"តើអ្នកឈ្មោះអ្វី ?" "តើអ្នកមានបងប្អូនប្រុស ឬស្រីដែរឬទេ ?" "តើអ្នកចូលចិត្តពណ៌អ្វីជាងគេ ?"* ជាដើម។ អ្នកដែលចាប់បានបាល់ត្រូវឆ្លើយនឹងសំណួររួចបោះបាល់បន្ត និងសួរសំណួរផ្ទាល់របស់គាត់។ ល្បែងនេះដំណើរការបានល្អ ប្រសិនបើអ្នកបន្ត បោះបាល់លឿន។

**ខ្ញុំចូលចិត្តធ្វើ...**

សូមឱ្យក្រុមអង្គុយជារង្វង់( មនុស្សពេញវ័យនិងកុមារ )។ សូមឱ្យអ្នករាល់គ្នាគិតពីអ្វីដែលគេចូលចិត្តធ្វើ។ បន្ទាប់មកជ្រើសរើសមនុស្សម្នាក់ឱ្យចាប់ផ្តើមដោយប្រាប់ដល់ក្រុម ឧទាហរណ៍ *"ខ្ញុំចូលចិត្តហែលទឹក"*។ បន្ទាប់មកអ្នកដែលនៅស្តាំដៃមនុស្សដំបូងនេះនឹងប្រាប់ដល់ក្រុមនូវអ្វីដែលមនុស្ស ដំបូងចូលចិត្តធ្វើ រួចគេក៏បន្ថែមនូវអ្វីដែលគេចូល ចិត្តធ្វើ ឧទាហរណ៍ *"សុខចូលចិត្តហែលទឹក ខ្ញុំចូលចិត្តដើរលំហែ"* មនុស្សនៅស្តាំដៃបន្តធ្វើបែបនេះ រហូតដល់អស់ មនុស្សក្នុងរង្វង់ ដោយអ្នកចុងក្រោយគេ ត្រូវនិយាយគ្រប់អ្វីដែលគ្រប់គ្នាចូលចិត្តធ្វើ។ សមាជិកដទៃក្នុងក្រុមអាចធ្វើកាយវិការបង្ហាញពីសកម្មភាពប្រសិនបើនរណាម្នាក់ពិបាករកនឹកឃើញ។

**ការដើរដោយជឿទុកចិត្តលើដៃគូ**

សូមឱ្យកុមារចាប់ដៃគូ។ កុមារម្នាក់នឹងត្រូវគេបិទភ្នែក ហើយកុមារម្នាក់ទៀតនឹងដឹកដៃគេឱ្យដើរ។ការដើរបែបនេះអាចធ្វើឡើងនៅទីវាលជុំវិញថ្នាក់ឬនៅលើផ្លូវ។ ការធ្វើបែបនេះអាចបន្តពី៥នាទី រហូតដល់កន្លះម៉ោងអាស្រ័យតាមអាយុកុមារ។ កុមារត្រូវផ្លាស់វេនគ្នា នៅពេលដល់ម៉ោងកំណត់។ សកម្មភាពនេះជួយបង្កើនបំណិនក្នុងការសង្កេតនិងការជឿទុកចិត្តនៅក្នុងក្រុម។

## សម្រាប់សិក្ខាកាមអាយុលើសពី៨ឆ្នាំ ៖

**ឈ្មោះ និងគុណនាម**

សិក្ខាកាមអង្គុយជារង្វង់។ សូមឱ្យសិក្ខាកាមម្នាក់ៗគិតពីគុណនាមមួយ ដើម្បីពណ៌នាពី អារម្មណ៏របស់ និងសុខភាពរបស់ពួកគេ។ គុណនាមត្រូវចាប់ផ្តើម ដោយអក្សរតែមួយនឹង ឈ្មោះរបស់ពួកគេដូចជា*"ខ្ញុំឈ្មោះសុខ ហើយខ្ញុំសប្បាយចិត្ត" ឬ" ខ្ញុំឈ្មោះរីណា ហើយខ្ញុំរីករាយក្នុងចិត្ត"*។ នៅពេលពួកគេនិយាយ ពួកគេអាចធ្វើកាយវិការដែលបញ្ជាក់ពីគុណនាមនោះ។ អ្នកដទៃទៀត នឹងនិយាយឈ្មោះកុមារនោះ និងធ្វើកាយវិការតាមសកម្មភាពគេបន្ទាប់ពីគេណែនាំខ្លួនរួច។ជាឧទាហរណ៍ *"គាត់ឈ្មោះសុខ ហើយគាត់សប្បាយចិត្ត"*។ អ្នកសម្របសម្រួលអាចចាប់ផ្តើមមុនគេដោយណែនាំខ្លួនគាត់តាមវិធីនេះ។

**ព្រះអាទិត្យរះលើ...**

សិក្ខាកាមអង្គុយជារង្វង់តូចដោយឱ្យមនុស្សម្នាក់នៅកណ្តាលរង្វង់ (អ្នកសម្របសម្រួល អាចចាប់ផ្តើមមុនគេ)។ អ្នក ដែលនៅកណ្តាលណែនាំខ្លួនមុនគេដោយនិយាយឈ្មោះរបស់គេ និង ល្បះមួយដែលពណ៌នាពីគេ។បន្ទាប់មក ស្រែកឡើងថា "ហេតុនេះព្រះអាទិត្យរះលើ..." និង ឱ្យឈ្មោះ ពណ៌មួយ លក្ខណៈនៃសម្លៀកបំពាក់ដែលមនុស្ស ខ្លះក្នុងក្រុមប្រើ ឬឱ្យឈ្មោះសកម្មភាព ទេពកោសល្យ ឬបំណិនដែលគេពេញចិត្ត។ ឧទាហរណ៍*"ខ្ញុំឈ្មោះអាមីខ្ញុំ ចូលចិត្តពណ៌ខៀវ ហើយព្រះអាទិត្យរះលើអ្នក ដែលពាក់អាវពណ៌ខៀវ"ឬ"ព្រះអាទិត្យរះលើអ្នក ដែលចូលចិត្តគូររូប "ឬ" ព្រះអាទិត្យរះលើអ្នកដែល ចេះច្រៀង"*។សិក្ខាកាមទាំងអស់ ត្រូវធ្វើតាមអ្វីដែលបាននិយាយ ត្រូវប្តូរកន្លែងគ្នា។ មនុស្ស ដែលនៅកណ្តាលព្យាយាមយកកន្លែងពួកគេនៅពេលពួកគេផ្លាស់កន្លែង ហេតុនេះនឹងមានមនុស្សម្នាក់នៅសល់ ដែលត្រូវនៅកណ្តាលគេ។ អ្នកនៅកណ្តាលថ្មីនេះស្រែកឡើងថា"ព្រះអាទិត្យ រះលើ..." និង ឱ្យឈ្មោះពណ៌សម្លៀក បំពាក់ បំណិន ឬទេពកោសល្យ។

**"សួស្តី" ជាភាសាជាច្រើន ក្នុងរយៈពេល៧២វិនាទី**

សិក្ខាកាមក្រោកឈររាយគ្នាក្នុងបន្ទប់។ អ្នកសម្របសម្រួលបង្រៀនពាក្យថា *"សួស្តី" ជាបីបួនភាសា។ ឧទាហរណ៍ "ហេឡូ" (ភាសាអង់គ្លេស) "កូនីឈីវ៉ាក់" (ភាសាជប៉ុន) "ហូឡា" (ភាសាអេស្ប៉ាញ) "អាសាឡាមូ អាលីកូម" (ភាសាអារ៉ាប) "ហាអេ" (ភាសាអាព្រិច) "ប៊ុងហ្សួ" (ភាសាបារាំង)* ។ល។ សិក្ខាកាមថាតាមពាក្យទាំង នោះដើម្បីឱ្យពួកគេនិយាយវាបាន និងចាំ។ គេអាចសរសេរវាលើក្រដាសផ្ទាំងធំ ដើម្បីឱ្យពួកគេអាចអាន និង ទន្ទេញ។ បន្ទាប់មកក្រោយពីរាប់បានបី(៣)អ្នកសម្របសម្រួលធ្វើសញ្ញាឱ្យសិក្ខាកាមដើរចុះឡើងក្នុងបន្ទប់។ ពួកគេនឹងជួបអ្នកដែលគេមិនស្គាល់ ហើយស្វាគមន៍ពួកគេដោយប្រើពាក្យ"សួស្តី"ជាច្រើនភាសា និងបន្ថែមភាសា ផ្ទាល់ខ្លួន សួរឈ្មោះ និង ការពណ៌នាខ្លីថាពួកគេជានរណាក្នុងរយៈពេល៧២វិនាទី។ បន្ទាប់ពី៧២វិនាទីរួច សូមរាប់ដល់៣ម្តងទៀតនិងសូមឱ្យពួកគេដូរ និង រកអ្នកដទៃក្នុងបន្ទប់ ដែលពួកគេមិនទាន់ បានជួប និងបន្ត ធ្វើបែប នេះឡើងវិញ ទៅតាមពេលវេលាដែលមាន។

# ឧបសម្ព័ន្ធទី៤៖ ល្បែងស្វាងអារម្មណ៍

**ការណែនាំ:** អ្នកសម្របសម្រួលអាចជ្រើសរើសល្បែងស្វាងគំនិតពីជម្រើសខាងក្រោម និង គប្បីធ្វើការកែសម្រួលតាមការគួរ សម្រាប់សម្របតាមតម្រូវការអតិវឌ្ឍន៍ខាងបញ្ញា ឬផ្លូវកាយរបស់សិក្ខាកាម។

## សម្រាប់សិក្ខាកាមអាយុលើសពី ៥ឆ្នាំ៖

**ចលនាផ្ទាល់ខ្លួន**

សូមឱ្យកុមារឈរជារង្វង់ និង ខិតចេញពីគ្នាដោយលាតសន្ទឹងដៃធ្វើយ៉ាងណាឱ្យនៅចម្ងាយ ដែលមិនប៉ះដៃគ្នា។ អ្នកសម្របសម្រួលសូមឱ្យកុមារធ្វើ"ចលនាផ្ទាល់ខ្លួន" ដោយឈរលើជើងទាំងពីរ រួចយកដៃប៉ះម្រាមជើងអោនងើបៗ ធ្វើជាលោតឡើងគេងលើគ្រែ ធ្វើជាអណ្តែតដូចពពកលើមេឃ។

**បត់ និង នៅនឹង**

សូមឱ្យកុមារធ្វើចលនានៅពេលភ្លេងលេងនិង ឱ្យពួកគេឈប់"នៅនឹងមួយកន្លែង"ពេលភ្លេងឈប់។ ដើម្បីឱ្យកាន់តែមានលក្ខណ:រស់រវើក សូមនិយាយពីចលនារបស់កុមារម្នាក់ៗ ( ឧទាហរណ៍ពិសីកំពុង បត់កែងដៃ" "តារាកំពុងបត់ជង្គង់")។

**គ្រាប់តាមកាយវិការកីឡាករ**

អ្នកសម្របសម្រួលសូត្រពីកីឡាដូចតទៅ ដើម្បីឱ្យកុមារធ្វើសកម្មភាពតាមក្នុងរយ:ពេលយ៉ាងតិច១០-១៥វិនាទី ៖

- រត់
- បណ្តើរបាល់
- វាយសីវីសបាល់តេនីស
- លោតឆ័ត្រយោងចុះពីទីខ្ពស់
- ទទួលបាល់ទះដែលគេគប់
- យារដៃវាយកូនហ្គោល
- ចោលបាល់
- បាញ់ព្រួញ
- ហែលក្នុងទឹក
- លោតបញ្ចូលបាល់បោះក្នុងសំណាញ់

**ធ្វើហាក់ដូចជា**

អ្នកសម្របសម្រួលអានល្បះមួយឱ្យក្រុមស្តាប់ និង សូមឱ្យកុមារធ្វើសកម្មភាពតាមល្បះ នីមួយៗក្នុងរយ:ពេល ៣០វិនាទី ៖

- រត់នៅមួយកន្លែងហាក់ដូចជាខ្លាឃ្មុំគួរឱ្យខ្លាចដ៏ធំមួយកំពុងដេញអ្នក
- លោតមួយកន្លែងធ្វើហាក់ដូចជាសម្តែងរឿងកំប្លែង
- លោតចាប់ធ្វើហាក់ដូចជាអ្នកកំពុងចាប់ប៉េងប៉ោងលើអាកាស
- ដើរជាចង្វាក់នៅមួយកន្លែង និងវាយស្គរធ្វើហាក់ដូចជាអ្នកកំពុងដើរក្បួនវាយស្គរ
- លាបពណ៌ធ្វើហាក់ដូចជាមានជក់លាបពណ៌ដាក់នៅលើក្បាលអ្នក

- ហែលធ្វើហាក់ដូចជាអ្នកនៅក្នុងអាងដ៏ធំ
- ធ្វើចលនាជើងលើឥដ្ឋធ្វើហាក់ដូចជាអ្នកកំពុងជិះស្គីលើទឹកកក
- រលាស់ខ្លួនធ្វើហាក់ដូចជាអ្នកជាឆ្កែដែលទទឹករោមអស់

## សម្រាប់សិក្ខាកាមអាយុលើសពី៨ឆ្នាំ ៖

### ចានផ្លែឈើ

កុមារអង្គុយពែនភ្នែនជារង្វង់។ កុមារម្នាក់ដើរតួជា“អ្នកហៅ”ឈរនៅកណ្តាលរង្វង់។ គ្មាន កន្លែងសម្រាប់ឱ្យអ្នកហៅអង្គុយក្នុងរង្វង់ទេ ។

អ្នកសម្របសម្រួលដាក់ឈ្មោះឱ្យសិស្សម្នាក់ៗជា “ម្នាស់” “ឪឡឹក” “ចេក ”ឬ “ស្វាយ” ( ទៅតាមលំដាប់រៀងរបស់កុមារ )។ “អ្នកហៅ” ហៅឈ្មោះផ្លែឈើ “ក្រូច”។ រាល់អ្នកដែលមានឈ្មោះថា“ក្រូច”ត្រូវដូរកន្លែងគ្នា។

អ្នកហៅព្យាយាមយកកន្លែងទំនេរ មុនពេលអ្នកដែលត្រូវដើរតួជា “ក្រូច” ដូរកន្លែងគ្នាបាន។ អ្នកដែលគ្មានកន្លែងក្លាយជាអ្នកហៅបន្ត ហើយហៅឈ្មោះផ្លែឈើមួយទៀត។

### ល្បែងប៉ះគ្នា

សូមឱ្យអ្នករាល់គ្នាឈររាយពេញក្នុងកន្លែងលេង។ នៅពេលអ្នកនិយាយថា “ទៅ” គ្រប់គ្នា ព្យាយាមប៉ះអ្នកដទៃ។ បើមនុស្សម្នាក់ប៉ះនរណាម្នាក់អ្នកដែលត្រូវគេប៉ះត្រូវអង្គុយចុះរហូតគេលេង ចប់។ ក៏ប៉ុន្តែបើមនុស្សពីរនាក់ប៉ះគ្នាក្នុងពេលស្មើគ្នាពួកគេត្រូវអង្គុយចុះទាំងពីរនាក់។ គេបន្តលេង បែបនេះរហូតដល់សល់តែមនុស្សម្នាក់មិនទាន់អង្គុយ។ អ្នកចុងក្រោយដែលនៅឈរជាអ្នកឈ្នះ។

### សំណាញ់មនុស្ស

ចែកមនុស្សប្រុស និង មនុស្សស្រីជាពីរក្រុម។ ឱ្យក្រុមនីមួយៗកាន់ដៃគ្នាធ្វើជារង្វង់ហើយ ឱ្យពួកគេទាំងអស់បង្ខិតចូលគ្នារហូតដល់ពួកគេនៅក្បែរគ្នា ហើយរង្វង់មានទំហំតូចចង្អៀត។ សូមបាប់ឱ្យពួកគេទំលាក់ដៃចុះ។ឥឡូវម្នាក់ៗត្រូវចាប់ដៃពីរផ្សេងទៀត ដែលមិនមែនជាដៃរបស់អ្នកដែលនៅជាប់ពួកគេ។ នោះវានឹងក្លាយជាសំណាញ់ចាក់ស្រែសគ្នាដ៏ធំមួយ។ បន្ទាប់មកសិក្ខាកាមត្រូវស្រាយ សំណាញ់នោះដោយមិនលែងដៃដែលខ្លួន ចាប់។ ពួកគេត្រូវដើររំលងដៃ លូនក្រោមដៃ និង លើកដៃចុះឡើង ប៉ុន្តែការធ្វើបែបនេះមានលក្ខណៈកំប្លែង និងទាមទារភាពឈ្លាសវៃ។

# ឧបសម្ព័ន្ធទី ៥៖គំនូសអំពីរាងកាយរបស់កុមារី និងកុមារា

## សម្រាប់ប្រើក្នុងប្រធានបទទី ១ អាយុ៥-៧ ឆ្នាំ និង  អាយុ ៨-១០ ឆ្នាំ



# ឧបសម្ព័ន្ធទី ៦៖ សេណារីយ៉ូស្តីពី “អារម្មណ៍អាចផ្លាស់ប្តូរ[23]”

## សម្រាប់ប្រើក្នុងប្រធានបទទី ២ អាយុ ៨-១០ ឆ្នាំ

**ការណែនាំ៖** អ្នកសម្របសម្រួលអាចពិនិត្យសេណារីយ៉ូឡើងវិញ និងធ្វើការកែសម្រួលតាមការចាំបាច់ ដើម្បីឆ្លើយតបទៅតាមភាពចាំបាច់សម្រាប់កុមារ (ឧទាហរណ៍ កុមារកំព្រា ឬកុមារអនាថា កុមារមកពីទីក្រុង និងកុមារមកពីភូមិជនបទ)។ ត្រៀមសេណារីយ៉ូមួយច្បាប់សម្រាប់មួយក្រុមតូច។ ចែកកុមារទៅជាក្រុមតូចៗ ដើម្បីឱ្យពួកគេពិភាក្សាគ្នាលើសេណារីយ៉ូនោះ។ សួរទៅកុមារឱ្យសម្រេចចិត្តថា តើតួនោះមានអារម្មណ៍ដូចម្តេចកាលពីដំបូង ហើយក្រោយមកអាម្មណ៍នោះក៏ផ្លាស់ប្តូរទៅជាយ៉ាងណា? សូមកត់ត្រាឈ្មោះអារម្មណ៍ បូករួមជាមួយសញ្ញាផ្លូវកាយដែលអមជាមួយអារម្មណ៍នោះ ដែលប្រហែលជាអាចប្រែប្រួលផងដែរ។ កុមារអាចប្រើប្រាស់កាតគំរូដែលបានផ្តល់ឱ្យ ដើម្បីពិពណ៌នាអំពីអារម្មណ៍របស់តួ។ វិធីបែបអន្តរកម្មមួយទៀតដែលអាចយកមកប្រើបាន គឺត្រូវចម្លងកាតគំរូយកទៅដាក់លើក្រដាសផ្ទាំងធំ រួចបិទក្រកាសនេះនៅជ្រុងផ្សេងៗក្នុងបន្ទប់។ បន្ទាប់មកកុមារអាចដើរទៅរកគំរូ/អារម្មណ៍នោះ (ហើយផ្លាស់ទីតាំងអារម្មណ៍មួយចំនួនតាមការចាំបាច់) ស្របពេលដែលអ្នកអាន សេណារីយ៉ូឮៗ។ ពិភាក្សាគ្នាក្នុងក្រុមធំ។

[23] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញ៉ូវសោតវ៉េល លេខាធិការដ្ឋានសុខុមាលភាពសិស្ស (១៩៩៧) ការអប់រំស្តីពីការការពារកុមារ ៖ ឯកសារ កម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ








**ស្ថានភាពទី ១**

_____( ឈ្មោះកុមារី ) នៅសួនច្បារជាមួយមិត្តភក្តិរបស់ខ្លួន។ ពួកគេកំពុងលេងបាល់ទាត់។ ក្រុមរបស់ ____ ( ឈ្មោះកុមារី ) កំពុងតែលេងអន់ជាងគេ។ ចុងក្រោយ _____( ឈ្មោះកុមារីបានទាត់បាល់ពិន័យ ជាហេតុធ្វើឱ្យក្រុមរបស់នាងឈ្នះ។ ដល់ម៉ោងត្រូវទៅផ្ទះវិញហើយ។ _____( ឈ្មោះកុមារី ) មានអារម្មណ៍ថាមានមោទនភាពយ៉ាងខ្លាំង។ នាងលាមិត្តភក្តិរបស់នាង។ នាងបានដើរកាត់សួនច្បាសរ។ ក្រុមក្មេងធំៗចំនួន ៣នាក់ កំពុងអង្គុយជុំវិញទោង រួចហួចដាក់នាង និងញ៉ោះនាង។

**ស្ថានភាពទី ២**

_____( ឈ្មោះកុមារា ) នៅផ្ទះតែម្នាក់ឯង។ ឪពុករបស់គេជិតមកដល់វិញហើយ។ _____( ឈ្មោះកុមារា ) ចូលទៅក្នុងផ្ទះដោយខ្លួនឯង រួចទូរស័ព្ទទៅប្រាប់ម្តាយនៅកន្លែងធ្វើការថាខ្លួនបានមកដល់ផ្ទះដោយសុវត្ថិភាពហើយ។ ម្តាយរបស់ _____( ឈ្មោះកុមារា ) នោះក៏និយាយថា គាត់មានអ្វីម្យ៉ាងគួរឱ្យភ្ញាក់ផ្អើលជូនទៅគាត់នៅយប់នេះ។ _____ ( ឈ្មោះកុមារា ) មានអារម្មណ៍រីករាយយ៉ាងខ្លាំង ហើយបានចាប់ផ្តើមធ្វើការងារដាក់ឱ្យធ្វើនៅផ្ទះរបស់ខ្លួន។ មានមនុស្សម្នាក់កំពុងគោះទ្វារមុខឮខ្លាំងៗ។ _____( ឈ្មោះកុមារា ) មើលទៅខាងក្រៅ ហើយបានឃើញអ្នកជិតខាងម្នាក់។ ឪពុកម្តាយគាត់បានគ្រាប់ថាមិនឱ្យគាត់បើកទ្វារឱ្យនរណាម្នាក់ឡើយ។

**ស្ថានភាពទី ៣**

_____( ឈ្មោះកុមារា ) ទៅគេងនៅផ្ទះមិត្តភក្តិខ្លួន។ ពួកគេលេងជាមួយគ្នាយ៉ាងសប្បាយ រហូតទាល់តែមិត្តរបស់គេបានវាយគ្នាជាមួយគេ ហើយបានចាប់ផ្តើមនិយាយចំអន់គេ។

**ស្ថានភាពទី ៤**

ម្តាយរបស់ _____( ឈ្មោះកុមារី ) បានគេងនៅពេទ្យ។ គាត់ទើបសម្រាលកូន។ _____( ឈ្មោះកុមារី ) ចង់ដឹងសុខទុក្ខម្តាយរបស់ខ្លួន និងចង់ដឹងថាតើកូននោះគួរឱ្យស្រលាញ់ ឬទេ ។ ពេលដែលម្តាយរបស់ _____( ឈ្មោះកុមារី ) បីទារកទើបកើតចូលមកដល់ផ្ទះ _____( ឈ្មោះកុមារី ) បានបីទារកនោះ ហើយទារកនោះហាក់ដូចជាញញឹមដាក់នាង។

**ស្ថានភាពទី ៥**

_____( ឈ្មោះកុមារា ) កំពុងសើចឮៗ។ ពូរបស់គេកំពុងចាក់ក្រឡេកគេ។ ពូរបស់គេបន្តចាក់ក្រឡេកគេទៀត ហើយចាប់ផ្តើមបោកចំបាប់ជាមួយគេ។ _____( ឈ្មោះកុមារា ) ចាប់ផ្តើមមានអារម្មណ៍មិនសូវស្រួល។ គាត់ចង់ឱ្យការចាក់ក្រឡេក និងការបោកចំបាប់នោះត្រូវបានបញ្ឈប់។ គាត់បានសូមឱ្យពូគាត់ឈប់ ប៉ុន្តែពូគាត់មិនរវល់នឹងសំដីគាត់ឡើយ។

**ស្ថានភាពទី៦**

_____( ឈ្មោះកុមារី ) កំពុងឈរនៅសាលារៀនថ្មី។ នាងជួបជាមួយនាយកសាលា និងគ្រូថ្មីរបស់នាង ហើយបន្ទាប់មកនាងក៏ទៅកាន់ថ្នាក់ថ្មីរបស់នាង។ នាងអង្គុយនៅកន្លែងរបស់នាង។ នាងបានឃើញថា នាងអង្គុយជាប់កុមារីម្នាក់ ដែលនាងធ្លាប់បានជួបពីមុនមក។ ពួកគេញញឹមរកគ្នា។

# ឧបសម្ព័ន្ធទី៧៖ កាតសេណារីយ៉ូស្តីពី “ការប៉ះពាល់សមស្រប ឬជាការរំលោភបំពានផ្លូវភេទ[24]"

## សម្រាប់ប្រើប្រាស់ក្នុងប្រធានបទទី៣ អាយុ ៨-១០ ឆ្នាំ

**ការណែនាំ៖** អ្នកសម្របសម្រួលអាចពិនិត្យសេណារីយ៉ូឡើងវិញ និងធ្វើការកែសម្រួលតាមការចាំបាច់ ដើម្បីឆ្លើយតបទៅតាមភាពចាំបាច់សម្រាប់កុមារ ( ឧទាហរណ៍ កុមារកំព្រា ឬកុមារអនាថា កុមារមកពីទីក្រុង និងកុមារមកពីភូមិជនបទ )។ ត្រៀមកាតសេណារីយ៉ូមួយច្បាប់សម្រាប់ក្រុមតូចនីមួយៗ។ បែកកុមារទៅជាក្រុមតូចៗ ដើម្បីឱ្យពួកគេពិភាក្សាគ្នាលើស្ថានភាពនោះ។ ប្រាប់អ្នកចូលរួមឱ្យសម្រេចចិត្តថាតើនោះជាការប៉ះពាល់សមស្រប ឬជាការរំលោភបំពានផ្លូវភេទ។ កុមារអាចប្រើប្រាស់កាតគំរូដែលផ្តល់ឱ្យដើម្បីបែកសេណារីយ៉ូ។ វិធីបែបអន្តរកម្មមួយទៀតដើម្បីធ្វើសកម្មភាពនេះគឺត្រូវ ចម្លងកាតគំរូយកទៅដាក់លើក្រដាស ផ្ទាំងធំ រួចបិទក្រដាសនេះនៅជ្រុងផ្សេងៗក្នុងបន្ទប់។ បន្ទាប់មកកុមារអាចដើរទៅរកគំរូ/អារម្មណ៍នោះ ស្របពេលដែលអ្នកអានសេណារីយ៉ូឮៗ។



[24] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញ៉ូវសោតវ៉េល លេខាធិការដ្ឋានសុខុមាលភាពសិស្ស ( ១៩៩៧ ) ការអប់រំស្តីពីការការពារកុមារ ៖ ឯកសារ កម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ

**1** កុមារាជំម្នាក់ បានចូលរួមជាមួយ ____ (ឈ្មោះកុមារា) និងមិត្តរបស់គេមួយក្រុម។ ថ្ងៃមួយ ក្រោយពេលចេញពីរៀន គេបានបង្ហាញរូបថតជាច្រើនសន្លឹកដល់ ____(ឈ្មោះកុមារា) និងមិត្តភក្តិរបស់គេ។ មនុស្សទាំងអស់នៅក្នុងរូបថតនោះសុទ្ធតែអាក្រាត។

**2** ____(ឈ្មោះកុមារី) មានអាយុដប់ឆ្នាំ ហើយកំពុងរស់នៅជាមួយម្តាយមីង ________ (ឈ្មោះស្ត្រី). ____(ឈ្មោះកុមារី) កំពុងមុជទឹក។ ____(ឈ្មោះស្ត្រី) ជូតសម្ងួតខ្លួនរបស់គេ និងយកប្រេងក្រអូបមកឈ្លីលាបពេញរាងកាយរបស់ ____(ឈ្មោះកុមារី)។ ____(ឈ្មោះកុមារី) មានអារម្មណ៍ ថាមិនស្រួលក្នុងចិត្តទាល់តែសោះ។

**3** ____(ឈ្មោះកុមារី) កំពុងស្លៀកពាក់។ ពូរបស់នាងដើរមកកាន់មាត់ទ្វារបន្ទប់របស់នាង។ គាត់ឈប់ រួចនិយាយថាគាត់ចង់ប៉ះខ្លួនប្រាណទាំងមូលរបស់ ____(ឈ្មោះក្មេងស្រី)

**4** កុមារាពីរនាក់កំពុងឡើងដើមឈើមួយដើម។ ក្មេងម្នាក់ធ្លាក់ចុះមកដី ហើយមានរបួស។ គេស្រែកយំ។ ក្មេងម្នាក់ទៀតចុះមករកមិត្តខ្លួន។ គាត់ដាក់ដៃត្រកងមិត្តគាត់ ហើយប្រាប់មិត្តថាមិនអីនោះឡើយ។

**5** ផ្នែកសម្ងាត់របស់ ____(ឈ្មោះក្មេងប្រុស) ត្រូវបានគេទាត់ចំ នៅក្នុង ពេលលេងល្បែងបាល់ទាត់។ វេជ្ជបណ្ឌិត កំពុងពិនិត្យលើ ____(ឈ្មោះកុមារា) ដើម្បីពិនិត្យមើលថាតើគេមានបញ្ហាអ្វីឬទេ ។ គ្រូបង្វឹកកីឡាក៏នៅជាមួយគាត់ដែរ។

**6** ____(ឈ្មោះបុរស) ដែលជាមិត្តរបស់គ្រួសារម្នាក់ចង់ឱ្យ ____(ឈ្មោះកុមារា) ដោះសម្លៀកបំពាក់ចេញ ដើម្បីឱ្យគាត់ថតរូប។ ____(ឈ្មោះកុមារា) មានអារម្មណ៍ភាន់ភាំងយ៉ាងខ្លាំង។ អាកាសធាតុត្រជាក់ ហើយគេមិនយល់ថាហេតុអ្វីបានជា ____ (ឈ្មោះបុរស) ចង់ឱ្យគេស្រាត ដើម្បីថតរូប។

**7** ____(ឈ្មោះកុមារា) ឈឺ។ គេគេងសម្រាកនៅលើគ្រែ។ ឪពុករបស់គេ យកទឹកក្រូចឱ្យគេញ៉ាំ និងអានរឿងឱ្យគេស្តាប់។ គេមានអារម្មណ៍ថាទទួលបានការយកចិត្តទុកដាក់ និងក្តីស្រលាញ់។

**8** នៅពេល ____(ឈ្មោះកុមារី) ឃើញម្តាយនៅរបងសាលា នៅម៉ោងចេញទៅផ្ទះ នាងរត់ទៅថើបម្តាយ។ ម្តាយនាងឱបនាងវិញ។ ____ (ឈ្មោះកុមារី) ចូលចិត្តឱ្យម្តាយនាងឱប។

**9** ____(ឈ្មោះកុមារី) ប្រើកៅអីរុញសម្រាប់ជនពិការ។ នាងត្រូវការឱ្យគេជួយលើកពីកៅអីរុញទៅកាន់កៅអីសាលារបស់នាង។ គ្រប់ពេលដែលគ្រូជួយលើកនាង គាត់តែងទះកំប៉េះគូទនាងថ្នមៗ។

**10** ____(ឈ្មោះកុមារា) មានត្រចៀកថ្លង់ ហើយបានធ្វើឱ្យរបួសជើងពេលកំពុងលេងបាល់ទាត់។ គ្រូរបស់គាត់ចាប់ជើងរបស់គាត់ ដើម្បីមើលថាតើរបួស ធ្ងន់ធ្ងរកម្រិតណា។

# ឧបសម្ព័ន្ធទី៨ ៖ ក្រដាសវាយតម្លៃខ្លួនឯង[25]

## សម្រាប់ប្រើក្នុងប្រធានបទទី ៧, ៨-១០ ឆ្នាំ

**ការណែនាំ**: សូមរៀបចំឯកសារថតចម្លងមួយច្បាប់សម្រាប់សិក្ខាកាមម្នាក់ៗ។

| ប្រសិនបើខ្ញុំមានអារម្មណ៍ថាគ្មានសុវត្ថិភាព...<br>( សូមផាត់ពណ៌លើមុខដែលសមស្រប ) | បាទ/ចាស | អាចទៅរួច | អាចជាការពិបាក |
|---|---|---|---|
| ខ្ញុំអាចនិយាយថា “ទេ” និង “ទៅ” ពីដៃគូ | ☺ | 😐 | ☹ |
| ខ្ញុំអាចនិយាយថា “ទេ” និង “ទៅ” ពីក្មេងធំជាងខ្ញុំ និងមានអំណាចជាងខ្ញុំ | ☺ | 😐 | ☹ |
| ខ្ញុំអាចនិយាយថា “ទេ” និង “ទៅ” ពីជនប្លែកមុខ | ☺ | 😐 | ☹ |
| ខ្ញុំអាចនិយាយថា “ទេ” និង “ទៅ” ពីមនុស្សពេញវ័យដែលខ្ញុំស្គាល់ | ☺ | 😐 | ☹ |

មូលហេតុដែលធ្វើឱ្យខ្ញុំកាន់តែពិបាកក្នុងការនិយាយថា ទេ និងទៅពីអ្នកដទៃ អាចបណ្ដាលមកពី...

[25] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញូវសោតវ៉េល លេខាធិការដ្ឋានសុខុមាលភាពសិស្ស ( ១៩៩៧ ) ការអប់រំស្ដីពីការការពារកុមារ ៖ ឯកសារ កម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ

# ឧបសម្ព័ន្ធទី ៩៖ កាតរឿងសម្ងាត់[26]

## សម្រាប់ប្រើក្នុងប្រធានបទទី ៨ អាយុ ៨-១០ ឆ្នាំ

**ការណែនាំ៖** អ្នកសម្របសម្រួលអាចពិនិត្យសេណារីយ៉ូឡើងវិញ និងធ្វើការកែសម្រួលតាមការចាំបាច់ ដើម្បី ឆ្លើយតបតាមភាពសមស្របសម្រាប់កុមារ ( ឧទាហរណ៍ កុមារកំព្រា ឬកុមារអនាថា កុមារមក ពីទីក្រុង និងកុមារមកពីភូមិជនបទ )។ ត្រៀមកាតរឿងសម្ងាត់មួយច្បាប់សម្រាប់ក្រុមតូចនីមួយៗ។ ចែកកុមារទៅជា ក្រុមក្នុងមួយក្រុមមានគ្នាបួននាក់។ ក្រុមនីមួយៗ ទទួលបានកាតរឿងសម្ងាត់មួយឈុត។ កុមារប្តូរវេនគ្នា ដើម្បីអានកាត និងចែកកាតទៅតាមក្រុម “មានអារម្មណ៍ល្អនឹងរក្សាទុក” ឬ “មានអារម្មណ៍ថាពិបាកបើទុក បន្តទៀត”។ កុមារប្រើប្រាស់កាតគំរូ ដែលត្រូវបានផ្តល់ឱ្យដើម្បីចែកការសម្ងាត់ទៅតាមក្រុម។ វិធីបែប    អន្តរកម្មមួយទៀតដើម្បីធ្វើសកម្មភាពនេះ គឺត្រូវចម្លងកាតគំរូទៅក្នុងក្រដា□សផ្ទាំងធំ រួចបិទក្រដាសនេះនៅ ជ្រុងផ្សេងៗក្នុងបន្ទប់។ បន្ទាប់មកកុមារអាចដើរទៅរកគំនូរដែលត្រឹមត្រូវនោះ ស្របពេលដែល អ្នកអានសេ ណារីយ៉ូពួៗ។ អ្នកសម្របសម្រួលគួរសរសេរចម្លើយត្រឹមត្រូវនៅលើក្តារខៀន ឬក្រដាសដើម្បី ឱ្យក្រុមអាចពិនិត្យលើការសម្រេចចិត្តរបស់ខ្លួន ( មានអារម្មណ៍ល្អនឹងរក្សាទុក៖ ១,២,៤,៥,៦ “មានអារម្មណ៍ថាពិបាកបើទុកបន្តទៀត”៖ ៣, ៧, ៨ )។ អ្នកសម្របសម្រួលគួរពន្យល់ប្រាប់ថា កុមារគួរនិយាយប្រាប់ទៅមនុស្សពេញវ័យ ដែលគួរឱ្យទុកចិត្តអំពីការសម្ងាត់ទាំងឡាយណា ដែលគេមាន អារម្មណ៍ថាពិបាកបើទុកបន្តទៀត។





[26] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញ៉ូវសោតវ៉េល លេខាធិការដ្ឋានសុខុមាលភាពសិស្ស ( ១៩៩៧ ) ការអប់រំស្តីពីការការពារកុមារ ៖ ឯកសារ កម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ

✂

១ ម៉ាក់ និងប៉ាទើបដឹងថាម៉ាក់មានផ្ទៃពោះ។ ទាំងអស់គ្នាសប្បាយចិត្តណាស់។ ពួកគេនៅមិនទាន់ចង់ឱ្យអ្នកនិយាយរឿងនេះប្រាប់នរណា"ទេ" ។ ពួកគេប្រាប់អ្នក កុំឱ្យនិយាយប្រាប់នរណាម្នាក់ឱ្យសោះមុនពេលទារកនោះកើត។

២ គ្រូបង្រៀនតន្ត្រីនៅសាលា នឹងត្រូវ"ចាកចេញ"។ គ្រប់គ្នានឹងនឹកគាត់។ សិស្សនៅថ្នាក់របសអ្នក បានគ្រោងធ្វើពិធីជប់លៀងលាគ្នាជូនគាត់។ ពួកគាត់ មិនទាន់ចង់ឱ្យគាត់ដឹងពីរឿងនេះទេ។

៣ អ្នកស្នាក់នៅផ្ទះមិត្តរបស់អ្នក។ បងប្រុសរបស់មិត្តអ្នក ប្រាប់អ្នកឱ្យដោះខោអាវចេញ និងងូតទឹកតែពីរនាក់ជាមួយគាត់។ គាត់ប្រាប់អ្នកថា អ្នកមិនត្រូវប្រាប់នរណាជាដាច់ខាត បើពុំដូច្នោះទេ អ្នកនឹងមានបញ្ហា។

៤ ទាំងអស់គ្នាក្នុងគ្រួសារអ្នក សុទ្ធតែចូលចិត្តស្ត្រីដែលរស់នៅជាប់របងគ្នានោះ។ ស្ត្រីនោះចិត្តល្អ ហើយតែងបេះផ្លែក្រូចឆ្មារគាត់ឱ្យអ្នកផ្ទះអ្នក។ ម៉ាក់និងប៉ានិយាយថា គាត់នោះចម្លែកបន្តិច ព្រោះគាត់និយាយជាមួយដើមឈើគាត់។ ពួកគាត់ប្រាប់អ្នកកុំឱ្យនិយាយរឿងនេះប្រាប់មិត្តរបស់អ្នក។

៥ មិត្តរបស់អ្នកម្នាក់ ដែលមកពីក្លឹបកុមារមានជម្ងឺ។ អ្នកទាំងអស់គ្នាធ្វើកាត ហើយអ្នកដឹកនាំក្លឹបបញ្ជូនសំបុត្រនោះទៅតាមប្រៃសណីយ៍។ ប្រសិនបើអ្នកជួបមិត្តរបស់អ្នកដែលកំពុងមានជម្ងឺនោះ មុនពេលគេបានទទួលកាត អ្នកមិនអាចនិយាយអំពីរឿងកាតនេះប្រាប់គាត់បានទេ ។

៦ លោកយាយរបស់អ្នកចូលចិត្តពិសាទឹកក្រូចឆ្មាពណ៌ផ្កាឈូក។ គ្រប់គ្នានៅក្នុងផ្ទះអ្នកគិតថានេះជារឿងគួរឱ្យអស់សំណើច។ លោកយាយរបស់អ្នកក៏សើចពីរឿងនេះដែរ។ គ្រួសារអ្នកប្រាប់អ្នកកុំឱ្យនិយាយរឿងនេះប្រាប់មិត្តរួមថ្នាក់របស់អ្នក។

៧ ពេលប៉ាអ្នកខឹង គាត់តែងវាយអ្នកនឹងដំបង។ ប្រមុះរបស់អ្នកធ្លាប់បែកពីរដងមកហើយ។ ម៉ាក់និងប៉ាហាមអ្នកមិនឱ្យប្រាប់នរណាអំពីមូលហេតុដែលធ្វើឱ្យប្រមុះបែកនោះឡើយ។

៨ គ្រូកីឡារបស់អ្នកតែងប៉ះផ្នែកឯកជននៃរាងកាយរបស់អ្នក ពេលអ្នកហ្វឹកហាត់។ គ្រូបង្វឹក អ្នកក៏ធ្វើដូច្នេះដាក់មិត្តរបស់អ្នកដែរ។ គ្រូបង្វឹក បានគំរាមថានឹងឈប់បង្រៀនក្រុមអ្នក ប្រសិនបើមាននរណាម្នាក់ និយាយអំពីរឿងនេះ។

# ឧបសម្ព័ន្ធទី១០ ៖ ទម្រង់វាយតម្លៃ[27]

## សម្រាប់ប្រើក្នុងសេចក្តីសន្និដ្ឋាន អាយុ៨-១០ ឆ្នាំ, ១១-១៧ ឆ្នាំ

**ការណែនាំ**: សូមរៀបចំឯកសារថតចម្លងមួយច្បាប់សម្រាប់សិក្ខាកាមម្នាក់ៗ។

កាលបរិច្ឆេទ:______________អាយុអ្នក ៖: __________________ ប្រុស ឬស្រី ៖ ______________________

( សូមផាត់ពណ៌មុខដែលសមស្រប )

| | ☺ | 😐 | ☹ |
|---|---|---|---|
| ១. ខ្ញុំពេញចិត្តចំពោះមេរៀនថ្ងៃនេះ | ☺ | 😐 | ☹ |
| ២. ខ្ញុំបានរៀនរបៀបដែលមានប្រយោជន៍ដើម្បីរក្សា សុវត្ថិភាពខ្ញុំ | ☺ | 😐 | ☹ |

៣. ចំណុចសំខាន់បំផុតដែលខ្ញុំបានរៀនថ្ងៃនេះគឺ ៖

.................................................................................................................................................

.................................................................................................................................................

៤. ខ្ញុំចង់រៀនបន្ថែមពី ៖

.................................................................................................................................................

.................................................................................................................................................

៥. ប្រសិនបើខ្ញុំព្រួយបារម្ភ ឬភ័យខ្លាចអំពីរឿងអ្វីមួយ ខ្ញុំអាចធ្វើសកម្មភាពមួយចំនួនដើម្បីស្វែងរកជំនួយ

.................................................................................................................................................

.................................................................................................................................................

៦. ខ្ញុំនឹងចែករំលែកអ្វីដែលខ្ញុំបានរៀនថ្ងៃនេះ៖

.................................................................................................................................................

.................................................................................................................................................

[27] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញ៉ូវសោតវ៉េល លេខាធិការដ្ឋានសុខុមាលភាពសិស្ស ( ១៩៩៧ ) ការអប់រំស្តីពីការការពារកុមារ ៖ ឯកសារ កម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ

# ឧបសម្ព័ន្ធទី ១១៖ សន្លឹកកិច្ចការស្តីពីការកំណត់អាកប្បកិរិយាមិនសមរម្យ[28]

## សម្រាប់ប្រើក្នុងប្រធានបទទី២ អាយុ ១១-១៧ ឆ្នាំ

**ការណែនាំ៖** អ្នកសម្របសម្រួលគួរពិនិត្យសេណារីយ៉ូឡើងវិញ និងធ្វើការកែសម្រួលតាមការចាំបាច់ ដើម្បីឱ្យឆ្លើយតបទៅតាមភាពសមស្របសម្រាប់ក្រុមកុមារ (ឧទាហរណ៍ កុមារកំព្រា ឬកុមារអនាថា កុមារមកពីទីក្រុង និងកុមារមកពីភូមិតាមជនបទ)។ សូមត្រៀមមួយច្បាប់សម្រាប់ អ្នកចូលរួមម្នាក់ៗ។ ចែកសំណៅសន្លឹកកិច្ចការស្តីពីការកំណត់អាកប្បកិរិយាមិនសមស្រប ដល់អ្នកចូលរួមម្នាក់ៗ និងអានស្ថានភាពទាំងនោះចេញមកព្ទៗ។ ប្រាប់អ្នកចូលរួមឱ្យពិភាក្សាជាមួយដៃគូលើសំណួរទាំងនោះ រួចរាយការណ៍ត្រលប់មកដល់ក្រុមវិញ។

[28] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញ៉ូវសោតវ៉េល លេខាធិការដ្ឋានសុខុមាលភាពសិស្ស (១៩៩៧) ការអប់រំស្តីពីការការពារកុមារ ៖ ឯកសារ កម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ

**សេណារីយ៉ូទី ១**

*________(ស្រី) មានអាយុដប់ឆ្នាំ កំពុងមើលទូរទស្សន៍នៅផ្ទះម្នាក់ឯង ក្រោយពេលចេញពីរៀន។ ម្ដាយ និងឪពុករបស់នាងមិនដែលមកដល់ផ្ទះមុនម៉ោងប្រាំមួយ"ទេ" ។*

*ដៃគូអាជីវកម្មរបស់ប៉ានាងឈ្មោះ ___________ (ប្រុស) បានមកដល់ទីនោះមុនម៉ោងប្រាំ ហើយសួរថាតើប៉ានាងត្រលប់មកផ្ទះវិញ ឬនៅ។ ___________(ប្រុស) អង្គុយនៅលើសាឡុងជាប់នឹង ______(ស្រី)។*

*ពេលគេនិយាយជាមួយគ្នា បុរសនោះចេះតែខិតទៅជិតនាងខ្លាំងឡើងៗ។ បន្ទាប់មកគេដាក់ដៃរបស់គេលើជើងរបស់នាង។ ________ (ស្រី) ចាប់ផ្ដើមមាន អារម្មណ៍មិនស្រួលជាខ្លាំង។*

**សេណារីយ៉ូទី ២**

*_____ (ប្រុស ១) អាយុ ១២ ឆ្នាំ ពេលខ្លះចេញទៅដើរលេងជាមួយមិត្តរបស់បងប្រុសគេ។ ថ្ងៃមួយគេបានឮមនុស្សទាំងនោះនិយាយអំពីសកម្មភាពផ្លូវភេទ និងផ្នែកសម្ងាត់នានានៃរាងកាយ។ ______ (ប្រុស ១) ចង់ដឹងរឿងទាំងនេះ ប៉ុន្តែមានអារម្មណ៍មិនស្រួលក្នុងចិត្ត។*

*បុរសម្នាក់ឈ្មោះ _______________(ប្រុស២) សំគាល់ឃើញប្រតិកម្មរបស់_________________ (ប្រុស ១) ហើយបាននិយាយស្ងាត់ៗ ពេលពួកគេកំពុងចេញទៅថា ឯងត្រូវតែធ្វើ។ ឯងនឹងផ្ដល់ក្ដីសប្បាយជាច្រើនឱ្យយើង។ បើឯង និយាយ អ្វីប្រាប់បងឯង ឯងត្រូវងាប់ជា មិនខាន។*

**ការងារ**

សូមធ្វើការជាមួយដៃគូ រួចឆ្លើយតបនឹងសំណួរខាងក្រោម៖

1. តើអ្វីជាអាកប្បកិរិយាមិនសមស្របក្នុងករណីនីមួយៗ? តើហេតុអ្វីបានជាអាកប្បកិរិយានោះជាអាកប្បកិរិយាមិនសមស្រប?
2. តើមនុស្សវ័យក្មេងដែលជាគោលដៅរបស់គេនោះ មានអារម្មណ៍ដូចម្ដេចនៅក្នុងស្ថានភាពទាំងនេះ?
3. តើអារម្មណ៍ទាំងនេះ អាចជាសញ្ញាប្រាប់ពីស្ថានភាពដែលអាចមានការគំរាមកំហែងដល់ខ្លួនយ៉ាងដូចម្ដេចខ្លះ?
4. តើអ្នកអាចនឹងមានប្រតិកម្មផ្នែករាងកាយ ឬអារម្មណ៍ដូចម្ដេច ប្រសិនបើអ្នកមានអារម្មណ៍ដូចនេះ?
5. តើគេអាចធ្វើអ្វីបានខ្លះដើម្បីបង្កើនសុវត្ថិភាពរបស់ខ្លួន ក្នុងស្ថានភាពខាងក្រោមនេះ៖
   - ក្នុងពេលកំពុងកើតហេតុ
   - ក្រោយពេលកើតហេតុ
   - នាពេលអនាគត?

# ឧបសម្ព័ន្ធទី ១២៖ សន្លឹកកិច្ចការស្តីពីសញ្ញាតឿនអាសន្ន[29]

## សម្រាប់ប្រើក្នុងវគ្គខ្លី ប្រធានបទទី២ អាយុ ១១-១៧ ឆ្នាំ

**ការណែនាំ៖** សូមត្រៀមសំណៅមួយច្បាប់សម្រាប់អ្នកចូលរួមម្នាក់ៗ។ ចែកសំណៅសន្លឹកកិច្ចការស្តីពីសញ្ញាតឿនអាសន្នសម្រាប់កុមារ ដល់អ្នកចូលរួម និងអានអំពីស្ថានភាពទាំងនោះឮៗ។ សូមឱ្យអ្នកចូលរួមកំណត់ អារម្មណ៍របស់មនុស្សវ័យក្មេងនីមួយៗថា តើទំនងជាមានអារម្មណ៍ដូចម្តេចក្នុងសេណារីយ៉ូនីមួយៗ។ សូមឱ្យពួកគេកត់ត្រាទុកពីអារម្មណ៍ទាំងអស់នេះនៅក្នុងសន្លឹកកិច្ចការរបស់ខ្លួន។ កុមារ អាចប្រើប្រាស់ កាតគំរូដែលផ្តល់ឱ្យ ដើម្បីពិពណ៌នាអារម្មណ៍របស់តួនីមួយៗ។ វិធីបែបអន្តរកម្មមួយទៀតដើម្បីធ្វើសកម្មភាពនេះ គឺត្រូវថតចម្លងកាតគំរូទាំងអស់ទៅដាក់លើក្រដាសផ្ទាំងធំ ហើយបិទក្រដាសនោះនៅតាមជ្រុង នានាក្នុងបន្ទប់។ បន្ទាប់មកកុមារអាចទៅរករូប/អារម្មណ៍ដែលត្រូវតាមសេណារីយ៉ូដែលអានចេញមកនោះ។

[29] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញ៉ូវសោតវ៉េល លេខាធិការដ្ឋានសុខុមាលភាពសិស្ស (១៩៩៧) ការអប់រំស្តីពីការការពារកុមារ ៖ ឯកសារ កម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ

| | អារម្មណ៍ |
|---|---|
| 1. រៀងរាល់ព្រឹកនៅពេលដែល _____ (ប្រុស) ទៅហាងទិញនំប៉័ង លោកស្រី _____ ដែលជាម្ចាស់ហាងតែងសម្លឹង និងញាក់ចិញ្ចើមដាក់គេ។ | |
| 2. នៅថ្ងៃខួបកំណើតទី ១២ ឆ្នាំរបស់ខ្លួន _____ (ស្រី) រៀបចំពិធីជប់លៀងមួយ។ មីង ពូ អ៊ំ បងប្អូនជីដូនមួយ និងមិត្តភក្តិរបស់នាងបានចូលរួម។ គ្រប់ៗគ្នាសុទ្ធតែឱប និងថើបនាង។ | |
| 3. _____(ប្រុស)មើលមិនសូវឃើញអ្វីដែលនៅឆ្ងាយពីគាត់"ទេ"។ ថ្ងៃមួយ ពេលគាត់ដើរទៅផ្ទះវិញ គាត់គិតថាមាននរណាម្នាក់កំពុងដើរតាមគាត់។ | |
| 4. មិត្តប្រុសរបស់ _____ (ស្រី) បានមកហៅនាងឱ្យទៅចូលរួមពិធីជប់លៀងមួយនាយប់នោះ។ នាងសម្រេចចិត្តទៅ។ ពេលពួកគេទៅដល់ នាងបានកត់សំគាល់ឃើញថា មនុស្សនៅទីនោះមានអាកប្បកិរិយាចម្លែកៗ។ ពួកគេទាំងនោះដើរមិនត្រង់ផ្លូវ ហើយនិយាយឮៗ និងមានចរិកកោងកាច។ | |
| 5. ពូ និងមីងរបស់ _____ (ស្រី) មកលេងនាងនៅថ្ងៃចុងសប្តាហ៍។ ពូរបស់នាងបានឱប និងថើប នាងរយៈពេលយ៉ាងយូរ។ | |
| 6. _____ (ស្រី) ចង់ទិញកង់ថ្មី។ បងជីដូនមួយរបស់នាង _____ (ប្រុស) ដែលមានអាយុ២៥ឆ្នាំ បាននិយាយថាគេនឹងឱ្យលុយនាងទិញកង់ ប្រសិនបើនាងក្លាយជាស្រីពិសេសរបស់គេ។ | |
| 7. ពេល _____ (ប្រុស ១) និង _____ (ប្រុស ២) កំពុងលេងបាល់ទាត់ ពេលនោះ _____ (ប្រុស ២) បានដួល ហើយត្រូវរបួសជង្គង់។ _____ (ប្រុស ១) ត្រកងគេឡើង និងជួយគ្រាគេទៅអង្គុយលើបង់។ | |
| 8. _____ (ប្រុស) កំពុង បង្អួតខ្លួនពេលជិះកង់បត់នៅផ្លូវកែង។ គាត់បាត់ការគ្រប់គ្រងលើកង់ ពេលមានឡានមួយកំពុងបើកសំដៅមក។ | |
| **9.** _____(ស្រី) កំពុងដើរលេងជាមួយមិត្តភក្តិខ្លួននៅក្នុងក្រុងមួយ។ ស្ត្រីវ័យក្មេងម្នាក់ដើរមករកនាង ហើយសួរថាតើនាងចង់រកលុយបន្ថែម តាមរយៈការចំណាយ ពេលជាមួយគេ និងមិត្តប្រុសរបស់គេដែលកំពុងមកលេងក្រុងនោះ នៅក្នុងបន្ទប់សណ្ឋាគាររបស់គេ ឬទេ។ | |



# ឧបសម្ព័ន្ធទី១៣៖ កាតវាយតម្លៃស្ថានភាព[30]

## សម្រាប់ប្រើក្នុងប្រធានបទទី២ អាយុ ១១- ១៧ ឆ្នាំ

**ការណែនាំ៖** សូមត្រៀមសំណៅមួយច្បាប់សម្រាប់អ្នកចូលរួមម្នាក់។ សូមចែកអ្នកចូលរួមទៅជាក្រុមតូចៗ។ សូមចែកកាតវាយតម្លៃស្ថានភាពមួយឈុតទៅឱ្យក្រុមនីមួយៗ។ ប្រាប់អ្នកចូលរួមឱ្យពិភាក្សាលើស្ថានភាពនីមួយៗ ហើយពិនិត្យមើលថាតើមានស្ថានភាពដទៃទៀតណាខ្លះ ដែលពួកគេចង់ស្វែងយល់ និងអាចកំណត់បានថាជាស្ថានភាពមានគ្រោះថ្នាក់ខ្ពស់ ឬមានគ្រោះថ្នាក់ទាប។ ប្រាប់ក្រុមនិមួយៗឱ្យជ្រើសរើសកាតមួយ រួចរាយការណ៍ត្រលប់ទៅកាន់ក្រុមធំវិញ។

[30] កែសម្រួលចេញពីនាយកដ្ឋានអប់រំតាមសាលានៃតំបន់ញ៉ូវសោតវ៉េល លេខាធិការដ្ឋានសុខុមាលភាពសិស្ស (១៩៩៧) ការអប់រំស្តីពីការការពារកុមារ ៖ ឯកសារ កម្មវិធីសិក្សាគាំទ្រដល់ការបង្រៀន និងរៀនពីការអភិវឌ្ឍខ្លួនឯង សុខភាព និងការអប់រំកាយ

| | | | |
|---|---|---|---|
| អ្នកជិតខាងថ្មីម្នាក់មកលេងផ្ទះអ្នក។ អ្នកនៅផ្ទះម្នាក់ឯង។ អ្នកចង់ធ្វើខ្លួនជាមនុស្សរួសរាយ។ | អ្នកជិតខាងថ្មីម្នាក់មកលេងផ្ទះអ្នក។ អ្នកនៅផ្ទះម្នាក់ឯង។ អ្នកចង់ធ្វើខ្លួនជាមនុស្សរួសរាយ។ | មិត្តប្រុសរបស់អ្នកលើកដៃឱបអ្នក និងចាប់ផ្តើមប៉ះសុដន់របស់អ្នក។ | ពេលនេះភ្លៀងកំពុងធ្លាក់ ហើយឈើច្រត់ដែលអ្នកប្រើ ចេះតែរអិលពេលប៉ះថ្លុកទឹក។បងប្រុសរបស់មិត្តអ្នកចង់បើកឡានជូនអ្នកទៅផ្ទះវិញ។ |
| មិត្តអ្នកបង្ហាញទូរស័ព្ទថ្មីមួយគ្រឿង ដែលនាងបានទទួលពីមិត្តជាបុរសវ័យ ចំណាស់ម្នាក់។ នាងនិយាយថា បើអ្នកចំណាយពេល នៅជាមួយនាង និងមិត្តជាបុរសរបស់នាង នោះអ្នកនឹងបានទូរស័ព្ទដូចនេះមួយគ្រឿងដែរ។ | មិត្តភក្តិរបស់គ្រួសារអ្នករស់នៅក្នុងទីក្រុង។ នាងបានអញ្ជើញអ្នកឱ្យទៅលេងនាង និងរកលុយក្នុងពេលឈប់សម្រាកពីសាលា។ | នេះជារដូវទេសចរឡើងខ្ពស់សម្រាប់ក្រុងរបស់អ្នក។ អ្នកសម្រេចចិត្តរកលុយខ្លះ តាមរយៈការលក់វត្ថុអនុស្សាវរីយ៍ ឱ្យភ្ញៀវដែលមក កាន់ភូមិរបស់អ្នក។ | អ្នកស្នើខ្លួនជូនភ្ញៀវមួយចំនួនឱ្យដើរមើលទេសភាពជុំវិញក្រុងរបស់អ្នក។ |
| ទេសចរម្នាក់ក្នុងក្រុងរបស់អ្នកសូមឱ្យអ្នកជួយបង្ហាញកន្លែងបន្ទប់ទឹកដល់គេ។ | ប្រធាននៅកន្លែងធ្វើការរបស់អ្នកទះគូទរបស់អ្នក។ | អ្នកវង្វេងផ្លូវ។ អ្នកដឹងថា អ្នកចាំបាច់ត្រូវតែស្ទាក់នរណាម្នាក់ដែលអ្នកមិនស្គាល់ ដើម្បីសួរផ្លូវ។ | ឪពុករបស់មិត្តអ្នកពោលពាក្យបែបលេបខាយពីសម្លៀកបំពាក់ដែលអ្នកកំពុងស្លៀក។ |
| អ្នកកំពុងរង់ចាំរថភ្លើងតែម្នាក់ឯង  នៅស្ថានីយ៍រថភ្លើងក្នុងមូលដ្ឋាន។ | មីងម្នាក់ទទូចចង់ឱ្យអ្នកអនុញ្ញាតិឱ្យគាត់ម៉ាស្សាពេញខ្លួនឱ្យអ្នក។ | ថ្មីៗនេះ មិត្តជិតស្និទ្ធបំផុតរបស់អ្នកច្រើនតែមិនសប្បាយចិត្ត និងខឹងច្រើន។ អ្នកសម្រេចចិត្តទៅមើលកុនជាមួយគ្នា ហើយអ្នកមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងពេលឃើញគាត់យកកូនកាំបិតមួយទៅជាប់ខ្លួន។ | គ្រូកីឡាម្នាក់ដាក់ដៃកៀកស្មាសិស្សម្នាក់ ដើម្បីផ្តល់ដំបូន្មាន និងលួងលោម។ |
| បុរសម្នាក់ដែលអង្គុយទល់មុខអ្នកក្នុងឡានក្រុង បានរើមកអង្គុយជាប់អ្នក។ គាត់ចេះតែផ្អែកមកលើអ្នក។ | អ្នកស្តាប់រឿងកំប្លែងមួយដែលមានលក្ខណៈបន្តុះបង្អាប់ស្ត្រី ហើយមានគេបង្ហាញរូបស្រីអាក្រាតកាយមួយចំនួនឱ្យអ្នកមើល។ | អ្នកដើរចូលទៅក្នុងបន្ទប់ទឹកសាធារណៈមួយកន្លែង គាប់ជួនពេលនោះអ្នកឃើញមនុស្សធំពីរនាក់កំពុងដោះដូរកញ្ចប់មួយជាមួយគ្នា។ | គ្រូបង្រៀនម្នាក់បានសូមឱ្យអ្នកនៅចាំក្រោយម៉ោងរៀន ដើម្បីរៀនបន្ថែម និងជួយលើការងារខ្លះ។ |

# ឧបសម្ព័ន្ធទី ១៤៖ របាយការណ៍អ្នកសម្របសម្រួល

**ការណែនាំ៖** ទម្រង់នេះ គួរត្រូវបានបំពេញដោយអ្នកសម្របសម្រួល និងចែករំលែកទៅដល់អ្នកគ្រប់គ្រង/អង្គការដែលពាក់ព័ន្ធ ដើម្បីជម្រុញដល់ការអង្កេតតាមដានលើលទ្ធផលនៃការរៀនសូត្រ និងកែលំអសកម្មភាពនាពេលអនាគត។

*ការអង្កេតរបស់អ្នកសម្របសម្រួល គឺជាផ្នែកដ៏សំខាន់មួយសម្រាប់ការវាយតម្លៃ និងកែលំអសកម្មភាព។ អ្នកសម្របសម្រួលគួរអង្កេតមើលអំពីរបៀបដែលកុមារ និងមនុស្សវ័យក្មេងឆ្លើយតបនឹងសំណួរ របៀបដែលពួកគេចូលរួមក្នុងសកម្មភាពក្រុម ថាតើកុមារមានការចាប់អារម្មណ៍នឹងមេរៀនឬទេ និងថាតើពួកគេសួរសំណួរដែលជម្រុញដល់ការគិតពិចារណាឬទេ ? នេះជាវិធីមួយដើម្បីវាស់ប្រតិកម្ម ការរៀនសូត្រ និងការផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកចូលរួម។*

១. សូមពន្យល់ចំណាប់អារម្មណ៍ទូទៅរបស់អ្នកចំពោះព្រឹត្តិការណ៍បណ្តុះបណ្តាលនោះ។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២. សូមពន្យល់អំពីបញ្ហានានាដែលអ្នកបានជួប។

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៣. តើមានការលើកឡើងនូវបញ្ហាផ្នែកការការពារកុមារសំខាន់ៗឬទេ ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៤. សូមផ្តល់យោបល់អំពីកម្រិតការយល់ដឹង និង ការចូលរួមបស់អ្នកចូលរួមនៅពេលចាប់ ផ្តើមមេរៀន ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

៥. សូមផ្តល់យោបល់អំពីកម្រិតការយល់ដឹង និងការចូលរួមរបស់អ្នកចូលរួម នៅពេលចុងមេរៀន (ដោយរួមបញ្ចូលនូវ i) ការអង្កេតអំពីការយល់ដឹងរបស់អ្នកចូលរួមអំពីសារសំខាន់ៗ ii) សង្ខេបរួមអំពីការឆ្លើយតបក្នុងការវាយតម្លៃ។)

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

៦. តើមេរៀនអ្វីខ្លះ ដែលអ្នកគិតថាចាំបាច់សម្រាប់វគ្គសិក្សានាពេលអនាគត ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

៧. តើគួរកែលំអសៀវភៅណែនាំ និងសម្ភារសិក្សាយ៉ាងណាខ្លះ ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

៨. តើចាំបាច់ត្រូវមានការអប់រំបន្ថែមទៀតឬទេ ? សម្រាប់នរណា ? ហេតុអ្វី ?

................................................................................................................................................

................................................................................................................................................

................................................................................................................................................

................................................................................................................................................

# កត់ចំណាំ

គម្រោងកុមារភាពផ្នែកបង្ការគឺជាការផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីការពារកុមារពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍ និងធ្វើដំណើរក្នុងប្រទេសកម្ពុជា (២០១១-២០១៤)។ គម្រោងកុមារភាពនេះមានការចូលរួមពីអង្គការទស្សនៈពិភពលោក (World Vision) និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) និង INTERPOL កម្មវិធីបានផ្តោតទៅលើទាំងផ្នែកទប់ស្កាត់ និង ការការពារ។



*រក្សាសុវត្ថិភាពកុមារឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទ៖*
*កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់វេទិកាពិភាក្សាជាមួយឪពុកម្តាយ និងអ្នកថែទាំ*



*រក្សាសុវត្ថិភាពកុមារឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទ៖*
*ឧបករណ៍អ្នកសម្របសម្រួលសម្រាប់វេទិកាពិភាក្សាជាមួយអ្នកតំណាងសហគមន៍*



*រក្សាសុវត្ថិភាពកុមារឱ្យរួចផុតពីការរំលោភបំពានក្នុងវិស័យទេសចរណ៍៖*
*កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់ការបណ្តុះបណ្តាលវិស័យទេសចរណ៍*

ឯកសារនេះក៏មានជាភាសាអង់គ្លេស ឡាវ ថៃ និងវៀតណាមផងដែរ ដោយត្រូវបានកែសម្រួលឱ្យស្របទៅតាមបរិបទប្រទេសនីមួយៗ។

កុមារដែលធ្វើការ និងរស់នៅក្នុងបរិដ្ឋានទេសចរណ៍មានភាពងាយរងគ្រោះជាពិសេសចំពោះការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។ សូម្បីតែក្មេងនៅតូច ក៏យើងអាចបង្រៀនពួកគេឱ្យចេះរបៀបការពារខ្លួនឯងពីការរំលោភបំពានផ្លូវភេទបានដែរ។ ជាការសំខាន់ណាស់ ដែលពួកគេត្រូវមានលទ្ធភាពទទួលបានព័ត៌មានត្រឹមត្រូវ ដែលសមស្របតាមដំណាក់កាលនៃការអភិវឌ្ឍរបស់ខ្លួន ស្តីពីការរំលោភបំពានផ្លូវភេទ។

*ឯកសារដែលមានចំណងជើងថា រក្សាសុវត្ថិភាពកុមារពីការរំលោភបំពាន៖ កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់អប់រំកុមារ និង មនុស្សវ័យក្មេង* មួយច្បាប់នេះមានផែនការមេរៀន និងឧបករណ៍ ដែលអ្នកសម្របសម្រួលអាចប្រើប្រាស់ ដើម្បីបំពាក់ឱ្យកុមារ និងមនុស្សវ័យក្មេងនូវចំណេះដឹង និង ជំនាញសមស្របតាមដំណាក់កាលអភិវឌ្ឍរបស់ពួកគេ ដើម្បីឱ្យពួកគេអាចស្គាល់ចេះទប់ស្កាត់ និងបញ្ឈប់ការរំលោភបំពានផ្លូវភេទបាន។ កញ្ចប់ឧបករណ៍ផ្តល់អ្វីៗគ្រប់យ៉ាងដែលអ្នកសម្របសម្រួលត្រូវការ ដើម្បីដំណើរការវគ្គដែលមានលក្ខណៈរស់រវើកជាមួយកុមារ និងមនុស្សវ័យក្មេង ទាំងនៅក្នុងបរិយាកាសបែបផ្លូវការ និងក្រៅផ្លូវការ និងត្រូវការឧបករណ៍ និងបច្ចេកវិជ្ជាដ៏តិចតួចបំផុត។ ផែនការមេរៀន ត្រូវបានចែកចេញទៅជាក្រុមអាយុចំនួនបីក្រុមគឺ៖ អាយុ ៥-៧ ឆ្នាំ អាយុ ៨-១០ ឆ្នាំ និង ១១-១៧ ឆ្នាំ។

ឯកសារនេះក៏មានជាភាសាខ្មែរ ឡាវ ថៃ និងវៀតណាមផងដែរ ដោយត្រូវបានកែសម្រួលឱ្យស្របទៅតាមបរិបទប្រទេសនីមួយៗ។

**Child Safe Tourism**

Take action against abuse

គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (២០១១-២០១៤)។ គម្រោងកុមារភាពនេះ បាននាំមកនូវកិច្ចសហការគ្នា រវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម។ កម្មវិធីបានផ្តោតទៅលើទាំងផ្នែកទប់ស្កាត់ និងការការពារ។

Australian Aid

World Vision®